# ប្រវត្តិព្រះអសីតិ
# មហាសាវ័ក
# ភាគទី ៥



ប្រមូលរៀបរៀងដោយ
ខ្ញុំព្រះករុណា
អាត្មាភាព **យង់ សុផាត**

# ប្រវត្តិព្រះអសីតិមហាសាវ័ក

## ភាគទី ៥

ប្រមូលរៀបរៀងដោយ
ខ្ញុំព្រះករុណា
អាត្មាភាព **យង់ សុផាត**

សម្រាប់ជាធម្មទាន

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ២២៥ [illegible]

រាជធានីភ្នំពេញ,ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ពិតថេរដីកា**
**ព្រះតេជគុណ យង់ សុផាត ប្រធានសមាគមធម្មទានអរិយវង្ស យង់ សុផាត**

**<u>កម្មវត្ថុ</u>** : អំពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្សយង់ សុផាត*** នៅក្រសួងមហាផ្ទៃ។

**<u>យោង</u>** : លិខិតលេខ***០១/១០ស.ធ.អ.យ.ផ*** ចុះថ្ងៃទី***២៣*** ខែ***តុលា*** ឆ្នាំ***២០០៩*** ស្តីពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្ស យង់ សុផាត*** ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំព្រះករុណាសូមពិតថេរដីកាព្រះតេជគុណប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលនៅភូមិ***រំចេក៣*** សង្កាត់***រតនៈ*** ក្រុង***បាត់ដំបង*** ខេត្ត***បាត់ដំបង*** នោះហើយ ។ ***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាសមាគមអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឱ្យគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍គណបក្សនយោបាយ ។

ក្រោយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន សមាគមធម្មទានអរិយវង្ស យង់ សុផាត ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីអោយបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមព្រះតេជគុណប្រធានជ្រាបជាព័ត៌មាន ។
សូមព្រះតេជគុណប្រធាន ទទួលនូវការគោរពអំពីខ្ញុំព្រះករុណា ។

ស ខេង

***<u>ចម្លងជូន</u>*** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
" <u>ដើម្បីជូនជ្រាប</u> "
- សាលាខេត្តបាត់ដំបង
" <u>ដើម្បីមុខការ</u> "
-ឯកសារ-កាលប្បវត្តិ

# អារម្ភកថា

សៀវភៅជីវប្រវត្តិព្រះអសីតិមហាសាវក ៨០ រូប ភាគ ៥ នេះ មានខ្លឹមសារជាប្រវត្តិរឿងរ៉ាវសាវកនាសម័យពុទ្ធកាល ដែលលោកបានទទួលតំណែងជាឯតទគ្គៈក៏មាន មិនបានទទួលតំណែងជាឯតទគ្គៈក៏មានដែរ ហើយមានឈ្មោះល្បីល្បាញនាសម័យនោះ ថែមទាំងជាអ្នកជួយផ្សព្វផ្សាយព្រះពុទ្ធសាសនា ឲ្យបានរុងរឿងចម្រើនដល់ពុទ្ធបរិស័ទនៅក្នុងសម័យនោះ ។

ក្នុងសម័យនោះ ពុទ្ធបរិស័ទដ៏ច្រើន សុទ្ធតែបានស្គាល់តំណែង ឬភាពអស្ចារ្យ នៃព្រះថេរៈទាំងអស់នោះ ដោយថា អ្នកខ្លះ បានស្តាប់ព្រះធម៌របស់លោក អ្នកខ្លះ បានធ្វើធម្មសាកច្ឆា អ្នកខ្លះ ក៏បានប្រគេនចង្ហាន់បិណ្ឌបាតដល់លោកជាដើម ។ ប៉ុន្តែ ឥឡូវនេះ ព្រះនាមរបស់ព្រះថេរៈខ្លះៗ ពុទ្ធបរិស័ទនាសម័យនេះ ស្ទើរតែលែងស្គាល់អស់ទៅហើយ ដោយសារហេតុនេះ សៀវភៅនេះនឹងបានជាពន្លឺជំនួយ ឲ្យដល់ពុទ្ធបរិស័ទ បានស្គាល់ច្បាស់នូវព្រះនាម តួនាទី ចរិយា អធ្យាស្រ័យ

វត្តបដិបត្តិ និងការសម្តែងព្រះធម៌ផ្សេងៗ របស់ព្រះថេរៈទាំងអស់នោះ ដែលមានសម្តែងទុកនៅក្នុង **គម្ពីរថេរគាថា** និងក្នុង **គម្ពីរអបទាន** ជាដើម ព្រោះថា ព្រះពុទ្ធសាសនា ដែលរុងរឿងចម្រើន ក៏អាស្រ័យមានអ្នកចងចាំ បដិបត្តិតាម និងចេះសម្តែងព្រះធម៌ ឲ្យដល់អ្នកដទៃបានស្តាប់ មិនមែនដោយប្រការដទៃទេ ដូច្នេះ ព្រះថេរៈទាំងអស់នោះជាសក្ខីភាពបញ្ជាក់ថា ព្រះពុទ្ធសាសនា ដែលរុងរឿងនៅក្នុងសម័យនោះ ក៏ដោយសារលោកផងដែរ ទើបខ្ញុំព្រះករុណា អាត្មាភាព ខំប្រឹងប្រែងស្វែងរកក្បួនច្បាប់មកចងក្រងទុកជាពន្លឺដល់ពុទ្ធបរិស័ទក្នុងសម័យនេះ ។

សៀវភៅនេះ ខ្ញុំមិនអាចដាក់ភាសាបាលីផងបានទេ ព្រោះថាមានសេចក្តីពិស្តារពេក បើអ្នកសិក្សាត្រូវការភាសាបាលី ចូរតាមរកមើលក្នុង **គម្ពីរព្រះត្រៃបិដក** និង **អដ្ឋកថា** ក្នុងចំណុចដែលលើកឡើងមកនីមួយៗ ចុះ ព្រោះគ្រប់ចំណុច ដែលលើកឡើងមកនោះ សុទ្ធតែបានប្រាប់ពី **គម្ពីរ** ឬច្បាប់ដើម ជាមូលដ្ឋានរួចអស់ហើយ ។

ខ្ញុំសង្ឃឹមថា សៀវភៅនេះ នឹងបានជាប្រយោជន៍ ចំពោះបុគ្គលអ្នកប្រាថ្នាការចេះដឹងក្នុងព្រះពុទ្ធវចនៈបើមិនក្រៃលែងក៏ប្រសើជាងអត់

ផងដែរ ខ្ញុំ និងសព្រហ្មចារី ខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្ត ពិនិត្យផ្ទៀងផ្ទាត់យ៉ាងហ្មត់ចត់ ទោះបីយ៉ាងនោះក៏ដោយ ក៏គង់នៅមាន ខុសមិនខាន ដូនដោយចេះមិនដល់ ដូនដោយការភ្លេចភ្លាំង ជាពិសេស នោះគឺអក្ខរាវិរុទ្ធ ដូច្នេះ យើងខ្ញុំ សូមសង្ឃឹមនៅលើលោកអ្នកជាបណ្ឌិត ជាសប្បុរស ជួយកែលម្អ ឲ្យដល់យើងខ្ញុំផង ដើម្បីជាប្រយោជន៍ដល់ ជាតិ សាសនា របស់យើងទាំងអស់គ្នា ។

សូមអស់មិត្តអ្នកអាន បានទទួលនូវការចេះដឹង ជាកេរ្តិ៍មតិក ផ្ទាល់ខ្លួន ដើម្បីបានជាកិច្ចប្រតិបត្តិ ឬបានជាឧបនិស្ស័យប្រហារបង់ នូវអាសវក្កិលេស បានចូលដល់សន្តិបទ គឺព្រះនិព្វាន ។

ចំពោះបុណ្យធម្មទាននេះ និងបុណ្យកុសលដទៃៗ ទៀត ដូច ជាបុណ្យថ្នាក់ការសម្តែងព្រះធម៌ នៅក្នុងកម្មវិធីបុណ្យផ្សេងៗ ទៅតាម ខេត្ត ក្រុង ជាច្រើន នៅក្នុងប្រទេសកម្ពុជានេះ ដោយខ្ញុំព្រះករុណា អាត្មាភាព បានសម្តែងព្រះធម៌ នៅកន្លែងណាៗ ក៏តែងតែបានទុកដាក់ ប្រាក់បូជាព្រះធម៌ នៅកន្លែងនោះវិញ គ្រប់ៗ កន្លែង ដោយសរុបប្រាក់ នៅក្នុង ព.ស. **២៥៥០ ប្រាក់ខ្មែរបាន ១៨.៤៩៥០០០ រៀល ( ១៨ លាន ៤**

**សែន ៩ ម៉ឺន ៥ ពាន់រៀល)** **និងប្រាក់ដុល្លារ ៦៤៥ ដុល្លារសហរដ្ឋអាមេរិក ។** *នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង* **ប្រទេសឥណ្ឌា ដែលមានពុទ្ធបរិស័ទនៅប្រមាណ ៦៥ នាក់** *ក្នុងនោះ ក៏មាន* **ព្រះសង្ឃ ១០ ព្រះអង្គផងដែរ** *ដែលមានលោកគ្រូអគ្គបណ្ឌិត* **ប៊ុត សាវង្ស** *ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដោយទៅ* **ថ្វាយបង្គំបាន ៥១ កន្លែង** *បានការឧបត្ថម្ភអំពីឧបាសក* **ឡាយ ស្វន្ថម** *និងឧបាសិកា* **ឌិម លក្ខណា** *នៅក្នុង* **ព.ស. ២៥៥០** *(១០.០២.២០០៧) ។*

## នឹកឃើញស្រុកព្រះ

*នឹកឃើញស្រុកព្រះ បានក្រាបសំពះ អង្គព្រះសាស្តា*
*សិរសាលំទោន ទុកដូចឈូកផ្កា បូជាសាស្តា*
*ជ្រះថ្លាក្រៃលែង ។*
*៦៥ អង្គា គាល់ព្រះភគវា ៥១ កន្លែង*
*នៅស្រុកឥណ្ឌា ចងចាំមិនលែង សោមនស្សពន់ពេក*
*ក្នុង ព.ស.២៥៥០ ។*

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥១ ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥០ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥១ ប្រាក់ខ្មែរបាន ១៥.៨៣១០០០ រៀល ( ១៥ លាន ៨ សែន ៣ ម៉ឺន ១ ពាន់រៀល) និង ប្រាក់ដុល្លារ ៤៥ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាន នានានៅក្នុង ប្រទេសស្រីលង្កា ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទ ទៅប្រមាណ ១២១ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៤ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ១៩ កន្លែង បានការឧបត្ថម្ភមកអំពីឧបាសក ឡាយ សុខុម និងឧបាសក សោម រតនៈ ឧបាសិកា ស៊ិប ចណ្ណា នៅក្នុង ព.ស. ២៥៥១ ( ០៤.០៤.២០០៨ ) ។

## នឹកឃើញលង្កា

នឹកឃើញលង្កា នឹកឃើញកាលណា ជ្រះថ្លាក្រៃលែង
នៅពុទ្ធស្ថាន ១៩ កន្លែង ដែលខ្ញុំបានស្វែង
ទៅថ្វាយបង្គំ ។

១២១ អង្គា  គាល់ព្រះបាទា  នាស្ថានមនោរម

លើសុមនកូដ  ជេស្ថាឧត្តម  ជាកំពូលភ្នំ

ក្នុងប្រវត្តិពុទ្ធ ។

ទឹកដីលង្កា  ទឹកដីអស្ចារ្យ  ពេញពោរដោយឫទ្ធិ

នឹកឃើញកាលណា ជ្រះថ្លាក្រៃពិត  ធម្មយាត្រាប្រណីត

ក្នុង ព.ស.២៥៥១ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥២ ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥១ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. **២៥៥២ ប្រាក់ខ្មែរបាន ២៧.១២៨០០០ រៀល (២៧ លាន ១ សែន ២ ម៉ឺន ៨ ពាន់រៀល) និងប្រាក់ដុល្លារ ១៩៥ ដុល្លារ ។** នៅបុណ្យកុសលមួយផ្នែកទៀតគឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌាជាលើកទីពីរ** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** មានលោកគ្រូធម្មបណ្ឌិត **រស់ សុទ្ធារត** និងលោកគ្រូធម្មាចារ្យ **អឿ សៅ** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **៦៧ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៥**

ព្រះអង្គផងដែរ បានការឧបត្ថម្ភមកអំពីឧបាសក **យឹត សុខណារា** ឧបាសិកា **ហ៊ុន ម៉ីវ៉ីរ៉ានី** M. SU SOKUNORA et MmeINN VISAL + NARITA et RAKSA. ក្រោមការជ្រោមជ្រែងរបស់ឧបាសិកា **អ៊ុំ រិទ្ធារី** ឧបាសិកា **ស៊ួន កល្យាណ** ឧបាសិកា **ស៊ួន ចរណៃ** នៅក្នុង **ព.ស. ២៥៥២** ( ១៦.០២.២០០៩ ) ។

## ជ្រះថ្លាខ្លាំងណាស់

ជ្រះថ្លាខ្លាំងណាស់ ព្រះពុទ្ធជាម្ចាស់ គុណធំក្រៃលែង
ច្រើនពុទ្ធសករាជ សាសនាអង្វែង ល្អហួសការថ្លែង
ឱ! ព្រះសាសនា ។
នៅស្រុកឥណ្ឌា ៦៧ អង្គា រួមគ្នានមស្ការ
១០៩ ពុទ្ធស្ថាន ព្រមចិត្តផ្ចង់ថ្វា បីតិអស្ចារ្យ
ក្នុង ព.ស. ២៥៥២ ។

នៅមានបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានផ្សេងៗ នៅក្នុង**ប្រទេសស្រីលង្កាជាលើកទីពីរ** ដែលមានលោកគ្រូធម្មបណ្ឌិត **រស់ សុខនារា** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ

៣៦ នាក់ នៅក្នុងនោះទៀត ក៏មាន ព្រះសង្ឃ ៣ ព្រះអង្គផងដែរ បាន ការឧបត្ថម្ភមកអំពីឧបាសក ឆាយ អ៊ីចស៊ាង ឧបាសិកា ហុង គីមសែ ក្រោមការជ្រោមជ្រែងរបស់ឧបាសក យន្ត សួន នៅក្នុង ព.ស. ២៥៥២ ( ១១.០៣.២០០៩ ) ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥៣ ផ្នែកខាងសម្តែង ព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥២ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥៣ ប្រាក់ខ្មែរបាន ១៣.០៨០០០០ រៀល ( ១៣ លាន ០ សែន ៨ ម៉ឺន) និងប្រាក់ដុល្លារ ២០៨ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង ប្រទេសឥណ្ឌាជាលើកទី ៣ ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ១១១ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៦ ព្រះអង្គផងដែរ ដោយទៅ ថ្វាយបង្គំបាន ៩៦ កន្លែង បានការជ្រោមជ្រែងពីឧបាសក ឡាយ សុខុម នៅក្នុង ព.ស. ២៥៥៣ ( ២៥.០១.២០១០ ) ។

# ស្រណោះស្រុកព្រះ

ស្រណោះស្រុកព្រះ ធ្លាប់តែល្អល្អះ ឥឡូវអនិច្ចា !
យើងខ្ញុំទាំងឡាយ បានទៅនមស្ការ ស្ងប់ស្ងែងអស្ចារ្យ
ឱះ ឱ ! ពុទ្ធស្ថាន ។
នឹកឃើញកាលណា ចិត្តខ្ញុំជ្រះថ្លា គ្មានអ្វីប្រៀបបាន
១១១ អង្គា ៩៦ ពុទ្ធស្ថាន ព.ស.រាប់បាន
២៥៥៣ ។

*នៅមានបុណ្យកុសលនៅក្នុង* **ព.ស. ២៥៥៤** *ផ្នែកខាងសម្តេចព្រះធម៌ ដូចគ្នានឹង* **ព.ស. ២៥៥៣** *ដែរ ដោយសរុបប្រាក់នៅក្នុង* **ព.ស. ២៥៥៤ ប្រាក់ខ្មែរបាន ៣១.៩៩០០០០ រៀល** ( **៣១ លាន ៩ សែន ៩ ម៉ឺន** ) **និងប្រាក់ដុល្លារ ៧២០ ដុល្លារ ។** *នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង* **ប្រទេសឥណ្ឌាជាលើកទី ៤** *ដែលមានលោកគ្រូអគ្គបណ្ឌិត* **ប៊ុត សាវង្ស** *ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ* **១១១ នាក់** *ក្នុងនោះ ក៏មាន* **ព្រះសង្ឃ ៥** *ព្រះអង្គផងដែរ ដោយទៅ*

*ថ្វាយបង្គំបាន* **៩៦ កន្លែង** *បានការជ្រោមជ្រែងពីឧបាសក* **ឡាយ សុខុម** *នៅក្នុង* **ព.ស. ២៥៥៤** *( ២៧.០២.២០១១ ) ។*

## គួរឱ្យសង្វេគ

*គួរឲ្យសង្វេគ ស្រណោះពន់ពេក ពេលឃើញពុទ្ធស្ថាន*
*ធ្លាប់តែរុងរឿង ចម្រើនថ្កើងថ្កាន ឥឡូវប្រែឋាន*
*ប្រៀបបានព្រៃស្ងាត់ ។*
*២៧៧ អង្គា ប្រណម្យវន្ទា បង្គំថ្វាយថ្វាត់*
*បូជនីយដ្ឋាន ១២ នាដែនពុទ្ធរដ្ឋ ធម្មយាត្រាកំណត់*
*ក្នុងពុទ្ធសករាជ ២៥៥៤ ។*

*ហេតុដូច្នេះ ដោយបុណ្យកុសលនេះ ខ្ញុំព្រះករុណា សូមឧទ្ទិស មហាកុសលទាំងអស់នេះ ជូនចំពោះញោមប្រុស* **យង់ សុខ** *( ស្លាប់ ) និងញោមស្រី* **ឈឹម ហាយ** *( ស្លាប់ ) ម្យ៉ាងទៀត ញាតិកានៅក្នុង សង្សារវដ្ត ជាពិសេសនោះ សូមលើកមហាកុសលទាំងអស់នេះ ជូន ចំពោះលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ* **ប៊ុត សាវង្ស** *លោកគ្រូធម្មបណ្ឌិត*

រស់ សុផាត និងលោកគ្រូធម្មាចារ្យ គាំ អុីច ជាដើម សូមឲ្យបាននូវចំណែកបុណ្យកុសលនេះ ស្មើនឹងអាត្មាភាពផងដែរ **សូមអនុមោទនា !!!** ក៏សូមឲ្យមិត្តអ្នកកំពុងតែកាន់សៀវភៅនេះអាន ឲ្យបានបុណ្យកុសលនៃធម្មទាននេះគ្រប់ៗ គ្នា សូមអនុមោទនានូវចំណែកនៃបុណ្យកុសលនេះ ឲ្យបានស្មើនឹងខ្ញុំព្រះករុណា អាត្មាភាពផងដែរ ។

ម្យ៉ាងទៀត ដោយអំណាចបុណ្យកុសលទាំងអស់នេះ ក៏សូមឲ្យបានជាឧបនិស្ស័យ ក្នុងការអស់ទៅនៃអាសវក្កិលេស នាកាលជាអនាគតកុំបីអាក់ខានឡើយ ( សូមឲ្យបានជាសាវកបារមីញាណ ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធអង្គណាទីមួយ ដែលជាឯតទគ្គៈផ្នែកខាងពហូសូត ១ មានសតិ ១ មានគតិ ១ មានធិតិ ១ ជាពុទ្ធុប្បដ្ឋាក ១ ) សូមឲ្យព្រះពុទ្ធសាសនារុងរឿងចម្រើន សូមឲ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក សូមឲ្យលោកទាំងមូល បានប្រកបដោយសន្តិភាព ព្រះសក្យមុនីទ្រង់ត្រាស់ថា **នត្ថិ សន្តិ បរំ សុខំ** ពុំមានសេចក្តីសុខដទៃ ក្រៅអំពីសេចក្តីស្ងប់ឡើយ ។

អាស្រមព្រះគន្ធកុដិ ថ្ងៃ ៨ កើត ខែពិសាខ ព.ស. ២៥៥៥

**ដោយប្រធានសមាគមធម្មទានអរិយវង្សយង់សុផាត**

ថ

# ឈ្មោះអ្នកជួយប្រែ និងពិនិត្យអក្ខរាវិរុទ្ធ

លោកអ្នកដ៏មានអាយុ ម៉ី សាលួន ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ សឿង កុសល ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ គីម ម៉ានិត ជួយប្រែ

លោកអ្នកដ៏មានអាយុ ម៉ុន ម៉ូរ៉ា ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ អ៊ឹម សុជាន ជួយប្រែ

លោកអ្នកដ៏មានអាយុ មាន ចន្ថនា ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ ពេជ្រ ឧត្តម ជួយវាយកុំព្យូទ័រ

ឧបាសក អ៊ឹម វ៉ៃយ៉ា ជាទីប្រឹក្សាក្នុងកិច្ចការផ្សាយធម្មទាន

ឧបាសក សន ឈៀត ជួយប្រែ

ឧបាសក ឡាន សុខុម ជួយប្រែ

ឧបាសក បួ ស៊ីផួ ជួយពិនិត្យអក្ខរាវិរុទ្ធ

លោកគ្រូធម្មាចារ្យ គាំ អ៊ីង ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក ឌិម ឌំនិត ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក រឹម សុមេធ ជួយពិនិត្យអក្ខរាវិរុទ្ធ

ឱ

# សមាជិកសមាគមធម្មទានអរិយវង្សយង់សុផាត

សម្តេចព្រះសង្ឃរាជគណមហានិកាយ **នន្ទ ង៉ែត** ជាប្រធានកិត្តិយស

| | |
|---|---|
| ភិក្ខុ អគ្គបណ្ឌិតោ **យង់ សុផាត** | ជាប្រធានសមាគម |
| លោកអភិបាលស្រុក **ស្រេង ស្រាង** | ជាទីប្រឹក្សាសមាគម |
| ឧបាសក **អ៊ឹម អ៉ៃយ៉ា** | ជាអនុប្រធានសមាគម |
| ឧបាសិកា **ង៉ែត យូអេង** | ជាអនុប្រធានសមាគម |
| សាមណេរ **ម៉ី សាលួន** | ជាលេខាធិការ |
| ឧបាសក **ឡាន សុខុម** | ជាលេខាធិការរង |
| ឧបាសិកា **តាំង ម៉េងជីង** | ជាហេរញ្ញិក |
| ឧបាសិកា **ជា នាង** | ជាបេឡា |

លោកគ្រូធម្មបណ្ឌិត **អឿ សៅ** សមាជិកកិត្តិយស និងឧបការគុណ

| | | |
|---|---|---|
| ឧបាសក **ឡាយ សុខុម** | សមាជិកកិត្តិយស | និងឧបការគុណ |
| ឧបាសិកា **អ៊ឹង រិទ្ធារី** | សមាជិកកិត្តិយស | និងឧបការគុណ |
| ឧបាសិកា **ហោ ភាព** | សមាជិកកិត្តិយស | និងឧបការគុណ |
| ឧបាសិកា **គួ ម៉ុនគាង** | សមាជិកកិត្តិយស | និងឧបការគុណ |
| ឧបាសិកា **ឈុំ សុធា** | សមាជិកកិត្តិយស | និងឧបការគុណ |

ឧបាសិកា ប៉ែន រម្មណីយ៍ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឱម លក្ខណា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក អ៊ុង ប៊ុនហួរ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា មួ ម៉ាឡា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក ប៊ុន ហេង សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ជុំ សុខុម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ហេង ស្រីជា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ហេង ស្រីចន្ធូ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ហេង គន្ធា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក ហេង សុភ័ត្រ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា កែ៉ប កល្យណ ជាសមាជិកសកម្ម

ឧបាសិកា ឡេង ធីតា ជាសមាជិកសកម្ម

ឧបាសិកា ម៉ៅ នី ជាសមាជិកសកម្ម

ឧបាសិកា ហេង ចន្ទបុញ្ញាវតី ជាសមាជិកសកម្ម

ឧបាសក ហ៊ុង សុវណ្ណារិទ្ធ ជាសមាជិកសកម្ម

ឧបាសក ហ៊ុង សុវណ្ណារ៉ែត ជាសមាជិកសកម្ម

# មាតិការឿង

ល.រ ទំព័រ

១- ឈ្មោះរបស់ភិក្ខុ ........................................................ ជ

២- ជីវប្រវត្តិរបស់ព្រះអានន្ទត្ថេរ ........................................ ១

ដែលជាឯតទគ្គៈផ្នែកខាងពហូសូត ១ មានសតិ ១ មានគតិ ១ មានធិតិ ១ ជាពុទ្ធុបដ្ឋាក ១

៣- ជីវប្រវត្តិរបស់ព្រះឧរុវេលកស្សបត្ថេរ ........................... ៥៥

ដែលជាឯតទគ្គៈផ្នែកខាងអ្នកមានមានបរិវារច្រើន

៤- ជីវប្រវត្តិរបស់ព្រះកាឡុទាយិត្ថេរ ................................. ៩៣

ដែលជាឯតទគ្គៈផ្នែកអ្នកធ្វើឲ្យត្រកូលជ្រះថ្លា

៥- ជីវប្រវត្តិរបស់ព្រះពក្កុលត្ថេរ ...................................... ១១៧

ដែលជាឯតទគ្គៈផ្នែកខាងគ្មានអាពាធ

៦- ជីវប្រវត្តិរបស់ព្រះសោភិតត្ថេរ ..................................... ១៥១

ដែលជាឯតទគ្គៈផ្នែកខាងរព្ញកឃើញនូវបុព្វេនិវាស

៧- ជីវប្រវត្តិរបស់ព្រះឧបាលិត្ថេរ .................................. ១៦៩

ដែលជាឯតទគ្គៈផ្នែកខាងទ្រទ្រង់ព្រះវិន័យ

៨- ជីវប្រវត្តិរបស់ព្រះនន្ទកត្ថេរ ...................................... ២១៩

ដែលជាឯតទគ្គៈផ្នែកខាងឲ្យឱវាទដល់ពួកភិក្ខុនី

៩- ជីវប្រវត្តិរបស់ព្រះនន្ទត្ថេរ ........................................ ២៥១

ដែលជាឯតទគ្គៈផ្នែកខាងអ្នករក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ

១០- ជីវប្រវត្តិរបស់ព្រះមហាកប្បិនត្ថេរ .......................... ២៧៨

ដែលជាឯតទគ្គៈផ្នែកខាងឲ្យឱវាទដល់ពួកភិក្ខុ

១១- ជីវប្រវត្តិរបស់ព្រះសាគតត្ថេរ ................................ ៣១៤

ដែលជាឯតទគ្គៈផ្នែកខាងឈ្លាសវៃក្នុងតេជោធាតុ

ឋ

# ប្រវត្តិព្រះអសីតិមហាសាវ័ក ៨០ រូប

*ព្រះថេរៈទាំង ៨០ រូប មានព្រះអញ្ញាកោណ្ឌញ្ញៈ ព្រះសារីបុត្រ ព្រះមហាមោគ្គល្លានជាដើម សុទ្ធសឹងតែជាមហាសាវ័កដែលមានជំនាញឯកទេស ដែលគ្មានអ្នកដទៃប្រដូចបាន បាលីហៅថា* **ឯតទគ្គៈ** *គឺបានដល់ភាពជាកំពូលរបស់ភិក្ខុមួយរូបៗ ដូចជាព្រះអញ្ញាកោណ្ឌញ្ញៈ ជាកំពូលផ្នែកខាងជាអ្នកបានបួសមុនគេ និងបានត្រាស់ដឹងព្រះធម៌មុនគេ ព្រះសារីបុត្រ ជាកំពូលផ្នែកខាង ជាអ្នកមានបញ្ញាគ្មានសាវ័កណាផ្ទឹមបាន ព្រះមហាមោគ្គល្លានជាកំពូលផ្នែកខាងឫទ្ធិ គ្មានសាវ័កណាស្មើផ្ទឹមបានដែរ យ៉ាងនេះជាដើម ។*

*ដូច្នេះ មហាសាវ័ករបស់ព្រះបរមគ្រូនៃយើងមាន ៨០ រូប ដូចមានព្រះនាមរបស់លោកខាងក្រោមនេះ គឺ*

*១- ព្រះអញ្ញាកោណ្ឌញ្ញៈ ២- ព្រះសារីបុត្រ*

*៣- ព្រះមោគ្គល្លាន ៤- ព្រះកស្សបៈ*

*៥- ព្រះអនុរុទ្ធ ៦-ព្រះភទ្ទិយកាឡិគោធាយបុត្រ*

| | |
|---|---|
| ៧- ព្រះលកុណ្ដកភទ្ទិយៈ | ៨- ព្រះបិណ្ឌោលភារទ្វាជៈ |
| ៩- ព្រះបុណ្ណមន្តានីបុត្រ | ១០- ព្រះមហាកច្ចាយនៈ |
| ១១- ព្រះចូឡបន្ថកៈ | ១២- ព្រះមហាបន្ថកៈ |
| ១៣- ព្រះសុភូតិ | ១៤- ព្រះរេវតខទិរវនិយៈ |
| ១៥- ព្រះកង្ខារេវតៈ | ១៦- ព្រះសោណកោលិវិសៈ |
| ១៧- ព្រះសោណកុដិកណ្ណៈ | ១៨- ព្រះសីវលី |
| ១៩- ព្រះវក្កលិ | ២០- ព្រះរាហុល |
| ២១- ព្រះរដ្ឋបាល | ២២- ព្រះកុណ្ឌធាន |
| ២៣- ព្រះវង្គីសៈ | ២៤- ព្រះឧបសេនវង្គន្តបុត្រ |
| ២៥- ព្រះទព្វមល្លបុត្រ | ២៦- ព្រះបិលិន្ទវច្ឆៈ |
| ២៧- ព្រះពាហិយទារុចីរិយៈ | ២៨- ព្រះកុមារកស្សបៈ |
| ២៩- ព្រះមហាកោដ្ឋិតៈ | ៣០- ព្រះអានន្ទ |
| ៣១- ព្រះឧរុវេលកស្សបៈ | ៣២- ព្រះកាឡុទាយី |
| ៣៣- ព្រះពាកុលៈ | ៣៤- ព្រះសោភិតៈ |
| ៣៥- ព្រះឧបាលិ | ៣៦- ព្រះនន្ទកៈ |

| | |
|---|---|
| ៣៧- ព្រះនន្ទសក្យៈ | ៣៨- ព្រះមហាកប្បិន |
| ៣៩- ព្រះសាគតៈ | ៤០- ព្រះរាធៈ |
| ៤១- ព្រះមោឃរាជ | ៤២- ព្រះមហានាម |
| ៤៣- ព្រះអស្សជិ | ៤៤- ព្រះយស |
| ៤៥- ព្រះវិមល | ៤៦- ព្រះសុពាហុ |
| ៤៧- ព្រះបុណ្ណជិ | ៤៨- ព្រះគវម្បតិ |
| ៤៩- ព្រះនទីកស្សបៈ | ៥០- ព្រះគយាកស្សបៈ |
| ៥១- ព្រះកគ្គុ | ៥២- ព្រះកិម្ពិលៈ |
| ៥៣- ព្រះមហាចុន្ទ | ៥៤- ព្រះអជិតៈ |
| ៥៥- ព្រះតិស្សមេត្តេយ្យ | ៥៦- ព្រះបុណ្ណកៈ |
| ៥៧- ព្រះមេត្តគូ | ៥៨- ព្រះធោតកៈ |
| ៥៩- ព្រះឧបសីវៈ | ៦០- ព្រះនន្ទកត្ថេរ |
| ៦១- ព្រះហេមកៈ | ៦២- ព្រះតោទេយ្យ |
| ៦៣- ព្រះកប្បៈ | ៦៤- ព្រះជតុកណ្ណី |
| ៦៥- ព្រះភទ្រាវុធ | ៦៦- ព្រះឧទយត្ថេរ |

| | |
|---|---|
| ៦៧- ព្រះបោសាលៈ | ៦៨- ព្រះបិង្គិយៈ |
| ៦៩- ព្រះនាគិតៈ | ៧០- ព្រះនាលកៈ |
| ៧១- ព្រះបុណ្ណៈ | ៧២- ព្រះមេឃិយៈ |
| ៧៣- ព្រះយសោជៈ | ៧៤- ព្រះសភិយៈ |
| ៧៥- ព្រះសេលៈ | ៧៦- ព្រះឧទាយី |
| ៧៧- ព្រះឧបវាណៈ | ៧៨- ព្រះអង្គុលិមាល |
| ៧៩- ព្រះវប្បៈ | ៨០- ព្រះភទ្ទិយៈ ។ |

# ✍ ជីវប្រវត្តិរបស់ព្រះអានន្ទត្ថេរ ✍

## " ដែលជាឯតទគ្គៈផ្នែកខាងពហូស្សុត ១ មានសតិ ១ មានគតិ ១ មានធិតិ ១ ជាពុទ្ធុបដ្ឋាក ១ "

*ព្រះអានន្ទត្ថេរ លោកជាឃ្លាំងព្រះធម៌ផង ថែមទាំងជាអ្នកបានទទួលតំណែងជាឯតទគ្គៈ ៥ ទៀតផង និងជាមហាសាវកមួយរូបដ៏ឆ្នើមក្នុងចំណោមព្រះអសីតិមហាសាវក៨០រូប ទាំងការបរិនិព្វានរបស់លោកនោះ ក៏ប្លែកអំពីសាវកអង្គដទៃទៀតដែរ ទាំងនេះបញ្ជាក់ឲ្យឃើញបានថា ជីវប្រវត្តិរបស់លោក គួរឲ្យយើងជ្រះថ្លាយ៉ាងក្រៃលែងណាស់ ។*

*ជីវប្រវត្តិអតីតជាតិរបស់ព្រះអានន្ទត្ថេរ មានសម្ដែងនៅក្នុង **អដ្ឋកថាមនោរថបូរណី** និង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីក្នុងព្រះបាលី **អានន្ទត្ថេរគាថា** និង **គម្ពីរខុទ្ទកនិកាយ ថេរគាថា** សម្ដែងឲ្យឃើញថា ការសន្សំបុណ្យបារមីគ្រប់យ៉ាង ក៏ដើម្បីឲ្យបានភាពប្រសើរ ជាងសាវកទាំងឡាយ រហូតទៅដល់ ៥ ប្រការ*

ដូចមានសេចក្ដីថា ៖

ក្នុងអតីតជាតិ បានឮថា ក្នុងកប្បទីមួយសែន រាប់ត្រឡប់ថយក្រោយ ពីកប្បនេះទៅ មានព្រះពុទ្ធព្រះនាមថាបទុមុត្តរៈឧប្បត្តិឡើងក្នុងលោក ពុទ្ធបិតាព្រះនាមថា **សុនន្ទរាជ** ពុទ្ធមាតាព្រះនាមថា **សុជាតា** ទ្រង់គ្រប់គ្រងរាជសម្បត្តិនៅក្នុងនគរហង្សវតី ។ព្រះពោធិសត្វព្រះនាមថា **ឧត្តរកុមារ** កាលនៅជាយុវរាស ឧត្តរកុមារមានអគ្គមហេសី និងព្រះរាជឱរសមុនពេលដែលស្ដេចយាងចេញទៅសាងព្រះផ្នួសម៉្លេះ ក្នុងថ្ងៃដែលព្រះអង្គចេញសាងព្រះផ្នួស ជាថ្ងៃដែលព្រះឱរសប្រសូត ហើយទ្រង់មានសេចក្ដីព្យាយាមរហូតបានសម្រេចជាព្រះសម្មាសម្ពុទ្ធ ទើបទ្រង់បន្លឺព្រះពុទ្ធឧទានថា **អនេកជាតិសង្សារំ** ជាដើម ទ្រង់គង់ប្រថាប់នៅពោធិបល្ល័ង្កអស់ ៧ ថ្ងៃ ហើយទ្រង់ឈានព្រះបាទចុះចាកពោធិបល្ល័ង្កនោះ មានផ្កាឈូកធំផុសឡើងមកទ្រព្រះបាទរបស់ព្រះអង្គ ទើបមានព្រះនាមថា ព្រះបទុមុត្តរៈ ។ ព្រះអង្គមានអគ្គសាវកព្រះនាមថា **ព្រះទេវិលត្ថេរ** និង **ព្រះចុឡជាតត្ថេរ** ព្រះអង្គមានអគ្គសាវិកាព្រះនាមថា **អមិត្តាថេរី** និងព្រះនាម

ថា **អសមាថេរី** មានពុទ្ធុប្បដ្ឋាកព្រះនាមថា **សុមនត្ថេរ** ទ្រង់មានភិក្ខុសង្ឃមួយសែនរូបជាបរិវារ ទ្រង់គង់ប្រថាប់នៅក្នុងក្រុងហង្សវតី ចំណែកព្រះកនិដ្ឋភាតារបស់ព្រះអង្គព្រះនាមថា **សុមនរាជកុមារ** ព្រះរាជបិតានន្ទរាជ បានព្រះរាជទានស្រុកសួយ ១២០ យោជន៍ ( កន្លែងខ្លះថាពីរពាន់យោជន៍) ដោយរាប់តាំងអំពីក្រុងហង្សវតីទៅ ឲ្យដល់សុមនរាជកុមារនោះ ឲ្យជាអ្នកគ្រប់គ្រងស្រុកទាំងអស់នោះ ចំណែកសុមនរាជកុមារនោះស្តេចយាងមកគាល់ព្រះរាជបិតា និងព្រះសាស្តាម្តងម្កាល ។

ថ្ងៃមួយ ជនបទកើតចលាចល សុមនកុមារ ទើបបញ្ជូនដំណឹងទៅថ្វាយព្រះរាជាៗ ទ្រង់តបទៅវិញថា បិតាបានតែងតាំងអ្នកឲ្យជាអ្នកមើលការខុសត្រូវចំពោះជនបទទាំងនោះ ដូច្នេះ ចូរអ្នកចាត់ចែងនូវកិច្ចការទាំងនោះចុះ សុមនរាជកុមារនោះ ក៏បានធ្វើជនបទទាំងនោះឲ្យស្ងប់រម្ងាប់ទៅវិញ ហើយបញ្ជូនដំណឹងទៅក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះទេវៈជនបទបានស្ងប់រម្ងាប់ហើយ ព្រះរាជាទ្រង់ត្រេកអរត្រាស់ថា បុត្រចូរប្រញាប់មក សុមនរាជកុមារ ព្រមទាំងអាមាត្យមួយពាន់នាក់ ទ្រង់បាន

ប្រឹក្សាជាមួយនឹងអាមាត្យទាំងនោះក្នុងវាំងថាវថា ព្រះរាជបិតារបស់ខ្ញុំទ្រង់ត្រេកអរណាស់ ប្រសិនបើព្រះរាជទានពរដល់ខ្ញុំ តើខ្ញុំគប្បីទទួលយកពរអ្វី ពួកអាមាត្យខ្លះ ក្រាបទូលដល់ព្រះរាជកុមារថា សូមទ្រង់ទទួលយកដំរី សេះ ជនបទ រតនៈ ៧ ប្រការ ។ អាមាត្យមួយពួកទៀតទូលថា ព្រះអង្គជាព្រះរាជឱរសរបស់ស្តេចផែនដី ចំពោះទ្រព្យសម្បត្តិព្រះអង្គរមែងមិនលំបាកទេ តែទ្រព្យទាំងអស់នោះ បើព្រះអង្គបានហើយ ត្រូវលះចោលទៅវិញទាំងអស់ មានតែបុណ្យទេទើបព្រះអង្គអាចនាំយកទៅបាន ព្រោះដូច្នោះ ប្រសិនបើព្រះសម្មតិទេពព្រះរាជទានពរ សូមព្រះអង្គទទួលពរគឺធ្វើការឧបដ្ឋាកព្រះបទុមុត្តរៈរហូតអស់មួយត្រៃមាសចុះ ទើបប្រសើរ ។

ព្រះរាជកុមារត្រាស់ថា ពួកលោកជាកល្យាណមិត្តរបស់ខ្ញុំ ពួកលោកមានគំនិតយ៉ាងនេះ ខ្ញុំនឹងធ្វើតាម ហើយស្តេចចូលទៅថ្វាយបង្គំព្រះរាជបិតាៗ ត្រាស់ថា បុត្រ បិតានឹងប្រទានពរឲ្យដល់បុត្រ ដូច្នេះហើយទើបក្រាបទូលថា បពិត្រព្រះរាជបិតា ទូលព្រះបង្គំមិនចង់បានអ្វីទេ ប៉ុន្តែចង់បានជាអ្នកទំនុកបម្រុងព្រះបទុមុត្តរៈ ដោយបច្ច័យទាំងឡាយ ៤

របូតអស់មួយត្រៃមាស ដើម្បីញ៉ាំងជីវិតឲ្យបានទទួលនូវប្រយោជន៍ ។ ព្រះរាជបិតាត្រាស់ថា បិតាមិនអាចប្រទានពរនេះឲ្យដល់បុត្របានទេ សុមនរាជកុមារក្រាបទូលថា បពិត្របិតា ធម្មតាក្សត្រមិនត្រាស់ព្រះបន្ទូលជាលើកទីពីរឡើយ ។ សូមព្រះរាជបិតា ព្រះរាជទានពរនេះឲ្យដល់ទូលព្រះបង្គំផងចុះ ពរដទៃទូលព្រះបង្គំមិនត្រូវការទេ ។ ព្រះរាជាត្រាស់ថា ធម្មតាថាព្រះទ័យនៃព្រះសម្មាសម្ពុទ្ធដឹងបានដោយលំបាក ប្រសិនបើព្រះភគវាទ្រង់មិនប្រាថ្នា កាលបើបិតាប្រទានពរនេះ ដល់បុត្រហើយ នឹងមានរឿងអ្វីៗ តើគិតយ៉ាងម៉េច ព្រះរាជកុមារក្រាបទូលថា ល្អហើយ ព្រះបិតា ទូលព្រះបង្គំនឹងជ្រាបព្រះទ័យនៃព្រះលោកនាថ ពោលដូច្នេះហើយទើបស្ដេចយាងចូលទៅកាន់វិហារ ។

សម័យនោះ ព្រះបទុមុត្តរៈទទួលភត្តរួចជាស្រេចហើយ ស្ដេចយាងចូលទៅក្នុងព្រះគន្ធកុដិ ព្រះរាជកុមារបានចូលទៅរកភិក្ខុទាំងឡាយដែលប្រជុំគ្នានៅក្នុងសាលាធម្មសភា ភិក្ខុទាំងនោះទូលសួរព្រះរាជកុមារថា តើព្រះរាជបុត្រស្ដេចយាងមកមានការអ្វី ព្រះរាជកុមារត្រាស់ថា មក

ដើម្បីចូលគាល់ព្រះមហាមុនី សូមលោកម្ចាស់ទូលដល់ព្រះសុគតសាស្តា ឲ្យខ្ញុំព្រះករុណាផង ភិក្ខុទាំងនោះទូលថា ព្រះរាជកុមារ ពេលនេះមិនអាចនឹងទៅជួបព្រះសយម្ភូបានទេ ទើបត្រាស់សួរទៀតថា តើមានអ្នកណាអាចចូលទៅគាល់ព្រះអង្គបានដែរឬ ភិក្ខុទាំងនោះទូលតបថា មានព្រះរាជបុត្រ គឺសុមនត្ថេរ ព្រះរាជកុមារសួរថា តើព្រះថេរៈនោះគង់នៅក្នុងទីណា ខ្ញុំព្រះករុណាប្រាថ្នានឹងចូលទៅគាល់ព្រះសាស្តា សូមឲ្យលោកម្ចាស់អង្គនោះទូលព្រះភគវាឲ្យខ្ញុំព្រះករុណាផង គ្រានោះ ព្រះថេរៈក៏ចូលអាបោកសិណ ហើយអធិដ្ឋានផែនដីឲ្យដូចជាទឹក មុជចុះទៅក្នុងផែនដីទៅប្រាកដត្រង់ព្រះគន្ធកុដិរបស់ព្រះសាស្តា ។

គ្រានោះ ព្រះសម្ពុទ្ធត្រាស់ជាមួយនឹងសុមនត្ថេរថា សុមនៈ អ្នកមកមានការអ្វី ព្រះថេរៈទូលថា ព្រះរាជបុត្រស្តេចយាងមក មានបំណងនឹងចូលគាល់ព្រះអង្គ ។ ប្រសិនបើយ៉ាងនោះ ចូរអ្នកទៅរៀបចំអាសនៈចុះ ។ កាលព្រះរាជកុមារកំពុងទតឃើញនោះឯង ព្រះថេរៈកាន់យកពុទ្ធាសនៈមុជចុះក្នុងព្រះគន្ធកុដិទៅប្រាកដខាងក្រៅបរិវេណព្រះគន្ធកុដិ

វិញ រៀបចំក្រាលអាសនៈ ព្រះរាជកុមារទ្រង់ទតឃើញហេតុដ៏អស្ចារ្យ ទាំងពីរនោះហើយ ទ្រង់ត្រិះរិះថា ភិក្ខុរូបនេះជាធំហ្ន៎ សូម្បីព្រះលោកនាថ ក៏ស្តេចចេញអំពីព្រះគន្ធកុដិមកដែរ ហើយទ្រង់គង់ប្រថាប់លើអាសនៈ ដែលរៀបចំទុក ព្រះមានព្រះភាគត្រាស់សួរថា តើព្រះរាជបុត្រយាងមក ដល់ពេលណា ? ព្រះរាជកុមារទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងពេល ព្រះអង្គស្តេចយាងចូលទៅព្រះគន្ធកុដិ តែភិក្ខុទាំងឡាយប្រាប់ថា ពេល នេះមិនអាចចូលទៅគាល់ព្រះអង្គបានទេ ហើយប្រាប់ខ្ញុំព្រះអង្គឲ្យទៅរក ព្រះថេរៈរូបនោះ ដែលជាទីស្និទ្ធស្នាលរបស់ព្រះអង្គ ព្រះបទុមុត្តរៈទ្រង់ ត្រាស់ថា ពិតមែនហើយ ភិក្ខុរូបនោះជាទីស្និទ្ធស្នាលរបស់តថាគត ព្រះ រាជកុមារទូលថា ភិក្ខុរូបនេះ ធ្វើអ្វីទើបជាទីស្និទ្ធស្នាលរបស់ព្រះអង្គ ? ព្រះសម្ពុទ្ធទ្រង់ត្រាស់ថាជាអ្នកបានថ្វាយទានរក្សាឧបោសថនិងបំពេញ សេចក្តីល្អដទៃទៀត ទើបបានសម្រេចនូវសេចក្តីប្រាថ្នានេះបាន ។ ព្រះរាជ កុមារទូលថា បពិត្រព្រះភគវា ខ្ញុំព្រះអង្គប្រាថ្នាឲ្យបានភាពស្និទ្ធស្នាល ដូចព្រះថេរៈរូបនេះដែរ ថ្ងៃស្អែកនេះ សូមព្រះអង្គអារាធនាទទួលភិក្ខា

របស់ខ្ញុំព្រះអង្គ ព្រះសម្ពុទ្ធទទួលដោយតុណ្ហីភាព ។

ព្រះរាជកុមារ ស្តេចយាងត្រឡប់ទៅកាន់ទីគង់ប្រថាប់ របស់ព្រះអង្គវិញ រៀបចំគ្រឿងសក្ការៈរហូតអស់មួយយប់ទល់ភ្លឺ បានថ្វាយខន្ធវារភត្ត ( ភិក្ខាដែលថ្វាយព្រះសាស្តាក្នុងចន្លោះពេលដែលជំរំស្នាក់នៅ)។ ថ្ងៃទី ៧ ថ្វាយបង្គំព្រះសាស្តាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានទទួលពរ ដើម្បីបានជាឧបដ្ឋាកទំនុកបម្រុងព្រះអង្គ រហូតអស់ត្រៃមាស ក្នុងវស្សានរដូវនេះ ពីព្រះរាជបិតា សូមព្រះអង្គទ្រង់គង់ចាំព្រះវស្សាក្នុងទីនេះចុះ ដើម្បីប្រយោជន៍ដល់ខ្ញុំព្រះអង្គផង ព្រះសាស្តាទ្រង់ពិចារណាមើលថា អត្ថប្រយោជន៍ដោយសេចក្តីល្អនេះ មានឬទេហ្ន៎ ក៏ទ្រង់ឃើញថាមាន ទើបត្រាស់ថា នែព្រះរាជកុមារ ព្រះតថាគតទាំងឡាយ រមែងត្រេកអរក្នុងទីស្ងាត់ ព្រះរាជកុមារត្រាស់ថា បពិត្រព្រះសុគត ខ្ញុំព្រះអង្គដឹងហើយៗ ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងឲ្យគេកសាងវិហារ ថ្វាយដល់ព្រះអង្គ ព្រមដោយភិក្ខុសង្ឃមួយសែនរូប ពេលនោះព្រះមានព្រះភាគទទួលការនិមន្តន៍ហើយ ស្តេច

យាងទៅកាន់សម្នាក់ព្រះរាជបិតាក្រាបទូលថា បពិត្រព្រះរាជបិតា ព្រះភគវាព្រមទទួលការនិមន្តន៍របស់ទូលព្រះបង្គំហើយ ទើបថ្វាយបង្គំលាព្រះរាជបិតាត្រឡប់ទៅវិញ ព្រះអង្គឲ្យគេចាត់ចែងកសាងវិហារក្នុងរយៈផ្លូវ មួយយោជន៍មួយកន្លែងៗ ស្តេចយាងទៅអស់ចម្ងាយផ្លូវពីរពាន់យោជន៍ ។

កាលស្តេចយាងទៅដល់ហើយ ទ្រង់ជ្រើសរើសទីកន្លែងកសាងវិហារក្នុងនគររបស់ព្រះអង្គ ទ្រង់ឃើញឧទ្យានរបស់កុដុម្ពិកៈឈ្មោះសោភៈ ទ្រង់ទិញដីនោះដោយតម្លៃមួយសែនកហាបណៈ កសាងវិហារអស់តម្លៃមួយសែនកហាបណៈ ថែមទាំងឲ្យកសាងព្រះគន្ធកុដិសម្រាប់ព្រះភគវាទៀតផង និងកសាងសេនាសនៈមណ្ឌបសម្រាប់សម្រាកពេលថ្ងៃ និងពេលយប់សម្រាប់ភិក្ខុទាំងឡាយ ក្រៅអំពីនោះ ឲ្យគេចាត់ចែងធ្វើកំពែងព័ទ្ធជុំវិញ និងខ្លោងទ្វាររួចជាស្រេចហើយ ទើបបញ្ជូនរាជបុរសទៅកាន់សម្នាក់ព្រះរាជបិតា ក្រាបទូលថា ការកសាងវិហាររួចជាស្រេចហើយ សូមព្រះបិតាអារាធនានិមន្តព្រះសាស្តាផង ។ កាលបើព្រះរាជបិតា បាន

ថ្វាយចង្ហាន់បិណ្ឌបាតចំពោះព្រះសម្ពុទ្ធ ឲ្យទ្រង់សោយរួចជាស្រេចហើយ ទូលថា បពិត្រព្រះសុគត កិច្ចរបស់សុមនរាជកុមារធ្វើរួចស្រេចអស់ហើយ គេរង់ចាំការនិមន្តន៍ទៅរបស់ព្រះអង្គ ព្រះមានព្រះភាគ មានភិក្ខុសង្ឃមួយសែនរូបហែហមជាបរិវារ កាលស្ដេចយាងទៅ ក៏ប្រថាប់ក្នុងវិហារទាំងឡាយ អស់រយៈផ្លូវមួយយោជន៍ ព្រះរាជកុមារទ្រង់ជ្រាបថា ព្រះសាស្ដាកំពុងយាងមក ក៏ចេញទៅទទួលអស់រយៈផ្លូវមួយយោជន៍ បានបូជាដោយផ្កាកម្រង និងគ្រឿងក្រអូបជាដើមរួចហើយ ក៏ចូលទៅកាន់ព្រះវិហារ ដើម្បីវេរថ្វាយព្រះសម្មាសម្ពុទ្ធ ។

ក្នុងថ្ងៃចូលព្រះវស្សា ព្រះរាជកុមារថ្វាយទានរួចហើយ ក៏ហៅបុត្រភរិយារបស់ខ្លួន និងពួកអាមាត្យមកហើយ ប្រាប់ថា ព្រះសាស្ដាយាងមកកាន់សម្នាក់របស់ពួកយើងដោយផ្លូវឆ្ងាយ ព្រះពុទ្ធជាម្ចាស់របស់យើង ទ្រង់ធ្ងន់ក្នុងធម៌ មិនឃើញតែអាមិស ព្រោះដូច្នោះ យើងនឹងស្លៀកសំពត់តែពីរផ្ទាំងរហូតអស់ត្រៃមាសនេះ សមាទានសីល ១០ ជានិច្ចក្នុងទីនេះឯង ពួកលោកចូរថ្វាយទានដល់ព្រះមានព្រះភាគ និងព្រះខីណាស្រព

មួយសែនរូប ។ សុមនរាជកុមារ ប្រថាប់នៅជិតនឹងទីនៅរបស់ព្រះសុមនះ ឃើញកិច្ចកម្មគ្រប់យ៉ាង ដែលព្រះថេរៈធ្វើវត្តដល់ព្រះមានព្រះភាគ ហើយត្រិះរិះថា ព្រះថេរៈរូបនេះស្និទ្ធស្នាលនឹងព្រះភគវាណាស់ យើងគួរឲ្យបាននូវតំណែងដូចព្រះថេរៈនេះ ។ កាលជិតចេញវស្សា ស្តេចចូលទៅកាន់ដំណាក់ថ្វាយមហាទាន ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ទ្រង់ដាក់ចីវរទៀបបាទារបស់ភិក្ខុមួយសែនរូប ហើយថ្វាយបង្គំព្រះលោកនាថ ទូលថា បពិត្រព្រះអង្គដ៏ចម្រើន បុណ្យដែលខ្ញុំព្រះអង្គបានធ្វើ តាំងពីការថ្វាយទានត្រង់ទីសម្រាកតាមផ្លូវមក ៧ ថ្ងៃនោះ ខ្ញុំព្រះអង្គមិនបានប្រាថ្នាសម្បត្តិសួគ៌ សម្បត្តិព្រហ្មទេ ខ្ញុំព្រះអង្គប្រាថ្នាឲ្យបានជាឧបដ្ឋាករបស់ព្រះពុទ្ធជាម្ចាស់ ដូចជាព្រះសុមនត្ថេរនេះប៉ុណ្ណោះ ។ ព្រះមហាមុនី ទ្រង់មិនឃើញអន្តរាយក្នុងការប្រាថ្នានេះ ទើបទ្រង់ព្យាករថា ព្រះរាជកុមារនឹងបានសម្រេចតាមសេចក្តីប្រាថ្នា ហើយស្តេចត្រឡប់ទៅ ។ ព្រះរាជកុមារបានស្តាប់ហើយត្រិះរិះថា ធម្មតាព្រះពុទ្ធទាំងឡាយ មិនត្រាស់ពាក្យជាលើកទីពីរ ។ ក្នុងថ្ងៃទី ២ ក៏បានកាន់បាត្រ និងចីវរតាមស្តេចទៅ ហាក់បីដូចបាត្រ និងចីវរ

របស់ព្រះគោតមជាម្ចាស់ ។ លុះស្លាប់ពីមនុស្សលោកនេះទៅ ក៏កើតក្នុងស្ថានសួគ៌រាប់សែនឆ្នាំ ។

ក្នុងសាសនាព្រះពុទ្ធកស្សប បានថ្វាយសំពត់ជណ្តប់ដើម្បីទ្រាប់បាត្រដល់ព្រះថេរៈដែលនិមន្តទៅបិណ្ឌបាត បន្ទាប់ពីស្លាប់ទៅ ក៏កើតក្នុងស្ថានសួគ៌ទៀត ចុតិចាកទេវលោកហើយ កើតជាស្តេចនៅក្នុងក្រុងពារាណសី កាលស្តេចយាងឡើងលើប្រាសាទជាន់ខាងលើ ក៏បានទតឃើញព្រះបច្ចេកពុទ្ធ ៨ អង្គ ដែលនិមន្តមកពីភ្នំគន្ធមាទន៍ ហើយក៏បានឲ្យគេនិមន្តព្រះបច្ចេកពុទ្ធទាំងនោះមកដើម្បីថ្វាយចង្ហាន់ ទ្រង់ឲ្យគេកសាងបណ្ណសាលា ៨ ខ្នង សម្រាប់ព្រះបច្ចេកពុទ្ធ ក្នុងឧទ្យានរបស់ព្រះអង្គ ទ្រង់តាក់តែងធ្វើដោយរតនៈសុទ្ធ គ្រែនិងស្បែកជើងធ្វើដោយកែវមណី ធ្វើការទំនុកបម្រុងអស់ម៉ឺនឆ្នាំ ។ លោកថ្វាយទានអស់សែនកប្ប កើតក្នុងស្ថានតុសិតជាមួយនឹងព្រះពោធិសត្វ ចុតិចាកស្ថានតុសិតនោះហើយ កើតក្នុងប្រាសាទរបស់អមិតោទនរាជ លោកកើតហើយ ធ្វើឲ្យព្រះញាតិទាំងអស់ត្រេកអររីករាយ ដូច្នេះ ទើបពួកញាតិថ្វាយព្រះនាមថា អានន្ទ ។

កាលព្រះទសពលជាម្ចាស់ ស្ដេចត្រាស់ដឹងហើយ ទ្រង់និមន្តមកក្រុងកបិលពស្តុជាគ្រាដំបូង កាលពួកព្រះរាជកុមារបព្វជ្ជាដើម្បីជាបរិវាររបស់ព្រះមានព្រះភាគ អានន្ទរាជកុមារ ក៏ចេញបួសក្នុងសម្នាក់ព្រះសាស្ដាព្រមជាមួយពួកសក្យៈ មានព្រះភទ្ទិយៈ អនុរុទ្ធ ភគ្គុ កិម្ពិលៈ ទេវទត្តនិងនាយឧបាលី ។ មិនយូរប៉ុន្មាន លោកបានស្ដាប់ធម្មកថារបស់ព្រះបុណ្ណមន្តានីបុត្រ ក៏បានសម្រេចសោតាបត្តិផល ។

ព្រះសុគតសាស្ដាជាម្ចាស់ ទ្រង់មានភិក្ខុឧបដ្ឋាកមិនច្បាស់លាស់អស់ ២០ ឆ្នាំ ក្នុងបឋមពោធិកាល គ្រាខ្លះព្រះនាគសមាលៈ គ្រាខ្លះក៏ព្រះនាគិតៈ គ្រាខ្លះក៏ព្រះឧបវាណៈ គ្រាខ្លះក៏ព្រះសុនក្ខត្តៈ គ្រាខ្លះក៏ព្រះចុន្ទៈ គ្រាខ្លះក៏ព្រះសាគតៈ គ្រាខ្លះក៏ព្រះរាធៈ គ្រាខ្លះក៏ព្រះមេឃិយៈ ។ ថ្ងៃមួយ ព្រះមានព្រះភាគ ស្ដេចពុទ្ធដំណើរទៅផ្លូវឆ្ងាយជាមួយនឹងព្រះនាគសមាលត្ថេរ ដល់ផ្លូវបែកជាពីរក៏ក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងទៅផ្លូវនេះ ព្រះមានព្រះភាគត្រាស់ថា មកភិក្ខុ តថាគតនឹងទៅតាមផ្លូវនេះជាមួយអ្នក ព្រះថេរៈក្រាបទូលថា បពិត្រព្រះមានព្រះភាគ

សូមទ្រង់ទៅតាមផ្លូវព្រះអង្គចុះ ខ្ញុំព្រះអង្គនឹងទៅតាមផ្លូវនេះ ហើយក៏ដាក់បាត្រ ចីវរទុកលើផែនដី ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកចូរហុចបាត្រ និងចីវរមកតថាគត កាលព្រះសុគតបានទទួលបាត្រ និងចីវរហើយក៏ស្តេចយាងទៅ ។ពេលដែលព្រះថេរៈនិមន្តបែកពីព្រះសម្ពុទ្ធ ទៅតាមផ្លូវតែម្នាក់ឯងនោះ ក៏បានជួបនឹងពួកចោរៗ ក៏ដណ្តើមយកបាត្រចីវររបស់លោក ថែមទាំងវាយព្រះថេរៈរហូតដល់បែកព្រះសិសៈ គ្រានោះលោកគិតថា ឥឡូវនេះ មានតែព្រះមានព្រះភាគជាម្ចាស់ទេ ជាទីពឹងរបស់អាត្មាអញ ហើយក៏មកកាន់សម្នាក់ព្រះមានព្រះភាគ ទាំងដែលមានឈាមហូរ ។ កាលព្រះមានព្រះភាគត្រាស់សួរថា មានរឿងអ្វីភិក្ខុ ? លោកក៏ឆ្លើយថា ពួកចោរបៀតបៀនខ្ញុំព្រះអង្គ ទ្រង់លួងលោមថា អ្នកកុំគិតអ្វីឡើយ តថាគតបបួលអ្នកមកជាមួយ ក៏ព្រោះតែហេតុទាំងនោះឯង ។

គ្រាមួយ ព្រះមានជោគ ស្តេចយាងទៅកាន់ស្រុកជន្តុគ្រាម ជិតបាចីនវង្សមិគទាយវ័នជាមួយព្រះមេឃិយត្ថេរ ក្នុងទីនោះព្រះមេឃិយត្ថេរ

ត្រាច់ទៅបិណ្ឌបាតក្នុងជន្តុគ្រាម ជួបនឹងចម្ការស្វាយគួរជាទីរីករាយ នៅក្បែរច្រាំងនៃស្ទឹង ក៏ក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់យកបាត្រនិងចីវររបស់ព្រះអង្គចុះ ខ្ញុំព្រះអង្គនឹងធ្វើសមណធម៌ក្នុងព្រៃស្វាយនោះ សូម្បីព្រះទសពលទ្រង់ហាមបីដង ក៏នៅតែទៅ កាលអកុសលវិតក្កចូលគ្របសង្កត់ ក៏ត្រឡប់មកទូលរឿងរ៉ាវថ្វាយព្រះមានព្រះភាគ ព្រះអង្គត្រាស់ថា តថាគតហាមឃាត់ព្រោះតែរឿងអ៊ីចឹងឯង ហើយស្តេចចារិកទៅកាន់ក្រុងសាវត្ថីតាមលំដាប់ ។ កាលព្រះមានព្រះភាគ ប្រថាប់នៅក្រុងសាវត្ថីនោះ ទ្រង់គង់លើពុទ្ធាសនៈ ដែលគេចាត់ចែងទុកត្រង់បរិវេណព្រះគន្ធកុដិ ហើយត្រាស់ហៅភិក្ខុទាំងឡាយមកប្រាប់ថា ម្នាលភិក្ខុទាំងឡាយឥឡូវនេះ តថាគតចាស់ហើយ ភិក្ខុខ្លះពោលថា ខ្ញុំព្រះអង្គនឹងទៅផ្លូវនេះ ហើយក៏គេចចេញទៅ ភិក្ខុខ្លះក៏ដាក់បាត្រ ចីវររបស់តថាគតលើផ្ទៃដី ពួកអ្នកចូរជ្រើសរើសភិក្ខុជាឧបដ្ឋាកពិតប្រាកដដល់តថាគតផង ភិក្ខុទាំងឡាយមានសេចក្តីសង្វេគ នឹកស្មានមិនដល់ ។ ខណៈនោះ ព្រះសារីបុត្រក្រោកចាកអាសនៈថ្វាយបង្គំក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ

ប្រាថ្នាជួបព្រះអង្គ ទើបបំពេញបារមីទាំងឡាយ អស់មួយអសង្ខេយ្យកម្រៃ មួយសែនកប្ប បុគ្គលមានបញ្ញាច្រើនដូចខ្ញុំព្រះអង្គ សមគួរជាឧបដ្ឋាក ឬ ខ្ញុំព្រះអង្គសូមជាឧបដ្ឋាក ព្រះមានព្រះភាគត្រាស់ហាមថា កុំឡើយសារីបុត្រ អ្នកនៅទិសណាក៏មិនទំនេរ ឱវាទរបស់អ្នកក៏ដូចជាឱវាទរបស់តថាគត កិច្ចដែលអ្នកត្រូវឧបដ្ឋាកតថាគតមិនមានទេ ព្រះអសីតិមហាសាវកតាំងពីព្រះមហាមោគ្គល្លានជាលំដាប់មក ក៏ក្រោកឡើង ក្រាបទូលដូចគ្នានឹងព្រះសារីបុត្រដែរ តែព្រះបរមសាស្តាទ្រង់ត្រាស់ហាមឃាត់ទាំងអស់ ចំណែកឯព្រះអានន្ទគង់នៅស្ងៀម លំដាប់នោះ ភិក្ខុទាំងឡាយពោលនឹងព្រះអានន្ទថា អានន្ទ ភិក្ខុសង្ឃទូលសូមតំណែងឧបដ្ឋាក លោកក៏គួរទូលសូមដែរ ព្រះអានន្ទពោលថា លោកដ៏មានអាយុទាំងឡាយ តើប្រយោជន៍អ្វីដោយតំណែងដែលខ្ញុំព្រះករុណាទូលសូម ព្រះមានព្រះភាគមិនឃើញខ្ញុំឬ ប្រសិនបើព្រះសាស្តាទ្រង់សព្វព្រះទ័យ ក៏នឹងត្រាស់ថា អានន្ទ ចូរជាឧបដ្ឋាកតថាគតដូច្នេះ លំដាប់នោះ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អានន្ទមិនចាំបាច់មានបុគ្គលដទៃបបួលឲ្យក្រោក

ឡើងទូលសូមទេ នឹងដឹងខ្លួនឯង ហើយឧបដ្ឋាកតថាគត ពេលនោះ ភិក្ខុទាំងឡាយពោលថា ក្រោកឡើងអានន្ទ លោកចូរក្រាបទូលសូមតំណែងជាឧបដ្ឋាកនឹងព្រះសម្មាសម្ពុទ្ធចុះ ។ គ្រានោះ ព្រះអានន្ទក្រោកឡើងក្រាបទូលសូមពរ ៨ ប្រការ អំពីព្រះទសពលដើម្បីធានាខ្លួនធ្វើជាឧបដ្ឋាក គឺ ១ សូមព្រះអង្គកុំឲ្យចីវរដែលគហបតីថ្វាយដល់ព្រះអង្គ ដល់ខ្ញុំព្រះអង្គឡើយ ២ សូមព្រះអង្គកុំប្រទានបិណ្ឌបាតដ៏ប្រណីតដល់ខ្ញុំព្រះអង្គ ៣ សូមព្រះអង្គកុំឲ្យខ្ញុំព្រះអង្គនៅក្នុងព្រះគន្ធកុដិរួមជាមួយ ៤ សូមព្រះអង្គកុំនាំខ្ញុំព្រះអង្គទៅក្នុងទីដែលគេនិមន្ត ៥ សូមព្រះអង្គស្តេចទៅកាន់ទីដែលខ្ញុំព្រះអង្គនិមន្តទុកហើយ ៦សូមមេត្តាឲ្យខ្ញុំព្រះអង្គនាំពួកពុទ្ធបរិស័ទដែលមកពីទិសផ្សេងៗ ចូលគាល់បានគ្រប់កាល ៧ បើខ្ញុំព្រះអង្គមានសេចក្តីសង្ស័យក្នុងកាលណា សូមព្រះអង្គឲ្យខ្ញុំព្រះអង្គចូលគាល់សួរបានក្នុងកាលនោះ ៨ បើព្រះអង្គសម្តែងធម៌ក្នុងទីណា ដែលខ្ញុំព្រះអង្គមិនបានស្តាប់ សូមព្រះអង្គសម្តែងធម៌នោះដល់ខ្ញុំព្រះអង្គម្តងទៀត ។ ចំណែកពរ ៤ ខាងដើម សូមហាមពរ ៤ ខាងចុងសូមសំណូមពរ ។

ព្រះពុទ្ធត្រាស់សួរថា អានន្ទ តើអ្នកឃើញទោសយ៉ាងណា ទើបហាមពរ ៤ ខាងដើម ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើខ្ញុំព្រះអង្គនឹងបាននូវវត្ថុបំណាងទាំងនោះ នឹងមានអ្នកជទៃពោលថា អានន្ទប្រើប្រាស់ចីវរ បានបិណ្ឌបាត ថែមទាំងនៅក្នុងព្រះគន្ធកុដិជាមួយព្រះអង្គ និងមានការនិមន្តន៍ទៅទីណា ក៏ជាមួយនឹងព្រះភគវាដែរ លាភទាំងអស់នេះកើតឡើង មកអំពីព្រះអានន្ទជានាខ្ទនធ្វើជាឧបដ្ឋាករបស់ព្រះមហាមុនី បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញទោសយ៉ាងនេះឯង ទើបសូមហាមពរទាំង ៤នេះអំពីព្រះអង្គ ។ចុះចំពោះសំណូមពរ ៤ ខាងចុងនោះ តើមានប្រយោជន៍យ៉ាងណា ទើបព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកពុទ្ធបរិស័ទដែលមានសទ្ធាក្នុងលោកនេះ កាលបើមិនបានឱកាសចូលគាល់ព្រះបរមសាស្តាហើយ ទើបពោលជាមួយខ្ញុំព្រះអង្គយ៉ាងនេះថា លោកម្ចាស់អានន្ទ ថ្ងៃស្អែកនេះ សូមលោកម្ចាស់ ជាមួយនឹងព្រះសក្យមុនីទទួលភត្តាហារនៅក្នុងផ្ទះរបស់ខ្ញុំ ប្រសិនបើព្រះអង្គមិនទទួលនិមន្តទៅទេនោះ ខ្ញុំព្រះអង្គមិនបានឱកាស

ឲ្យពុទ្ធបរិស័ទចូលគាល់តាមសេចក្តីប្រាថ្នាបាន បើខ្ញុំព្រះអង្គមានសេចក្តីសង្ស័យ ពួកគេនឹងពោលថា អានន្ទ អ្នកធ្វើជាឧបដ្ឋាករបស់ព្រះភគវាបានប្រយោជន៍អ្វី សូម្បីតែព្រះអង្គក៏មិនអនុគ្រោះដល់អ្នកផង នឹងមានគេសួរដល់ខ្ញុំព្រះអង្គថា គាថានេះ ព្រះសូត្រនេះ ព្រះអង្គទ្រង់សម្តែងនៅក្នុងទីណា ប្រសិនបើខ្ញុំព្រះអង្គមិនដឹងទេនោះ ពួកគេនឹងពោលថា អានន្ទសូម្បីត្រឹមតែប៉ុណ្ណេះ មិនដឹងទៅហើយ តើមានប្រយោជន៍អ្វីក្នុងការនៅរួមជាមួយព្រះមានព្រះភាគនោះ ខ្ញុំព្រះអង្គឃើញប្រយោជន៍ដូច្នេះឯង ទើបសូមពរទាំងនេះ កាលបើព្រះអង្គទ្រង់សណ្តាប់នូវការសូមពរទាំងអស់នោះហើយ ក៏ព្រះអង្គត្រាស់ថា អានន្ទ តថាគតប្រទានពរឲ្យដល់អ្នក ឲ្យសមតាមបំណងដែលអ្នកសុំពរចុះ ពេលនោះ ព្រះអានន្ទបានទទួលពរទាំងនោះហើយ ទើបបានជានាខ្លួនធ្វើជាឧបដ្ឋាកព្រះសុគតតរហូតមក ។

ការសន្សំបុណ្យបារមីទាំងឡាយ ដែលបានបំពេញរហូតមួយសែនកប្បមកហើយ ក៏បានធ្វើឲ្យព្រះអានន្ទសម្រេចតាមសេចក្តីប្រាថ្នា ចំពោះ

តំណែងជាពុទ្ធុបដ្ឋាកនោះ តាំងពីថ្ងៃដែលបានទទួលតំណែងជាពុទ្ធុបដ្ឋាកមក អានន្ទតែងតែឧបដ្ឋាកព្រះទសពលដោយកិច្ចទាំងឡាយយ៉ាងនេះជាដើម គឺដោយការរៀបចំទឹកសម្រាប់ប្រើប្រាស់ និងទឹកសម្រាប់ឆាន់ ឬឈើស្ទន់ ទាំងបានច្របាច់ព្រះហស្ត និងព្រះបាទ ថែមទាំងបានបោសសម្អាតបរិវេណព្រះគន្ធកុដិ ដោយគិតថា ព្រះសាស្តាគួរធ្វើកិច្ចនេះក្នុងវេលានេះ ហើយមានការទ្រោលប្រទីបបំភ្លឺជុំវិញព្រះគន្ធកុដិ ។ នៅពេលអធ្រាត្រ ព្រះអានន្ទ តែងដើរពិនិត្យមើលជុំវិញបរិវេណព្រះគន្ធកុដិមួយយប់ ៩ ដង លោកមានសេចក្តីត្រិះរិះយ៉ាងនេះថា ប្រសិនបើយើងទៅសិង ព្រះសាស្តាត្រាស់ហៅយើងក៏មិនបានឮ ព្រោះដូច្នោះហើយ ទើបទ្រោលប្រទីបដើរជុំវិញព្រះគន្ធកុដិ ។ កាលជាខាងក្រោយមក ព្រះភគវាទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពន ទ្រង់សរសើរព្រះអានន្ទថា ជាឃ្លាំងធម៌ ដោយអនេកប្បរិយាយ ទើបស្ថាបនាព្រះអានន្ទទុកក្នុងតំណែងជាឯតទគ្គៈប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវករបស់តថាគត ផ្នែកខាងពហុស្សូត មានសតិ មានគតិ មានធិតិ និងពុទ្ធុបដ្ឋាក ក្នុងព្រះសាសនានេះ ។

សម័យមួយ ព្រះអានន្ទ អាស្រ័យនៅជងព្រៃមួយកន្លែង ក្នុងដែនកោសល លោកជាអ្នកច្រើនទៅដោយការទទួលពុទ្ធបរិស័ទហួសកាលវេលា ។ គ្រានោះ មានទេវតាដែលអាស្រ័យនឹងជួរព្រៃនោះ មានការអាណិតប្រាថ្នាប្រយោជន៍ឲ្យដល់ព្រះអានន្ទ ដើម្បីឲ្យលោកមានសេចក្ដីសង្វេគ ទើបចូលទៅរកដល់ទីកន្លែង ហើយពោលជាមួយព្រះអានន្ទថា

លោកម្ចាស់អានន្ទ សូមចូលទៅកាន់ផ្ទះគឺគល់ឈើ សូមបង្អោនចិត្តទៅកាន់ព្រះនិព្វាន ។លោកម្ចាស់ចូរសម្លឹងឈាន កុំមានសេចក្ដីប្រមាទ ការជួបសន្ទនារវាងគ្រហស្ថ មានប្រយោជន៍អ្វីដល់លោកម្ចាស់ ។

គ្រានោះ ព្រះអានន្ទ ត្រូវទេវតាពោលដាស់តឿន ក៏កើតសេចក្ដីសង្វេគក្នុងចិត្តឡើង ។

សម័យមួយ ព្រះមហាកស្សបត្ថេរ ប្រាប់ដល់ភិក្ខុទាំងឡាយថា អាវុសោទាំងឡាយ គ្រាមួយ ខ្ញុំចេញចាកក្រុងបាវា ធ្វើដំណើរទៅកាន់ក្រុងកុសិនារារួមជាមួយភិក្ខុសង្ឃប្រមាណ ៥០០ រូប ខ្ញុំបានគេចចេញអំពីផ្លូវ ទៅអង្គុយសម្រាកនៅក្រោមម្លប់ឈើមួយដើម មានអាជីវកម្នាក់

កាន់ផ្កាមន្ទារវៈចេញពីក្រុងកុសិនារា ទៅកាន់ក្រុងបាវា ខ្ញុំបានឃើញអាជីវកនោះមកអំពីចម្ងាយ ទើបសួរទៅកាន់អាជីវកថា អ្នកជ្រាបដំណឹងព្រះសាស្តារបស់យើងដែរឬទេ ?អាជីវកឆ្លើយថា ខ្ញុំម្ចាស់ជ្រាបទេតើ ព្រះសមណគោតមបានបរិនិព្វានទៅ ៧ ថ្ងៃហើយ ផ្កាមន្ទារវៈនេះ ខ្ញុំករុណាបានកាន់មកអំពីទី ដែលព្រះអង្គបរិនិព្វាននោះឯង ។បណ្តាភិក្ខុទាំងនោះ ភិក្ខុពួកខ្លះដែលមិនទាន់ប្រាសចាករាគៈ ក៏យំសោក ខ្សឹកខ្សួល កន្ទក់កន្ទេញ ដួលដេកលើផែនដី បម្រះនន្ទៀលយំរៀបរាប់ថា ព្រះសាស្តាស្តេចបរិនិព្វានឆាប់ពេកណាស់ ព្រះសុគតស្តេចបរិនិព្វានឆាប់ពេកណាស់ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោក ទ្រង់បាត់ទៅឆាប់ពេកណាស់ ឯពួកភិក្ខុដែលប្រាសចាករាគៈហើយ មានសតិសម្បជញ្ញៈ អត់សង្កត់ចិត្ត ដោយគិតថា សង្ខារទាំងឡាយមិនទៀង ។ គ្រានោះ ខ្ញុំបានពោលជាមួយនឹងភិក្ខុទាំងនោះថា ណ្ហើយចុះអ្នកទាំងឡាយ កុំសោកសៅ ខ្សឹកខ្សួលឡើយ ព្រះសាស្តា ទ្រង់ត្រាស់ប្រាប់អ្នកហើយមិនមែនឬថា សង្ខារទាំងឡាយមិនទៀង មានការកើតឡើងហើយ ក៏ត្រូវតែមានការបែកធ្លាយជាធម្មតា

ទោះជាអ្នកប្រាថ្នាថា កុំឲ្យព្រោត់ប្រាសយ៉ាងនេះយ៉ាងនោះ មិនមែនជាឋានៈឡើយ ។ លំដាប់នោះ មានភិក្ខុបួសចាស់ឈ្មោះសុភទ្ទ អង្គុយនៅកណ្តាលបរិស័ទនោះ ហើយពោលនឹងភិក្ខុទាំងឡាយនោះថា អ្នកទាំងឡាយ កុំសោកសៅ ខ្សឹកខ្សួលឡើយ ពួកយើងនឹងបានរួចផុតស្រឡះអំពីអាជ្ញារបស់ព្រះសមណគោតមហើយ កាលបើពួកយើងធ្វើអ្វីនីមួយតែងតែពោលថា អំពើនេះអ្នកគួរធ្វើ អំពើនេះអ្នកមិនគួរធ្វើទៅវិញ ឥឡូវនេះ ពួកអ្នកប្រាថ្នាធ្វើនូវអំពើណា ចូរធ្វើនូវអំពើនោះចុះ បើមិនប្រាថ្នាធ្វើអំពើណាទេ ក៏កុំធ្វើអី ។ ភិក្ខុទាំងឡាយ កាលបើបានស្តាប់សុភទ្ទពោលដូច្នោះហើយ ទើបពោលឡើងថា

ណ្ហើយចុះ អ្នកទាំងឡាយ ពួកយើងនឹងសង្គាយនាព្រះធម៌ ព្រះវិន័យ ព្រោះថា ខាងមុខសភាពដែលមិនមែនជាធម៌នឹងរុងរឿង ធម៌រមែងអន់ថយ ខាងមុខសភាពមិនមែនជាវិន័យនឹងរុងរឿង វិន័យនឹងមានការសាបសូន្យទៅ ខាងមុខអធម្មវាទីនឹងមានកម្លាំង ធម្មវាទីនឹងថយកម្លាំង អវិនយវាទីនឹងមានកម្លាំង វិនយវាទីនឹងថយកម្លាំង ។ ភិក្ខុទាំងឡាយ

ពោលថា ប្រសិនបើដូច្នោះ សូមព្រះថេរៈជ្រើសរើសភិក្ខុទាំងឡាយចុះ ដើម្បីសង្គាយនា ។ គ្រានោះ ព្រះមហាកស្សប ក៏បានជ្រើសរើសនូវព្រះអរហន្តបាន ៤៩៩ រូប ភិក្ខុទាំងនោះពោលនឹងព្រះមហាកស្សបថា បពិត្រលោកម្ចាស់ ព្រះអានន្ទនៅជាសេក្ខបុគ្គល (គឺសោតាបន្ន) ពិតមែនតែលោកមិនអាចលុះដោយឆន្ទាគតិ ទោសាគតិ មោហាគតិ ភយាគតិ លោកបានរៀនព្រះធម៌ ព្រះវិន័យយ៉ាងច្រើន ក្នុងសម្នាក់ព្រះវិជិតមារ ព្រោះហេតុនោះ សូមព្រះថេរៈជ្រើសរើសយកព្រះអានន្ទផង ។ទើបព្រះមហាកស្សប ជ្រើសរើសយកព្រះអានន្ទបញ្ចូលផង ហើយប្រឹក្សាគ្នាថា នឹងធ្វើសង្គាយនាព្រះធម៌ ព្រះវិន័យនៅទីឯណាហ្ន៎ បន្ទាប់មក ក៏ព្រមគ្នាធ្វើសង្គាយនានៅនគររាជគ្រឹះ ដែលមានទីគោចរក៏ច្រើន មានសេនាសនៈក៏ច្រើន សមគួរដល់ពួកយើងនឹងទៅចាំវស្សាក្នុងនគររាជគ្រឹះ ដើម្បីសង្គាយនាព្រះធម៌ ព្រះវិន័យ ឯភិក្ខុពួកដទៃកុំគប្បីចូលទៅនៅចាំវស្សាក្នុងនគររាជគ្រឹះឡើយ ។ លំដាប់នោះ ព្រះថេរៈទាំងឡាយបានទៅកាន់នគររាជគ្រឹះ ដើម្បីសង្គាយនាព្រះធម៌ព្រះវិន័យ ហើយប្រឹក្សាគ្នាថា បពិត្រ

ព្រះករុណាម្ចាស់ទាំងឡាយ ព្រះមានព្រះភាគ ទ្រង់សរសើរការជួសជុលសេនាសនៈដែលវិនាសទ្រុឌទ្រោម ប្រសិនបើដូច្នោះ ពួកយើងនឹងជួសជុលសេនាសនៈ ដែលវិនាសទ្រុឌទ្រោមក្នុងខែដំបូងសិនហើយ នឹងប្រជុំសង្គាយនាព្រះធម៌ព្រះវិន័យក្នុងកណ្តាលខែ គ្រានោះ ព្រះថេរៈបានជួសជុលសេនាសនៈ ដែលវិនាសទ្រុឌទ្រោមក្នុងដើមខែ ។

ពួកភិក្ខុបានពោលនឹងព្រះអានន្ទថា អាវុសោ ការប្រជុំនឹងមានក្នុងថ្ងៃស្អែកនេះ តែលោកនៅជាសេក្ខបុគ្គលនៅឡើយ ព្រោះហេតុនោះលោកមិនគួរទៅកាន់ទីប្រជុំ សូមលោកចូរជាអ្នកមិនប្រមាទចុះ ដូច្នេះ ។ ព្រះអានន្ទត្រិះរិះថា ការប្រជុំនឹងមានក្នុងថ្ងៃស្អែកនេះ ក៏កិច្ចដែលយើងនៅជាសេក្ខបុគ្គលនឹងគប្បីទៅកាន់ទីប្រជុំនោះ មិនសមគួរដល់យើងពិតមែន ហើយក៏បានចម្រើនកាយគតាសតិ ដែលចម្រើនជាប់រហូតរាត្រី ក្នុងពេលបច្ចូសសម័យនៃរាត្រី (ជិតភ្លឺ) ចុះចាកទីចង្រ្កមហើយចូលទៅកាន់វិហារគិតថា នឹងចូលទៅសិង ក៏ទម្រេតកាយ ព្រះបាទទាំងពីរទើបតែផុតអំពីផែនដី តែព្រះសិរសាមិនទាន់ដល់ខ្នើយ ក្នុងចន្លោះនេះ ព្រះទ័យ

ក៏រួចស្រឡះចាកអាសវៈទាំងឡាយ មិនប្រកាន់មាំដោយឧបាទាន ការពិតណាស់ ព្រះអានន្ទនេះ នៅសម្រាកខាងក្រៅដោយការចង្រ្កម ។ កាលមិនអាចនឹងញ៉ាំងនូវគុណវិសេសឲ្យកើតឡើងបាន ទើបគិតថា ព្រះមានជោគបានត្រាស់ពាក្យនេះដល់អាត្មាអញមិនមែនឬថា អានន្ទ អ្នកជាអ្នកដែលបានធ្វើបុណ្យទុកមកហើយ ចូរប្រឹងប្រែងប្រកបនូវសេចក្តីព្យាយាម នឹងជាអ្នកគ្មានអាសវៈដោយឆាប់រហ័ស ធម្មតាទោសនៃព្រះតម្រាស់របស់ព្រះពុទ្ធទាំងឡាយរមែងមិនមាន អាត្មាអញប្រារព្ធសេចក្តីព្យាយាម ច្រើនហួសទៅ ព្រោះហេតុនេះ ចិត្តរបស់អាត្មាអញ ទើបប្រព្រឹត្តទៅដើម្បីភាពរាយមាយ ណ្ហើយចុះ អាត្មានឹងប្រកបនូវសេចក្តីព្យាយាមឲ្យស្មើ នឹងសម្រាកបន្តិច ទើបទម្រេតកាយលើគ្រែ ជើងទាំងពីរទើបតែផុតអំពីផែនដី ក្បាលនៅមិនទាន់ដល់ខ្នើយ ក្នុងចន្លោះនោះ ចិត្តក៏រួចស្រឡះចាកអាសវៈទាំងឡាយ មិនប្រកាន់មាំដោយឧបាទាន ភាពជាព្រះអរហន្តរបស់ព្រះថេរៈរូបនេះ វៀរចាកឥរិយាបថទាំង ៤ ។ ព្រោះដូច្នោះ កាលបើមានអ្នកសួរថា ក្នុងព្រះសាសនានេះ ភិក្ខុរូបណា

មិនសិង មិនគង់ មិនឈរ មិនចង្រ្កម បានសម្រេចព្រះអរហន្ត គប្បីឆ្លើយតបថា គឺព្រះអានន្ទត្ថេរ ។

ក្នុងថ្ងៃទី ២ ព្រះថេរៈទាំងឡាយ ធ្វើភត្តកិច្ចស្រេចហើយ ទុកបាត្រនិងចីវរ ហើយទៅទីប្រជុំគ្នានៅសាលាធម្មសភា ។ឯព្រះអានន្ទត្ថេរ មានបំណងនឹងឲ្យអ្នកដទៃ ដឹងការសម្រេចភាពជាព្រះអរហន្តរបស់ខ្លួន មិននិមន្តទៅព្រមជាមួយនឹងភិក្ខុទាំងឡាយទេ ភិក្ខុទាំងឡាយកាលនឹងគង់លើអាសនៈរបស់ខ្លួនតាមលំដាប់វស្សា បានគង់វៀរអាសនៈទុកសម្រាប់ព្រះអានន្ទត្ថេរ ។ កាលបើភិក្ខុពួកខ្លះ ក្នុងសាលាធម្មសភានោះ សួរថា នុ៎ះជាអាសនៈលោកម្ចាស់ណា ក្នុងសម័យនោះឯង ព្រះថេរៈគិតថា ឥឡូវនេះ ជាពេលដែលអាត្មាអញនឹងនិមន្តទៅ ។ កាលនឹងសម្តែងអានុភាពរបស់ខ្លួន ទើបជ្រែកចូលទៅក្នុងដី ហើយបង្ហាញខ្លួនលើអាសនៈរបស់ខ្លួននោះឯង ។អាចារ្យមួយពួកពោលថា និមន្តមកតាមផ្លូវអាកាស ហើយមកគង់លើអាសនៈក៏មាន ។ គ្រានោះ ព្រះមហាកស្សបប្រកាសឲ្យសង្ឃដឹង ដោយញត្តិកម្មវាចាដូច្នេះថា

បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មនេះមាន កាលសមគួរដល់សង្ឃហើយ ខ្ញុំនឹងគប្បីសួរព្រះវិន័យជាមួយព្រះឧបាលី ។

ព្រះឧបាលីប្រកាសឲ្យសង្ឃដឹង ដោយញត្តិកម្មវាចាដូច្នេះថា

បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មនេះមាន កាលសមគួរដល់សង្ឃហើយ ខ្ញុំកាលបើព្រះមហាកស្សបសួរវិន័យ ហើយ ខ្ញុំគប្បីវិសជ្ជនា ។ លំដាប់នោះ ព្រះមហាកស្សបសួរព្រះឧបាលី ថា ឧបាលី បឋមបារាជិកសិក្ខាបទ ព្រះសម្ពុទ្ធទ្រង់បញ្ញត្តក្នុងទីណា ?

ឧបាលី. ក្នុងនគរវេសាលី ។

មហាកស្សប. ទ្រង់ប្រារព្ធបុគ្គលណា ?

ឧបាលី. ទ្រង់ប្រារព្ធសុទិន្នកិក្ខុ ជាកូននៃកលន្ទសេដ្ឋី ។

មហាកស្សប. ព្រោះរឿងអ្វី ?

ឧបាលី. ព្រោះរឿងប្រព្រឹត្តអសទ្ធម្ម ។

បន្ទាប់អំពីនោះ ព្រះមហាកស្សប សួរដល់វត្ថុ និទាន បុគ្គល បញ្ញត្តិ អនុប្បញ្ញត្តិ អាបត្តិ អនាបត្តិ នៃបឋមបារាជិកសិក្ខាបទចំពោះ

ព្រះឧបាលី ហើយសួរទៅទៀតថា ទុតិយបារាជិក ព្រះមានព្រះភាគបញ្ញត្តក្នុងទីណា ?

ឧបាលី. ក្នុងនគររាជគ្រឹះ លោកម្ចាស់ ។

មហាកស្សប. ទ្រង់ប្រារព្ធបុគ្គលណា ?

ឧបាលី. ទ្រង់ប្រារព្ធភិក្ខុធនិយៈ ជាកូនស្មូនឆ្នាំង ។

មហាកស្សប. ព្រោះរឿងអ្វី ?

ឧបាលី. ព្រោះអទិន្នាទាន ។

បន្ទាប់ពីនោះ ព្រះមហាកស្សប សួរវត្ថុ និទាន បញ្ញត្តិ អនុប្បញ្ញត្តិ អាបត្តិ អនាបត្តិ ចំពោះព្រះឧបាលិហើយ សួរតទៅ ទៀតថា តតិយបារាជិក ទ្រង់បញ្ញត្តក្នុងទីណា ?

ឧបាលី. ក្នុងនគរវេសាលី លោកម្ចាស់ ។

មហាកស្សប. ទ្រង់ប្រារព្ធបុគ្គលណា ?

ឧបាលី. ទ្រង់ប្រារព្ធនឹងភិក្ខុច្រើនរូប ។

មហាកស្សប. ព្រោះរឿងអ្វី ?

ឧបាលី. ព្រោះមនុស្សវិគ្គហៈ គឺធ្វើរាងកាយនៃមនុស្សឲ្យធ្លាក់ចុះចាកជីវិត ។

បន្ទាប់ពីនោះ ព្រះមហាកស្សប សួរវត្ថុ និទាន បុគ្គល បញ្ញត្តិ អនុប្បញ្ញត្តិ អាបត្តិ អនាបត្តិ ចំពោះព្រះឧបាលី ហើយសួរតទៅទៀតថា ចតុត្ថបារាជិកសិក្ខាបទ ទ្រង់បញ្ញត្តក្នុងទីណា ?

ឧបាលី. ក្នុងនគរវេសាលី លោកម្ចាស់ ។

មហាកស្សប. ទ្រង់ប្រារព្ធបុគ្គលណា ?

ឧបាលី. ទ្រង់ប្រារព្ធភិក្ខុដែលចាំវស្សា ក្បែរស្ទឹងវគ្គមុទា ។

មហាកស្សប. ព្រោះរឿងអ្វី ?

ឧបាលី. ព្រោះឧត្តរិមនុស្សធម៌ ។

បន្ទាប់ពីនោះ ព្រះមហាកស្សប សួរដល់វត្ថុ និទាន បុគ្គល បញ្ញត្តិ អនុប្បញ្ញត្តិ អាបត្តិ អនាបត្តិ នៃចតុត្ថបារាជិកសិក្ខាបទចំពោះព្រះឧបាលី ហើយសួរឧភតោវិន័យដោយរបៀបនេះឯង ឯព្រះឧបាលីក៏ឆ្លើយតាមដែលព្រះមហាកស្សបសួរហើយ ។ ក្នុងកាលនោះ ព្រះ

មហាកស្សបប្រកាសសង្ឃឲ្យដឹងដោយញត្តិកម្មវាចាថា

បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មនេះមានកាលសមគួរដល់សង្ឃហើយ ខ្ញុំគប្បីសួរព្រះសូត្រចំពោះអានន្ទ ។ឯព្រះអានន្ទក៏ប្រកាសសង្ឃឲ្យដឹងដោយញត្តិកម្មវាចាថា

បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មនេះមានកាលសមគួរដល់សង្ឃហើយ ព្រះមហាកស្សបសួរព្រះសូត្រចំពោះខ្ញុំៗគប្បីដោះស្រាយក្នុងកាលឥឡូវនេះ ។ លំដាប់នោះ ព្រះមហាកស្សបសួរចំពោះព្រះអានន្ទថា ព្រហ្មជាលសូត្រ ទ្រង់សម្តែងក្នុងទីណា ?

អានន្ទ. សម្តែងក្នុងឧទ្យានអម្ពលដ្ឋិកា ចន្លោះក្រុងរាជគ្រឹះ និងក្រុងនាលន្ទា លោកម្ចាស់ ។

មហាកស្សប. ទ្រង់ប្រារព្ធបុគ្គលណា ?

អានន្ទ. ទ្រង់ប្រារព្ធសុប្បិយបរិព្វាជក និងព្រហ្មទត្តមាណព ។

លំដាប់នោះ ព្រះមហាកស្សប សួរនិទាន និងបុគ្គលនៃព្រហ្ម-ជាលសូត្រចំពោះព្រះអានន្ទ ហើយសួរតទៅទៀតថា សាមញ្ញផលសូត្រ

ទ្រង់សម្តែងក្នុងទីណា ?

អានន្ទ. ក្នុងវិហារជីវកម្ពវ័ន ក្បែរក្រុងរាជគ្រឹះ លោកម្ចាស់ ។

មហាកស្សប. សម្តែងនឹងបុគ្គលណា ?

អានន្ទ. សម្តែងនឹងព្រះបាទអជាតសត្តុវេទេហីបុត្រ ។

លំដាប់នោះ ព្រះមហាកស្សប សួរនិទាន និងបុគ្គលនៃសាមញ្ញផលសូត្រចំពោះអានន្ទ ហើយសួរនិកាយទាំង ៥ ដោយទំនងនេះឯង។ ព្រះអានន្ទក៏វិសជ្ជនា តាមដែលព្រះមហាកស្សបសួរហើយ ។ លំដាប់នោះ ព្រះអានន្ទ បានពន្យល់ប្រាប់ព្រះថេរៈទាំងឡាយថា បពិត្រលោកម្ចាស់ដ៏ចម្រើន កាលព្រះមានព្រះភាគជិតបរិនិព្វាន ទ្រង់មានបន្ទូលថា នែអានន្ទ លុះអំណឹះឥតពីតថាគតទៅ បើសង្ឃប្រាថ្នាដកនូវសិក្ខាបទតូចៗ ចេញខ្លះក៏បាន ។ ព្រះថេរៈទាំងឡាយសួរថា នែអានន្ទ ចុះលោកបានទូលសួរព្រះមានព្រះភាគឬទេថា សិក្ខាបទណាតូចៗ ។ ព្រះអានន្ទឆ្លើយថា ខ្ញុំព្រះករុណាមិនបានទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន សិក្ខាបទពួកណា ជាសិក្ខាបទតូចៗ ទេ ។ ព្រះថេរៈពួកខ្លះ

ពោលយ៉ាងនេះថា ក្រៅពីបារាជិក ៤ ជាសិក្ខាបទតូចៗ ។ ព្រះថេរៈពួកខ្លះពោលថា វៀរបារាជិក ៤ សង្ឃាទិសេស ១៣ ជាសិក្ខាបទតូចៗ ។ ព្រះថេរៈខ្លះទៀតពោលថា វៀរបារាជិក ៤ សង្ឃាទិសេស ១៣ អនិយត ២ និស្សគ្គិយបាចិត្តិយ ៣០ សុទ្ធិកបាចិត្តិយ ៩២ បាដិទេសនីយ ៤ ជាសិក្ខាបទតូចៗ ។ គ្រានោះឯង ព្រះមហាកស្សបត្ថេរ ប្រកាសសង្ឃឲ្យដឹងដោយទុតិយកម្មវាចាថា

ម្នាលអាវុសោទាំងឡាយ សូមសង្ឃស្តាប់ខ្ញុំ សិក្ខាបទទាំងឡាយរបស់ពួកយើង បានផ្សព្វផ្សាយដល់ពួកគ្រហស្ថ ពួកគេក៏ដឹងថា អំពើនេះគួរ អំពើនេះមិនគួរដល់សមណសក្យបុត្រ ។ បើយើងទាំងឡាយដកសិក្ខាបទតូចៗចេញ ពួកគ្រហស្ថនឹងពោលថា ព្រះសមណគោតមបញ្ញត្តសិក្ខាបទដល់សាវកទាំងឡាយ បានត្រឹមតែមួយរយៈកាល ។ សាវកពួកនេះសិក្សាសិក្ខាបទទាំងឡាយ តែក្នុងកាលព្រះសាស្តាគង់នៅ កាលបើព្រះសាស្តាបរិនិព្វានទៅហើយ ក៏មិនសិក្សាក្នុងសិក្ខាបទនោះ បើការព្រមព្រៀងមានកាលគួរដល់សង្ឃហើយ សង្ឃមិនគប្បីបញ្ញត្តសិក្ខាបទ

ថែម មិនគប្បីដកនូវសិក្ខាបទ ដែលព្រះមានព្រះភាគបញ្ញត្តទុក ហើយគប្បីសមាទានប្រព្រឹត្តក្នុងសិក្ខាបទទាំងឡាយ ដែលទ្រង់បញ្ញត្តរួចហើយចុះ នេះជាញត្តិ ។ម្នាលអាវុសោទាំងឡាយ សូមសង្ឃស្តាប់ខ្ញុំ សិក្ខាបទរបស់ពួកយើងទាំងឡាយ ក៏មានទូទៅដល់គ្រហស្ថដែរ ។ សូម្បីពួកគ្រហស្ថក៏ដឹងថា អំពើនេះគួរដល់សមណសក្យបុត្ត អំពើនេះមិនគួរ បើយើងទាំងឡាយដកនូវសិក្ខាបទនោះចេញ ប្រាកដជាមានពាក្យពោលថា ព្រះសមណគោតមបញ្ញត្តសិក្ខាបទដល់សាវ័កទាំងឡាយ បានត្រឹមតែមួយរយៈកាលប៉ុណ្ណោះ ពួកសាវ័កនេះ សិក្សាសិក្ខាបទទាំងឡាយតែក្នុងកាលព្រះសក្យមុនីគង់នៅ កាលបើព្រះភគវាបរិនិព្វានទៅហើយ ព្រះសមណៈទាំងនោះ មិនបានសិក្សាក្នុងសិក្ខាបទទាំងឡាយ ឥឡូវនេះ សង្ឃកុំគប្បីបញ្ញត្តនូវសិក្ខាបទ ដែលទ្រង់មិនបានបញ្ញត្ត មិនគប្បីដកនូវសិក្ខាបទដែលទ្រង់បានបញ្ញត្តរួចហើយ នាំគ្នាសមាទានប្រព្រឹត្តក្នុងសិក្ខាបទទាំងឡាយតាមដែលព្រះអង្គបញ្ញត្តទុករួចហើយ បើគាប់ចិត្តដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវនៅស្ងៀម ខ្ញុំសូមចាំទុក

ដោយអាការនៅស្ងៀមយ៉ាងនេះឯង ។

គ្រានោះឯង ព្រះថេរៈទាំងឡាយ បានពោលជាមួយព្រះអានន្ទថា នែអាវុសោអានន្ទ ទោសដែលលោកមិនបានទូលសួរ ព្រះលោកនាថថា បពិត្រព្រះអង្គដ៏ចម្រើន តើសិក្ខាបទណាជាសិក្ខាបទតូចៗ នេះជាអាបត្តិទុក្កដសម្រាប់អ្នក ចូរលោកសម្តែងអាបត្តិទុក្កដនោះចេញ ។ ព្រះអានន្ទពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះខ្ញុំព្រះករុណារឭកមិនបានដែលមិនបានទូលសួរព្រះសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចម្រើន សិក្ខាបទណាជាសិក្ខាបទតូចៗ ខ្ញុំមិនឃើញហេតុដែលមិនបានទូលសួរនោះថាជាអាបត្តិទុក្កដ តែព្រោះការជឿលោកមានអាយុទាំងឡាយ ខ្ញុំព្រមសម្តែងអាបត្តិទុក្កដនោះចេញ ។ ព្រះថេរៈទាំងឡាយពោលតទៅទៀតថា នែអាវុសោអានន្ទ អំពើអាក្រក់ដែលលោកជាន់ដេរសំពត់វស្សិកសាដករបស់ព្រះមានជោគ សូម្បីទាំងនេះក៏ជាអាបត្តិទុក្កដដល់អ្នក ចូរលោកសម្តែងអាបត្តិទុក្កដនោះ ។ ព្រះអានន្ទពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាជាន់ដេរសំពត់វស្សិកសាដករបស់ព្រះសាស្តាមិនមែនធ្វើដោយ

សេចក្តីមិនគោរពទេ ខ្ញុំព្រះករុណាមិនបានឃើញហេតុដែលជាន់ដេរនោះ ថាជាអាបត្តិទុក្កដ តែព្រោះការជឿលោកម្ចាស់ទាំងឡាយ ខ្ញុំព្រះករុណា ព្រមសម្តែងនូវអាបត្តិទុក្កដនោះចេញ ។ព្រះថេរៈទាំងឡាយពោលតទៅ ទៀតថា នែអាវុសោអានន្ទ អំពើអាក្រក់ដែលលោកឲ្យមាតុគ្រាមថ្វាយបង្គំ ព្រះសរីរៈរបស់ព្រះសក្យមុនីមុនគេ ព្រះសរីរៈរបស់ព្រះសុគតប្រឡាក់ ដោយទឹកភ្នែក របស់ពួកមាតុគ្រាមទាំងអស់ដែលយំនោះ នេះក៏ជាអាបត្តិ ទុក្កដដែរ ។ព្រះអានន្ទពោលថា បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណាគិតថា មាតុគ្រាមទាំងនេះកុំឲ្យនៅយូរដល់ពេលព្រលប់ ទើបឲ្យពួកមាតុគ្រាម ថ្វាយបង្គំព្រះសរីរៈរបស់ព្រះសម្ពុទ្ធមុន ខ្ញុំព្រះករុណាមិនឃើញហេតុដែល ឲ្យមាតុគ្រាមថ្វាយបង្គំព្រះសរីរៈ របស់ព្រះអង្គថាជាអាបត្តិទុក្កដ តែខ្ញុំជឿ តាមលោកម្ចាស់ទាំងឡាយ ព្រមសម្តែងនូវអាបត្តិទុក្កដនោះចេញ ។

ព្រះថេរៈទាំងឡាយពោលតទៅទៀតថា នែអាវុសោអានន្ទ នេះ ជាអំពើអាក្រក់របស់លោកដែរ ព្រោះព្រះមានព្រះភាគទ្រង់ធ្វើនូវនិមិត្ត ដ៏គ្រោតគ្រាត ទ្រង់ធ្វើឱកាសដ៏គ្រោតគ្រាត នៅតែលោកមិនបានទូលសូម

អង្វរព្រះភគវាថា សូមឲ្យព្រះអង្គគង់នៅអស់មួយកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ នេះក៏ជាអាបត្តិទុក្កដដល់អ្នកដែរ ចូរលោកសម្តែងអាបត្តិទុក្កដនោះ។ព្រះអានន្ទពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាត្រូវមារគ្របសង្កត់ចិត្ត ទើបមិនបានទូលសូមអារាធនាព្រះជិនស្រីថា សូមព្រះអង្គទ្រង់គង់នៅអស់មួយកប្ប សូមព្រះសុគតទ្រង់គង់នៅអស់មួយកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើនជាដើម ខ្ញុំព្រះករុណាមិនឃើញហេតុនេះថាជាអាបត្តិទុក្កដទេ ប៉ុន្តែខ្ញុំជឿលោកម្ចាស់ទាំងឡាយ ព្រមសម្តែងអាបត្តិទុក្កដនោះចេញ ។ ព្រះថេរៈទាំងឡាយពោលតទៅទៀតថា នែអាវុសោអានន្ទ អំពើអាក្រក់ដែលលោកបានជួយខ្នះខ្នែងឲ្យមាតុគ្រាមនៅក្នុងធម្មវិន័យនេះ ដែលព្រះតថាគតទ្រង់ប្រកាសហើយ នេះក៏ជាអាបត្តិទុក្កដដល់អ្នក ចូរលោកសម្តែងអាបត្តិទុក្កដនេះ។ ព្រះអានន្ទពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាបានធ្វើការខ្នះខ្នែងឲ្យមាតុគ្រាមបួសក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ប្រកាស

ហើយដោយគិតថា ព្រះនាងមហាបជាបតិគោតមីជាព្រះមាតុច្ឆា ( ម្តាយមីង ) នៃព្រះវិជិតមារ បានបីបាច់ចិញ្ចឹមរក្សា ទ្រង់ប្រទានខីរធារៈ ( ទឹកដោះ ) ដល់ព្រះភគវា កាលពុទ្ធមាតា ( ព្រះនាងមហាមាយាទេវី ) ជាព្រះមាតាបង្កើតបានសោយវិលាល័យ ព្រះនាងថែមទាំងបានបំបៅដោះព្រះសយម្ភូផង ខ្ញុំព្រះករុណាមិនឃើញហេតុនេះថាជាអាបត្តិទុក្កដប៉ុន្តែខ្ញុំជឿលោកម្ចាស់ទាំងឡាយ ព្រមសម្តែងអាបត្តិទុក្កដនេះចេញ ។

សម័យនោះឯងព្រះរាហុលត្ថេរ ត្រាច់ទៅបិណ្ឌបាតក្នុងទក្ខិណាគិរីជនបទ ព្រមដោយភិក្ខុសង្ឃមួយពួកធំ ប្រមាណ ៥០០ រូប នាកាលព្រះថេរៈទាំងឡាយសង្គាយនាព្រះធម៌ និងព្រះវិន័យ បានសម្រាកនៅក្នុងទក្ខិណាគិរីជនបទ តាមសមគួរដល់អធ្យាស្រ័យហើយ ក៏ចូលទៅរកព្រះថេរៈទាំងឡាយដែលគង់នៅក្នុងវត្តវេឡុវ័ន ក្បែរក្រុងរាជគ្រឹះ ថែមទាំងបានធ្វើការរាក់ទាក់ជាមួយនឹងព្រះថេរៈទាំងនោះ រួចហើយក៏អង្គុយក្នុងទីដ៏សមគួរ ។ ព្រះថេរៈទាំងឡាយ បានពោលជាមួយនឹងព្រះរាហុលថា នៃរាហុល យើងបានសង្គាយនាព្រះធម៌ព្រះវិន័យហើយ ចូរអ្នកទទួលដឹង

ព្រះធម៌ព្រះវិន័យនោះ ដែលព្រះថេរៈទាំងឡាយបានសង្គាយនារួចហើយ ។ ព្រះរាហុលពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើនទាំងឡាយ តើការសង្គាយនារៀបរយហើយឬតែថាខ្ញុំព្រះករុណាបានស្តាប់បានទទួលមកក្នុងទីចំពោះព្រះភក្ត្រនៃព្រះសម្ពុទ្ធដោយប្រការណា ខ្ញុំនឹងទ្រទ្រង់ទុកប្រតិបត្តិដោយប្រការនោះ ។ គ្រានោះឯង ព្រះអានន្ទ បានពោលជាមួយនឹងព្រះថេរៈទាំងឡាយថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះមុនីកាលទៀបនឹងបរិនិព្វាន ព្រះអង្គទ្រង់មានព្រះបន្ទូលនឹងខ្ញុំព្រះករុណាថា ម្នាលអានន្ទ អំណើះអត់អំពីតថាគតទៅ សង្ឃប្រូវដាក់ព្រហ្មទណ្ឌដល់ឆន្នភិក្ខុផង ។

ព្រះថេរៈទាំងឡាយសួរថា អាវុសោអានន្ទ លោកបានទូលសួរព្រះសម្ពុទ្ធដែរឬ ព្រះអង្គឲ្យដាក់ព្រហ្មទណ្ឌយ៉ាងណា ? ព្រះអានន្ទតបថា បានទូលសួរដែរ ព្រហ្មទណ្ឌនោះតើដូចម្តេច ព្រះអង្គត្រាស់ថា ម្នាលអានន្ទ កុំឲ្យភិក្ខុទាំងឡាយនិយាយរក កុំគប្បីប្រដៅទូន្មានឆន្នភិក្ខុឡើយ ។ ព្រះថេរៈទាំងឡាយពោលថា នែអាវុសោអានន្ទ បើដូច្នោះ ចូរលោកដាក់ព្រហ្មទណ្ឌដល់ឆន្នភិក្ខុចុះ ។ ព្រះអានន្ទ បានប្រឹក្សាគ្នាថា បពិត្រលោក

ម្ចាស់ តើខ្ញុំព្រះករុណាគប្បីដាក់ព្រហ្មទណ្ឌដល់ឆន្នភិក្ខុបានយ៉ាងណា ភិក្ខុនេះកាចរឹងរូសណាស់ ។ ព្រះថេរៈទាំងឡាយពោលថា នែអាវុសោអានន្ទ បើដូច្នោះ លោកចូរទៅជាមួយនឹងភិក្ខុច្រើនរូប ។ ព្រះអានន្ទទទួលពាក្យព្រះថេរៈបញ្ជាហើយ ឡើងជិះទូកព្រមជាមួយនឹងភិក្ខុប្រមាណ ៥០០ រូប ទៅកាន់ក្រុងកោសម្ពី លុះបានឡើងអំពីទូកហើយ បានទៅគង់ក្រោមម្លប់ឈើមួយដើម ជិតព្រះរាជឧទ្យាននៃព្រះបាទឧទេន ។ គ្រានោះ ព្រះបាទឧទេន និងអគ្គមហេសីប្រថាប់នៅក្នុងព្រះរាជឧទ្យាន ព្រមដោយពួករាជបរិវារ ។អគ្គមហេសីរបស់ព្រះបាទឧទេន ទ្រង់បានជ្រាបដំណឹងថា លោកម្ចាស់អានន្ទ ជាអាចារ្យរបស់ពួកយើង គង់ក្រោមម្លប់ឈើមួយដើមជិតព្រះរាជឧទ្យាន ក៏ទូលសូមព្រះរាជាថា ពួកខ្ញុំម្ចាស់ប្រាថ្នានឹងទៅសួរសុខទុក្ខលោកម្ចាស់អានន្ទ ។ ព្រះបាទឧទេនត្រាស់ថា បើដូច្នោះ ចូរអ្នកទាំងអស់គ្នាទៅសួរសុខទុក្ខព្រះអានន្ទចុះ ។ លំដាប់នោះឯង អគ្គមហេសីរបស់ព្រះបាទឧទេន បានចូលទៅរកព្រះអានន្ទ លុះចូលទៅដល់ហើយ ក៏បានថ្វាយបង្គំព្រះអានន្ទ រួចអង្គុយក្នុងទីដ៏សមគួរ ។ ព្រះអានន្ទ បានពន្យល់

ដល់អគ្គមហេសីនៃព្រះបាទឧទេន ឲ្យឃើញច្បាស់ ឲ្យប្រព្រឹត្តតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ។ អគ្គមហេសីរបស់ព្រះបាទឧទេន កាលបើព្រះអានន្ទបានពន្យល់ឲ្យឃើញច្បាស់ ឲ្យសមាទាន ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ទើបបានថ្វាយសំពត់ឧត្តរាសង្គៈ ៥០០ ផ្ទាំងដល់ព្រះអានន្ទ ។ លំដាប់នោះឯង អគ្គមហេសីរបស់ព្រះបាទឧទេន ត្រេកអររីករាយនឹងភាសិតរបស់ព្រះអានន្ទ ទើបក្រោកចាកអាសនៈ ថ្វាយបង្គំលា ធ្វើប្រទក្សិណចៀសចេញទៅ ចូលទៅគាល់ព្រះបាទឧទេន ។ ពេលនោះ ព្រះបាទឧទេន បានទតឃើញអគ្គមហេសីមកអំពីចម្ងាយ មកដល់ហើយបានសួរថា ពួកអ្នកទាំងអស់គ្នា បានសួរសុខទុក្ខព្រះអានន្ទហើយឬ ? អគ្គមហេសីក្រាបទូលថា ពួកខ្ញុំទាំងអស់គ្នា បានសួរសុខទុក្ខលោកម្ចាស់អានន្ទរួចហើយ ។

ឧទេន. ពួកនាង បានថ្វាយអ្វីដល់ព្រះអានន្ទខ្លះដែរឬទេ ?

មហេសី. ពួកខ្ញុំម្ចាស់បានថ្វាយសំពត់ឧត្តរាសង្គៈ ៥០០ ផ្ទាំងដល់លោកម្ចាស់អានន្ទដែរ ។ ព្រះបាទឧទេន ក៏ពោលទោសតិះដៀលបន្ទុះ

បន្ទាប់ថា មិនសមបើសមណៈឈ្មោះអានន្ទ ទទួលយកចីវរច្រើនដល់ម៉្លេះទេ សមណៈរូបនេះ ធ្វើនូវជំនួញសំពត់ ឬនឹងតាំងរានលក់សំពត់ ។ ហើយទើបចូលទៅរកព្រះអានន្ទ ទ្រង់ប្រាស្រ័យសំណេះសំណាលជាមួយនឹងព្រះអានន្ទ លុះបញ្ចប់ការប្រាស្រ័យសំណេះសំណាល និងពាក្យដែលគួររឭកដល់គ្នាហើយ បានប្រថាប់គង់នៅក្នុងទីដ៏សមគួរ ទើបត្រាស់សួរថា បពិត្រលោកម្ចាស់អានន្ទ ពួកអគ្គមហេសីរបស់ខ្ញុំបានមកឬ ?

អានន្ទ. អគ្គមហេសីរបស់ព្រះអង្គបានមក ។

ឧទេន. ពួកអ្នកទាំងអស់នោះ បានថ្វាយអ្វីដល់លោកម្ចាស់ខ្លះទេ?

អានន្ទ. បានថ្វាយសំពត់ដល់អាត្មា ៥០០ ផ្ទាំងដែរ ។

ឧទេន. លោកម្ចាស់អានន្ទ នឹងយកចីវរធ្វើអ្វីច្រើនដល់ម៉្លេះ ?

អានន្ទ. អាត្មានឹងចែកដល់ភិក្ខុទាំងឡាយ ដែលមានចីវរគ្រាំគ្រា ។

ឧទេន. តើលោកម្ចាស់នឹងធ្វើយ៉ាងណាចំពោះចីវរគ្រាំគ្រានោះ?

អានន្ទ. អាត្មានឹងយកសំពត់ចីវរទាំងនោះទៅធ្វើកម្រាលគ្រែ ។

ឧទេន. លោកម្ចាស់យកធ្វើអ្វីចំពោះសំពត់កម្រាលគ្រែចាស់នោះ?

អានន្ទ. អាត្មានឹងយកសំពត់ទាំងនោះទៅធ្វើស្រោមពូក ។

ឧទេន. លោកម្ចាស់ធ្វើយ៉ាងណាចំពោះស្រោមពូកចាស់នោះ ?

អានន្ទ. អាត្មានឹងយកសំពត់ទាំងនោះទៅធ្វើជាកម្រាលផែនដី ។

ឧទេន. ចុះលោកម្ចាស់នឹងធ្វើយ៉ាងណា ចំពោះសំពត់កម្រាលផែនដីចាស់នោះ ?

អានន្ទ. អាត្មានឹងយកសំពត់កម្រាលផែនដីចាស់នោះ ទៅធ្វើជាសំពត់ជូតជើង ។

ឧទេន. ចុះលោកម្ចាស់ធ្វើយ៉ាងណាចំពោះសំពត់ជូតជើងនោះ ?

អានន្ទ. អាត្មានឹងយកសំពត់ជូតជើងចាស់នោះទៅធ្វើជាសំពត់ជូតធូលីវិញ ។

ឧទេន. ចុះលោកម្ចាស់យកសំពត់ជូតធូលីចាស់នោះទៅធ្វើអ្វី ?

អានន្ទ. អាត្មានឹងចិញ្ច្រាំនូវសំពត់ជូតធូលីចាស់នោះ ហើយច្របាច់លាយជាមួយភក់ យកទៅបូកលាបជញ្ជាំង ។

គ្រានោះ ព្រះបាទឧទេនទ្រង់ត្រិះរិះថា សមណសក្យបុត្រទាំង

ឡាយយកសំពត់ទៅប្រើប្រាស់ដោយឧបាយនៃប្រាជ្ញាមិនប្រមូលសន្សំសំពត់ទុក ហើយក៏ទ្រង់ប្រគេនសំពត់ ៥០០ ផ្ទាំងទៀតដល់ព្រះអានន្ទ ពេលនោះ បរិក្ខារ គឺចីវរបានកើតដល់ព្រះអានន្ទជាលើកដំបូង គឺសំពត់មួយពាន់ផ្ទាំង ។ គ្រានោះឯង ព្រះអានន្ទចូលទៅកាន់វត្តឃោសិតារាម គង់លើអាសនៈដែលគេក្រាលទុក ឆន្នភិក្ខុចូលទៅរកព្រះអានន្ទ បានធ្វើអភិវាទរួចហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ព្រះអានន្ទបានពោលនឹងឆន្នភិក្ខុថា នៃអាវុសោឆន្ន សង្ឃបានដាក់ព្រហ្មទណ្ឌដល់លោកហើយ ។

ឆន្ន. លោកម្ចាស់អានន្ទ ក៏ព្រហ្មទណ្ឌនោះ តើដូចម្ដេចខ្លះ ?

អានន្ទ. នៃអាវុសោ ឆន្ន លោកប្រាថ្នានឹងនិយាយពាក្យណា ក៏និយាយពាក្យនោះចុះ ភិក្ខុទាំងឡាយនឹងមិននិយាយរក មិនប្រដៅទូន្មានដល់លោកទៀតឡើយ ។

ឆន្ន. លោកម្ចាស់អានន្ទ ដោយហេតុត្រឹមតែភិក្ខុទាំងឡាយមិននិយាយរក មិនដាស់តឿន មិនប្រៀនប្រដៅខ្ញុំ ទាំងនេះឈ្មោះថា សង្ឃសម្លាប់ខ្ញុំហើយឬ ហើយក៏ដួលជ្រប់នៅក្នុងទីនោះឯង ។

តមក ឆន្នភិក្ខុលំបាកចិត្តចំពោះព្រហ្មទណ្ឌនោះ ទើបគេចទៅនៅតែម្នាក់ឯង ជាអ្នកមិនប្រមាទ មានសេចក្តីព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន មិនយូរប៉ុន្មាន បានធ្វើឲ្យជាក់ច្បាស់នូវគុណដ៏ប្រសើរបំផុត ជាទីបំផុតនៃព្រហ្មចរិយធម៌ ដែលកុលបុត្រទាំងឡាយចេញចាកផ្ទះបួសដោយប្រពៃ ជាអ្នកមានបំណងស្វែងរកនោះ ដោយប្រាជ្ញាដ៏ប្រពៃ ដោយខ្លួនឯង ក្នុងបច្ចុប្បន្នជាតិនេះចូលទៅដល់ហើយ បានដឹងច្បាស់ហើយថា ជាតិអស់ហើយ ព្រហ្មចរិយធម៌នៅចប់ហើយ កិច្ចដែលគួរធ្វើ បានធ្វើរួចស្រេចហើយ កិច្ចដទៃទៀតមិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ឆន្នភិក្ខុក៏ជាព្រះអរហន្តមួយរូបដែរ លុះពេលដែលឆន្នភិក្ខុបានសម្រេចជាព្រះអរហន្តហើយ បានចូលទៅរកព្រះអានន្ទ ហើយពោលថា បពិត្រលោកម្ចាស់អានន្ទដ៏ចម្រើន សូមលោកម្ចាស់រម្ងាប់ព្រហ្មទណ្ឌដល់ខ្ញុំឥឡូវនេះចុះ ។ ព្រះអានន្ទពោលថា នែឆន្ន លោកបានធ្វើឲ្យជាក់ច្បាស់ហើយនូវព្រះអរហត្ត ក្នុងកាលជាទីបំផុតណា ឯព្រហ្មទណ្ឌរបស់លោក ក៏រម្ងាប់ក្នុងកាលជាទីបំផុតនោះដែរ ។

ក្នុងពេលសង្គាយនាព្រះវិន័យ មានភិក្ខុ ៥០០ រូប មិនលើសមិនខ្វះ ។ ព្រោះហេតុនោះការសង្គាយនាព្រះវិន័យក្នុងកាលនោះបណ្ឌិតទើបហៅថា **បញ្ចសតិកាសង្គាយនា** គឺសង្គាយនារបស់ភិក្ខុមានចំនួន ៥០០រូប ដូច្នេះឯង ។

ព្រះអានន្ទត្ថេរ លោកបានពិចារណាមើលអាយុសង្ខារ ក្នុងកាលដែលមានព្រះជន្មបាន ១២០ វស្សា ដឹងថា អាយុអស់ហើយ ទើបប្រាប់ថា ខ្ញុំព្រះករុណានឹងបរិនិព្វានក្នុងថ្ងៃទី ៧ រាប់ពីថ្ងៃនេះតទៅ ។ បណ្ដាមហាជន អ្នកនៅច្រាំងស្ទឹងរោហិណីទាំងពីរខាង ជ្រាបដំណឹងហើយនាំគ្នាពោលថា

ពួកយើងមានឧបការៈច្រើនដល់ព្រះថេរៈៗគួរនឹងបរិនិព្វានខាងត្រើយរបស់យើង ព្រះថេរៈបានស្ដាប់ពាក្យទាំងនោះហើយ គិតថា ពួកជនទាំងពីរខាង ម្នាក់ៗ ក៏មានឧបការគុណដល់យើងដូចគ្នា យើងមិនអាចពោលថា ត្រើយខាងនេះមិនមានឧបការគុណទេ បើយើងបរិនិព្វានត្រើយខាងនេះ អ្នកត្រើយខាងនោះ ប្រាកដជាមានការឈ្លោះគ្នាជាមួយ

អ្នកត្រើយខាងនេះ ដើម្បីនឹងចង់បានគ្រប់គ្រង យកអដ្ឋិធាតុរបស់យើង ប្រសិនបើយើងបរិនិព្វានត្រើយនោះ ត្រើយនេះក៏នឹងឈ្លោះគ្នា ការឈ្លោះគ្នានឹងកើតឡើង ក៏ព្រោះតែយើង ទើបព្រះថេរៈពោលប្រាប់ដល់ជនទាំងពីរខាងថា អ្នកទាំងអស់គ្នា ក៏សុទ្ធតែជាអ្នកមានឧបការគុណដូចគ្នា ចូរនាំគ្នាទៅកាន់ត្រើយរបស់ខ្លួនរៀងៗ ខ្លួនចុះ ។ ដល់ថ្ងៃទី ៧ ព្រះអានន្ទគង់ពែនភ្នែនលើអាកាសប្រមាណ ៧ ជួរត្នោតកណ្ដាលស្ទឹង ថែមទាំងបានសម្ដែងធម៌ដល់មហាជន រួចហើយ លោកបានអធិដ្ឋានថា សូមឲ្យសរីរៈរបស់យើងបែកជាពីរចំណែក ។ មួយចំណែក ចូរធ្លាក់នៅត្រើយខាងនេះ មួយចំណែកទៀត ចូរធ្លាក់ត្រើយខាងនោះ ហើយចូលសមាបត្តិមានតេជោធាតុជាអារម្មណ៍ មានអណ្ដាតភ្លើងឆេះឡើង ។ ព្រះអដ្ឋិធាតុបែកជាពីរចំណែក ធ្លាក់ទៅត្រើយខាងនេះផង ខាងនោះផង មហាជនជាច្រើនបានយំសោកខ្សឹកខ្សួលសំឡេងយំដូចជាសំឡេងផែនដីស្រុតការយំពេលនេះ ច្រើនជាងពេលដែលព្រះបរមសាស្ដាបរិនិព្វានទៅទៀត ។

ពួកពុទ្ធបរិស័ទបានយំសោកខ្សឹកខ្សួលអស់៤ខែ ហើយត្អូញត្អែរ

ថា កាលដែលព្រះថេរៈទទួលបាត្រចីវររបស់ព្រះសាស្តា ក៏ហាក់បីដូចជាព្រះសាស្តាទ្រង់គង់ព្រះជន្មនៅឡើយ ឥឡូវនេះ ព្រះសាស្តារបស់យើងមួយអង្គទៀត បានបរិនិព្វានទៅទៀតហើយ ។

ព្រោះថា ព្រះអានន្ទត្ថេរ ត្រូវព្រះបរមសាស្តា ទ្រង់លើកតម្កើងឲ្យប្រសើរជាងភិក្ខុដែលជាសាវករបស់ព្រះអង្គមាន ៥ ប្រការថា

ឯទតគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ពហុស្សុតានំ យទិទំ អានន្ទោ ។ សតិមន្តានំ យទិទំ អានន្ទោ ។ គតិមន្តានំ យទិទំ អានន្ទោ ។ ធិតិមន្តានំ យទិទំ អានន្ទោ ។ ឧបដ្ឋាកានំ យទិទំ អានន្ទោ ម្នាលភិក្ខុទាំងឡាយ អានន្ទជាអ្នកប្រសើរជាងភិក្ខុ ដែលជាសាវករបស់តថាគត ១ ផ្នែកខាងជាពហូសូត ២ ផ្នែកខាងមានសតិ ៣ ផ្នែកខាងមានគតិ ៤ ផ្នែកខាងមានធិតិ និង ៥ ផ្នែកខាងជាអ្នកឧបដ្ឋាក ។

## ពណ៌នាបន្ថែមសេចក្តីទាក់ទងនឹងព្រះអានន្ទត្ថេរ

១ ព្រះអានន្ទ ជាព្រះអនុជរបស់ព្រះមានព្រះភាគជាម្ចាស់ ។

២/១- ផ្នែកខាងជាពហូសូតនោះ ពីព្រោះលោកបានរៀនព្រះពុទ្ធវចនៈពីព្រះមានជោគ និងភិក្ខុដទៃៗ ទៀតជាច្រើន ថែមទាំងព្រះអានន្ទនេះ ជាឃ្លាំងធម៌ទៀតផង និងឲ្យឃើញបានថា ការជ្រើសរើសអំពីសម្នាក់សង្ឃ ឲ្យព្រះអានន្ទវិសជ្ជនាព្រះសូត្រ និងព្រះអភិធម្ម ក្នុងការសង្គាយនាលើកទី ១ ដែលមានព្រះមហាកស្សបជាប្រធាន ។

២/២- ផ្នែកខាងមានសតិនោះ ពីព្រោះការរៀនសូធ្យនូវព្រះពុទ្ធវចនៈ សតិរបស់លោកមានការទ្រទ្រង់ចាំទុក មានកម្លាំងខ្លាំងជាងភិក្ខុដទៃ ។

២/៣- ផ្នែកខាងមានគតិ ពីព្រោះលោកបានឮពាក្យតែមួយបទ ក៏អាចយល់សេចក្តីបានដល់ ៦ ម៉ឺនបទ ។

២/៤- ផ្នែកខាងមានធិតិ ពីព្រោះលោកមានការព្យាយាមរៀនសូធ្យទន្ទេញ ទ្រទ្រង់ចាំទុក និងព្យាយាមឧបដ្ឋាកព្រះសាស្តាទៀតផង ។

២/៥-ផ្នែកខាងជាអ្នកឧបដ្ឋាកនោះ ពីព្រោះលោកជាអ្នកឧបដ្ឋាកដ៏យូរ អាចធ្វើឲ្យព្រះទ័យព្រះសាស្តាទុកចិត្តបាន និងឲ្យឃើញថា ព្រះអង្គជិតនឹងបរិនិព្វាន ព្រះសម្ពុទ្ធបានសរសើរព្រះអានន្ទថា អានន្ទជាបណ្ឌិត

តែងដឹងកាល មុននឹងចូលទៅគាល់តថាគត ដឹងថា នេះជាកាលរបស់ភិក្ខុ នេះជាកាលរបស់ពួកភិក្ខុនី នេះជាកាលរបស់ពួកឧបាសក នេះជាកាលរបស់ពួកឧបាសិកា នេះជាកាលរបស់ពួកព្រះរាជា នេះជាកាលរបស់ពួកអាមាត្យ នេះជាកាលរបស់ពួកអន្យតិ្ថិយ ។ថែមទាំងជាអ្នកបានក្រាបទូលសួរដល់វិធីបដិបត្តិក្នុងមាតុគ្រាម និងសរីរៈរបស់ព្រះសាស្តា ក្រោយអំពីបរិនិព្វាន ។ជាអ្នកក្រាបទូលអង្វរព្រះពុទ្ធជាម្ចាស់ សូមទ្រង់អនុញ្ញាតឲ្យស្ត្រីបួសផង ។ មុននឹងព្រះអង្គបរិនិព្វាន ព្រះសាស្តាត្រាស់លួងលោមព្រះអានន្ទ ថែមទាំងឲ្យកម្លាំងចិត្តខំព្យាយាមថា អានន្ទចូរប្រកបនូវសេចក្តីព្យាយាមចុះ អ្នកនឹងជាអ្នកមិនមាននូវអាសវៈដោយឆាប់រហ័ស ។

៣- ព្រះអានន្ទ ជាអ្នកមានគុណដ៏ច្រើនក្នុងការផ្សព្វផ្សាយព្រះធម៌ ដូចជាសម្តែងធម៌ដល់ព្រះបាទឧទេន និងអគ្គមហេសី បានសម្តែងធម៌ដល់ភិក្ខុនីដែលក្លែងធ្វើជាឈឺ និងឆ្លើយបញ្ហាដល់កោកនុទបរិព្វាជកជាដើម ។

៤- ព្រះអានន្ទសួរព្រះសារីបុត្រថា ដោយហេតុត្រឹមប៉ុណណា ទើបភិក្ខុជាអ្នកពិចារណាឃើញបានដោយឆាប់រហ័សក្នុងកុសលធម៌ទាំងឡាយ

រៀនបានល្អ រៀនបានច្រើន និងរបស់ដែលខ្លួនរៀនរួចហើយ រមែងមិនជាក់ច្បាស់ ព្រះសារីបុត្រពោលថា ពាក្យរបស់ព្រះអានន្ទជាពហូសូតសេចក្ដីនេះ ចូរជាក់ច្បាស់ដល់លោកចុះ ។ ព្រះអានន្ទពោលថា នែអាវុសោ បើដូច្នោះ ចូរលោកស្ដាប់ដោយយកចិត្តទុកដាក់ចុះ ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកឈ្លាសវៃក្នុងអត្ថ ក្នុងធម៌ និងព្យញ្ជនៈ ក្នុងនិរុត្តិ និងឈ្លាសវៃខាងដើម និងខាងចុង ដោយហេតុត្រឹមតែប៉ុណ្ណោះឯង ។ ព្រះសារីបុត្រពោលថា នែអាវុសោ គួរឲ្យអស្ចារ្យណាស់ មិនធ្លាប់មានមកដែលព្រះអានន្ទពោលទុកល្អហើយនេះ ទាំងពួកយើងក៏ទ្រទ្រង់ចាំថាព្រះអានន្ទ ជាអ្នកប្រកបដោយធម៌ ៥ ប្រការ គឺជាអ្នកឈ្លាសវៃក្នុងអត្ថ ក្នុងធម៌ ក្នុងព្យញ្ជនៈ ក្នុងនិរុត្តិ ទាំងឈ្លាសវៃក្នុងខាងដើម និងខាងចុង ។

៥-គ្រាមួយ ព្រះមានជោគទ្រង់សម្ដែងធម៌ដល់ភិក្ខុដោយសង្ខេប ភិក្ខុទាំងឡាយចង់បានពិស្ដារ នាំគ្នាទៅសួរព្រះអានន្ទ លោកក៏អធិប្បាយឲ្យភិក្ខុទាំងឡាយយល់ចូលចិត្តដោយពិស្ដារ ក្រោយមក ភិក្ខុទាំងនោះបានក្រាបទូលសេចក្ដីនោះដល់ព្រះសាស្ដា ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ

ទាំងឡាយ ល្អហើយៗ ម្នាលភិក្ខុទាំងឡាយ អានន្ទជាបណ្ឌិត ជាអ្នកមានបញ្ញាច្រើន ប្រសិនបើអ្នកទាំងឡាយចូលទៅរកតថាគត ហើយសួរនូវសេចក្តីនោះ តថាគតផ្ទាល់ក៏អធិប្បាយសេចក្តីនោះ ដូចអានន្ទដែរ ។

៦-ក្នុងគ្រាដែលព្រះទេវទត្តធ្វើសង្ឃភេទ ទេវទត្តបានប្រាប់ដល់អានន្ទថា នែអាវុសោអានន្ទ ឥឡូវនេះ ខ្ញុំនឹងធ្វើឧបោសថ និងសង្ឃកម្មបែកពីព្រះមានព្រះភាគ និងភិក្ខុសង្ឃតាំងអំពីថ្ងៃនេះតទៅ អានន្ទក៏ចូលគាល់ព្រះសាស្តា ក្រាបទូលឲ្យទ្រង់ជ្រាបសេចក្តីនោះ ព្រះមានព្រះភាគទ្រង់បន្លឺឧទានថា សេចក្តីល្អមនុស្សល្អធ្វើបានដោយងាយ សេចក្តីល្អមនុស្សអាក្រក់ធ្វើបានដោយលំបាក មនុស្សអាក្រក់ធ្វើអាក្រក់បានដោយងាយ អំពើអាក្រក់ ព្រះអរិយៈជាម្ចាស់ទាំងឡាយធ្វើបានដោយកម្រ ។

៧-ព្រះអានន្ទពោលដោយការបដិបត្តិធម៌ ការរៀនសូត្រ បង្ហាញការឧបដ្ឋាក និងការសម្រេចព្រះអរហត្តទុកថា បណ្ឌិតមិនគួរធ្វើខ្លួនឲ្យជាមិត្តនឹងមនុស្សដែលចូលចិត្តញុះញង់ ចូលចិត្តក្រោធ កំណាញ់ និងជាអ្នកប្រាថ្នាឲ្យអ្នកដទៃវិនាស ព្រោះការសមាគមនឹងមនុស្សអាក្រក់

ជាអំពើលាមក តែបណ្ឌិតគួរធ្វើខ្លួនឲ្យជាមិត្តសម្លាញ់នឹងមនុស្សដែល មានសទ្ធា មានសីលជាទីស្រឡាញ់ មានបញ្ញា និងជាអ្នកបានស្តាប់ បានរៀនសូត្រច្រើន ព្រោះការសមាគមនឹងមនុស្សល្អ រមែងមានតែ សេចក្តីចម្រើន ។ ព្រះអានន្ទត្ថេរ បានរៀនសូត្រធម៌ពីព្រះពុទ្ធផ្ទាល់បាន ៨២.០០០ ព្រះធម្មក្ខន្ធ បានរៀនអំពីសម្នាក់ភិក្ខុ មានព្រះសារីបុត្រជា ដើមបាន ២.០០០ ព្រះធម្មក្ខន្ធ រួមទៅជា ៨៤.០០០ ព្រះធម្មក្ខន្ធ ដែល លោកចាំរត់មាត់ ។

អាត្មាអញ បានឧបដ្ឋាកព្រះមានព្រះភាគជាម្ចាស់ ដោយមេត្តា កាយកម្ម មេត្តាវចីកម្ម មេត្តាមនោកម្ម ដូចស្រមោលជាប់តាមព្រះកាយ ព្រះអង្គរហូត ២៥ ឆ្នាំ ។ កាលព្រះអង្គពុទ្ធដំណើរទៅ អាត្មាអញក៏បាន ដើរតាមក្រោយព្រះអង្គ កាលព្រះអង្គសម្តែងធម៌ ញាណក៏កើតឡើង ដល់អាត្មា អញជាអ្នកមានកិច្ចត្រូវធ្វើ ជាព្រះសេក្ខៈ មិនទាន់សម្រេច អរហត្ត ។

ព្រះសាស្តាអង្គណា ទ្រង់អនុគ្រោះយើង ព្រះសាស្តាអង្គនោះ

ស្តេចបរិនិព្វានទៅមុនហើយ ។ កាលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ដល់នូវកាលប្រសើរដោយអាការទាំងពួង ស្តេចបរិនិព្វានហើយ លំដាប់នោះឯង យើងស្លុតចិត្ត ព្រឺរោមយ៉ាងខ្លាំង ។

យើងមានការស្និទ្ធស្នាលនឹងព្រះសាស្តា យើងបានធ្វើតាមពាក្យប្រៀនប្រដៅរបស់ព្រះអង្គរួចស្រេចហើយ មានការៈធ្ងន់ដាក់ចុះហើយ ដកចេញនូវតណ្ហា ដែលជាគ្រឿងនាំទៅកាន់ភពបានហើយ ៕

( ជីវប្រវត្តិរបស់ព្រះអានន្ទត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះឧរុវេលកស្សបត្ថេរ ✍

## " ដែលជាឯតទគ្គៈផ្នែកខាងអ្នកមានមានបរិវារច្រើន "

លោកកសាងគុណធម៌ទុកទាំងចំណែកខ្លួន ទាំងណែនាំឲ្យអ្នកដទៃធ្វើតាមផង រហូតជាកំពូលផ្នែកមានបរិវារច្រើន ជាព្រះអសីតិមហាសាវក គឺព្រះសាវកធំរបស់ព្រះពុទ្ធជាម្ចាស់ ៨០ លោកមួយរូបផងដែរ ដែលមានជីវប្រវត្តិរៀបរាប់ទុកទាំងអតីតជាតិ និងបច្ចុប្បន្នជាតិ ។

ជីវប្រវត្តិរបស់លោកមានសម្ដែងទុកនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ក្នុង **អដ្ឋកថាបរមត្ថទីបនី** និង **អដ្ឋកថាមនោរថបូរណី** ក្នុងទីនេះនឹងពោលតាម **អដ្ឋកថាមនោរថបូរណី** ដែលពន្យល់សេចក្ដីបាលី **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ឲ្យពិស្ដារចេញទៅ ដូចមានសេចក្ដីថា ៖

ក្នុងអតីតកាល ព្រះឧរុវេលកស្សបៈ កើតឡើងនៅក្នុងផ្ទះរបស់អ្នកមានត្រកូលមួយ ក្នុងក្រុងហង្សវតី លុះចម្រើនវ័យឡើងហើយបានទៅស្ដាប់ព្រះធម្មទេសនារបស់ព្រះបទុមុត្តរសម្ពុទ្ធជាម្ចាស់ បានឃើញព្រះអង្គ ទ្រង់តាំងព្រះថេរៈមួយរូប ទុកក្នុងតំណែងដ៏ប្រសើរបំផុតជាង

សាវកទាំងឡាយ ផ្នែកមានបរិវារច្រើន ទើបគិតថា យើងគួរនឹងបាន ដូចជាព្រះថេរៈនោះក្នុងអនាគតកាល ។

កុលបុត្រនោះ ( ឧរុវេលកស្សបៈ ) កាលគិតដូច្នេះហើយ ទើបរៀបចំថ្វាយមហាទានដល់ព្រះភិក្ខុសង្ឃ ដែលមានព្រះបទុមុត្តរសម្ពុទ្ធជាម្ចាស់ជាប្រធាន ការថ្វាយមហាទានធ្វើអស់ ៧ ថ្ងៃ ក្នុងថ្ងៃចុងក្រោយបានថ្វាយសំពត់ចីវរ ហើយតាំងសេចក្តីប្រាថ្នាថា សូមឲ្យខ្ញុំព្រះអង្គបានទទួលតំណែងដ៏ប្រសើរបំផុតផ្នែកមានបរិវារច្រើន ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយ ដោយផលនៃបុណ្យកុសលនេះ ក្នុងអនាគតកាលឯណោះចុះ ។ ព្រះបទុមុត្តរសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ពិចារណាឃើញដល់ការប្រព្រឹត្តទៅ ក្នុងអនាគតកាលរបស់កុលបុត្រនោះ មិនមានហេតុរារាំងដោយប្រការណា ទើបទ្រង់ព្យាករថា អ្នកនឹងបានជាកំពូលផ្នែកមានបរិវារច្រើន សមតាមសេចក្តីប្រាថ្នា ក្នុងព្រះសាសនារបស់ព្រះសមណគោតមជាម្ចាស់ ដោយស្តេចនឹងឧប្បត្តិឡើងក្នុងមួយសែនកប្បខាងមុខទៀត ។

កុលបុត្រនោះ ស្តាប់ការព្យាករណ៍ហើយ កើតសេចក្តីត្រេកអរ

យ៉ាងក្រៃលែង ហាក់បីដូចជាសេចក្តីប្រាថ្នា នឹងសម្រេចក្នុងថ្ងៃស្អែកនេះ ឬខានស្អែក ហើយធ្វើកល្យាណកម្មបន្តរហូតអស់ជីវិត ។ ក្នុងវេលាដែលលោកកើតស្លាប់ៗ នៅក្នុងភពផ្សេងៗ ក្នុងកំណើតទេវតា និងមនុស្សនោះៗ កាលរាប់ថយក្រោយអំពីកប្បនេះទៅបាន ៩២ កប្ប ។

ជាតិមួយលោកត្រឡប់មកកើតជាព្រះអនុជ មានព្រះមាតាផ្សេងពីព្រះមានព្រះភាគជាម្ចាស់ផុស្សៈ បិតានាមថា **មហិន្ទរាជា** ( ឈ្មោះព្រះរាជា ក្នុងអដ្ឋកថាគម្ពីរបរមត្ថជោតិកាពោលថា ជ័យសេន និងមហេសីឈ្មោះ ព្រះនាងសិរិមា ) និងមានព្រះអនុជ ២ ព្រះអង្គទៀត រួមជា ៣ ព្រះអង្គ ក្នុងមួយព្រះអង្គៗ ទ្រង់ទទួលតំណែងមានយសសក្តិផ្សេងៗគ្នា ។ គ្រាមួយនៅឯបច្ចន្តជនបទ គឺស្រុកជាយដែនរបស់ព្រះមហិន្ទរាជាកើតមានបច្ចាមិត្ត គិតបះបោរឡើង ទើបព្រះរាជាត្រាស់ហៅ រាជឱរសទាំង ៣ ព្រះអង្គចូលគាល់ ហើយមានព្រះរាជតម្រាស់ថា ម្នាលបុត្រទាំង ៣ ឥឡូវនេះ បច្ចន្តជនបទកំពុងមានសត្រូវច្រើន ហេតុការណ៍ទាំងនេះមិនចាំបាច់បិតា ឬបុត្រទាំង ៣ ត្រូវទៅបង្ក្រាបបច្ចាមិត្តក្នុងបច្ចន្តជនបទ ឲ្យស្ងប់ទាំងអស់គ្នាទេ បើបិតានឹងលើកទៅបង្ក្រាបពួកសត្រូវ

បុត្រទាំង ៣ ចូរវង់ចាំបដិបត្តិ ទំនុកបម្រុងព្រះមានព្រះភាគរបស់យើងឲ្យល្អផង ។

ចំណែកព្រះឱរសទាំង ៣ ព្រះអង្គ ព្រមក្រាបទូលទទួលស្ម័គ្រចិត្តឡើងថា បពិត្រព្រះរាជបិតា ហេតុដែលកើតឡើងពេលនេះ ទូលបង្គំទាំង ៣ នឹងស្ម័គ្រចិត្តទៅកម្ចាត់ពួកបច្ចាមិត្តថ្វាយព្រះបិតា ។ ព្រះមហិន្ទរាជាទ្រង់សព្វព្រះហឫទ័យ ក្នុងព្រះរាជឱរសយ៉ាងក្រៃលែង ហើយត្រាស់អនុញ្ញាតដល់ព្រះឱរសទាំង ៣ ព្រះអង្គ ដើម្បីទៅប្រតិបត្តិការបង្ក្រាបចលាចល ។

ព្រះឱរសទាំង ៣ ព្រះអង្គ ទ្រង់ក្រាបបង្គំលាព្រះរាជបិតាព្រមទាំងស្តេចលើកចតុរង្គសេនាទៅកាន់បច្ចន្តជនបទ ហើយទ្រង់នាំគ្នាកម្ចាត់ពួកសត្រូវ ដែលក្បត់ឲ្យស្ងប់ហើយ ទើបស្តេចលើកពួកយោធានិវត្តន៍មកកាន់ព្រះនគរវិញ ។ តែខណៈដែលលើកកងទ័ពត្រឡប់មកក្នុងចន្លោះផ្លូវ រាជឱរសទាំង ៣ ព្រះអង្គ ទ្រង់ប្រឹក្សាគ្នាថា ម្នាលអ្នកទាំងឡាយកាលពួកយើងត្រឡប់ទៅដល់ព្រះនគរហើយ ប្រសិនបើព្រះបិតាព្រះរាជទានពរដល់ពួកយើង ពួកយើងនឹងជ្រើសរើសទទួលពរអ្វីល្អហ្ន៎ ។

ចំណែកពួកទូលបង្គំទាំងអស់ នាំគ្នាក្រាបបង្គំទូលថា បពិត្រព្រះបិតា មិនថាជាព្រះរាជសម្បត្តិណាៗ ក៏ដោយ ដែលព្រះបិតាព្រះរាជទានមិនមានអ្វីដែលសំខាន់ស្មើការបានបដិបត្តិទំនុកបម្រុងព្រះមានព្រះភាគដែលជាព្រះជេដ្ឋាធិរាជនោះឡើយ ។ ព្រះឱរសទាំង ៣ ព្រះអង្គទ្រង់គិតន័យនោះ ហើយទ្រង់សព្វព្រះទ័យ ទើបត្រាស់ថា ន័យដែលពួកយើងគិតឃើញមកនោះ ប្រពៃហើយ គ្រាដែលស្ដេចយាងមកដល់ព្រះនគរហើយ ទើបទ្រង់នាំគ្នាចូលគាល់ព្រះរាជបិតា ព្រមទាំងក្រាបទូលដល់ជ័យជម្នះឲ្យទ្រង់ជ្រាប ។

ព្រះរាជាទ្រង់សោមនស្សជាខ្លាំង ទ្រង់ត្រាស់ព្រះរាជទានពរដល់ព្រះរាជឱរសទាំង ៣ ព្រះអង្គ ឲ្យទ្រង់ជ្រើសរើសតាមការសព្វព្រះទ័យ ។

ទើបរាជឱរសទាំង ៣ ព្រះអង្គ ទ្រង់ក្រាបទូលទទួលព្រះរាជទានពរថា បពិត្រព្រះបិតា សូមទ្រង់ព្រះករុណាព្រះរាជទានពរដល់ខ្ញុំព្រះអង្គទាំង ៣ ឲ្យមានឱកាសបដិបត្តិទំនុកបម្រុងព្រះផុស្សសម្មាសម្ពុទ្ធជាម្ចាស់រហូតអស់ត្រៃមាសចុះ ព្រះអង្គ ។

ព្រះរាជា ទ្រង់មានព្រះទ័យមិនសប្បាយត្រាស់បដិសេធថា ការ

បដិបត្តិព្រះមានព្រះភាគនោះ បិតាមិនអាចនឹងអនុញ្ញាតដល់បុត្រទាំង ៣ បានទេ ចូរពិចារណាសូមពរដទៃចុះ ។ រាជឱរសទាំង ៣ ទ្រង់ក្រាបទូលថា បពិត្រព្រះបិតា ពរដទៃទូលបង្គំមិនទទួលទេ សូមព្រះបិតាទ្រង់ព្រះករុណា ព្រះរាជទានពរដែលទូលបង្គំសូមហើយនោះចុះ ។

ព្រះរាជាទ្រង់លំបាកព្រះទ័យ មិនដឹងបដិសេធដោយឧបាយយ៉ាងណាបាន ព្រោះថាទ្រង់បានយល់ព្រមរួចហើយ ទើបត្រាស់អនុញ្ញាតថា ម្នាលបុត្រទាំង ៣ ព្រះបិតាឲ្យពរដល់បុត្រហើយ តែថាព្រះមានព្រះភាគមានឧបមាដូចស្តេចរាជសីហ៍ មានប្រក្រតីប្រកបក្នុងទីស្ងាត់អស់កាលជានិច្ច និងមានប្រក្រតីប្រព្រឹត្តនៅតែម្នាក់ឯង ដូច្នោះកាលបុត្រទាំង ៣ នឹងបដិបត្តិទំនុកបម្រុងព្រះមានព្រះភាគនោះ ចូរកុំប្រមាទជាដាច់ខាត ។

រាជឱរសទាំង ៣ ក៏ទ្រង់ប្រឹក្សាគ្នាថា កាលពួកយើងនឹងបដិបត្តិទំនុកបម្រុងព្រះមានព្រះភាគជាម្ចាស់ នឹងធ្វើការបដិបត្តិយ៉ាងណាទើបសមគួរ ហើយព្រះរាជឱរសទាំង ៣ អង្គ ទ្រង់មានការគិតឃើញដូចគ្នាថា នឹងសមាទានសីល ១០ បានតែងតាំងបុរស ៣ នាក់ ឲ្យជាអ្នកថែទាំរក្សាភេងទាន រង់ចាំចាត់ចែងទេយ្យទាន ថ្វាយដល់ព្រះមានព្រះភាគ

ជាម្ចាស់ ដោយចែកតួនាទីគ្នា ។

ឲ្យអាមាត្យម្នាក់ជាអ្នករកស្បៀងម្នាក់ទៀតជាអ្នកចាត់ការទូទៅ និងអាមាត្យម្នាក់ទៀត ជាអ្នករៀបចំទេយ្យធម៌បម្រើភិក្ខុសង្ឃ ហើយក៏ធ្វើតាមការដែលបានប្រឹក្សាគ្នាគ្រប់ប្រការ ។

បុរសទាំង ៣ នោះ លុះមកដល់ក្នុងជាតិចុងក្រោយ បានមកកើតជាព្រះបាទពិម្ពិសារ វិសាខឧបាសក និងព្រះរដ្ឋបាលត្ថេរ ។

ព្រះរាជឱរសទាំង ៣ ព្រះអង្គស្តេចនាំគ្នាសមាទានសីល ១០ រហូតអស់ត្រៃមាស ( គឺបីខែ ) ដើម្បីកាន់គោលនៃការបូជាដ៏ខ្ពង់ខ្ពស់ ដោយការបដិបត្តិតាមពាក្យប្រៀនប្រដៅ សូម្បីមានការបដិបត្តិដោយការបរិច្ចាគចតុប្បច្ច័យទំនុកបម្រុងហើយក៏ដោយ ។

លុះចេញវស្សាហើយព្រះរាជឱរសទាំង ៣ ព្រះអង្គ ចាត់ចែងថ្វាយទេយ្យធម៌ដោយព្រះអង្គឯង ទាំងទ្រង់ធ្វើបុណ្យរហូតអស់ព្រះជន្ម ។ បានមកដល់ជាតិចុងក្រោយនេះ ព្រះរាជឱរសទាំង ៣ ព្រះអង្គ ត្រឡប់មកកើតក្នុងមគធរដ្ឋ បានកើតក្នុងត្រកូលព្រាហ្មណ៍ **កស្សបគោត្ត** មុនព្រះបរមគ្រូរបស់យើងទាំងឡាយ មានឈ្មោះដូចគ្នាទាំងអស់ថា **កស្សបៈ**

តែមានពាក្យនាំមុខឈ្មោះផ្សេងគ្នា ដោយអាស្រ័យឈ្មោះទីកន្លែងយកមកផ្សំជាមួយនឹងឈ្មោះរបស់លោក ដូចជាអ្នកដែលអាស្រ័យនៅជនបទឧរុវេល មានឈ្មោះថា ឧរុវេលកស្សបៈ មានបរិវារ ៥០០ នាក់ រូបទី ២ អាស្រ័យនៅមាត់ប្រាំងមហាគង្គានទី ទើបត្រូវហៅឈ្មោះថា នទីកស្សបៈ មានបរិវារ ៣០០ នាក់ និងប្អូនពៅមានឈ្មោះថា គយាកស្សបៈ ព្រោះអាស្រ័យនៅជនបទគយាសីសៈ មានបរិវារ ២០០ នាក់ ។ កាលបងប្អូនទាំង ៣ នាក់មានវ័យចម្រើនឡើង បាននាំគ្នារៀនសូត្រវិជ្ជាត្រៃវេទ ក្នុងសាសនាព្រាហ្មណ៍ចប់សព្វគ្រប់ហើយ មានចំណេះវិជ្ជាអាចបង្រៀនវិជ្ជាត្រៃវេទដល់មាណពជាច្រើន រហូតធ្វើឲ្យពួកមាណពព្រមចូលមកជាបរិវារ ទាំងជាអ្នកមានឈ្មោះបោះសំឡេងល្បីល្បាញដល់មហាជន ។

សម័យតមក ទាំង ៣ នាក់បងប្អូនពិចារណាឃើញលទ្ធិដែលខ្លួនរាប់អាននោះ មិនមានខ្លឹមសារ និងមានប្រយោជន៍ត្រឹមតែបច្ចុប្បន្នជាតិនេះប៉ុណ្ណោះ ចំណែកប្រយោជន៍ក្នុងជាតិខាងមុខនោះមើលមិនឃើញឡើយ ព្រោះដូច្នោះ ទើបព្រះឧរុវេលកស្សបៈបបួលប្អូនទាំងពីរនាក់ ព្រមទាំងបរិវារ ទាំងអស់ចេញទៅបួសជាជដិល គឺអ្នកបួសប្រភេទបួងសក់ឲ្យ

ខ្ពស់ឡើង និងបំពេញវត្តដោយការបូជាភ្លើង បើហៅអ្នកបួសនេះម្យ៉ាងទៀត ក៏ហៅថា ឥសី ប្រែថា អ្នកស្វែងរកគុណ គឺសេចក្តីល្អ ឬអ្នកឃើញភ័យ ។

ការចេញបួសនេះ បងទី ១ តាំងអាស្រមនៅជនបទឧរុវេលា បងទី ២ តាំងអាស្រមនៅមាត់ប្រាំងមហាគង្គានទី និងប្អូនពៅតាំងអាស្រមនៅជនបទគយាសីសៈមាត់ប្រាំងស្ទឹងគយា ហើយទាំង ៣ នាក់បងប្អូនបានចេញបួសបំពេញវត្តមកជាយូរ រហូតមានប្រាកដកិត្តិគុណសព្ទទៅក្នុងដែនមគធៈ ។ លុះកាលព្រះពោធិសត្វ ទ្រង់ចេញសាងផ្នួស បានត្រាស់ដឹងជាព្រះសម្ពុទ្ធ ទ្រង់ប្រកាសធម្មចក្រហើយ បានបញ្ចវគ្គិយជាព្រះអរហន្តសាវក និងព្រះយសត្ថេរ ព្រមទាំងសម្លាញ់ ៥៤ រូប ហើយរួមមានព្រះអរហន្តទាំងអស់ ៦០ រូប ទើបព្រះមានព្រះភាគទ្រង់បញ្ជូនព្រះអរហន្តសាវកទាំងអស់នោះ ចេញទៅផ្សាយព្រះពុទ្ធសាសនា ក្នុងទិសានុទិស ( ទិសតូច និងទិសធំ ) ។

ចំណែកព្រះអង្គ ទ្រង់ពិចារណាឃើញឧបនិស្ស័យដ៏បរិបូណ៌ដោយកុសលបារមី ដែលនឹងបានសម្រេចមគ្គផលរបស់ជដិលទាំង ៣

នាក់បងប្អូន និងមហាជនក្នុងដែនមគធៈជាច្រើន ទាំងទ្រង់មានព្រះបំណង នឹងប្រតិស្ឋាន ព្រះសាសនាក្នុងដែនមគធរដ្ឋនោះ ដោយទ្រង់ប្រាថ្នានឹងឲ្យព្រះឧរុវេលកស្សបៈ មកជាកម្លាំងនៃការប្រកាសព្រះសាសនាផង ។

រឿងយាងប្រោសជដិល ៣ នាក់បងប្អូនរបស់ព្រះមានព្រះភាគ មានពណ៌នាទុកក្នុងបាលី **គម្ពីរមហាវគ្គ ព្រះវិនយបិដក** សេចក្តីថា ៖

ព្រះមានព្រះភាគស្តេចពុទ្ធដំណើរមួយព្រះអង្គឯង ទ្រង់សំដៅចំពោះជនបទឧរុវេលាសេនានិគម តែក្នុងចន្លោះផ្លូវទ្រង់ទេសនាប្រោសកុមារភទ្ទវគ្គិយ ៣០ នាក់ និងប្រទានឧបសម្បទាឲ្យ ហើយទ្រង់បញ្ជូនទៅប្រកាសព្រះសាសនា ចំណែកព្រះអង្គទ្រង់ពុទ្ធដំណើរតទៅ រហូតដល់ជនបទឧរុវេលា ដែលជាទីនៅរបស់ឧរុវេលកស្សបជដិលដែលមានបរិវារ ៥០០ នាក់ ។ ព្រះមានព្រះភាគ ស្តេចយាងទៅដល់អាស្រមរបស់ឧរុវេលកស្សបជដិល ក្នុងវេលាល្ងាច ទ្រង់ត្រាស់ថា នែ៎ ! កស្សបៈ បើអ្នកមិនជំទាស់ទេ តថាគត សូមស្នាក់នៅក្បែររោងបូជាភ្លើងមួយយប់ផងបានទេ ។

ជដិលឧរុវេលកស្សបទូលថា បពិត្រព្រះមហាសមណៈ ខ្ញុំមិន

ជំទាស់ទេ តែថាមានស្តេចនាគ ដែលកាចសាហាវមានឫទ្ធិ មានពិសត្រង់ចង្កូម មានពិសខ្លាំងក្លាបានអាស្រ័យនៅក្នុងរោងភ្លើងនោះ សូមកុំឲ្យស្តេចនាគនោះបៀតបៀនព្រះអង្គឡើយ ព្រោះស្តេចនាគអាចធ្វើអន្តរាយដល់ព្រះអង្គបាន ។

ម្យ៉ាងទៀត ជដិលឧរុវេលកស្សបមិនពេញចិត្តឲ្យព្រះមានជោគស្នាក់នៅឡើយធ្វើអាការមិនពេញចិត្តនិយាយត្រឡប់ថាមិនមានកន្លែងឲ្យស្នាក់ ទោះបីរោងបូជាភ្លើងទំនេរមិនមានជដិលស្នាក់នៅក៏ដោយ នេះព្រោះឃើញថា ជាអ្នកបួសលទ្ធិផ្សេងគ្នានឹងខ្លួន ។ព្រះសាស្តាត្រាស់សុំទីស្នាក់អាស្រ័យជាលើកទី ២ ទៀត ចំណែកជដិលឧរុវេលកស្សបៈក៏ទូលត្រឡប់ដូចមុន ។

ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលឧរុវេលកស្សបៈ តថាគតយល់ថា ស្តេចនាគនោះគង់នឹងមិនបៀតបៀនតថាគត អ្នកចូរអនុញ្ញាតរោងភ្លើង ដល់តថាគតស្នាក់អាស្រ័យចុះ ។

ជដិលឧរុវេលកស្សប សង្កេតឃើញព្រះមានព្រះភាគជាម្ចាស់ទ្រង់មិនខ្លាចក្រែងស្តេចនាគសោះឡើយ ទើបយល់ព្រមអនុញ្ញាតដោយ

ទូលថា បើដូច្នោះ សូមព្រះអង្គចូរស្នាក់អាស្រ័យតាមសប្បាយចុះ ។ ព្រះមានព្រះភាគ កាលបានទទួលអនុញ្ញាតហើយ ទើបស្តេចចូលទៅកាន់រោងភ្លើង ទ្រង់ក្រាលកម្រាលដែលធ្វើដោយស្មៅ ហើយប្រថាប់គង់តាំងព្រះកាយឲ្យត្រង់ មានសតិតាំងមាំ ដោយមិនបានទ្រង់មានអាការខ្លាចក្រែងស្តេចនាគនោះឡើយ ។

ចំណែកស្តេចនាគ បានសម្លឹងឃើញព្រះសម្មាសម្ពុទ្ធស្តេចយាងចូលមកក្នុងទីកន្លែងរបស់ខ្លួន ក៏កើតចិត្តខឹងក្រោធទើបផ្ញុំពិសបង្ហុយទៅពេញរោងភ្លើង ។ លំដាប់នោះ ព្រះមានជោគទ្រង់ព្រះតម្រិះថា តថាគតគួរនឹងសម្តែងឥទ្ធានុភាពឲ្យកើតជាផ្សែង តែមិនឲ្យប៉ះពាល់សម្បុរស្បែកសាច់ សរសៃ ឆ្អឹង និងខួរក្នុងឆ្អឹងរបស់ស្តេចនាគនោះ ដើម្បីរម្ងាប់តេជះរបស់ស្តេចនាគឲ្យអស់ទៅ ហើយទ្រង់ធ្វើឥទ្ធានុភាពដូចទ្រង់ព្រះតម្រិះនោះ ។

ស្តេចនាគកាលត្រូវផ្សែងដែលកើតអំពីពុទ្ធានុភាព មិនអាចនឹងអត់ទ្រាំសេចក្តីក្រោធបាន ទើបបង្ហុយផ្សែងមួយរំពេច ហើយផ្ញុំពិសជាអណ្តាតភ្លើងឆេះសន្ធោសន្ធៅឡើង ។ ព្រះមានព្រះភាគ ទ្រង់ចូល

តេជោកសិណសមាបត្តិ បណ្ដាលឲ្យកើតអណ្ដាតភ្លើងរុងរឿងភ្លឺចិញ្ចាច ដើម្បីទ្រង់ទប់ទល់នឹងការក្រអឺតក្រទមរបស់ស្ដេចនាគ ។

ភ្លើងទាំងពីរចំណែក ឆេះសន្ធោសន្ធៅមានពន្លឺភ្លឺស្វាង ដូចដុតបំផ្លាញរោងភ្លើងនោះឲ្យវិនាសជាផេះ ។ ពួកជដិលបាននាំគ្នាមកឈរព័ទ្ធរោងភ្លើង ម្នាក់ៗ ពោលថា

ព្រះមហាសមណៈនេះ មានសិរីរូបឆោមស្អាតក្រៃលែងណាស់ គួរឲ្យស្ដាយដែលត្រូវមកស្លាប់ ដោយពិសរបស់ស្ដេចនាគក្នុងទីនេះ ។ លុះព្រឹកឡើង ព្រះមានព្រះភាគទ្រង់កម្ចាត់ឫទ្ធិនាគឲ្យអន្តរធាន លះភាពរឹងរូសទ្រង់បណ្ដាលឲ្យបត់កាយដេកចុះទៅក្នុងបាត្រ ហើយទ្រង់នាំមកឲ្យជដិលឧរុវេលកស្សបៈមើល ដោយត្រាស់ថា នេះនៃកស្សបៈ ស្ដេចនាគរបស់អ្នកអស់ឫទ្ធិហើយ ។

ឧរុវេលកស្សបៈឃើញដូច្នោះហើយគិតថា ព្រះមហាសមណៈនេះមានអានុភាពច្រើន មានឫទ្ធិច្រើន អាចបង្ក្រាបស្ដេចនាគឲ្យចាញ់បាន តែយ៉ាងណាក៏ដោយ ព្រះមហាសមណៈនេះនៅមិនទាន់បានជាព្រះអរហន្តដូចជាយើង ចំណែកជម្រៅនៃចិត្តក៏គិតជ្រះថ្លាក្នុងឥទ្ធិបាដិហារិយ៍ ទើប

ពោលថា បពិត្រមហាសមណៈ សូមនិមន្តនៅក្នុងអាស្រមរបស់យើងចុះ យើងនឹងថ្វាយអាហារឲ្យឆាន់រាល់ថ្ងៃ ។

ព្រះមានព្រះភាគ ស្ដេចយាងទៅប្រថាប់ក្នុងដងព្រៃមួយ ដែលនៅជិតអាស្រមឧរុវេលកស្សបៈនោះ មិនទ្រង់សម្រាកនៅក្នុងអាស្រមរបស់ជដិល លុះដល់មជ្ឈិមយាម ( យាមកណ្ដាល ) នៃយប់ដំបូង ស្ដេចចាតុម្មហារាជ ( ស្ដេចចាតុម្មហារាជទាំង ៤ បានដល់ ១ ស្ដេចវេស្សវណ្ណ ឬស្ដេចកុវេរៈ ប្រចាំទិសឧត្តរ ២ ស្ដេចវិរុឡ្ហកៈ ប្រចាំទិសខាងត្បូង ៣ ស្ដេចធតរដ្ឋៈ ប្រចាំទិសខាងកើត ៤ ស្ដេចវិរូបក្ខៈ ប្រចាំទិសខាងលិច ) ទាំង ៤ ចុះមកកាន់ពុទ្ធសម្នាក់ថ្វាយបង្គំហើយ ស្ថិតឈរនៅក្នុងទិសទាំង ៤ មានរស្មីភ្លឺស្វាង ដូចគំនរភ្លើងក្នុងទិសទាំង ៤ ដូច្នោះ ។

លុះដល់វេលាព្រឹក ឧរុវេលកស្សបៈមកកាន់សម្នាក់របស់ព្រះមានព្រះភាគក្រាបទូលថា បពិត្រព្រះមហាសមណៈ សូមនិមន្តព្រះមហាសមណៈទៅឆាន់ភត្តាហារចុះ ខ្ញុំចាត់ចែងទុកស្រេចហើយ បពិត្រព្រះមហាសមណៈ កាលពីយប់មិញឃើញរស្មីភ្លឺពេញមណ្ឌលដងព្រៃនេះ

អ្នកណាមកកាន់សម្នាក់របស់ព្រះអង្គឬទើបមានពន្លឺភ្លឺរុងរឿងសព្វទិស ទាំង ៤ ។ ព្រះសាស្តាត្រាស់ប្រាប់ថា ម្នាលឧរុវេលកស្សបៈ ពន្លឺនោះកើត អំពីស្តេចមហារាជទាំង ៤ ចុះមកកាន់សម្នាក់តថាគតដើម្បីស្តាប់ធម៌ ។

ឧរុវេលកស្សបៈស្តាប់ព្រះតម្រាស់ហើយ គិតថា ព្រះមហាសមណៈ រូបនេះមានអានុភាពច្រើន សូម្បីតែស្តេចចាតុម្មហារាជក៏ចុះមករក តែ យ៉ាងណា ក៏មិនមែនជាព្រះអរហន្តដូចជាយើងទេ ។ ព្រះមានព្រះភាគ ជាម្ចាស់ ស្តេចមកឆាន់ភត្តាហាររបស់ឧរុវេលកស្សបៈស្រេចហើយ ស្តេច ត្រឡប់មកកាន់សម្នាក់ក្នុងដងព្រៃនោះដូចដើម ។

លុះដល់រត្តិកាល ព្រះឥន្ទ្រស្តេចមកកាន់ពុទ្ធសម្នាក់ ទ្រង់ថ្វាយបង្គំ នមស្ការព្រះមានព្រះភាគជាម្ចាស់ហើយ ប្រថាប់ឈរនៅក្នុងទីដ៏សមគួរ ទ្រង់បញ្ចេញព្រះរស្មីមានពន្លឺដូចគំនរភ្លើងធំ ភ្លឺរុងរឿងក្រៃលែងជាងយប់ មុន ។ លុះដល់ព្រឹកឡើង ឧរុវេលកស្សបៈទៅកាន់សម្នាក់របស់ព្រះ មានព្រះភាគ ទូលឲ្យស្តេចទៅឆាន់ភត្តាហារ ហើយទូលសួរថា កាល យប់មិញ មានអ្នកណាមកកាន់សម្នាក់របស់ព្រះអង្គ ទើបមានរស្មីភ្លឺ ក្រៃលែងជាងយប់ដំបូង ។

ព្រះសាស្តាត្រាស់តបថា ម្នាលឧរុវេលកស្សបៈ កាលយប់មិញ មានស្តេចកោសិយរាជ ស្តេចមករកតថាគតដើម្បីស្តាប់ធម៌ ។ ឧរុវេលកស្សបៈ ព្រមទទួលសេចក្តីអស្ចារ្យដែលប្រាកដឡើង ដោយមិនធ្លាប់ជួបប្រទះមកពីកាលមុន ។

ព្រះមានព្រះភាគជាម្ចាស់ ស្តេចយាងទៅធ្វើភត្តកិច្ចស្រេចហើយ ស្តេចត្រឡប់មកគង់ក្នុងជង់ព្រៃនោះទៀត លុះដល់វេលាយប់អគ្រាត្រ ស្តេចសហម្បតីព្រហ្មចុះមកកាន់ពុទ្ធស្ថាន មានរស្មីរុងរឿងភ្លឺស្វាងជាងរាត្រីដែលកន្លងមក ។ ព្រឹកឡើង ឧរុវេលកស្សបៈទៅទូលអារាធនាឆាន់ភត្តាហារ ហើយទូលសួរនូវហេតុការណ៍ ក្នុងពេលយប់ដែលបានឃើញទៀត ។

ព្រះមានព្រះភាគជាម្ចាស់ត្រាស់តបថា កាលពីយប់មិញ មានស្តេចសហម្បតីព្រហ្មមកកាន់សម្នាក់របស់តថាគត ។ ជដិលមានការគិតដូចមុន ព្រះមានព្រះភាគជាម្ចាស់ ឆាន់ភត្តាហាររបស់ឧរុវេលកស្សបៈហើយ ទើបស្តេចសម្រាកក្នុងសម្នាក់របស់ព្រះអង្គ ។ ថ្ងៃស្អែកឡើងជាថ្ងៃដែលមហាយញ្ញលាភ នឹងកើតដល់ជដិលឧរុវេលកស្សប មនុស្ស

ទាំងឡាយ ក្នុងដែនអង្គៈនឹងនាំខាទនីយភោជនីយាហារចំនួនច្រើន មកជូនដល់ជដិលឧរុវេលកស្សបៈ ។

ពេលយប់ឧរុវេលកស្សបៈគិតថា ព្រឹកនេះមហាជននឹងនាំអាហារផ្សេងៗ ជាច្រើនមកកាន់សម្នាក់របស់យើង បើព្រះមហាសមណៈរូបនេះសម្តែងឥទ្ធិបាដិហារិយ៍ លាភសក្ការៈនឹងកើតដល់មហាសមណៈនេះជាច្រើន យើងនឹងវិនាសសាបសូន្យចាកគ្រប់សក្ការបូជានឹងធ្វើដូចម្តេចហ្ន៎ ថ្ងៃស្អែកនេះកុំឲ្យមហាសមណៈរូបនេះមកទីនេះបាន ។

ព្រះសាស្តាជាម្ចាស់ ទ្រង់ជ្រាបដល់ការគិតរបស់ឧរុវេលកស្សបៈ ដោយចេតោបរិយញ្ញាណ គឺការដឹងចិត្តរបស់អ្នកដទៃ ។ លុះព្រឹកឡើង ទើបព្រះអង្គយាងទៅកាន់ឧត្តរកុរុទ្វីប ទ្រង់ចារិកបិណ្ឌបាតកត្តាហារ ហើយស្តេចត្រឡប់មកធ្វើភត្តកិច្ចក្នុងអនោតត្តស្រះ ហើយទ្រង់សម្រាកពេលថ្ងៃក្នុងទីនោះ ពេលសាយណ្ហសម័យមកដល់ ទើបស្តេចត្រឡប់មកគង់ក្នុងពុទ្ធសម្នាក់ក្នុងដងព្រៃនោះ ។

ព្រឹកឡើង ឧរុវេលកស្សបៈទៅទូលនិមន្តសោយកត្តាហារព្រមដោយពាក្យសួរថា ថ្ងៃម្សិលមិញ ព្រះមហាសមណៈទៅស្វែងរកអាហារ

ឯណា ហេតុអ្វីមិនមកកាន់សម្នាក់របស់ខ្ញុំ ខ្ញុំរឭកដល់ព្រះមហាសមណៈ។ ព្រះសម្មាសម្ពុទ្ធ ត្រាស់ដល់ការដែលមានចិត្តគិតត្រិះរិះនោះ ឲ្យយល់យ៉ាងជាក់ច្បាស់ ។

ឧរុវេលកស្សបៈស្តាប់ហើយស្ងុតចិត្ត គិតថា ព្រះមហាសមណៈនេះមានឫទ្ធិច្រើន ដឹងបានសូម្បីដល់ចិត្តរបស់ខ្ញុំ តែនៅមិនបានជាព្រះអរហន្តដូចខ្ញុំម្ចាស់ ។ ក្នុងចន្លោះកាលដែលព្រះមានព្រះភាគគង់នៅក្នុងដងព្រៃ ដើម្បីប្រោសពួកជដិលនេះ សំពត់បង្សុកូលចីវរកើតដល់ព្រះអង្គ ទើបព្រះអង្គ ទ្រង់និមន្តទៅពិចារណាសំពត់បង្សុកូល ដែលរុំសាកសពរបស់នាងបុណ្ណទាសី ដែលត្រូវបោះចោលនៅក្នុងព្រៃខ្មោចនៅស្រស់ ( អាមកសុសាន ) ។

ការដែលព្រះអង្គ ទ្រង់ជាឧកតោជាតិ គឺទ្រង់កើត ២ ដងជាខត្តិយរាជ និងជាព្រះសម្មាសម្ពុទ្ធ ទ្រង់ជាសាស្តារបស់មនុស្ស និងទេវតាទាំងឡាយ តែព្រះលោកនាយកនៅទ្រង់ជាក់កិត្តិយស មកបង្សុកូលសំពត់រុំសាកសព ក្រដែលទេវតា និងមនុស្សធ្វើបានមហាប្រថពីដ៏ធំកើតការញាប់ញ័រជាមហាស្ចារ្យ រហូតទៅដល់ទឹកទ្រផែនដី ។

ព្រះសាស្តាទ្រង់ត្រិះរិះមករហូតផ្លូវថា នឹងជម្រះសំពត់បង្សុកូលទីណាល្អហ្ន៎ ។ ព្រះឥន្ទ្រស្តេចចុះមកជីកស្រះបោក្ខរណីដោយព្រះហស្តក្នុងផ្ទាំងសិលា សម្រេចដោយអំណាចទេវឫទ្ធិ និងមានទឹកពេញស្រះ ហើយក្រាបទូលឲ្យទ្រង់ជម្រះសំពត់បង្សុកូល បានរកផ្ទាំងសិលាធំមកដាក់ឲ្យទ្រង់បោកគក់តាមព្រះពុទ្ធតម្រិះ ។

ព្រះមានព្រះភាគ ទ្រង់ជម្រះរហូតអស់ក្លិនអសុក (ក្លិនសាកសពដែលស្អុយ ) ហើយទ្រង់ព្រះតម្រិះនឹងរកទីហាលសំពត់បង្សុកូល ។ រុក្ខទេវតាដែលស្ថិតនៅដើមថ្ងាន់ក៏បង្អោនមែកចុះមកថ្វាយ ឲ្យទ្រង់ហាលសំពត់បង្សុកូលចីវរនោះហើយព្រះអង្គនឹងទ្រង់បត់សំពត់ ព្រះឥន្ទ្រទ្រង់លើកផ្ទាំងសិលាមកថ្វាយ ។ លុះព្រឹកស្អែក ឧរុវេលកស្សបៈទៅគាល់ព្រះមានព្រះភាគមើលឃើញស្រះទឹក ផ្ទាំងសិលា ២ ផ្ទាំង និងមែកថ្ងាន់បង្អោនចុះមក ទើបនឹកប្លែកក្នុងចិត្ត ដែលវត្ថុទាំងនេះមិនធ្លាប់មានពីមុនមក ទើបទូលសួរដល់វត្ថុផ្សេងៗ ទាំងនោះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ប្រាប់ឲ្យដឹងសព្វគ្រប់ ។

ឧរុវេលកស្សបៈស្តាប់ហើយស្ងួតចិត្តត្រិះរិះថា ព្រះមហាសមណៈ

រូបនេះមានអានុភាពច្រើនក្រៃលែង សូម្បីព្រះឥន្ទ្រក៏ស្ដេចចុះមកធ្វើនាទីជាវេយ្យាវច្ចករ តែទោះបីជាយ៉ាងណា ក៏មិនមែនជាព្រះអរហន្តដូចខ្ញុំ ។

លុះថ្ងៃបន្ទាប់មក ជដិលកស្សបៈទៅទូលអារាធនាសោយព្រះក្រយាហារ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា ម្នាលកស្សបៈ អ្នកចូរទៅមុនចុះ តថាគតនឹងទៅតាមក្រោយ កាលទ្រង់បញ្ជូនឧរុវេលកស្សបៈទៅហើយ ទើបព្រះអង្គទ្រង់ហោះទៅនាំយកផ្លែព្រីងធំប្រចាំទ្វីប ក្នុងព្រៃហិមពាន្តមក ហើយស្ដេចទៅដល់រោងបូជាភ្លើងមុនឧរុវេលកស្សបៈ ។

លុះឧរុវេលកស្សបៈមកដល់រោងភ្លើង ទើបសួរថា ព្រះមហាសមណៈ និមន្តមកតាមផ្លូវណា បានជាដល់មុន ។ ព្រះសាស្ដាត្រាស់ប្រាប់ហេតុនៃការយាងមក ហើយត្រាស់ថា ម្នាលកស្សបៈ ផ្លែព្រីងធំប្រចាំទ្វីបនេះ មានពណ៌ ក្លិន រស ដែលមានឱជា បើអ្នកប្រាថ្នានឹងបរិភោគក៏អញ្ជើញចុះ ឧរុវេលកស្សបៈពិចារណាឃើញសេចក្ដីអស្ចារ្យដូចដែលមានមកហើយ ។

កាលព្រះសាស្ដាទ្រង់ឆាន់កត្តាហារហើយ ទើបទ្រង់ត្រឡប់មកគង់ក្នុងទីសម្នាក់ព្រៃដដែលដូចដើម ។ ស្អែកឡើងទៀត ព្រះមានព្រះភាគ

ទ្រង់ធ្វើឥទ្ធិបាដិហារិយ៍ ដើម្បីឲ្យជដិលបានឃើញភាពជាមហស្ចារ្យ ៤ ដងទៀត ក្រោយពីជដិលទៅទូលអារាធនាឲ្យទៅឆាន់កត្តាហារ ទ្រង់បញ្ជូនឧរុវេលកស្សបៈឲ្យទៅមុន ។ ចំណែកព្រះអង្គទ្រង់យាងហោះទៅនាំយកផ្លែស្វាយមកម្តង ទ្រង់នាំយកផ្លែកន្ទួតព្រៃមកម្តង ទ្រង់នាំយកក្រូចមកអំពីព្រៃហិមពាន្តមកម្តង ហើយស្តេចឡើងទៅឋានតាវត្តិង្ស ទ្រង់នាំយកបារិច្ឆត្តកព្រឹក្សមកម្តង ហើយស្តេចមកដល់រោងភ្លើងមុនឧរុវេលកស្សបៈរាល់ដង ។

ថ្ងៃមួយ ពួកជដិលពុះឧសដើម្បីបង្កាត់ភ្លើង តែមិនអាចពុះឧសឲ្យបែកបាន ទើបគិតថា បើដូច្នេះព្រោះឫទ្ធានុភាពរបស់មហាសមណៈពិត ។

ព្រះភគវាស្តេចមានព្រះតម្រាស់សួរ លុះទ្រង់ជ្រាបសេចក្តីនោះហើយត្រាស់ថា អ្នកទាំងឡាយចូរពុះឧសតាមសេចក្តីប្រាថ្នាចុះ ហើយពួកជដិល ក៏ចាប់ផ្តើមពុះឧសបែកបានតាមសេចក្តីត្រូវការ ។

សម័យមួយ ជដិលទាំង ៥០០ តាំងចិត្តនឹងបូជាភ្លើង បង្កាត់ភ្លើងដូចម្តេចក៏មិនឆេះ ទើបត្រឡប់គិតដល់ឫទ្ធិរបស់ព្រះសាស្តាដូចមុន ។

ព្រះសម្ពុទ្ធត្រាស់សួររហូតទ្រង់ជ្រាបសេចក្តីហើយ ទ្រង់អនុញ្ញាត

ឲ្យបន្កាត់ភ្លើងបាន ភ្លើងក៏ឆេះឡើងទាំង ៥០០ គំនរ ព្រមគ្នាក្នុងវេលាតែមួយ ។

ពេលបូជាភ្លើងស្រេចហើយ ពួកជដិលនឹងពន្លត់ភ្លើង ភ្លើងក៏មិនរលត់ ទើបគិតដល់ព្រះមានព្រះភាគទៀត ព្រះអង្គត្រាស់សួររឿងហើយក៏ទ្រង់អនុញ្ញាតឲ្យពន្លត់ភ្លើងអស់ទាំង ៥០០ គំនរ ។

ថ្ងៃមួយ **អាកាសធាតុរងា** ពួកជដិលនាំគ្នាចុះងូតទឹកក្នុង **ស្ទឹងនេរញ្ជរា** ព្រះមុនីទ្រង់មានព្រះករុណាដល់ពួកជដិល ទ្រង់ពិចារណាថា កាលពួកជដិលឡើងពីទឹកហើយនឹងរងា ទើបទ្រង់និម្មិតចង្ក្រានប្រមាណ ៥០០ មានភ្លើងឆេះ ថែមទាំងតាំងទុកក្នុងទីជិតកំពង់ និងទីឡើងអំពីស្ទឹង ។ គ្រាជដិលទាំងឡាយឡើងអំពីស្ទឹងមករងាខ្លាំង បានបបួលគ្នាចូលទៅអាំងភ្លើង តាមចង្ក្រានទាំងនោះ ហើយនាំគ្នាសន្និដ្ឋានថា មុខជាព្រះសមណគោតមនិម្មិតទុកឲ្យជាពិតប្រាកដ ចាត់ទុកថា គួរឲ្យអស្ចារ្យក្រៃលែងណាស់ ។

ថ្ងៃមួយទៀត មហាមេឃតាំងឡើងក្នុងវេលាដែលមិនមែនជារដូវភ្លៀង ហើយបណ្តាលឲ្យភ្លៀងធ្លាក់ចុះមកជាច្រើន ក្រសែទឹកមាន

អន្ទង់ធំហូរលិចទៅក្នុងស្ថានទីទាំងពួងដោយជុំវិញបរិវេណនោះ ។ ធម្មតាព្រះមានព្រះភាគ ស្តេចស្ថិតនៅក្នុងប្រទេសណា សូម្បីទីនោះទឹកលិចតែទ្រង់អធិដ្ឋាន មិនឲ្យទឹកលិចចូលទៅក្នុងស្ថានទីនោះបាន ។

ហើយក្នុងគ្រាដែលភ្លៀងធ្លាក់ធំ ព្រះអង្គទ្រង់ព្រះតម្រិះថា តថាគតនឹងញ៉ាំងទឹកនោះឲ្យខ្ពស់ឡើង ពេញប្រាំងទៅក្នុងទិសដោយជុំវិញខ្លួនក្នុងទីកណ្តាលនោះ នឹងមានផ្ទៃភូមិភាគរាបស្មើជាប្រក្រតី តថាគតនឹងចង្ក្រមនៅទីនោះ ហើយទ្រង់អធិដ្ឋាន បណ្តាលឲ្យដូចជាពុទ្ធតម្រិះនោះគ្រប់ប្រការ ។

ចំណែកជដិលឧរុវេលកស្សបគិតថា ទឹកនឹងលិចព្រះមហាសមណៈឬមិនលិចហ្ន៎ ឬថានឹងគេចទៅកាន់ប្រទេសដទៃ ទើបជិះទូករួមជាមួយពួកជដិល ប្រញាប់អុំទូកទៅមើលដោយរហ័ស ទៅដល់ទីដែលព្រះពុទ្ធអង្គទ្រង់ស្ថិតនៅ ឃើញទឹកឡើងខ្ពស់ជាកំផែងព័ទ្ធជុំវិញ ហើយឃើញព្រះមានព្រះភាគស្តេចចង្ក្រមនៅលើផ្ទៃដីមិនមានទឹកឡើយ ទើបបន្លឺស្រែកហៅ ។

ព្រះមានព្រះភាគទ្រង់ត្រាស់តបថា ម្នាលកស្សបៈ តថាគតនៅ

ទីនេះ ហើយស្តេចហោះឡើងលើអាកាស និងអណ្តែតចុះកាន់ទូករបស់ពួកជដិល ទើបឧរុវេលកស្សបៈគិតថា ព្រះសមណគោតមនេះមានឫទ្ធិច្រើនក្រៃលែងណាស់ ទោះបីមានតេជានុភាពច្រើនដូច្នោះក៏ពិត តែមិនមែនជាព្រះអរហន្ត ដូចយើងដែរ ។

ពិតណាស់រាប់តាំងពីព្រះមានព្រះភាគជាម្ចាស់ស្តេចចេញចាកព្រៃឥសិបតនមិគទាយវ័នជិតក្រុងពារាណសី ក្នុងថ្ងៃមួយរោចខែកត្តិកមកគង់ប្រថាប់នៅឯឧរុវេលាប្រទេស រហូតដល់ថ្ងៃពេញបូរមីខែបុស្សជាវេលាពីរខែ ទ្រង់សម្តែងឥទ្ធិបាដិហារិយ៍ទូន្មានឧរុវេលកស្សបៈដោយប្រការច្រើនយ៉ាង ។ សូម្បីដូច្នោះ ឧរុវេលកស្សបៈក៏នៅតែមានចិត្តគិតក្រអឺតក្រទម ប្រកាន់ខ្លួនថា ជាព្រះអរហន្ត ព្រោះមានទិដ្ឋិដ៏ខ្លាំងក្លា ព្រះពុទ្ធអង្គទ្រង់ពិចារណានឹងធ្វើឲ្យឧរុវេលកស្សបៈកើតមានចិត្តគិតសង្វេគខ្លួនឯង ទើបត្រាស់ថា ម្នាលកស្សបៈ ខ្លួនអ្នកនៅមិនទាន់បានជាព្រះអរហន្តទេ ទាំងផ្លូវបដិបត្តិរបស់អ្នកនៅឆ្ងាយ មិនមែនជាផ្លូវមគ្គផលឯណា ហេតុអ្វីហ្ន៎ ទើបអ្នកប្រកាន់ខ្លួនថាជាព្រះអរហន្តបោកប្រាសខ្លួនឯង ទាំងដែលខ្លួនឯងក៏មិនដឹងខ្លួនថា បានសម្រេចមោក្ខធម៌ឯណា

នីមួយឡើយ និងបោកប្រាសអ្នកដទៃថា ខ្លួនជាព្រះអរហន្តទៀត ម្នាលកស្សបៈដល់ពេលដែលគួរសោរកាពខ្លួនឯងហើយថា អ្នកនៅមិនទាន់បានជាព្រះអរហន្តទេ ទាំងនៅមិនទាន់បានបដិបត្តិធម៌ ដើម្បីជាព្រះអរហន្តទៀតផង ម្នាលកស្សបៈ អ្នកនឹងបានជាព្រះអរហន្ត ក្នុងកាលមិនយូរឡើយ ។

កាលឧរុវេលកស្សបៈស្តាប់ពុទ្ធវាទហើយ ទើបដឹងខ្លួន ខ្មាសអៀន ឱនសិរសាចុះទៀបព្រះយុគលបាទ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមបព្វជ្ជាឧបសម្បទាក្នុងសម្នាក់របស់ព្រះអង្គ ហើយសូមដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាសរណៈ គឺជាទីពឹងទីរឭក ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលកស្សបៈ ខ្លួនអ្នកជាអាចារ្យធំ ជាប្រធានរបស់ពួកជដិល ៥០០ នាក់ ចូរចង្អុលបង្ហាញឲ្យពួកជដិលបរិវារ រីករាយត្រេកអរព្រមគ្នាសិន ហើយតថាគតព្រមឲ្យបព្វជ្ជាឧបសម្បទាបាន ។

ឧរុវេលកស្សបៈ ក្រាបថ្វាយបង្គំលាមកកាន់អាស្រមរបស់ខ្លួនវិញ ហើយប្រាប់ពួកជដិល ដែលជាសិស្សឲ្យដឹងបំណងរបស់ខ្លួន ។

សិស្សគ្រប់គ្នាក៏រីករាយត្រេកអរព្រមព្រៀងគ្នានឹងបព្វជ្ជាឧបសម្បទាក្នុងពុទ្ធសម្នាក់ ហើយជដិលទាំងឡាយ បានបបួលគ្នាបណ្តែតគ្រឿងបរិក្ខារ និងគ្រឿងតាក់តែងសក់ ផ្នួងសក់ សម្រែក ជងរែក គ្រឿងបូជាភ្លើង ចុះក្នុងស្ទឹងទាល់តែអស់ ។

កាលដែលពួកជដិល នាំគ្នាបណ្តែតគ្រឿងបរិក្ខាររបស់ខ្លួន ដោយពិចារណាឃើញលទ្ធិរបស់ខ្លួនមិនមានខ្លឹមសារ កើតសេចក្តីតក់ស្លុតក្នុងការបដិបត្តិដែលមិនត្រឹមត្រូវ ទើបលះបង់លទ្ធិរបស់ពួកខ្លួនចេញហើយនាំគ្នាចូលគាល់ព្រះបរមគ្រូ ថ្វាយអភិវាទព្រះយុគលបាទ ព្រមទាំងទូលសូមបព្វជ្ជាឧបសម្បទា ។

ព្រះមានព្រះភាគទ្រង់ព្រះករុណា ប្រោសប្រទានការឧបសម្បទាឲ្យដោយវិធី **ឯហិភិក្ខុឧបសម្បទា** ដោយព្រះអង្គត្រាស់ថា

អ្នកចូរមកជាភិក្ខុចុះ ធម៌ដែលតថាគតសម្តែងល្អហើយ អ្នកចូរប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីធ្វើទីបំផុតទុក្ខដោយប្រពៃចុះ ។ ទ្រង់ត្រាស់ត្រឹមប៉ុណ្ណោះ រាប់ថាបួសបានជាភិក្ខុហើយ ការបួសដោយវិធីនេះ ហៅថាឯហិភិក្ខុឧបសម្បទា ជាវិធីបួសដែលប្រើបានតែចំពោះព្រះមុនីប៉ុណ្ណោះ។

ឥទ្ធិបាដិហារិយ៍ដែលព្រះមានព្រះភាគ ទ្រង់ប្រើសម្រាប់ទូន្មាន ឧរុវេលកស្សបត្ថេរ និងពួកបរិវាររហូតទ្រង់ឈ្នះមានទាំងអស់ប្រមាណ ៣ ពាន់ ៥ រយយ៉ាង ដែលរាប់រួមទាំងបាដិហារិយ៍ទ្រង់ទូន្មានស្តេចនាគផង សម័យតមក នទីកស្សបតាបស ដែលជាប្អូនទី ១ ឃើញគ្រឿងបរិក្ខារទាំងពួងអណ្តែតទឹកមក ចំណាំបានធ្វើឲ្យគិតថា ក្រែងអន្តរាយនឹងមានដល់បងប្រុស ទើបប្រើតាបស ដែលជាសិស្សទៅស៊ើបមើលដឹងហេតុហើយ នទីកស្សបៈនាំតាបសជាសិស្សទាំង ៣០០ មកកាន់សម្នាក់របស់ឧរុវេលកស្សបៈ សួរហេតុមើល លុះដឹងសេចក្តីហើយក៏ជ្រះថ្លា ហើយបបួលគ្នាបណ្តែតគ្រឿងបរិក្ខាររបស់តាបសទៅក្នុងស្ទឹងនោះ នាំគ្នាចូលគាល់ក្រាបទូល សូមបព្វជ្ជាឧបសម្បទាចំពោះព្រះមុនីជាម្ចាស់ ។

ព្រះមានព្រះភាគ ទ្រង់ព្រះករុណាប្រោសប្រទានការឧបសម្បទាដោយឯហិភិក្ខុឧបសម្បទា ដូចគ្នាគ្រប់រូប ដូចពួកជដិលដំបូង ។ចំណែកគយាកស្សបតាបសដែលជាប្អូនពៅ ឃើញគ្រឿងបរិក្ខាររបស់បងប្រុសអណ្តែតទឹកមកក៏ចាំបាន ហើយមានការគិតដូចនទីកស្សបៈ បាននាំ

តាបសជាបរិវារ ២០០ ទៅកាន់សម្នាក់របស់ឧរុវេលកស្សបៈ កាលសាកសួរដឹងសេចក្តីពិតសព្វគ្រប់ហើយ ក៏កើតសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ទើបបបួលគ្នាបណ្តែតបរិក្ខារទាំងអស់របស់ជដិលចុះទៅក្នុងស្ទឹង ហើយព្រមទៅគាល់ព្រះសាស្តា ក្រាបទូលសូមឧបសម្បទាអំពីព្រះសាស្តាៗ ទ្រង់អនុញ្ញាតការឧបសម្បទា ដល់ជដិលទាំងឡាយដោយវិធីឯហិភិក្ខុឧបសម្បទាដូចឧរុវេលកស្សបៈគ្រប់យ៉ាង ។

ភិក្ខុទាំងឡាយ មានបរិក្ខារ គឺបាត្រ និងចីវរជារបស់សម្រេចមកដោយបុញ្ញឫទ្ធិ ព្រោះលោកទាំងនោះធ្លាប់ធ្វើចីវរទានទុកក្នុងអតីតជាតិ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់នាំភិក្ខុទាំង ១០០៣ រូបនោះ ទៅកាន់គយាសីសប្រទេស ហើយគង់លើផ្ទាំងសិលា ទ្រង់អាវជ្ជនាការ គឺទ្រង់មានការរលឹកមើលថា ធម៌ទេសនាណា ទើបសមគួរដល់អធ្យាស្រ័យនិងជាទីសប្បាយ របស់ភិក្ខុទាំងឡាយនេះ ក៏ទ្រង់ឃើញថា ពួកភិក្ខុទាំងនេះបានជាជដិលបូជាភ្លើង គួរតែតថាគតនឹងសម្តែងនូវភពទាំង ៣ គឺកាមភព រូបភព និងអរូបភព ឲ្យជារោងភ្លើងដែលកំពុងឆេះសន្ធោសន្ធៅឲ្យប្រាកដដល់ភិក្ខុទាំងឡាយ ហើយទើបទ្រង់សម្តែងអាទិត្តបរិយាយសូត្រ

( សូត្រដែលទ្រង់សម្តែងប្រៀបដោយរបស់ក្តៅ ) តាមដែលប្រាកដនៅក្នុងបាលី **គម្ពីរទីឃនិកាយ មហាវគ្គ** សេចក្តីក្នុង **អាទិត្តបរិយាយសូត្រ** ដោយសង្ខេបថា ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងជារបស់ក្តៅ វត្ថុទាំងពួងបានដល់អ្វី ហើយក្តៅដោយសារអ្វី ។

វត្ថុទាំងពួង បានដល់ អាយតនៈខាងក្នុង ៦ គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត និងអាយតនៈខាងក្រៅ ៦ គឺរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ( សម្ផស្ស ) ធម្មារម្មណ៍ និងមានវិញ្ញាណសម្ផស្ស វេទនាជាអ្នកសោយអារម្មណ៍ ដឹងសុខទុក្ខ ។

ក្តៅដោយភ្លើង គឺរាគៈ ទោសៈ មោហៈ ជាតិ ជរា ព្យាធិ មរណៈ សោកៈ បរិទេវៈ ( ការរៀបរាប់ដោយខូចចិត្ត, ការទួញយំ ) ទុក្ខ ទោមនស្ស ឧបាយាសៈ ( ការក្រៀមក្រំចិត្ត ) ។ ក្នុងរឿងនេះ ព្រះអរិយសាវកឃើញថា ជាភ្លើងដុតបំផ្លាញឆេះរោល ចាប់ផ្តើមពីបដិសន្ធិមក ទើបកើតសេចក្តីនឿយណាយក្នុងវត្ថុទាំងនេះ ។

កាលព្រះសាស្តា ទ្រង់ត្រាស់ទេសនា ភិក្ខុទាំងឡាយពិចារណាតាមសេចក្តីពិត ចិត្តរបស់ភិក្ខុទាំងនោះ ក៏រួចផុតចាកអាសវកិលេស

ទាំងអស់ មិនប្រកាន់មាំដោយឧបាទាន សម្រេចជាព្រះអរហន្ត ដល់ព្រម ដោយបដិសម្ភិទា ៤ ប្រការ ។

ការផ្សាយព្រះពុទ្ធសាសនាក្នុងដែនមគធៈ ព្រះឧរុវេលកស្សបៈ បានជាកម្លាំងដ៏សំខាន់របស់ព្រះមានព្រះភាគជាម្ចាស់ ដែលធ្វើឲ្យអ្នកស្រុកមគធៈ ព្រមទទួលកាន់ព្រះពុទ្ធសាសនាដោយងាយឡើង ដូចមានរឿងនៅក្នុងបាលី **គម្ពីរមហាវគ្គ ព្រះវិនយបិដក** រឿងពិម្ពិសារសមាគម និងដំណើរស្តេចយាងចូលកាន់ក្រុងរាជគ្រឹះ ។

ព្រះមានព្រះភាគ ទ្រង់សម្រាកនៅក្នុងជនបទគយាសីសៈល្មមសមគួរដល់ព្រះអធ្យាស្រ័យហើយ ទ្រង់នាំព្រះអរហន្តសាវក ១០០៣ រូប ស្តេចចេញចាកជនបទគយាសីសៈទៅកាន់លដ្ឋិវន គឺចម្ការត្នោតជំទង់ ដែលនៅជិតក្រុងរាជគ្រឹះមហានគរ ហើយទ្រង់គង់ប្រថាប់នៅឯចម្ការត្នោតជំទង់នោះ ដោយព្រះអង្គមានព្រះបំណងនឹងទ្រង់ដោះចេញនូវពាក្យបេ្តជ្ញារបស់ព្រះបាទពិម្ពិសារបរមក្សត្រ ដែលទ្រង់ធ្វើទុកចំពោះព្រះអង្គ មុននឹងបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះ ។

ព្រះបាទពិម្ពិសារបរមក្សត្រនៃដែនមគធៈ ទ្រង់ជ្រាបដំណឹងថា

ព្រះសមណគោតមស្ដេចនាំភិក្ខុទាំងឡាយ មកគង់ប្រថាប់នៅក្នុងឧទ្យានត្នោតជុំទង់ ទើបនាំរាជបរិវារមួយសែនពីរម៉ឺននាក់ ព្រមដោយពួកព្រាហ្មណ៍ និងគហបតីរួមជាមួយផង ស្ដេចចេញទៅចូលគាល់ព្រះសម្ពុទ្ធជាម្ចាស់ ក្នុងស្ថានទីដែលប្រថាប់គង់នោះ ។

តែពួករាជបរិវារ ពួកព្រាហ្មណ៍ និងគហបតីទាំងអស់នោះ នាំគ្នាសម្ដែងសេចក្ដីគោរពខ្លះ មិនគោរពខ្លះ មានកិរិយាអាការដែលមិនមានរបៀប ហើយពេលបែងចែកជាចំណែកៗ ប្រមាណជា ១២ ចំណែក អាការរបស់រាជបរិវារទាំងនោះ ខណៈចូលគាល់ព្រះមានព្រះភាគ មានអាការផ្សេងៗ ដែលមិនគួរឲ្យមើល ។

កាលទៅដល់ ពួកអ្នកដែលមានកិរិយាសុភាពក៏បានថ្វាយបង្គំខ្លះ ប្រណម្យអញ្ជលីខ្លះ ពួកខ្លះដែលមិនជ្រះថ្លាក៏ត្រឹមតែពោលវាចាប្រាស្រ័យជាមួយខ្លះ ប្រកាសឈ្មោះ និងគោត្តរបស់ខ្លួន ពួកខ្លះនៅស្ងៀមមិនសម្ដែងអាការឡើងចុះអ្វីៗ ឡើយ ។

ព្រះមានព្រះភាគ ទ្រង់ទតឃើញកិរិយាអាការរបស់រាជបរិវារទាំងនោះ មានសេចក្ដីក្រអឺតក្រទម នៅមិនទាន់សមគួរនឹងទទួលស្ដាប់

ព្រះធម្មទេសនាបាន គឺមនុស្សទាំងនេះមានសេចក្តីសង្ស័យថា ព្រះតថាគត ឬឧរុវេលកស្សបត្ថេរ អ្នកណាជាអ្នកមានអានុភាពច្រើនជាង សមគួរតែតថាគតនឹងដោះសេចក្តីសង្ស័យក្នុងរឿងនេះជាមុន ។

ព្រះមានព្រះភាគ ទ្រង់ពិចារណាឃើញហេតុនេះហើយ ទ្រង់ត្រាស់សួរដល់ព្រះឧរុវេលកស្សបត្ថេរឲ្យបានឮគ្រប់គ្នា ដែលជាសញ្ញាប្រាប់ឲ្យព្រះឧរុវេលកស្សបៈ ជួយកាត់សេចក្តីសង្ស័យមហាជនទាំងនោះថា

ម្នាលកស្សបៈ ព្រោះហេតុអ្វី ទើបអ្នកលះបង់លទ្ធិពីដើមរបស់អ្នកហើយមកបួសជាសាវករបស់តថាគតវិញ ។ ព្រះឧរុវេលកស្សបៈ ក្រោកឡើងក្រាបថ្វាយបង្គំព្រះសាស្តា ដោយបញ្ចង្គប្រតិស្ឋាន ដោយកិរិយាទន់ភ្លន់រៀបរយបីដង មានអង្គ ៥ បានដល់អវយវៈទាំង ៥ យ៉ាង គឺបាតដៃទាំងពីរ ជង្គង់ទាំងពីរ និងក្បាលមួយក្រាបចុះលើផែនដី ហើយហោះឡើងទៅក្នុងអាកាសខ្ពស់ប្រមាណស្មើដើមត្នោត ហើយក៏ត្រឡប់ចុះមកក្រាបថ្វាយបង្គំព្រះយុគលបាទ បានក្រាបទូលដោយសំឡេងខ្លាំងៗថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុដែលខ្ញុំព្រះអង្គ លះបង់លទ្ធិពីដើមចេញមកបួសជាសាវករបស់ព្រះអង្គ ព្រោះបានឃើញផ្លូវរបស់ព្រះអង្គ

ជាផ្លូវនៃសន្តិសុខ មិនមានកិលេសជាគ្រឿងរារាំងធ្វើឲ្យកើតទុក្ខ មិនមានកង្វល់មកពាក់ព័ន្ធ មិនមែនជាធម៌ដែលជឿតាមគ្នា តែជាគុណដែលប្រាកដដល់ចិត្តខ្ញុំព្រះអង្គ ទើបខ្ញុំព្រះអង្គលះបង់ការបូជាភ្លើងចោល ។

លុះលោកពោលដូច្នេះចប់ហើយ បានប្រកាសតទៅថា ព្រះអង្គជាបរមសាស្តារបស់ខ្ញុំព្រះអង្គៗ ជាសាវករបស់ព្រះអង្គ ហើយត្រឡប់ហោះឡើងទៅលើអាកាសទៀត ដោយមានកម្ពស់ពីរជួរត្នោត ហើយត្រឡប់ចុះមកថ្វាយបង្គំព្រះយុគលបាទ ព្រមទាំងប្រកាសសម្តែងខ្លួនថាជាសាវករបស់ព្រះមានព្រះភាគ ដូចមុនទៀត ។

ការហោះឡើងទៅកាន់អាកាស និងត្រឡប់មកថ្វាយបង្គំព្រះយុគលបាទ ទាំងពោលប្រកាសដូច្នោះ ព្រះឧរុវេលកស្សបៈ លោកធ្វើអស់ ៧ ដង ដោយរាប់រួមកម្ពស់នៃការហោះគ្រាចុងក្រោយប្រមាណ ៧ ជួរត្នោតលៃ ។

បរិស័ទទាំងអស់ដែលប្រជុំគ្នានោះ អស់សេចក្តីសង្ស័យ ស្រាយនូវការក្រអឺតក្រទម ចិត្តក៏ទន់ភ្លន់ ព្រមទាំងបានស្តាប់ព្រះធម៌ទេសនាតទៅប្រៀបដូចភាជនៈដែលកខ្វក់ស្មោកគ្រោកត្រូវខាត់ពណ៌ តុបតែងយ៉ាងល្អ

សមគួរនឹងជាក់របស់មានតម្លៃបានដូច្នោះ នេះជាពុទ្ធវិធីដោះស្រាយបញ្ហា ចំពោះមុខ ដោយទ្រង់ធ្វើឲ្យជនទាំងពួងប្រាកដក្នុងចិត្តថា ព្រះពុទ្ធទ្រង់ប្រសើរជាងឧរុវេលកស្សបត្ថេរ ។ បន្ទាប់មក ព្រះមានព្រះភាគចាប់ផ្តើមដុសខាត់ចិត្តរបស់អ្នកនគររាជគ្រឹះ មានព្រះបាទពិម្ពិសារជាប្រធានឲ្យស្អាតដោយគ្រឿងខាត់ គឺធម្មៈ ដោយព្រះអង្គទ្រង់លើកអនុបុព្វីកថាមកសម្តែង ។

កាលទ្រង់ឃើញថា ចិត្តថាស្អាតហើយ ទើបទ្រង់សម្តែងអរិយសច្ច ៤ បានដល់ ***ទុក្ខ*** គឺសភាពដែលតាំងនៅមិនបាន ***សមុទយៈ*** គឺហេតុឲ្យកើតទុក្ខ ***និរោធ*** គឺការរំលត់ទុក្ខ និង ***មគ្គ*** គឺផ្លូវបដិបត្តិឲ្យបានដល់ទីរំលត់ទុក្ខ ។ ចំនួនបរិស័ទដែលមានទាំងអស់ ១២ ចំណែក ( ១២០០០០ នាក់ ) មានលទ្ធផលថា ១១ ចំណែកបានធម្មចក្ខុ គឺជាព្រះអរិយបុគ្គលក្នុងព្រះពុទ្ធសាសនា លោកហៅបុគ្គលបានសម្រេចជាអរិយៈនេះថា ព្រះសោតាបន្ន មួយចំណែកទៀតតាំងនៅក្នុងត្រៃសរណគមន៍ គឺដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃថាជាទីពឹង ទីរឭក ជាឧបាសក ឧបាសិកា ។

ព្រះបាទពិម្ពិសារជាប្រធាន ក៏ទ្រង់បានជាសោតាបន្ន ទ្រង់ពោល

សរសើរព្រះធម៌ទេសនា និងបានថ្វាយឧទ្យានវេឡុវ័ន ទុកជាវត្តដំបូងក្នុងព្រះពុទ្ធសាសនា ។

ផលដែលកើតមានដល់មហាជនក្នុងនគររាជគ្រឹះ មានព្រះបាទពិម្ពិសារជាប្រធាន ក្នុងគ្រានោះ ឧរុវេលកស្សបត្ថេរជាកម្លាំងសំខាន់ ដែលជួយដឹកនាំចិត្តឲ្យកើតសេចក្តីទន់ភ្លន់បានដោយងាយ ដូចក្រមួនឃ្មុំដែលត្រូវភ្លើងឆេះរោល គឺជាផលដែលប្រកបដោយប្រយោជន៍ ដល់ព្រះពុទ្ធសាសនាយ៉ាងច្រើន ទើបធ្វើឲ្យព្រះសង្ឃសាវក ១០០០ រូបនោះ នាំគ្នាជាបរិវារជាប់តាមព្រះឧរុវេលកស្សបត្ថេរតទៅទៀត ។

ភិក្ខុ ១០០០ រូបនោះ តមកលោកបានកូនសិស្សម្នាក់ ១ រូបទៀត ទើបមានភិក្ខុរួមជា ២០០០ រូប ហើយកូនសិស្សទាំងនោះ មានកូនសិស្សម្នាក់ ១ រូបទៀត ដូច្នោះ កាលរួមទាំងអាចារ្យទាំងសិស្សជា ៣០០០ រូប ។

គុណ គឺសេចក្តីល្អរបស់ព្រះឧរុវេលកស្សបត្ថេរ ដែលជាអ្នកជួយប្រតិស្ឋានព្រះសាសនាក្នុងដែនមគធៈ ការជួយប្រកាសព្រះសាសនាដោយការជំនាញ និងការចេះយល់អធ្យាស្រ័យបរិស័ទ ទើបជាហេតុ

ធ្វើឲ្យលោកមានបរិវារច្រើនលើសជាង ៥០០ រូប ហើយមានមកថែមថ្មីទៀតជាច្រើនក្រៃលែង ។

ព្រោះដូច្នេះ ទើបព្រះមានជោគទ្រង់តែងតាំងព្រះឱរុវេលកស្សបៈ ទុកក្នុងឋានៈឯតទគ្គៈ បានដល់តំណែងដែលប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកមានបរិវារច្រើន ។

ដែលមានសេចក្តីនៅក្នុងព្រះបាលី គម្ពីរអង្គុត្តរនិកាយ ឯកនិបាត ដូចមានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ព្រះឱរុវេលកស្សបៈ ជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ជាសាវករបស់តថាគត ផ្នែកមានបរិវារច្រើន ។

ព្រះឱរុវេលកស្សបត្ថេរនេះ ក្រោយពីបានជាព្រះអរហន្តហើយ បានពោលគាថាដែលមានប្រាកដក្នុងបាលី គម្ពីរខុទ្ទកនិកាយ ថេរគាថា ដូចមានសេចក្តីថា ៖

ខ្ញុំឃើញបាដិហារ្យរបស់ព្រះគោតម ព្រះអង្គមានយសដល់ម៉្លោះ ក៏នៅតែមិនក្រាបសំពះ ព្រោះតែសេចក្តីច្រណែន និងសេចក្តីប្រកាន់ឲ្យភាន់ច្រឡំ ។

ព្រះសាស្តាជាសារថីរបស់ជន ទ្រង់ជ្រាបសេចក្តីត្រិះរិះរបស់ខ្ញុំហើយ បានដាស់តឿន លំដាប់នោះ ខ្ញុំមានសេចក្តីសង្វេគ និងសេចក្តីព្រឺរោម ដែលមិនធ្លាប់កើតៗ ហើយ ។

កាលខ្ញុំនៅជាជដិលក្នុងកាលមុន ការសម្រេចលាភសក្ការៈណាតិចតួច គ្រានោះ ខ្ញុំលះបង់នូវការសម្រេច គឺលាភសក្ការៈនោះហើយមកបួសក្នុងសាសនាព្រះជិនស្រី ។

កាលពីដើម ខ្ញុំជាអ្នកត្រេកអរ ដោយការបូជាធ្វើកាមធាតុជាប្រធាន កាលខាងក្រោយមក ខ្ញុំបានដករាគៈ ទោសៈ និងមោហៈចោលហើយ ។

ខ្ញុំដឹងខន្ធ ដែលធ្លាប់អាស្រ័យនៅក្នុងកាលពីដើម បានជម្រះទិព្វចក្ខុឲ្យស្អាត ជាអ្នកមានឫទ្ធិ ដឹងចិត្តអ្នកដទៃ ទាំងបានសម្រេចទិព្វសោត ។

មួយទៀត កុលបុត្រចេញចាកផ្ទះមកបួសក្នុងធម្មវិន័យ ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះខ្ញុំបានដល់ហើយតាមលំដាប់ ទាំងធ្វើឲ្យអស់សំយោជនធម៌ទាំងពួង ។

គំរូដ៏ល្អរបស់ព្រះឧរុវេលកស្សបត្ថេរ ដែលយើងគួរនឹងនាំមកបដិបត្តិនោះ គឺបុគ្គលដែលជាអ្នកគ្រប់គ្រង ឬជាប្រធានលើមនុស្សជាច្រើន ឬជាប្រធានគ្រួសារក៏ដោយ កាលដែលនឹងចងភ្ជាប់ចិត្តរបស់បរិវារឲ្យជាពួកមួយនឹងខ្លួនបាន ត្រូវអាស្រ័យគោលការណ៍ក្នុងភាពជាអ្នកចេះយកចិត្តបរិវារ ដោយការចេះសង្គ្រោះដោយអាមិស គឺរបស់ផ្សេងៗ ខ្លះដោយធម៌ គឺការណែនាំប្រៀនប្រដៅ ឬសន្ទនាធម៌ខ្លះ តាមសមគួរដល់សេចក្តីត្រូវការរបស់បរិវារ ដើម្បីឲ្យកើតមនុស្សសម្ពន្ធ ទើបអាចជាអ្នកប្រមូលផ្តុំ ឬអ្នកបញ្ជា និងជាទីរាប់អានរបស់បរិវារបានល្អ ដូចជាព្រះឧរុវេលកស្សបត្ថេរ លោកបានធ្វើជាគំរូ រហូតបានទទួលការសរសើរពីព្រះមានព្រះភាគថា ជាអ្នកមានបរិវារច្រើនជាទីបំផុត ក្នុងសម័យពុទ្ធកាលនេះ ដែលមានតែលោក ១ រូប ប៉ុណ្ណោះ ។

ជីវប្រវត្តិរបស់ព្រះឧរុវេលកស្សបត្ថេរ ដល់អវសានតាមកាលកំណត់របស់អាយុសង្ខារ ទើបរំលត់ខន្ធចូលកាន់ព្រះនិព្វាន ។l

( ជីវប្រវត្តិរបស់ព្រះឧរុវេលកស្សបត្ថេរ ចប់ )

8888888888888888888888888888888888888888888888888

# ✍ ជីវប្រវត្តិរបស់ព្រះកាឡុទាយិត្ថេរ ✍

## " ដែលជាឯតទគ្គៈផ្នែកអ្នកធ្វើឱ្យត្រកូលជ្រះថ្លា "

គុណសម្បត្តិពិសេសរបស់លោក គឺជាសហជាតជាមួយនឹងព្រះសាស្តាជាឯតទគ្គៈ ជាអសីតិមហាសាវកមួយរូបដោយលើកតម្កើងលោកតាមហេតុផល គឺជាសមណទូត និងមគ្គុទ្ទេសក៍ ថ្នាក់ខ្ពង់ខ្ពស់ ។

រឿងរ៉ាវទាក់ទងបុព្វកម្មរបស់ព្រះកាឡុទាយិត្ថេរ ក្នុង **អដ្ឋកថាវិសុទ្ធជនវិលាសិនី** និងក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** លោកបានពោលដល់ជីវប្រវត្តិរបស់លោកទុកថា ៖

កាលព្រះបទុមុត្តរសម្មាសម្ពុទ្ធជាម្ចាស់ ស្តេចបាននិមន្តដំណើរទៅក្នុងផ្លូវឆ្ងាយ ខ្ញុំបានថ្វាយផ្កាបទុម ផ្កាឧប្បល ផ្កាម្លិះ និងអាហារដល់ព្រះអង្គ ដោយសេចក្តីជ្រះថ្លា លុះព្រះអង្គសោយស្រេចហើយ ទ្រង់ក៏ទទួលផ្កាឈើរបស់ខ្ញុំព្រះអង្គ ទើបទ្រង់ព្យាករអនាគតកាលរបស់ខ្ញុំថា អ្នកដែលបូជាតថាគតដោយផ្កាឈើ និងអាហារក្នុងគ្រានេះ នឹងបានជាស្តេចនៃទេវតាទាំងឡាយ រហូតដល់ ១៨ ជាតិ ក្នុងពេលដែលជាទេវរាជ

នោះ នឹងមានផ្កាបទុម ផ្កាឧប្បល និងផ្កាម្ជិះមកពាក់ជាពិតាននៅលើអាកាស បានជាស្តេចចក្រពត្តិ ១៥ ជាតិ ទាំងបានជាព្រះរាជាគ្រប់គ្រងក្នុងប្រទេសនីមួយៗ រហូតដល់ ៥០០ ជាតិ ។

ក្នុងរយៈពេល ១ សែនកប្បខាងមុខ នឹងមានព្រះពុទ្ធមួយព្រះអង្គកើតក្នុងរាជវង្សរបស់ព្រះបាទឱក្កាករាជ ព្រះនាមថា **គោតម** ស្តេចឧប្បត្តិឡើងក្នុងលោក អ្នកដែលបូជាតថាគតក្នុងគ្រាឥឡូវនេះ នឹងបានបព្វជ្ជាក្នុងព្រះសាសនារបស់ព្រះគោតមនោះ ហើយនឹងអស់អាសវក្កិលេស បានទទួលតំណែងដ៏ប្រសើរបំផុត មានឈ្មោះថា **កាឡុទាយី** ។

ឥឡូវនេះ ខ្ញុំបានទម្លាយរាគៈ ទោសៈ មានះ មក្ខៈ និងអាសវៈទាំងពួងអស់ហើយ ព្រះពុទ្ធអង្គទ្រង់បានប្រោសប្រាណ ទ្រង់តែងតាំងខ្ញុំទុកក្នុងតំណែងដ៏ប្រសើរ ខ្ញុំបានសម្រេចបដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ ប្រការហើយ ។

ចំណែកក្នុង **អដ្ឋកថាមនោរថបូរណី** និងក្នុង **អដ្ឋកថាបរមត្ថទីបនី** បានពន្យល់សេចក្តីបាលី **កាឡុទាយីថេរគាថា គម្ពីរខុទ្ទកនិកាយ ថេរគាថា** បានពណ៌នាជីវប្រវត្តិក្នុងអតីតជាតិ និងបច្ចុប្បន្នជាតិរបស់កាឡុទាយិថា

ក្នុងសម័យព្រះបទុមុត្តរសម្មាសម្ពុទ្ធជាម្ចាស់ ព្រះកាឡុទាយិត្ថេរ បានកើតជាកុលបុត្តក្នុងក្រុងហង្សវតី ថ្ងៃមួយបានទៅស្តាប់ព្រះធម៌ទេសនា របស់ព្រះបទុមុត្តរសម្ពុទ្ធជាម្ចាស់ បានឃើញព្រះបទុមុត្តរសម្ពុទ្ធ ទ្រង់តែងតាំងភិក្ខុមួយរូបទុកក្នុងតំណែងឯតទគ្គៈ គឺជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកធ្វើត្រកូលឲ្យជ្រះថ្លា ។

លុះកុលបុត្ត (កាឡុទាយី) នោះពេញចិត្តក្នុងតំណែងដ៏ប្រសើរបំផុតក្នុងផ្នែកនោះ ទើបបានធ្វើបុណ្យកុសល ហើយតាំងមនោបណិធានឲ្យបានតំណែងនោះ ។

ពេលលោកអស់ជីវិតអំពីជាតិនោះហើយ បានវិលវល់កើតស្វាប់ សោយទិព្វសម្បត្តិ និងមនុស្សសម្បត្តិនៅក្នុងទេវលោក និងមនុស្សលោក រហូតអស់កាលដ៏យូរប្រមាណ ១ សែនកប្ប ។ លុះដល់ថ្ងៃដែលព្រះពោធិសត្វនៃយើងទាំងឡាយ ទ្រង់បានស្តេចចុះមកបដិសន្ធិក្នុងព្រះគភ៌របស់ព្រះនាងសិរិមហាមាយាពុទ្ធមាតានោះ កុលបុត្តកាឡុទាយីក៏បានចុះមកបដិសន្ធិក្នុងគភ៌ភរិយារបស់អាមាត្យ ក្នុងក្រុងកបិលពស្តុ ថ្ងៃជាមួយគ្នានឹងព្រះមានព្រះភាគនៃយើងទាំងឡាយនោះឯង ។

មង្គលសម័យ ដែលព្រះពោធិសត្វប្រសូតចាកគភ៌ព្រះមាតា ក្នុងព្រៃលុម្ពិនីវ័ននោះ កុលបុត្តឧទាយីក៏ប្រសូតចាកគភ៌មាតាព្រមគ្នា នឹងព្រះពោធិសត្វដែរ ព្រោះដូច្នោះ ទើបមាតាបិតានាំទារកដែលដេកនៅលើសំពត់ទុកូលពស្រ្តចូលទៅថ្វាយព្រះបាទសុទ្ធោទនៈ ដើម្បីប្រយោជន៍នឹងឲ្យបានជាបរិវាររបស់ព្រះបរមពោធិសត្វ ។

ពិតណាស់ក្នុងថ្ងៃដែលជាមហាអភិលក្ខិតកាល ខណៈដែលព្រះបរមពោធិសត្វប្រសូតចាកព្រះឧទរនោះ មានសហជាតិ គឺអ្នកដែលកើតឆ្នាំ ខែ ថ្ងៃជាមួយនឹងព្រះពោធិសត្វនោះមានទាំងអស់ ៧ ប្រការគឺ

ដើមមហាពោធិ៍ ១ ព្រះនាងពិម្ពាមាតារបស់ព្រះរាហុល ១ កំណប់ទ្រព្យទាំង ៤ រណ្តៅ ១ សេះកណ្ឌកៈ ១ នាយឆន្ន ១ កាឡុទាយី ១ ព្រះអានន្ទ ១ ។

ថ្ងៃដែលពួកញាតិតាំងឈ្មោះឲ្យបុត្តរបស់អាមាត្យ ពួកហោរាព្រឹទ្ធាចារ្យតាំងឈ្មោះឲ្យថា **ឧទាយី** ហេតុនៃការតាំងឈ្មោះឲ្យនេះ ព្រោះថា ក្នុងថ្ងៃនោះ មហាជនក្នុងព្រះនគរទាំងអស់ម្នាក់ៗ មានចិត្តព្រឺរោមឡើង ដោយបីតិបាមោជ្ជ តែបើទារកគង់នឹងមានសម្បុរជៅខ្មៅបន្តិច

ទើបមានពាក្យនាំមុខឈ្មោះថា កាឡ ប្រែថា ខ្មៅ និងរួមជាមួយឈ្មោះ ដើម ទើបជា កាឡុទាយី ។

កាឡុទាយីកុមារនោះ បានជាសម្លាញ់របស់ព្រះពោធិសត្វនៃយើងទាំងឡាយ រហូតមកដល់ចម្រើនវ័យ ។

តមកថ្ងៃមួយ ពេលព្រះពោធិសត្វស្តេចចេញមហាភិនេស្រ្កមណ៍ ទ្រង់បំពេញព្យាយាម រហូតដល់បានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ និងទ្រង់សម្តែងធម្មចក្កប្បវត្តនសូត្រ ដែលជាបឋមទេសនាហើយ ស្តេចយាងប្រោសវេនេយ្យសត្វទៅតាមលំដាប់ ស្តេចបានយាងទៅចាំវស្សា នៅឯវត្តវេឡុវ័នមហាវិហារ ក្នុងក្រុងរាជគ្រឹះ ជាវត្តដែលព្រះបាទពិម្ពិសារ ទ្រង់សាងថ្វាយជាវត្តដំបូង ។

ក្នុងកាលនោះ ព្រះបាទសុទ្ធោទនមហារាជពុទ្ធបិតា ទ្រង់ជ្រាបថា ព្រះសិទ្ធត្ថរាជបុត្រ បានត្រាស់ដឹងសព្វញ្ញុតញ្ញាណ ស្តេចយាងមកគង់ចាំព្រះវស្សាក្នុងវត្តវេឡុវ័ននាក្រុងរាជគ្រឹះ ទើបមានព្រះរាជឱង្ការត្រាស់បញ្ជាឲ្យអាមាត្យម្នាក់ជាមួយនឹងបរិវារ ១ ពាន់នាក់ទៅក្រាបទូលអារាធនាព្រះមានព្រះភាគឲ្យយាងត្រឡប់មកកាន់ក្រុងកបិលពស្តុ ។

អាមាត្យម្នាក់នោះ បាននាំបរិវារ ១ ពាន់នាក់ ទៅតាមព្រះរាជបញ្ជា ពេលធ្វើដំណើរទៅអស់ផ្លូវចម្ងាយ ៦០ យោជន៍ ក៏បានដល់វត្តវេឡុវ័ន មហាវិហារ ក្នុងពេលដែលអាមាត្យនាំបរិវារទៅដល់ ជាពេលដែល ព្រះមានព្រះភាគ ទ្រង់ប្រថាប់គង់នៅក្នុងកណ្តាលបរិស័ទ ត្រាស់ប្រទាន ព្រះធម៌ទេសនា ។

អាមាត្យនោះ លុះសម្តែងសេចក្តីគោរពហើយ ទើបអង្គុយនៅ ក្នុងទីបំផុតនៃបរិស័ទ ដោយគិតថា នឹងត្រូវបញ្ជូបរាជតម្រាស់ព្រះ បាទសុទ្ធោទនមហារាជសិន ហើយអង្គុយតាំងចិត្តស្តាប់ព្រះធម៌ទេសនា រហូតចប់ក៏បានសម្រេចជាព្រះអរហន្ត ព្រមទាំងបរិវារ ១ ពាន់នាក់នោះ ផងដែរ ហើយបានទទួលការឧបសម្បទាជាឯហិភិក្ខុ ទ្រទ្រង់នូវបាត្រ ចីវរ និងបរិក្ខារដែលកើតឡើងដោយអំណាចបុញ្ញឫទ្ធិ មានលក្ខណាការ ដូចព្រះមហាថេរៈមានវស្សាបាន ១០០ ដូច្នោះ បានជាព្រះអរហន្តសាវក ហើយ ក៏មិនបានក្រាបទូលឲ្យព្រះមានជោគ ទ្រង់ជ្រាបនូវព្រះរាជបញ្ជា របស់ពុទ្ធបិតា ដែលត្រាស់បញ្ជាមក ។

ព្រះបាទសុទ្ធោទនមហារាជទ្រង់រំពឹងថា ហេតុអ្វីទើបបុត្ររបស់

យើងមិនឃើញមក ដំណឹងល្អអាក្រក់ក៏មិនធ្លាប់បានដឹង អាមាត្យរបស់យើងក៏បាត់ទៅ ព្រះអង្គទ្រង់សម្រេចព្រះហឫទ័យបញ្ជូនអាមាត្យ និងបរិវារ ១ ពាន់នាក់ ទៅម្តងទៀត ។

អាមាត្យម្នាក់ដែលត្រូវបញ្ជូនទៅជាលើកទី២ក៏បានទទួលស្តាប់ធម៌ហើយក៏សម្រេចជាព្រះអរហន្ត ព្រមទាំងបរិវារ បានចេញបួសទៀត ក្នុងទីបំផុតក៏បាត់ដូចមុន ។ព្រះបាទសុទ្ធោទនមហារាជ ទ្រង់ដឹងថាអាមាត្យទី ២ បាត់ទៅ ទើបទ្រង់បញ្ជូនទៅទៀត ទ្រង់បញ្ជូនទៅទាំងអស់ ៩ នាក់ ម្នាក់ៗ មានបរិវារជាប់តាមមួយពាន់ រួម ៩ នាក់ បរិវារ ៩ ពាន់នាក់ ។

អាមាត្យទាំង ៩ នាក់ ជាមួយនឹងបរិវារ ៩ ពាន់នាក់ កាលបានសម្រេចធម៌ជាន់ខ្ពស់ជាព្រះអរហន្តហើយ មិនមានកិច្ចណាមួយនឹងក្រាបទូលអារាធនាព្រះមានព្រះភាគជាម្ចាស់ឡើយ ស្ងាត់ឈឹងទៅ ទាំងមិនបញ្ជូនដំណឹងឲ្យព្រះបាទសុទ្ធោទនមហារាជទ្រង់ជ្រាបផងទេ ។ ព្រះបាទសុទ្ធោទនមហារាជទ្រង់ត្រិះរិះ ដោយអាក់អន់ព្រះហឫទ័យថា ពួកអាមាត្យដែលយើងបញ្ជូនទៅមានចំនួនច្រើន មិនមាននរណាម្នាក់ដែលស្មោះត្រង់ចំពោះយើង មិនមាននរណាម្នាក់ក្លាហានក្រាបទូលឲ្យបុត្រ

របស់យើង យាងមកកាន់នគរកបិលពស្តុនេះសោះ ។

ទ្រង់ពិចារណាការបញ្ជូនបុគ្គលដទៃទៅ ជាការក្រែងព្រះហឫទ័យរបស់ព្រះបាទសុទ្ធោទនមហារាជ ដោយទ្រង់ខ្លាចថា គង់នឹងដូចក្នុងគ្រាមុនទៀត ជាហេតុធ្វើឲ្យទ្រង់ប្រើវិចារណញ្ញាណយ៉ាងខ្លាំងថា នឹងបញ្ជូនបុគ្គលណាទៅទើបបានផល ទ្រង់ពិចារណាសព្វគ្រប់ហើយ ទើបទ្រង់ឃើញថា កាឡុទាយីអាមាត្យតែម្នាក់ប៉ុណ្ណោះ ដែលជាមិត្តសម្លាញ់ជាមួយនឹងបុត្រយើង ហើយកាឡុទាយីអាមាត្យនោះ ជាអ្នកដែលស្មោះត្រង់ចំពោះយើង លុះទ្រង់ពិចារណាឃើញដូច្នោះហើយ ទ្រង់ត្រាស់ហៅកាឡុទាយីអាមាត្យចូលគាល់ ហើយមានព្រះរាជតម្រាស់ថា ម្នាលកាឡុទាយី អ្នកចូរនាំបរិវារ ១ ពាន់នាក់ ទៅរកបុត្ររបស់យើង ចូរនាំបុត្ររបស់យើងមកកាន់ក្រុងកបិលពស្តុនេះឲ្យបាន ។

កាឡុទាយីជាអាមាត្យទី ១០ ទទួលព្រះរាជឱង្ការហើយ ក្រាបបង្គំទូលសូមព្រះបរមរាជានុញ្ញាតថា បពិត្រព្រះអង្គជាសម្មតិទេព ខ្ញុំព្រះអង្គសូមព្រះរាជទានពរ ទ្រង់មេត្តាអនុញ្ញាតឲ្យខ្ញុំព្រះអង្គ មានឱកាសបានបព្វជ្ជា ដូចជាពួកអាមាត្យ និងបរិវារដែលទៅមុនហើយនោះចុះ ខ្ញុំព្រះ

អង្គសូមទទួលបញ្ជានឹងនាំព្រះរាជឱរសយាងត្រឡប់មកឲ្យបាន ។

ព្រះបាទសុទ្ធោទនៈត្រាស់ថា ម្នាលកាឡុទាយី អ្នកបព្វជ្ជា ឬធ្វើយ៉ាងណាតាមអធ្យាស្រ័យចុះ យើងមិនថាអ្វីទេ សូមឲ្យនាំព្រះឱរសាធិរាជរបស់យើងត្រឡប់មកឲ្យបាន ។ កាឡុទាយីអាមាត្យក្រាបបង្គំទូលទទួលព្រះរាជបញ្ជាថា បពិត្រព្រះសម្មតិទេព ព្រះករុណាថ្លៃវិសេស ហើយនាំបរិវារ ១ ពាន់នាក់ ធ្វើដំណើរចេញអំពីក្រុងកបិលពស្តុ ឆ្ពោះទៅកាន់ក្រុងរាជគ្រឹះ លុះទៅដល់ហើយ ក៏បានទទួលស្តាប់ព្រះធម៌ទេសនាអំពីព្រះមានព្រះភាគជាម្ចាស់ រហូតបានសម្រេចជាព្រះអរហន្ត ព្រមទាំងបរិវារ ១ ពាន់នាក់នោះផង ហើយបានទទួលព្រះពុទ្ធានុញ្ញាត បព្វជ្ជាឧបសម្បទាជាភិក្ខុ ក្នុងព្រះពុទ្ធសាសនាដោយវិធី **ឯហិភិក្ខុឧបសម្បទា** គឺព្រះមានព្រះភាគ ទ្រង់អនុញ្ញាតឲ្យឧបសម្បទាដោយព្រះអង្គឯង ។ ក្រោយពីឧបសម្បទាហើយ កាឡុទាយិត្ថេរពិចារណាដល់ហេតុការណ៍ដែលនឹងអារាធនាព្រះសម្ពុទ្ធថា កាលនេះមិនមែនជាកាលដែលព្រះមុនីស្តេចនឹងយាងទៅកាន់ក្រុងកបិលពស្តុព្រះនគររបស់ពុទ្ធបិតាទេ បើជិតដល់វស្សានរដូវមានដើមឈើ ក្នុងព្រៃចេញផ្កា ផ្លែព្រោងព្រាត នៅលើ

ដីមីដេវជាសទៅដោយស្មៅខ្ចីដ៏ស្រស់បំព្រង មើលម្តងហើយចង់មើលម្តងទៀត កាលនោះទើបសមគួរដល់ព្រះមានព្រះភាគនឹងស្តេចយាងទៅ ពិចារណាដល់ហេតុការណ៍នេះហើយ លោកក៏រង់ចាំកំណាត់រដូវកាលដែលមិនដល់វស្សានរដូវ (រដូវផ្កាឈើលូតលាស់)។លុះអស់ហេមន្តរដូវ លោកឃើញថា ជាកាលដ៏សមគួរស្តេចយាងហើយ ទើបក្រាបទូលពណ៌នាដំណើរផ្លូវដែលគួរឲ្យរីករាយ ដើម្បីនឹងឲ្យព្រះមានព្រះភាគស្តេចយាងត្រឡប់ទៅកាន់ក្រុងកបិលពស្តុ ដោយគាថា ១០ គាថា ដូចមានចារឹកនៅក្នុងបាលី **គម្ពីរខុទ្ទកនិកាយ ថេរគាថា** ថា

**នេវាតិសីតំ ន បនាតិឧណ្ហំ** ជាដើម សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន រដូវដែលមិនត្រជាក់ពេក មិនក្តៅពេក ជាសុខស្រួល គួរដើរទៅកាន់ផ្លូវឆ្ងាយបាន ពួកសក្យៈ និងពួកកោលិយ្យៈ សូមជួបព្រះអង្គដែលមានព្រះភក្ត្របែរត្រឡប់មកខាងក្រោយ កំពុងឆ្លងស្ទឹងរោហិណី ។ អ្នកស្រែភ្ជួរស្រែ ដោយសេចក្តីប្រាថ្នា ក៏ព្រោះពូជ ដោយសេចក្តីប្រាថ្នា ពួកឈ្មួញ អ្នករកទ្រព្យឆ្លងសមុទ្រ ដោយសេចក្តីប្រាថ្នា ។ ខ្ញុំព្រះអង្គឋិតនៅដោយសេចក្តីប្រាថ្នាណា សេចក្តីប្រាថ្នារបស់ខ្ញុំព្រះអង្គនោះ សូម

ឲ្យសម្រេច ។ ខ្ញុំព្រះអង្គជាបុត្រនៃព្រះពុទ្ធ ព្រះអង្គមិនមានបុគ្គលដទៃគ្របសង្កត់បាន ព្រះអង្គីរសមិនមានបុគ្គលដទៃប្រៀបបាន ប្រកបដោយតាទិគុណបពិត្រព្រះអង្គជាសក្យៈ ព្រះអង្គជាបិតានៃបិតារបស់ខ្ញុំព្រះអង្គបពិត្រព្រះគោតម ព្រះអង្គជាជីតារបស់ខ្ញុំព្រះអង្គដោយធម៌ ។

ម្យ៉ាងទៀត ការពណ៌នាមាគ៌ាដែលកាឡុទាយិត្ថេរក្រាបទូលដល់ព្រះមានព្រះភាគ ដើម្បីឲ្យស្តេចពុទ្ធដំណើរទៅកាន់ក្រុងកបិលពស្តុ ដែលរាប់ជាគាថាមានសំនួនដ៏ពីរោះត្រចៀកក្រៃលែងណាស់ ដូចមានចេសក្តីនៅក្នុង **គម្ពីរបឋមសម្ពោធិកថា** ដែលពណ៌នាសេចក្តីតាមព្រះគាថានៃ **គម្ពីរជិនមហានិទាន** មានសេចក្តីពីរោះក្រៃលែង ចូររកមើលផងចុះ ។

ការធ្វើនាទីជាសមណទូតរបស់កាឡុទាយិត្ថេរ ដើម្បីជួយឲ្យព្រះបាទសុទ្ធោទនមហារាជទ្រង់មានព្រះហឫទ័យរីករាយ ដែលអាស្រ័យព្រះមានព្រះភាគជាម្ចាស់ មានសម្តែងទុកក្នុង **គម្ពីរមនោរថបូរណី** និង **អដ្ឋកថាបរមត្ថទីបនី** តទៅថា ៖

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យអារាធនានោះហើយ ទ្រង់ជ្រាបថាឥឡូវនេះកាឡុទាយីមកពណ៌នាអំពីផ្លូវ ដើម្បីនឹងឲ្យតថាគតយាងទៅ

រដូវកាលនេះល្មមសមគួរហើយដល់តថាគត នឹងយាងទៅកាន់ក្រុងកបិលពស្តុ ទ្រង់កំណត់ដូច្នេះហើយ ព្រះអង្គព្រមទាំងភិក្ខុសង្ឃ ២ ម៉ឺនរូប មានយសបរិវារ ស្តេចយាងចេញអំពីក្រុងរាជគ្រឹះ ទ្រង់ពុទ្ធដំណើរទៅដោយស្រួល ទ្រង់សម្រាកតាមរោងក្នុងចន្លោះផ្លូវពេលយាងទៅបាន ១ យោជន៍ ប្រយោជន៍ដើម្បីប្រោសមហាជនតាមផ្លូវ ដែលយាងធ្វូងកាត់ទៅដោយលំដាប់ រហូតដល់ក្រុងកបិលពស្តុ ។

ចំណែកព្រះកាឡុទាយិត្ថេរ បានហោះទៅប្រាប់ដំណឹងដល់ព្រះបាទសុទ្ធោទនមហារាជជាមុនរាល់ថ្ងៃ បានឈរនៅលើអាកាសសម្តែងខ្លួនឲ្យប្រាកដដល់ព្រះបាទសុទ្ធោទនមហារាជៗ បានត្រាស់សួរថា អ្នកជានរណា ? មកពីណា ? ហេតុដែលត្រាស់សួរយ៉ាងនេះព្រោះចាំមិនបាននិងមិនធ្លាប់ឃើញភេទនេះពីមុនមក ។

គួរតែព្រះកាឡុទាយិត្ថេរថ្វាយព្រះពរឆ្លើយថា អាត្មាជាបុត្តរបស់អាមាត្យ ជាអ្នកដែលព្រះអង្គទ្រង់ប្រើឲ្យទៅក្រាបទូលអារាធនាព្រះពុទ្ធតែមិនថ្វាយព្រះពរដូច្នោះ ត្រឡប់ជាមានថេរវាចាថា សូមថ្វាយព្រះពរមហាបពិត្រ អាត្មាភាពជាបុត្តរបស់ព្រះពុទ្ធ ទ្រង់មិនមានវត្ថុណារារាំង

បានឡើយ ទ្រង់មានព្រះរស្មី ៦ ប្រការ ផ្សាយចេញពីព្រះវរកាយ រកបុគ្គលណាប្រៀបគ្មាន ទ្រង់មានព្រះហឫទ័យករុណា ។ មហាបពិត្រ ទ្រង់ជាព្រះបិតារបស់បិតាអាត្មាភាព ព្រោះដូច្នោះ ទើបមហាបពិត្រជាក្មេករបស់អាត្មាភាព ជាជម្មតាក្នុងលោក ។

លុះព្រះបាទសុទ្ធោទនមហារាជ ទ្រង់ស្តាប់វាចារបស់ព្រះថេរៈហើយ ទ្រង់យល់បានកើតសោមនស្សរីករាយយ៉ាងក្រៃលែង ទើបត្រាស់អារាធនាឲ្យចុះមកគង់លើបល្ល័ង្កដែលមានតម្លៃច្រើន ហើយចាត់ចែងរៀបចំភោជនាហារដាក់បាត្រប្រគេន ។

ព្រះកាឡុទាយិត្ថេរ ពេលទទួលប្រគេនបាត្រដាក់ភោជនាហារនោះ ហើយសម្តែងអាការដើម្បីនឹងថ្វាយព្រះពរលាទៅ ។

ព្រះបាទសុទ្ធោទនៈមានបន្ទូលថា លោកម្ចាស់ ព្រះមានព្រះភាគជាម្ចាស់នៅទីណា ? ព្រះកាឡុទាយិត្ថេរ បានថ្វាយព្រះពរថា ព្រះសម្ពុទ្ធជាម្ចាស់ ព្រមទាំងភិក្ខុសង្ឃ ២ ម៉ឺនរូប កំពុងស្តេចយាងមកតាមផ្លូវដើម្បីនឹងមកគាល់មហាបពិត្រ ។

ព្រះបាទសុទ្ធោទនមហារាជ លោកម្ចាស់ បើដូច្នោះ សូមលោក

ឆាន់អាហារនេះសិនចុះ ហើយសូមនាំអាហារដទៃទៅថ្វាយដល់ព្រះរាជបុត្រ ដែលជាព្រះឱរសរបស់ខ្ញុំក្នុងខាងក្រោយ ពេលបុត្តខ្ញុំនៅមិនទាន់មកដល់នគរនេះដរាបណា សូមលោកម្ចាស់មកនាំយកអាហារពីទីនេះទៅថ្វាយបុត្តខ្ញុំ ដរាបនោះចុះ ព្រះបាទសុទ្ធោទនមហារាជត្រាស់បវារណា ចំពោះព្រះកាឡុទាយិត្ថេរ ។

ព្រះកាឡុទាយិត្ថេរ ធ្វើភត្តកិច្ច គឺឆាន់ចង្ហាន់ក្នុងព្រះរាជនិវេសន៍របស់ព្រះបាទសុទ្ធោទនមហារាជនោះ លុះឆាន់ភត្តាហារស្រេចហើយបានសម្តែងធម៌ដល់ព្រះបាទសុទ្ធោទនមហារាជ និងរាជបរិវារទាំងអស់ធ្វើអ្នករាជវាំងទាំងអស់ ដែលមានព្រះបាទសុទ្ធោទនមហារាជជាប្រធានកើតសេចក្តីជ្រះថ្លាក្នុងព្រះរតនត្រ័យ មុនបានឃើញព្រះមានព្រះភាគជាម្ចាស់ ទាំងបានសម្តែងបាដិហារិយ៍ ដោយការអធិដ្ឋានឲ្យបាត្រដែលមានអាហារពេញនោះ អណ្តែតឡើងទៅក្នុងអាកាស ក្នុងទីចំពោះមុខមនុស្សជាច្រើន ហើយលោកហោះឡើងតាមទៅយកបាត្រនោះ យកទៅថ្វាយព្រះមានព្រះភាគជាម្ចាស់ បានធ្វើយ៉ាងនោះរាល់ថ្ងៃ ។

ព្រះមានព្រះភាគ ឆាន់ព្រះក្រយាហារដែលព្រះកាឡុទាយិត្ថេរ

នាំមកអំពីព្រះរាជនិវេសន៍រាល់ថ្ងៃ រាប់ពីថ្ងៃស្តេចពុទ្ធដំណើរដំបូងរហូតដល់ស្តេចយាងបាន ៦០ យោជន៍ ទើបដល់ក្រុងកបិលពស្តុ ។

ជាលើកដំបូង ក្រោយពីបានចេញសាងផ្នួសរហូតបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ព្រះអង្គបានយាងត្រឡប់មកកាន់ក្រុងកបិលពស្តុនេះ ដោយការក្រាបទូលអារាធនារបស់ព្រះកាឡុទាយិត្ថេរ ដែលជារាជទូតទី ១០ ព្រមដោយបរិវារ ១ ពាន់នាក់ បើរាប់រួមទាំងប្រធាន និងបរិវារទាំងអស់ដែលព្រះបាទសុទ្ធោទនមហារាជ ទ្រង់បញ្ជូនទៅក្នុងពេលដំបូងផង ក៏មានចំនួន ១ ម៉ឺន ១០ នាក់គត់ ។

តែសេចក្តីអង់អាចក្នុងការធ្វើនាទីជារាជទូត ឲ្យព្រះបាទសុទ្ធោទនមហារាជទាំងអស់នោះ ត្រូវលើកឲ្យដល់ព្រះកាឡុទាយិត្ថេរ ដែលជាអ្នកឆ្លាតក្នុងការក្រាបទូលអារាធនា ចាត់ទុកថាជាកំពូលអ្នកនាំផ្លូវ គឺជាអ្នកធ្វើនាទីនាំផ្លូវព្រះមានព្រះភាគទៀតដែរ ។

ទ្រង់ពុទ្ធដំណើរអំពីក្រុងរាជគ្រឹះ ដល់ក្រុងកបិលពស្តុ ព្រះអង្គយាងទៅបាន ១ ថ្ងៃ ១ យោជន៍ បានគង់សម្រាកក្នុងសាលាសម្នាក់ពេលយប់ ពេលយាងទៅអស់រយៈចម្ងាយផ្លូវ ១ យោជន៍ ចម្ងាយផ្លូវ

ទាំងអស់ ៦០ យោជន៍ ទើបទ្រង់ប្រើពេលវេលាទាំងអស់ ៦០ ថ្ងៃគត់ ។

ហេតុការណ៍ ដែលព្រះមានព្រះភាគជាម្ចាស់យាងទៅកាន់ក្រុងកបិលពស្តុ មានរឿងសម្តែងទុកនៅក្នុង **បឋមពោធិកថា** ក្នុង **អដ្ឋកថាវិសុទ្ធជនវិលាសិនី** និងក្នុង **អដ្ឋកថាតតិយសមន្តប្បាសាទិកា** នៃរឿង **រាហុលវត្ថុកថា** មានសេចក្តីថា ៖

ព្រះមានព្រះភាគ ព្រមដោយភិក្ខុសង្ឃប្រមាណ ២ ម៉ឺនរូបស្តេចចេញចាកវត្តវេឡុវ័នមហាវិហារក្រុងរាជគ្រឹះ ទៅដល់ក្រុងកបិលពស្តុហើយ ទ្រង់នាំព្រះសង្ឃទាំងអស់ចូលប្រថាប់ក្នុងនិគ្រោធារាម ដែលព្រះញាតិទាំងពីរខាងរួមគ្នាកសាងថ្វាយជាវត្តក្នុងព្រះពុទ្ធសាសនា ដែលតាំងនៅក្បែរមាត់ច្រាំងស្ទឹងរោហិណី ជាវត្តដែលមានរមណីយដ្ឋានសមគួរដល់ភិក្ខុសង្ឃចូលស្នាក់អាស្រ័យ ។

ហេតុការណ៍ ពេលព្រះអង្គស្តេចយាងមកដល់ក្រុងកបិលពស្តុបានទតឃើញការប្រកាន់ខ្លួន ដោយអំណាចខត្តិយមានះរបស់ពួកព្រះញាតិ មានប្រការផ្សេងៗ ដូចជាការតុបតែងពួករាជកុមារតូចៗ និងពួករាជកុមារី និងពួកអ្នកក្រុងឲ្យចេញមកទទួលខាងមុខ ចំណែកពួកខត្តិ-

យរាជជាធំនៅខាងក្រោយមិនសម្ដែងសេចក្ដីគោរពជាដើម នៅពេលដែលព្រះបាទសុទ្ធោទនមហារាជ ទ្រង់សម្ដែងសេចក្ដីគោរពជាដំបូង ពួកព្រះញាតិទើបអស់មានះ និងធ្វើសេចក្ដីគោរពគ្រប់គ្នា ។

ការប្រជុំរបស់ពួកព្រះញាតិ ក្នុងថ្ងៃទទួលសម្ដេចព្រះសាស្ដានោះ ចាត់ជាមហាសន្និបាតគឺការប្រជុំធំ និងជាមហាសមាគមរបស់ព្រះញាតិ ដើម្បីសម្ដែងបីតិរីករាយចំពោះព្រះមានព្រះភាគជាម្ចាស់ ព្រោះការចាកចេញទៅអស់ពេលវេលាដ៏យូរ ទំរាំនឹងបានមកជួបគ្នា សេចក្ដីត្រេកអរក្នុងចិត្ត រមែងកើតឡើងជាធម្មតា ដោយមានមនុស្សជាទីស្រឡាញ់មកជួបគ្នា ។

ព្រះអង្គមុននឹងទ្រង់សម្ដែងធម៌ប្រោសពួកព្រះញាតិបាន ទ្រង់សម្ដែងបាដិហារិយ៍ឲ្យបានឃើញគ្រប់គ្នា យ៉ាងមហស្ចារ្យ ដោយយាងឡើងទៅគង់លើអាកាស ហើយទ្រង់ធ្វើឲ្យភ្លៀងបោក្ខរព័ស្ស ធ្លាក់ចុះមកក្នុងមហាសមាគមរបស់ព្រះញាតិ ធ្វើឲ្យបានរីករាយចិត្តគ្រប់ៗ គ្នា ។

ភ្លៀងបោក្ខរព័ស្សនេះមានពណ៌ក្រហមដូចជើងព្រាប បុគ្គលណាប្រាថ្នាឲ្យទទឹក ទើបបុគ្គលនោះទទឹក បើមិនប្រាថ្នាឲ្យទទឹកក៏មិនទទឹក

គ្រាប់ភ្លៀងនេះរអិលរមៀលជ្រុះអំពីកាយ ដូចតំណក់ទឹកដែលធ្លាក់អំពីស្លឹកឈូក លុះធ្លាក់ហើយជ្រាបបាត់ទៅ មិនហូរជន់លិចដូចទឹកភ្លៀងធម្មតាទេ បន្ទាប់មកព្រះមានព្រះភាគ ទ្រង់សម្ដែងមហាវេស្សន្ដរជាតក ដែលមាននៅក្នុង **គម្ពីរខុទ្ទកនិកាយ មហានិបាតជាតក** ដោយទ្រង់នាំរឿងអតីតជាតកមកត្រាស់ប្រៀបធៀប ។

ក្នុងថ្ងៃ ដែលព្រះមានជោគសម្ដែងព្រះធម៌ចប់ហើយ មិនមាននរណាម្នាក់ទូលអារាធនាឲ្យឆាន់ចង្ហាន់ក្នុងថ្ងៃស្អែកឡើយ ដូច្នោះព្រឹកឡើង ព្រះបរមសាស្ដា ព្រមទាំងព្រះភិក្ខុសង្ឃជាច្រើន ស្ដេចចារិកចេញបិណ្ឌបាត តាមផ្លូវផ្សេងៗ គ្នា ទើបធ្វើឲ្យកើតកោលាហលវឹកវរឡើង ។

ម្យ៉ាងទៀត គម្ពីរវិសុទ្ធិមគ្គពោលដល់កិច្ចវត្តក្នុងការត្រាច់បិណ្ឌបាត ដែលព្រះពុទ្ធទាំងឡាយ និងភិក្ខុសង្ឃទាំងអស់ តែងបដិបត្តិបែបនេះ មានអានិសង្សច្រើនប្រការ ដូចជាតាំងនៅក្នុងអរិយវង្ស និងជាអ្នកមានការចិញ្ចឹមជីវិតអាស្រ័យកម្លាំងស្មង និងជាអ្នកសន្ដោសក្នុងរសអាហារ សូម្បីបានអាហារមានរសផ្សេងៗ មកក៏ដោយ តែទ្រង់ហាមតណ្ហាក្នុងរសចេញ អាហារទាំងនោះមិនមានទោស ជួយកាត់បន្ថយមានះ គឺការ

ប្រកាន់ខ្លួនចេញបាន ចង់ទៅកាន់ទិសទាំងឡាយក៏មិនត្រូវខ្វល់ខ្វាយក្នុង រឿងអាហារដូចជាយកវាស ត្រូវត្រៀមស្បៀងក្នុងការដើរផ្លូវ ថែមទាំង មិនត្រូវអាបត្តិ ដោយគណភោជនសិក្ខាបទ (ទាយកប្រាប់ឈ្មោះភោជន ហើយទទួលមកឆាន់ព្រមគ្នា ៤ រូប ) និងបរម្បរភោជនសិក្ខាបទ ( ភិក្ខុ ទទួលនិមន្តទុកហើយ មិនទៅឆាន់ចង្ហាន់ដែលគេនិមន្តទុកមុន ត្រឡប់ ទៅឆាន់ទីដទៃ ) បានទម្លាយសេចក្តីខ្ជិលច្រអូស និងធ្វើឲ្យកើតសេចក្តី ព្យាយាម ដោយការត្រាច់ទៅតាមលំដាប់ផ្ទះ គឺជាការចិញ្ចឹមជីវិតដែល បរិសុទ្ធ និងបានបញ្ចេញកម្លាំងកាយក្នុងពេលព្រឹករាល់ថ្ងៃ បានអនុគ្រោះ ដល់មនុស្ស និងទេវតាទាំងឡាយ ដែលជាអ្នកប្រាថ្នានឹងធ្វើសេចក្តីល្អ មានទានជាដើម ។

ព្រះបាទសុទ្ធោទនមហារាជ ទ្រង់ជ្រាបដំណឹងអំពីព្រះនាងពិម្ពា ដែលជាអ្នកចូលទៅក្រាបបង្គំទូល ឲ្យទ្រង់ជ្រាបបំណងចង់ឲ្យទូល អារាធនានិមន្តត្រឡប់ថា ខណៈនេះព្រះមានព្រះភាគជាម្ចាស់ ទ្រង់ជា ព្រះបិយោរស ទ្រង់នាំព្រះភិក្ខុសង្ឃទាំងឡាយស្តេចចារិកទៅតាមថ្នល់ ប្រកល្អកផ្សេងៗ ទ្រង់សព្វព្រះទ័យ ក្នុងការធ្វើដូចជាពួកអ្នកសុំទាន

គួរឲ្យខ្មាសគេណាស់ ជាការបំបាក់រាជវង្សដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គ ទ្រង់ប្រញាប់ចេញអំពីរាជនិវេសន៍មកកាន់ចន្លោះផ្លូវ ដើម្បីទ្រង់រាំងពុទ្ធដំណើរ ព្រមទាំងត្រាស់ហាមថា សូមបុត្រកុំធ្វើយ៉ាងនេះការធ្វើបែបនេះមិនមែនរាជប្រពៃណីដែលក្សត្រទាំងឡាយនឹងគប្បីប្រព្រឹត្តបដិបត្តិឡើយ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ប្រាប់ក្នុងរឿងនេះថា មហាបពិត្រ ការធ្វើបែបនេះរបស់តថាគត មិនមែនជាវង្សរបស់ក្សត្រ តែជាវង្សរបស់ព្រះពុទ្ធដទៃទេ គឺជាពុទ្ធវង្ស ព្រះពុទ្ធជាម្ចាស់ទាំងឡាយធ្វើតាមគ្នាមកគ្រប់សម័យកាល ។

លុះព្រះមានព្រះភាគ ទ្រង់មានពុទ្ធដីកាដូច្នេះហើយ ទើបប្រោសប្រទានសម្តែងព្រះធម៌ទេសនាថា

**ឧត្តិដ្ឋេ នប្បមជ្ជេយ្យ ធម្មំ សុចរិតំ ចរេ** ជាដើម សេចក្តីថា បុគ្គលមិនគប្បីប្រមាទ ក្នុងការក្រោកឡើងទទួលនូវអាហារក្បែរទ្វារផ្ទះរបស់អ្នកដទៃ បុគ្គលជាអ្នកប្រព្រឹត្តសុចរិតធម៌ កុំប្រព្រឹត្តធម៌ដែលជាទុច្ចរិតឡើយ បុគ្គលប្រព្រឹត្តសុចរិតធម៌ជានិច្ច រមែងនៅជាសុខ ក្នុងលោកនេះ និងលោកខាងមុខ ។

លុះទ្រង់ត្រាស់ចប់ ព្រះបាទសុទ្ធោទនមហារាជ បានសម្រេចសោតាបត្តិផល ហើយទ្រង់ទទួលបាត្រ និងទ្រង់ត្រាស់អារាធនាភិក្ខុទាំងឡាយ ដោយមានព្រះមានព្រះភាគជាប្រធាន ឲ្យស្តេចឡើងកាន់ប្រាសាទ ដើម្បីសោយព្រះក្រយាហារក្នុងព្រះរាជនិវេសន៍របស់ព្រះអង្គ ។ ក្នុងថ្ងៃទី ២ ព្រះមានព្រះភាគ ទ្រង់យាងទៅទទួលអាហារបិណ្ឌបាតក្នុងព្រះរាជនិវេសន៍ បានត្រាស់ធម្មទេសនាប្រោសព្រះនាងមហាបជាបតិគោតមី ( ព្រះមាតុច្ឆា ) ឲ្យបានសម្រេចសោតាបត្តិផល ចំណែកព្រះបាទសុទ្ធោទនមហារាជ បានសម្រេចសកទាគាមិផល ក្នុងថ្ងៃទី ៣ ត្រាស់ធម៌ទេសនាមហាធម្មបាលជាតកប្រោសព្រះពុទ្ធបិតា រហូតបានសម្រេចព្រះអនាគាមិផល ។

លុះក្នុងសម័យខាងមុខតទៅ ព្រះបាទសុទ្ធោទនមហារាជផ្ទំនៅលើក្រឡាបន្ទំដ៏មានសិរី ខាងក្រោមមហាស្វេតច្ឆត្រ ក៏បានសម្រេចព្រះអរហត្តផល ( ជាអ្នកឆ្ងាយចាកសឹកសត្រូវ គឺកិលេស ឬជាអ្នកមិនមានកិលេស ជាឈ្មោះលោកុត្តរធម៌ដែលព្រះអរហន្តបានសម្រេច ) ហើយស្តេចរំលត់ខន្ធ ចូលកាន់ព្រះនិព្វាន ។ តពីនោះមក ព្រះមានព្រះភាគ

ស្ដេចយាងទៅប្រាសាទរបស់ព្រះនាងយសោធរារាជទេវី ទ្រង់ត្រាស់ធម៌ទេសនាបន្ទោបង់ទោមនស្សរបស់ព្រះនាង ញ៉ាំងសេចក្ដីជ្រះថ្លាឲ្យកើតឡើងដល់ព្រះនាង ដោយទ្រង់លើក **ចន្ទកិន្នរីជាតក** ដោយពិស្ដារមកសម្ដែងឲ្យស្ដាប់ រហូតធ្វើឲ្យព្រះនាង តាំងនៅក្នុងសោតាបត្តិផល ហើយព្រះអង្គត្រឡប់មកនិគ្រោធារាមវិញ ។

ក្នុងថ្ងៃទី ៤ ព្រះមានព្រះភាគនិមន្តយាងទៅទទួលបិណ្ឌបាត នៅឯប្រាសាទនន្ទរាជកុមារ ដែលជាព្រះអនុជព្រះមាតាផ្សេងនឹងព្រះអង្គ កំពុងរៀបមង្គលការជាមួយនាងជនបទកល្យាណី ពេលសម្រេចភត្តកិច្ចហើយត្រាស់ឲ្យនន្ទកាន់បាត្រតាមព្រះអង្គ រហូតដល់និគ្រោធារាម ទើបប្រទានជាភិក្ខុលើកដំបូង ក្រោយពីបួសហើយ ព្រះនន្ទមានការមិនសប្បាយចិត្ត ព្រោះនឹកដល់នាងជនបទកល្យាណីៗ ប្រាប់មកថា សូមម្ចាស់បងប្រញាប់មកវិញ តែព្រះមានព្រះភាគទ្រង់ប្រើឧបាយទូន្មានឲ្យបាត់សេចក្ដីអផ្សុក រហូតបានសម្រេចព្រះអរហត្តផល ។

ក្នុងថ្ងៃទី ៧ ព្រះនាងពិម្ពា ទ្រង់បញ្ជូនព្រះរាហុលរាជឱរសមកក្រាបទូលសូមរាជសម្បត្តិ ប្រាថ្នានឹងបានជាក្សត្រតទៅក្នុងខាងមុខ

ព្រះអង្គ ទ្រង់ប្រទានលោកុត្តរទ្រព្យ ដោយត្រាស់ឲ្យព្រះសារីបុត្តត្ថេរ ជាព្រះឧបជ្ឈាយ៍ នាំទៅបព្វជ្ជាជាសាមណេរ ដោយវិធីតិសរណគមនៈ ចាត់ជាសាមណេរអង្គដំបូងក្នុងព្រះពុទ្ធសាសនា និងជាគ្រាដំបូងដែលព្រះសម្ពុទ្ធទ្រង់អនុញ្ញាត ក្នុងការបព្វជ្ជាដោយតិសរណគមនៈ គឺការបន្លឺវាចាដល់ព្រះរតនត្រ័យ ។

ផលល្អដែលកើតឡើងក្នុងព្រះសាសនា និងព្រះញាតិទាំងឡាយ មានព្រះបាទសុទ្ធោទនមហារាជពុទ្ធបិតាជាដើម កើតពីពុទ្ធដំណើរមកកាន់ក្រុងកបិលពស្តុជាគ្រាដំបូងនោះ គឺជាគុណសម្បត្តិនៃកាឡុទាយិត្ថេរ ដែលជាអ្នកធ្វើនាទី ទាំងជារាជទូត គឺទទួលព្រះរាជបញ្ជាអំពីព្រះបាទសុទ្ធោទនមហារាជ ឲ្យទៅក្រាបទូលអារាធនាព្រះមានព្រះភាគជាម្ចាស់យាងត្រឡប់មកកាន់ក្រុងកបិលពស្តុ លោកអាចធ្វើមុខនាទីជារាជទូតរហូតបានសម្រេចផល ទាំងជាសមណទូត គឺអ្នកនាំដំណឹងការយាងមករបស់ព្រះមានព្រះភាគ មកប្រាប់ឲ្យព្រះបាទសុទ្ធោទនមហារាជទ្រង់បានជ្រាបរាល់ថ្ងៃ រហូតព្រះសាស្តាស្តេចយាងមកដល់ក្រុងកបិលពស្តុ ទាំងអាចប្រើសេចក្តីជំនាញ និងចំណេះវិជ្ជាដែលរៀនអំពីព្រះសាសនា

ធ្វើឲ្យព្រះបាទសុទ្ធោទនៈ និងបណ្តាព្រះញាតិ មានការជឿជ្រះថ្លាក្នុងព្រះរតនត្រ័យមុននឹងបានឃើញព្រះសាស្តា ធ្វើឲ្យទ្រង់បរិច្ចាគកត្តាហារដល់លោកនិងដល់ព្រះមានព្រះភាគជាម្ចាស់រាល់ថ្ងៃក្នុងចន្លោះផ្លូវដែលពុទ្ធដំណើរមកនោះ ។

កាលជាខាងក្រោយមក ព្រះសាស្តាទ្រង់គង់ក្នុងជំនុំអរិយសង្ឃ ហើយទ្រង់តែងតាំងព្រះកាឡុទាយិត្ថេរ ទុកក្នុងតំណែងឯតទគ្គៈ ដូចមានក្នុងព្រះបាលី **អង្គុត្តរនិកាយ ឯកនិបាត** ឯតទគ្គបាលីថា ៖

**ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ កុលប្បសាទកានំ យទិទំ កាឡុទាយី ។** ម្នាលភិក្ខុទាំងឡាយ កាឡុទាយីជាឯតទគ្គៈ គឺជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវ័ករបស់តថាគត ផ្នែកធ្វើត្រកូលឲ្យជ្រះថ្លា ។

ព្រះកាឡុទាយិត្ថេរ ពេលលោកតាំងអាយុសង្ខារប្រកបដោយគុណប្រយោជន៍ ទាំងក្នុងចំណែកផ្ទាល់ខ្លួន និងជនដទៃ មកតាមសមគួរដល់កាលហើយ ក៏រំលត់ខន្ធចូលកាន់ព្រះនិព្វាន ។៚

( ជីវប្រវត្តិរបស់ព្រះកាឡុទាយិត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះពក្កុលត្ថេរ ✍

## " ដែលជាឯតទគ្គៈផ្នែកខាងគ្មានអាពាធ "

ព្រះពក្កុលត្ថេរ ក៏រាប់ចូលនៅក្នុងចំណោមព្រះអសីតិមហាសាវក គឺជាសាវកមួយរូប ដែលបានទទួលការលើកតម្កើង ឲ្យជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងគ្មានអាពាធអំពីព្រះមានជោគ ទាំងលោកមានជីវប្រវត្តិប្លែកចម្លែកអស្ចារ្យ មិនដូចជីវប្រវត្តិសាវកអង្គដទៃឡើយ ។

ដែលមានសម្ដែងក្នុង **អដ្ឋកថាបបញ្ចសូទនី** ដែលអធិប្បាយសេចក្ដីព្រះបាលី **ពក្កុលត្ថេរច្ឆរិយព្ភូតសូត្រ** និង **គម្ពីរមជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ** អធិប្បាយសេចក្ដីដែលទាក់ទងនឹងឈ្មោះរបស់ព្រះថេរៈ ដូចមានសេចក្ដីថា ៖

ពាក្យថា **ពាកុលៈ** នោះប្រែថា មានត្រកូលពីរ និង ពាកុលស័ព្ទនេះ បែកចេញជាពីរបទ គឺ ពា មួយបទ និង កុល មួយបទ ។

ពា ប្រែថា ពីរ ព្រោះប្លែងចេញមកពីពាក្យថា ទ្វិ ឬ ទ្វា ប្រែថា

ពីរ ៗ កុល ប្រែថា ត្រកូល ឬ សកុល សម្តៅដល់ វង្ស ខ្សែស្រឡាយ ផៅពង្ស និងជាតិដ៏ល្អ ៗ

ចំណែកអដ្ឋកថាមនោរថបូរណីមានសេចក្តីថា ពាក្យថា **ពាកុល** ព្រោះជាអ្នកចម្រើននៅក្នុងត្រកូលសេដ្ឋីទាំងពីរ ឬជាអ្នកដែលត្រកូលសេដ្ឋីទាំងពីរចិញ្ចឹម ៗ ឬន័យមួយទៀត **ពាកុល** ដែលប្រែថា មានត្រកូលពីរ សម្តៅដល់ជាអ្នកនៅក្នុងផ្ទៃមួយជាតិពីរដង បានដល់ នៅក្នុងផ្ទៃមាតាមួយដង និងនៅក្នុងពោះត្រីមួយដងទៀត ក៏រាប់ថាជីវប្រវត្តិរបស់លោកគួរសិក្សាយ៉ាងក្រៃលែង ៗ

រឿងអតីតជាតិរបស់ព្រះពក្កុលត្ថេរ មានប្រាកដនៅក្នុង **អដ្ឋកថាមនោរថបូរណី** និង **អដ្ឋកថាបរមត្ថទីបនី** ដែលអធិប្បាយសេចក្តីបាលីគម្ពីរ **ខុទ្ទកនិកាយ ថេរគាថា** មានសេចក្តីថា ៖

ក្នុងទីបំផុតមួយអសង្ខេយ្យ និងមួយសែនកប្ប ដោយរាប់ថយក្រោយអំពីភទ្ទកប្បនេះ ព្រះពក្កុលត្ថេរនោះ បានកើតនៅក្នុងត្រកូលព្រាហ្មណ៍ មុនព្រះអនោមទស្សីសម្ពុទ្ធ ស្តេចឧប្បត្តិឡើងក្នុងលោក

ប៉ុន្តែមិនប្រាកដថាឈ្មោះអ្វី ។ កាលបើពកុលព្រាហ្មណ៍នោះចម្រើនវ័យធំឡើង គេបានទៅសិក្សាវិជ្ជាត្រៃវេទក្នុងសម្នាក់អាចារ្យទិសាបាមោក្ខ ។

ប៉ុន្តែកាលបើលោកពិចារណាវិជ្ជាត្រៃវេទមើលហើយ មិនឃើញយល់វត្ថុដែលជាសារៈ គឺខ្លឹមសារក្នុងវិជ្ជាត្រៃវេទនោះ ទើបលះបង់វិជ្ជាត្រៃវេទនោះចេញ ហើយមកបួសជាតាបសឥសី ដោយមានគំនិតគិតថា នឹងស្វែងរកនូវប្រយោជន៍សម្រាប់ខ្លួន ។ ហេតុនោះ កាលលោកកាន់ភេទជាតាបស បានតាំងចិត្តបំពេញផ្នួសតាមបែបប្រពៃណីអាចារ្យមុនៗ ប្រព្រឹត្តប្រតិបត្តិរហូតបានសម្រេចអភិញ្ញា ៥ សមាបត្តិ ៨ ។

លុះតមក ព្រះអនោមទស្សីសម្មាសម្ពុទ្ធ បានត្រាស់ដឹងនៅក្នុងលោក មានព្រះអរិយសង្ឃជាបរិវារហែហមទៅតាមព្រះអង្គកន្លែងនានា ដើម្បីទ្រង់សម្តែងធម៌ទេសនា ប្រោសពុទ្ធបរិស័ទឲ្យបានសម្រេចមគ្គផលទៅតាមឧបនិស្ស័យរៀងៗខ្លួន ។តាបសនោះបានជ្រាបដំណឹងថា ព្រះពុទ្ធកើតឡើងក្នុងលោកហើយ ក៏បានចូលទៅគាល់ព្រះអនោមទស្សីសម្ពុទ្ធ ក៏បានស្តាប់ព្រះធម្មទេសនា រួចហើយក៏កើតសេចក្តីជ្រះថ្លា មានសទ្ធា

ប្រកាសខ្លួនជាអ្នកដល់ព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។

ពក្កុលៈនោះ សូម្បីបានស្តាប់ព្រះធម៌ទេសនា អំពីព្រះមានជោគអនោមទស្សីក៏ដោយ ក៏មិនបានសម្រេចមគ្គផលអ្វីឡើយ ទាំងមិនអាចលះបង់ភេទជាតាបសនោះចេញបានឡើយ ។ ទាំងនេះប្រសិនបើពិចារណាដល់វាសនាបារមីរបស់តាបស ដែលកសាងសន្សំបុណ្យកុសលទុកក្នុងអតីតជាតិនោះ ក៏គង់នៅមិនទាន់គ្រប់គ្រាន់ នេះប្រការមួយ ។

កាលបើពិចារណាដល់ហេតុបច្ចុប្បន្ន តាបសនេះបានស្តាប់ព្រះធម៌ទេសនាហើយ អាចកើតវិចិកិច្ឆា គឺសេចក្តីសង្ស័យ និងឧទ្ធច្ចកុក្កុច្ចៈ គឺសេចក្តីរាយមាយ គិតដល់ការប្រព្រឹត្តទៅវាងធម៌ទេសនារបស់ព្រះសម្មាសម្ពុទ្ធអនោមទស្សី ជាមួយនឹងអភិញ្ញាសមាបត្តិដែលខ្លួនបាន ធ្វើឲ្យកើតការសម្រេចចិត្តមិនត្រូវ នេះជាប្រការមួយទៀត ។

សូម្បីតាបសនោះ មិនបានសម្រេចធម៌ជាន់ខ្ពស់ក៏ដោយ ទាំងមិនទាន់ព្រមលះបង់ភេទជាតាបសនោះបាន ប៉ុន្តែតែងតែចូលទៅស្តាប់ព្រះធម៌ទេសនាព្រះអនោមទស្សីសម្មាសម្ពុទ្ធជានិច្ចកាល ។ គ្រាមួយ ព្រះ

អនោមទស្សី ទ្រង់អាពាធរោគខ្យល់ក្នុងឧទរ កាលបើតាបសនោះជ្រាបថា ព្រះមានព្រះភាគអនោមទស្សី ទ្រង់មានអាពាធ ទើបចូលទៅក្រាបបង្គំទូលសួរថា ព្រះអង្គមានអាពាធអ្វី ? ព្រះអនោមទស្សីត្រាស់តបថា ម្នាលតាបស តថាគតកើតរោគអាពាធខ្យល់ក្នុងឧទរ ។ កាលបើតាបសនោះបានស្តាប់ពុទ្ធតម្រាស់ដូច្នេះហើយ ទើបគិតថា ពេលនេះ ជាពេលដែលយើងគួរនឹងធ្វើបុណ្យ គិតរួចហើយទើបប្រញាប់ទៅជើងភ្នំបេះថ្នាំផ្សេងៗ មកថ្វាយដល់ព្រះថេរៈដែលជាឧបដ្ឋាកទទួលនាទីព្យាបាលដោយប្រាប់ថា សូមលោកម្ចាស់នាំយកថ្នាំនេះចូលទៅថ្វាយដល់ព្រះមានជោគផងចុះ ព្រះថេរៈបាននាំយកថ្នាំនោះទៅថ្វាយដល់ព្រះអនោមទស្សី ដោយតាមពាក្យអង្វររបស់តាបសនោះ ។

កាលបើព្រះសម្ពុទ្ធអនោមទស្សី ទ្រង់សោយថ្នាំនេះរួចហើយ រោគខ្យល់ក្នុងឧទរក៏ស្ងប់ទៅ នៅពេលដែលព្រះអង្គបាត់អាពាធ តាបសនោះទើបក្រាបទូលតាំងសេចក្តីប្រាថ្នាថា ដោយអានិសង្សដែលខ្ញុំថ្វាយថ្នាំដល់ព្រះអង្គនេះ បើខ្ញុំព្រះអង្គកើតក្នុងជាតិណាៗ សូមកុំឲ្យរោគកើត

មានដល់ខ្ញុំព្រះអង្គឡើយ ។ កាលដែលថ្វាយថ្នាំនេះដល់ព្រះអនោមទស្សី បានជាកល្យាណកម្មរបស់តាបសយ៉ាងល្អ ពេលដែលតាបសនោះស្លាប់ទៅហើយ បានទៅកើតក្នុងព្រហ្មលោកដោយអំណាចអភិញ្ញាសមាបត្តិ ហើយចុតិចាកព្រហ្មលោកមកវិញក៏កើតក្នុងមនុស្សលោក មានការត្រាច់រង្គាត់វិលស្លាប់វិលកើតក្នុងមនុស្សទេវតា **អស់មួយអសង្ខេយ្យ** ។

លុះកន្លងមកដល់ពុទ្ធកាលនៃព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ តាបសនោះបានមកកើតនៅក្នុងនគរហង្សវតី ធ្លាប់បានចូលទៅគាល់ព្រះបទុមុត្តរៈជាម្ចាស់ និងបានឃើញព្រះពុទ្ធទ្រង់តែងតាំងភិក្ខុមួយរូបទុកក្នុងតំណែងដ៏ប្រសើរជាងភិក្ខុសាវកទាំងឡាយអ្នកគ្មានអាពាធ ក៏នឹកពេញចិត្តតំណែងនោះ ដូច្នេះហើយ ទើបធ្វើអធិការកុសលក្នុងសម្នាក់ព្រះសម្មាសម្ពុទ្ធ-បទុមុត្តរៈ ហើយប្រាថ្នាតំណែងនោះចំពោះព្រះភក្ត្រនៃព្រះអង្គនោះ ។

ជីវប្រវត្តិជាអសីតិសាវករបស់ព្រះពក្កុលត្ថេរ មាននៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដូចមានរឿងតំណាលទុកថា ៖

ខ្ញុំឈ្មោះសោភិតៈ នៅក្នុងព្រៃហិមពាន្តអាស្រមដ៏ល្អរបស់ខ្ញុំ គឺ

ពួកសិស្សរបស់ខ្ញុំកសាងហើយ ។ មណ្ឌបទាំងឡាយជាច្រើន ដើមឈើភ្លើងមានផ្ការីក ក៏មានក្នុងទីនោះ ដើមខ្វិត ដើមច្បា ដើមខ្នឹង ដើមរំចេក ក៏មានក្នុងទីនោះជាច្រើន ដើមចង្អេរទ្រាយ ដើមពុទ្រា ដើមកន្ទួតព្រៃ ដើមម៉ាក់ប្រាង វល្លិឃ្លោក ដើមស្វាយ ដើមស្វាយ.ស មានផ្ការីក ក៏មានក្នុងទីនោះជាច្រើន ដើមរាក់ស ដើមញ្ញៅ ដើមចេក ដើមក្រូចថ្លុងក៏មានក្នុងទីនោះ ដើមជន្ទាត់ដៃ ដើមអង្គ្រែង ដើមប្រិយង្គុក៏មានច្រើនក្នុងទីនោះ ៗ ដើមស្រួល ដើមស្រល់ ដើមកទម្ព ដើមជ្រៃក្រឹម ដើមក្រសាំង (ក៏មានក្នុងទីនោះ) អាស្រមរបស់ខ្ញុំប្រាកដយ៉ាងនេះ ខ្ញុំព្រមទាំងពួកសិស្ស ក៏នៅក្នុងអាស្រមនោះ ។ ព្រះមានព្រះភាគ ព្រះនាមអនោមទស្សី ជាសយម្ភូលោកនាយក ទ្រង់ស្វែងរកទីសម្រាប់ពួនសម្ងំ ស្តេចបានចូលមកកាន់អាស្រមរបស់ខ្ញុំ ។ លុះព្រះអនោមទស្សី ព្រះអង្គមានព្យាយាមច្រើន មានយសធំ កំពុងស្តេចយាងចូលមក អាពាធបណ្តាលអំពីខ្យល់ ក៏បានតាំងឡើង ដល់ព្រះលោកនាថ ក្នុងមួយរំពេច ។ ខ្ញុំកាលត្រាច់ទៅក្នុងព្រៃ បានឃើញព្រះលោកនាយក ក៏ចូលមកជិតព្រះមានជោគទ្រង់

មានចក្ខុ មានយសច្រើន ។ លុះខ្ញុំបានឃើញឥរិយាបថ ក៏កំណត់ទុកក្នុងកាលនោះថា ព្យាធិទាំងឡាយ ពិតជានឹងកើតដល់ព្រះពុទ្ធ ដោយឥតសង្ស័យ ។ ខ្ញុំបានត្រឡប់មកកាន់អាស្រម ដោយប្រញាប់ប្រញាល់ ខ្ញុំមានបំណងនឹងធ្វើថ្នាំ ក្នុងសម្នាក់ពួកសិស្សរបស់ខ្ញុំ ខ្ញុំបានហៅពួកសិស្សក្នុងកាលនោះ ។ ពួកសិស្សទាំងអស់ ជាអ្នកមានសេចក្តីគោរព បានទទួលស្តាប់ពាក្យរបស់ខ្ញុំ ហើយមកប្រជុំក្នុងទីជាមួយគ្នា ព្រោះពួកសិស្សទាំងនោះ ជាអ្នកមានសេចក្តីគោរពដល់ខ្ញុំជាគ្រូ ។ ខ្ញុំបានឡើងកាន់ភ្នំជាប្រញាប់ហើយ បានធ្វើនូវឱសថទាំងអស់ ខ្ញុំធ្វើផ្សំនឹងទឹកសម្រាប់ផឹក បានថ្វាយដល់ព្រះពុទ្ធដ៏ប្រសើរ ។ កាលព្រះសព្វញ្ញូ លោកនាយកមានយសធំ កាលទ្រង់សោយហើយ រោគខ្យល់នៃព្រះសុគត ទ្រង់ស្វែងរកគុណធំ ក៏បានស្ងប់រម្ងាប់យ៉ាងឆាប់ ។ ព្រះអនោមទស្សី មានយសច្រើន ទ្រង់ឃើញសេចក្តីក្រវល់ក្រវាយស្ងប់រម្ងាប់ហើយ ទ្រង់គង់លើអាសនៈរបស់ព្រះអង្គ រួចទ្រង់ពោលនូវគាថាទាំងនេះថា

បុរសណា បានប្រគេនភេសជ្ជៈដល់តថាគតផង បានរម្ងាប់ព្យាធិ

របស់តថាគតផង តថាគតនឹងសរសើរបុរសនោះ អ្នកទាំងឡាយចូរស្តាប់ភាសិត ដែលតថាគតនឹងសម្តែងចុះ ។ បុរសនេះនឹងត្រេកអរក្នុងទេវ-លោក អស់មួយសែនកប្ប នឹងរីករាយក្នុងការប្រគំតន្ត្រីក្នុងទេវលោកនោះសព្វកាល ។ លុះត្រឡប់មកកាន់មនុស្សលោកវិញ ត្រូវកុសលមូលដាស់តឿន នឹងបានជាស្តេចចក្រពត្តិ អស់មួយពាន់ដង ។ ក្នុងកប្បទី ៥៥ បុរសនេះនឹងបានកើតជាក្សត្រសោយរាជ្យ ព្រះនាមអនោមិ ជាធំ ក្នុងជម្ពូទ្វីប ជាធំលើផែនដី ឈ្នះសង្គ្រាម មានសមុទ្រទាំង ៤ ជាទីបំផុត ។ នឹងបានជាស្តេចចក្រពត្តិ បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើនញុំាងទេវតាក្នុងឋានតាវត្តិង្សឲ្យកម្រើក ហើយនឹងសោយនូវឥស្សរភាព ។ បុរសនោះ ទោះនឹងកើតជាទេវតាក្តី ជាមនុស្សក្តី នឹងមិនមានអាពាធនឹងវៀរបង់នូវព្យាធិ ជាគ្រឿងក្តៅក្រហាយក្នុងលោក ។ក្នុងកប្បប្រមាណមិនបានអំពីកប្បនេះ មានព្រះសាស្តា ព្រះនាមគោតម ទ្រង់នឹងសម្ភពក្នុងត្រកូលនៃស្តេចឱក្កាកៈ ទ្រង់ត្រាស់ឡើងក្នុងលោក ឯបុរសនេះ នឹងបានជាអ្នកទទួលនូវមត៌ក ក្នុងធម៌របស់ព្រះសាស្តានោះ ជាឱរសដែល

ធម៌និម្មិតហើយ ហើយកំណត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។ បុរសនេះនឹងដុតនូវកិលេសទាំងឡាយ ហើយនឹងធ្វើនូវខ្សែនៃតណ្ហា នឹងបានជាសាវ័កនៃព្រះសាស្ដា ឈ្មោះពក្កុលៈ ។ ព្រះមានព្រះភាគព្រះនាមគោតម ជាសក្យៈដ៏ប្រសើរ ទ្រង់បានជ្រាបនូវដំណើរទាំងអស់នេះ ទ្រង់គង់ក្នុងពួកភិក្ខុ នឹងតាំងពក្កុលភិក្ខុក្នុងទីជាឯតទគ្គៈ ។ ព្រះមានព្រះភាគព្រះនាមអនោមទស្សី ជាលោកនាយក ជាសយម្ភូ ទ្រង់ប្រមើលមើលសេចក្តីស្ងប់ស្ងាត់ ក៏បានស្តេចចូលមកអាស្រមរបស់ខ្ញុំ ។ លុះព្រះសព្វញ្ញូ ជាលោកនាយក ទ្រង់មានព្យាយាម ស្តេចចូលមកដល់ហើយ ខ្ញុំក៏ជ្រះថ្លា បានញុំាងព្រះអង្គឲ្យឆាន់ថ្នែតស្អប់ស្អល់ ដោយឱសថទាំងពួង ដោយដៃរបស់ខ្លួន ។ ខ្ញុំនោះបានធ្វើអំពើល្អហើយ ចំពោះបុញ្ញក្ខេត្តដ៏ល្អ ខ្ញុំមិនអាចញុំាងអំពើដែលខ្ញុំធ្វើល្អហើយ ក្នុងកាលនោះ ឲ្យអស់ទៅបាន ព្រោះការដល់ព្រមដោយពូជ ។ ខ្ញុំឈ្មោះថាមានលាភ អត្តភាពជាមនុស្ស ឈ្មោះថា ខ្ញុំបានល្អហើយ ដ្បិតខ្ញុំបានឃើញព្រះនាយក ខ្ញុំក៏បានដល់អចលបទ គឺព្រះនិព្វាន ដោយសំណល់នៃកម្មនោះឯង ។

ព្រះគោតមជាសក្យៈដ៏ប្រសើរ ទ្រង់បានជ្រាបដំណើរទាំងអស់នេះ ទ្រង់គង់ក្នុងពួកភិក្ខុ ហើយតាំងខ្ញុំក្នុងទីជាឯតទគ្គៈ ។ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃភេសជ្ជៈ ។ កិលេសទាំងឡាយ ខ្ញុំដុតចោលហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ អាសវៈទាំងអស់របស់ខ្ញុំ អស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ឱ! ដំណើរដែលខ្ញុំមក ក្នុងសម្នាក់នៃព្រះសម្ពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ចំណែកសេចក្តីពិស្តារ ទាក់ទងនឹងជីវប្រវត្តិរបស់ព្រះពក្កុលត្ថេរ មានក្នុង **អដ្ឋកថាមនោរថបូរណី** ដូចមានសេចក្តីថា ៖

កុលបុត្រនោះ បានធ្វើអធិការកុសលទុកក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ ហើយតាំងសេចក្តីប្រាថ្នាដើម្បីបាននូវភាពដ៏ប្រសើរ

ជាឯកិក្ខុទាំងឡាយផ្នែកខាងគ្មានអាពាធ ហើយក៏បំពេញបុណ្យកុសល រហូតអស់ជីវិត ក៏បានទៅសោយទិព្វសម្បត្តិនៅក្នុងទេវលោក និងមនុស្ស លោក មានរយៈកាលជាច្រើន ។

កាលលោកត្រឡប់មកកើតនៅក្នុងត្រកូលព្រាហ្មណ៍ នៅក្នុងនគរ ពន្ធុមតី មុនព្រះវិបស្សីទ្រង់ឧប្បត្តិឡើងនៅក្នុងលោក បានបួសជាតាបស សម្រេចអភិញ្ញាសមាបត្តិនៅក្បែរជិតព្រៃហិមពាន្ត ។កាលតមក ព្រះវិបស្សី ទ្រង់ត្រាស់ដឹងជាព្រះពុទ្ធ មានភិក្ខុសង្ឃ ៦ លាន ៨ សែនរូប ជាបរិវារ ព្រះអង្គប្រថាប់នៅខេមមិគទាយវ័ន ដើម្បីប្រោសព្រះបាទពន្ធុមតីមហា រាជ ជាពុទ្ធបិតា ក្នុងនគរពន្ធុមតី ។

កាលបើតាបសនោះជ្រាបដំណឹងថា ព្រះវិបស្សីត្រាស់ដឹងនៅក្នុង លោកហើយ ព្រះអង្គបរិបូណ៌ដោយគុណ ទើបចូលទៅគាល់ព្រះសាស្តា ដើម្បីស្តាប់ព្រះធម៌ទេសនា ហើយតាំងនៅក្នុងត្រៃសរណគមន៍ ប៉ុន្តែ មិនលះបង់ចោលភេទជាតាបសទេ តែងតែចូលទៅគាល់ព្រះវិបស្សីរឿយៗ ថ្ងៃមួយ ភិក្ខុទាំងឡាយកើតរោគឈឺព្រះសីសៈ ព្រោះត្រូវខ្យល់បក់នាំយក

លម្អងផ្កាឈើ ដែលមានពិសមកអំពីព្រៃហិមពាន្ត មានតែព្រះវិបស្សី និងអគ្គសាវកទាំងពីររូបតែប៉ុណ្ណោះ ដែលមិនកើតរោគឈឺព្រះសីសៈ ព្រោះផ្កាឈើដែលមានពិសជាដើមហេតុ ។

កាលតាបសនោះ បានចូលមកគាល់ព្រះវិបស្សីហើយ បានឃើញភិក្ខុទាំងឡាយសិងគ្របព្រះសីសៈទើបក្រាបទូលសួរថា ភិក្ខុទាំងឡាយមានអាពាធអ្វី ? ព្រះវិបស្សីត្រាស់តបថា ម្នាលតាបស ភិក្ខុទាំងឡាយមានអាពាធឈឺព្រះសីសៈ ព្រោះមកពីផ្កាឈើ ដែលមានពិសជាដើមហេតុ ។ តាបសនោះជ្រាបហេតុផលនៃអាពាធ របស់ភិក្ខុទាំងឡាយហើយក៏គិតភ្លាមថា ឱកាសនេះ ជាឱកាសដែលយើងគួរនឹងជួយព្យាបាលភិក្ខុដែលអាពាធទាំងនោះ ដើម្បីឲ្យកើតបុណ្យកុសលដល់យើង ទើបជាការល្អ ហើយក៏ប្រញាប់ទៅរកថ្នាំផ្សេងៗ ដោយអានុភាពរបស់ខ្លួនមកផ្សំជាភេសជ្ជៈប្រគេនដល់ភិក្ខុទាំងឡាយដែលអាពាធ ភិក្ខុទាំងឡាយបានទទួលភេសជ្ជៈនោះហើយ ក៏បាត់អាពាធមួយរំពេចក្នុងពេលនោះ ។

សម័យតមក តាបសនោះ ក៏អស់ជីវិតទៅកើតក្នុងព្រហ្មលោក

ហើយមានការត្រាច់រង្គាត់ក្នុងមនុស្សទេវតារហូត ៩១ កប្ប ។ លុះមកដល់ពុទ្ធកាលរបស់ព្រះសម្មាសម្ពុទ្ធកស្សបៈ តាបសនោះបានមកកើតនៅក្នុងក្រុងពារាណសី កាលមានអាយុដែលនឹងគ្រប់គ្រងផ្ទះតាមលោកិយប្រពៃណីបានហើយ ទើបគិតថា ផ្ទះរបស់យើងក៏ចាស់គ្រាំគ្រាទៅហើយ យើងគួរនឹងទៅរកគ្រឿងផ្ទះដើម្បីជួសជុលឲ្យល្អឡើងវិញ គិតដូច្នេះហើយទើបចេញទៅជាមួយនឹងពួកជាងផ្ទះ ក៏បានទៅជួបមហាវិហារចាស់គ្រាំគ្រាមួយកន្លែងក្នុងចន្លោះផ្លូវ ក៏គិតថា ការធ្វើផ្ទះរបស់យើងគួរផ្អាកទុកសិនចុះ ព្រោះថា ផ្ទះរបស់យើងមិនអាចជាប់តាមយើងទៅបាន ក្នុងពេលដែលយើងស្លាប់ទៅហើយ យើងគួរនឹងធ្វើបុណ្យកុសល ដែលជារបស់ជាប់តាមខ្លួនទៅកាន់បរលោកវិញ ទើបសមគួរ ។

លុះកុលបុត្រនោះ គិតដូច្នេះហើយ បានអង្វរឲ្យពួកជាងឈើទៅនាំយកគ្រឿងឈើផ្សេងៗ មកសាងជាព្រះវិហារ សាលាឆាន់ កុដិ រោងបាយ រហូតដល់ទីសម្រាកពេលថ្ងៃ និងពេលយប់ និងវច្ចកុដិក្នុងបរិវេណក្បែរព្រះវិហារនោះ ព្រមជាមួយនឹងការរៀបចំរកវត្ថុ ដែលជាថ្នាំ

សម្រាប់រក្សារោគប្រគេនដល់ភិក្ខុទាំងឡាយ ។

ទាំងកុលបុត្រនោះបានធ្វើបុណ្យកុសលដទៃទៀត រហូតអស់ជីវិត ក៏បានទៅកើតនៅក្នុងទេវលោកខ្លះ មនុស្សលោកខ្លះ អស់មួយពុទ្ធន្តរ ទើបបានមកកើតជាបុត្រសេដ្ឋីនៅក្នុងក្រុងកោសម្ពី មុនព្រះសមណគោតម ទ្រង់ឧប្បត្តិឡើងក្នុងលោក ។ តាំងអំពីកុលបុត្រនោះ មកចុះចាប់បដិសន្ធិ នៅក្នុងគភ៌ភរិយាសេដ្ឋីក្រុងកោសម្ពីហើយ ត្រកូលរបស់សេដ្ឋី ក៏ចម្រុង ចម្រើនដោយលាភ និងយសជាច្រើន ។

ចំណែកភរិយារបស់លោកសេដ្ឋីដែលមានគភ៌នោះ កាលមាន គភ៌គ្រប់ខែហើយ ក៏បានប្រសូតបុត្រមកជាប្រុស ហើយមានការគិតថា បុត្ររបស់យើងជាមនុស្សមានបុណ្យច្រើន ដែលធ្លាប់ធ្វើទុករួចមកហើយ ប្រសិនបើគេមានអាយុនៅជរាបណា រមែងនឹងឲ្យសម្បត្តិច្រើនសន្ធឹក សន្ធាប់ដល់យើងពិតប្រាកដពុំខាន ។

មានការយល់ថា ប្រសិនបើបានយកទារកនេះទៅងូតទឹកក្នុង ស្ទឹងយមុនា រមែងមិនមានរោគភ័យអ្វីឡើយ មាតាបិតារបស់ទារកនោះ

ទើបឲ្យគេនាំយកទៅដើម្បីឲ្យផ្ដួតទឹក ក្នុងស្ទឹងយមុនា ។ ចំណែកព្រះមជ្ឈិមកាណកាចារ្យទាំងឡាយ បានពោលរឿងដែលទាក់ទងការធ្វើមង្គលនៃទារកនោះ កាលបើទារកនោះកើតបាន ៥ ថ្ងៃ មាតាបិតា ព្រមទាំងពពួកញាតិឲ្យគេចាត់ចែងធ្វើមង្គល មានការកោរសក់ជាដើម ក៏បានដាក់នាមឲ្យទារកនោះ ទើបឲ្យពពួកកីលៀង ឬមេដោះនាំយកទៅផ្ងូតទឹកជម្រះខ្លួនក្នុងស្ទឹងយមុនា ។ ក្នុងខណៈនោះ មានត្រីធំហែលមកតាមក្រសែទឹក បានក្រឡេកឃើញទារកនោះ សម្គាល់ថាជាអាហារ ទើបត្របាក់យកទារកលេបចូលទៅក្នុងពោះ ។

ធម្មតាអ្នកមានបុណ្យបារមីដូចទារកនេះ រមែងមិនមានអន្តរាយ សូម្បីនឹងចូលទៅនៅក្នុងពោះត្រីនោះក៏ដោយ ការលំបាកត្រឹមតែបន្តិចបន្តួចក៏មិនមាន ប៉ុន្តែត្រឡប់ដេកយ៉ាងសប្បាយ ដូចដេកនៅលើដំណាក់ដ៏ប្រសើរ ។ ដោយអាស្រ័យតេជះបុណ្យបារមីរបស់ទារកនោះ ក៏បណ្ដាលឲ្យត្រីនោះកើតការក្ដៅក្រហល់ក្រហាយ ហាក់បីដូចថា លេបដុំរងើកភ្លើងដ៏ក្ដៅចូលទៅក្នុងពោះដូច្នោះ ។ការក្ដៅក្រហល់ក្រហាយដែលកើតឡើង

នៅខាងក្នុងខ្លួនរបស់ត្រីនោះ ធ្វើឲ្យត្រីហែលត្រដាបត្រដួស ហែលឆ្វេងកាត់ផ្លូវរហូតដល់ ៣០ យោជន៍ ចៃដន្យវង្វេងចូលទៅជាប់សំណាញ់របស់អ្នកនេសាទ នៅក្នុងនគរពារាណសី ។

គ្រប់គ្រា ក្នុងពេលមានត្រីធំជាប់សំណាញ់ រមែងត្រូវស្លាប់នៅក្នុងសំណាញ់នោះ ហើយទើបលើកឡើងមក ប៉ុន្តែត្រីនេះ ត្រូវអ្នកនេសាទ ជួយគ្នាដោះចេញអំពីសំណាញ់រួចហើយ ក៏ស្លាប់ល្មម ដោយមិនត្រូវសម្លាប់ ។ ដោយបុណ្យកុសលរបស់ទារកនោះ បានសន្សំមកហើយ ធម្មតាអ្នកនេសាទ ពេលណាបានត្រីធំ គេសម្លាប់រួចហើយ ពួកគេនឹងពន្លះ ឬកាត់ចេញជាកំណាត់តូចៗ ខ្លះ ជាកំណាត់ធំៗ ខ្លះ ប៉ុន្តែត្រីនេះមិនត្រូវពន្លះ ឬកាត់ជាកំណាត់តូចធំឡើយ យកទៅលក់ទាំងមូល។

អ្នកនេសាទ នាំគ្នាសែងយកត្រី ទៅពពាយនាយលក់ក្នុងក្រុងដោយតម្លៃមួយពាន់កហាបណៈ ប៉ុន្តែមិនមាននរណាទិញ ព្រោះតម្លៃថ្លៃពេក ។ ក្នុងក្រុងពារាណសី មានត្រកូលសេដ្ឋីម្នាក់ មានទ្រព្យសម្បត្តិ ៨០ កោដិ ប៉ុន្តែជាត្រកូលដែលមិនមានបុត្រធីតា ។ អ្នកនេសាទបានដើរ

ពពាយនាយលក់ត្រីនោះ  រហូតដល់ផ្ទះលោកសេដ្ឋីនោះ ។លោកសេដ្ឋី បានឃើញអ្នកនេសាទនាំយកត្រីមកលក់ ទើបសួរថា ត្រីនេះលក់តម្លៃប៉ុន្មាន ? អ្នកនេសាទឆ្លើយថា លក់តម្លៃមួយពាន់កហាបណៈ លោកសេដ្ឋីក៏សម្រេចចិត្តថាទិញ ទើបជូនប្រាក់មួយពាន់កហាបណៈឲ្យទៅអ្នកលក់ត្រីនោះ ដោយមិនបានតថ្លៃអ្វីឡើយ ។ថ្ងៃដទៃៗ កិរិយារបស់លោកសេដ្ឋី មិនធ្លាប់មករវល់ទាក់ទិនជាមួយនឹងរឿងការធ្វើត្រី ឬធ្វើសាច់អ្វីឡើយ ប៉ុន្តែក្នុងថ្ងៃនេះ កិរិយារបស់លោកសេដ្ឋីបានធ្វើដោយខ្លួនឯង មានការពន្វះសាច់ត្រីម្តងបន្តិចៗ ក៏បានឃើញទារកនៅក្នុងពោះត្រីនៅមានជីវិតនៅឡើយ ទារកនោះមានពណ៌សម្បុរដូចជាមាស កាលបើកិរិយារបស់លោកសេដ្ឋីបានឃើញទារកហើយ ក៏កើតសេចក្តីស្រឡាញ់ដូចជាកូនបង្កើតរបស់ខ្លួន ហើយនិយាយចេញដោយសំឡេងខ្លាំងថា យើងបានបុត្រក្នុងពោះត្រីហើយ ក៏នាំយកទារកនោះទៅរកលោកសេដ្ឋីជាស្វាមី ។

លោកសេដ្ឋីនៅមិនទាន់ព្រមប្រកាន់យកជាកម្មសិទ្ធ ដើម្បីទុកដូចជាកូនរបស់ខ្លួនឡើយ ទើបឲ្យគេវាយស្គរស្រែកប្រកាសថា អ្នកណា

មានកូនបាត់ដែរឬទេ ? ចូរមកយកទៅចុះ ។ កាលបើមិនមាននរណាមកទទួលទារកនោះ លោកសេដ្ឋីបាននាំយកទារកនោះចូលទៅគាល់ព្រះបាទពារាណសី ក្រាបបង្គំទូលឲ្យទ្រង់ជ្រាបរឿងហើយ ក៏ក្រាបទូលសួរថា ខ្ញុំព្រះអង្គនឹងធ្វើដូចម្តេចចំពោះទារកនេះ ។

ព្រះបាទពារាណសីត្រាស់តបថា នែលោកសេដ្ឋី ទារកនេះជាអ្នកមានបុណ្យច្រើនណាស់ ទើបមិនមានអន្តរាយ កាលដែលគេនៅក្នុងពោះត្រី លោកចូរចិញ្ចឹមទុកចុះ ។ សេដ្ឋី និងភរិយាបានចិញ្ចឹមទារកនោះទុកដូចជាកូន មិនមានស្អប់ខ្ពើមឆ្អើមស្អប់ឬបន្តិចបន្តួចឡើយ ។ កាលតមក ត្រកូលសេដ្ឋីដែលជាមាតាបិតា នៅក្នុងក្រុងកោសម្ពីក៏ដឹងរឿងរ៉ាវឮដំណឹងថា មានត្រកូលសេដ្ឋីនៅក្នុងក្រុងពារាណសី បានទារកនៅក្នុងពោះត្រី ក៏ប្រញាប់នាំគ្នាមកកាន់ផ្ទះលោកសេដ្ឋី នៅក្នុងក្រុងពារាណសីនោះមួយរំពេច ។

ក្នុងខណៈដែលមកដល់ផ្ទះលោកសេដ្ឋីក្នុងក្រុងពារាណសីនោះ ពីរនាក់ស្វាមី និងភរិយា ដែលជាសេដ្ឋីក្នុងក្រុងកោសម្ពី ជាមាតាបិតា

បង្កើតរបស់ទារកនោះ ក្រឡេកឃើញទារកនោះកំពុងតែលេង ក៏ចាំបាន ថាជាបុត្ររបស់ខ្លួន ទើបនិយាយឡើងថា ទារកនេះគួរឲ្យអាណិតណាស់ ប៉ុន្តែទារកនេះជាកូនរបស់យើង ក៏បានសម្តែងហេតុផលតាំងអំពីខាងដើម ទាល់តែចប់ ឲ្យសេដ្ឋីក្នុងក្រុងពារាណសីស្តាប់ ហើយចេញវាចាសូមកូន មកវិញ ។ចំណែកកិរិយារបស់សេដ្ឋីក្នុងក្រុងពារាណសី មិនព្រមប្រគល់ ឲ្យឡើយ ដោយអាងថា ទារកនេះបានមកអំពីពោះត្រី ដែលខ្លួនទិញតម្លៃ មួយពាន់កហាបណៈ ព្រោះដូច្នោះ ទារកនេះសូម្បីមិនមែនជាកូនរបស់ ខ្លួនពិតប្រាកដក៏ដោយ ក៏ហាក់បីដូចជាកូនរបស់ខ្លួន មិនព្រមឲ្យទៅជា ដាច់ខាត ។ ខាងមាតាបិតាពិតប្រាកដ បាននិយាយអង្វរគ្រប់យ៉ាងថា ទារកនេះមិនមែនបុត្ររបស់លោកពិតប្រាកដទេ ការពិតជាបុត្ររបស់ខ្ញុំ ព្រោះគេនៅក្នុងពោះរបស់ខ្ញុំ ១០ ខែ ។ ចំណែកមាតាបិតាចិញ្ចឹមបាន និយាយជំទាស់តទៅទៀតថា បុត្ររបស់អ្នកអាចនឹងត្រូវត្រីជទែលេបស៊ី បាត់ទៅហើយ គង់មិនមែនត្រីដែលខ្ញុំបានទារកនេះមកទេ ។សេដ្ឋីដែល ជាមាតាបិតាពិតប្រាកដ ឃើញអាកប្បកិរិយាថាមិនព្រមឲ្យ ទើបនាំគ្នា

ចូលទៅគាល់ព្រះបាទពារាណសី ដើម្បីឲ្យព្រះអង្គជួយវិនិច្ឆ័យ ក្នុងរឿងក្តីនេះ ។

ព្រះបាទពារាណសីទ្រង់វិនិច្ឆ័យថា នរណាៗ មិនអាចសម្រេចបានថា មាតាដើមនោះ មិនមែនមាតារបស់ទារកនេះ ព្រោះទារកនេះបានរស់នៅក្នុងផ្ទៃរបស់មាតាដើម ១០ ខែដែរ ។ អ្នកលក់ត្រីនោះ កាលបើបានលក់ទៅហើយ មិនបានទទួលត្រីនោះទុក ទើបមិនចាត់ថាជាមាតាបិតារបស់ទារកនេះ ។ ចំណែកកិរិយារបស់លោកសេដ្ឋីក្នុងក្រុងពារាណសី នរណាៗ ក៏មិនអាចសម្រេចបានថា មិនមែនមាតារបស់ទារក ព្រោះបានទារកមកពីក្នុងពោះត្រី ។ ព្រោះដូច្នោះ ទើបឲ្យទារកនេះជាទាយាទរបស់ត្រកូលទាំងពីរ និងឲ្យត្រកូលទាំងពីរជួយអភិបាលចិញ្ចឹមទារកនេះ ។ ចាប់ផ្តើមអំពីនោះមក ត្រកូលសេដ្ឋីទាំងពីរនោះ មានតែការចម្រើនឡើងដោយលាភយស ជាលំដាប់លំដោយមក ។ ត្រកូលសេដ្ឋីទាំងពីររួមគ្នាដាក់ឈ្មោះឲ្យកុមារនោះថា **ពាកុលៈ ឬ ពក្កុលៈ** ព្រោះជាអ្នកស្ថិតនៅក្នុងការគ្រប់គ្រងរបស់ត្រកូលទាំងពីរ ។ កាលបើពក្កុលៈធំ

ពេញវ័យហើយ ត្រកូលទាំងពីរបានកសាងប្រាសាទ ៣ ខ្នង ទុកក្នុងក្រុងរបស់ខ្លួនរៀងៗ ខ្លួន ឲ្យដល់ពក្កុលៈនោះ ពក្កុលៈស្នាក់អាស្រ័យនៅក្នុងក្រុងទាំងពីរនោះ ក្រុងនីមួយៗ ៤ ខែ ចំណែកពេលដែលនៅសល់អំពី ៤ ខែទៀតនោះ ជាពេលធ្វើដំណើរក្នុងរវាងក្រុងទាំងពីរ ដោយទូក ។ កាលបើពក្កុលៈនៅក្រុងនីមួយៗ គ្រប់ ៤ ខែហើយ ទើបត្រកូលទាំងពីរឲ្យចាត់ចែងកសាងមណ្ឌបឡើងលើទូក ហើយឲ្យពក្កុលៈ ជាមួយនឹងអ្នកបម្រើឡើងទៅនៅក្នុងមណ្ឌបលើទូកនោះ ហើយបញ្ជូនទៅកាន់ក្រុងមួយទៀត ដែលចំណាយពេលប្រមាណ ៤ ខែ ។

ចំណែកអ្នកក្រុងមួយទៀត កាលឃើញពួកគេជូនមកបានពាក់កណ្ដាលផ្លូវ អស់ពេលពីរខែហើយ បាននាំគ្នាចេញទៅទទួលចូលមកកាន់ក្រុងរបស់ខ្លួន ក៏ចំណាយពេលពីរខែទៀតដូចគ្នា រួមពេលធ្វើដំណើរទាំងអស់ ៤ ខែ ។ កាលបើពក្កុលៈនៅក្នុងត្រកូលនោះគ្រប់ ៤ ខែហើយ ទើបប្រញាប់ទៅក្រុងមួយទៀត ប្រើពេល ៤ ខែទៀតដូចគ្នា ជាការផ្លាស់ប្ដូរវិលទៅវិលមកនោះ រាប់ពេលដែលពក្កុលៈសោយនូវសេចក្ដី

សុខនេះបាន ៨០ ឆ្នាំពេញ ។

ក្នុងគ្រានោះ ព្រះសិទ្ធត្ថពោធិសត្វរបស់យើង ទ្រង់បានសម្រេចសម្មោធិញ្ញាណ ជាព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រកាសព្រះធម្មចក្រដ៏ប្រសើរ ហើយស្តេចចារិកទៅដោយលំដាប់ រហូតមកដល់ក្រុងកោសម្ពី ប៉ុន្តែមជ្ឈិមភាណកាចារ្យទាំងឡាយ បានពោលទុកថា ស្តេចយាងមកដល់ក្រុងពារាណសី ពក្កុលៈជ្រាបដំណឹងការយាងមកដល់នៃព្រះសាស្តា ទើបព្រមដោយបរិវារមានចំនួនច្រើន បានកាន់ផ្កាឈើ និងគ្រឿងក្រអូបចូលទៅគាល់ព្រះសម្ពុទ្ធ ដើម្បីនឹងបានស្តាប់ធម៌ទេសនា ហើយក៏មានសទ្ធាជ្រះថ្លា ប្រាថ្នានឹងបព្វជ្ជាឧបសម្បទានៅក្នុងធម្មវិន័យនេះទើបក្រាបទូលសូមបព្វជ្ជាឧបសម្បទាចំពោះព្រះលោកនាថ ។

កាលបើពក្កុលៈ បានទទួលព្រះពុទ្ធានុញ្ញាត ការបព្វជ្ជាឧបសម្បទាជាភិក្ខុហើយ បានស្តាប់ពុទ្ធោវាទ ដែលព្រះអង្គទ្រង់ប្រៀនប្រដៅមិនឲ្យប្រមាទ ឲ្យព្យាយាមប្រឹងប្រែងចម្រើនវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មានក្នុងថ្ងៃទី ៨ ក៏បានសម្រេចជាព្រះអរហន្ត ព្រមដោយបដិសម្ភិទា ៤ រាប់

ពីថ្ងៃដែលបព្វជ្ជាឧបសម្បទាមក ។ ចាប់ផ្ដើមពីថ្ងៃសម្រេចកិច្ចនៃបព្វជ្ជាឧបសម្បទាហើយព្រះពក្កុលត្ថេរឧស្សាហ៍ប្រកបកិច្ចក្នុងព្រះពុទ្ធសាសនារហូតប្រាកដថា លោកប្រព្រឹត្តប្រតិបត្តិតឹងរ៉ឹងបំផុតក្នុងនេសជ្ជិកធុតង្គ គឺការសមាទានអង្គុយមិនព្រមសិង និងអារញ្ញិកធុតង្គ បានដល់ ការសមាទាននៅក្នុងព្រៃជាប្រក្រតី ។

ចំណែកពួកអ្នកបម្រើរបស់លោកកាលនៅជាយរាវាសនៅក្នុងក្រុងទាំងពីរនោះ បាននាំគ្នាទៅកាន់ក្រុងរៀងៗ ខ្លួន រួចហើយបានធ្វើសំពត់ត្រៃចីវរបញ្ជូនទៅប្រគេន ព្រះពក្កុលត្ថេរមានចំនួនច្រើន ចំណែកព្រះពក្កុលត្ថេរ បានប្រើប្រាស់ត្រៃចីវរដែលបញ្ជូនពីក្រុងកោសម្ពី និងក្រុងពារាណសីនោះ មួយចំណែកៗ កន្លះខែរហូតជានិច្ច ។ វត្ថុណាជារបស់ល្អ ដែលមាននៅក្នុងត្រកូលទាំងពីរ សេដ្ឋីទាំងពីរក្រុងនោះ បានបញ្ជូនវត្ថុនោះៗ ទៅប្រគេនព្រះពក្កុលត្ថេរ មិនដែលលុះពេលឡើយ ។

ក្នុងពេលដែលព្រះពក្កុលត្ថេរ នៅជាយរាវាសរហូតអស់រយៈពេល ៨០ ឆ្នាំនោះ លោកមិនដែលមានជំងឺអ្វីឡើយ សូម្បីត្រឹមតែបន្តិចបន្តួច

ក៏មិនមាន ។ ចាប់ផ្តើមពីលោកបានបព្វជ្ជាឧបសម្បទាមកហើយ ក៏មិនដែលមានអាពាធសោះ ទាំងមិនខ្វះខាតនូវបច្ច័យ ៤ ទៀត ។

មូលហេតុដែលលោកមិនមានអាពាធនៅក្នុងបច្ចុប្បន្នជាតិនេះ ដោយអំណាចបុណ្យកុសលដែលធ្លាប់ប្រគេនថ្នាំ និងការតាំងសេចក្តីប្រាថ្នាទុកក្នុងអតីតជាតិ ទើបព្រះមានព្រះភាគ ទ្រង់តែងតាំងលោកទុកក្នុងតំណែងជាឯតទគ្គៈ ផ្នែកខាងអ្នកគ្មានអាពាធ ដែលបានពោលទុកនៅក្នុង គម្ពីរអង្គុត្តរនិកាយ ឯកនិបាត ដូចមានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ព្រះពក្កុលៈ ជាអ្នកប្រសើរជាងភិក្ខុទាំងឡាយដែលជាសាវករបស់តថាគត ផ្នែកខាងអ្នកគ្មានអាពាធ ។

កាលបើព្រះពក្កុលត្ថេរ បានសម្រេចជាព្រះអរហន្ត និងបានទទួលតំណែងឯតទគ្គៈហើយ លោកបានពោលគាថា ៣ គាថា ក្នុងចំណោមភិក្ខុសង្ឃ ដែលប្រាកដសេចក្តីនៅក្នុង គម្ពីរខុទ្ទកនិកាយ ថេរគាថា ថា ៖

បុគ្គលណា ( មិនធ្វើ ) នូវអំពើដែលគួរធ្វើ ក្នុងកាលមុន ហើយចង់ធ្វើក្នុងកាលក្រោយវិញ បុគ្គលនោះ រមែងឃ្លាតចាកឋានៈ

ជាសុខផង តែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយផង ។ បុគ្គលធ្វើអំពើណា ត្រូវនិយាយតែអំពើនោះមិនធ្វើអំពើណាមិនត្រូវនិយាយអំពើនោះឡើយ បណ្ឌិតទាំងឡាយ តែងកំណត់ដឹងច្បាស់នូវបុគ្គលកាលមិនធ្វើ បានតែនិយាយ ។ សេចក្តីទុក្ខរលត់ទៅក្នុងព្រះនិព្វានណា ព្រះនិព្វាននោះ ដែលព្រះសម្ពុទ្ធ ទ្រង់សម្តែងហើយ ជាគុណជាតមិនមានសេចក្តីសោក ប្រាសចាកធូលី ជាទីក្សេមក្សាន្តនាំមកនូវសេចក្តីសុខ ដោយប្រពៃមែនពិត ។

កិច្ចការផារព្រះសាសនា ដែលរាប់ថា ជាការសំខាន់របស់ព្រះពក្កុលត្ថេរ បានដល់ ការប្រាស្រ័យចរចាឆ្លើយឆ្លងគ្នា ជាមួយអចេលកស្សប ដែលជាសម្លាញ់ចាស់របស់លោកឲ្យកើតការយល់ចូលចិត្ត ឲ្យមានការជឿជ្រះថ្លាក្នុងព្រះសាសនា ដូចមានរឿងប្រាកដនៅក្នុង គម្ពីរមជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ ពក្កុលត្ថេរច្ឆរិយព្ភូតសូត្រ ថា ៖

សម័យមួយ ព្រះពក្កុលៈមានអាយុ នៅក្នុងវត្តវេឡុវ័នជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង អចេលឈ្មោះកស្សប

ជាសម្លាញ់របស់ព្រះពក្កុលៈមានអាយុ ក្នុងកាលនៅជាគ្រហស្ថពីដើម បានចូលទៅរកព្រះពក្កុលៈមានអាយុ លុះចូលទៅដល់ហើយ ក៏និយាយពាក្យរាក់ទាក់ សំណេះសំណាល ទៅរកព្រះពក្កុលៈមានអាយុ លុះបញ្ចប់ពាក្យសំណេះសំណាល និងពាក្យដែលគួររឭកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ លុះអចេលកស្សបអង្គុយក្នុងទីសមគួរហើយ ក៏សួរព្រះពក្កុលៈមានអាយុដូច្នេះថា បពិត្រព្រះពក្កុលៈមានអាយុ លោកម្ចាស់បួសយូរប៉ុន្មានឆ្នាំហើយ ។ ព្រះពក្កុលៈឆ្លើយថា អាត្មាបួស ៨០ វស្សាហើយ ។ អចេលកស្សបសួរទៀតថា បពិត្រព្រះពក្កុលៈមានអាយុ ចុះ ៨០ វស្សានេះ លោកសេពមេថុនប៉ុន្មានដង ? ម្នាលអាវុសោកស្សប អ្នកកុំសួរអាត្មាថា បពិត្រព្រះពក្កុលៈមានអាយុ ចុះ ៨០ វស្សានេះ លោកសេពមេថុនប៉ុន្មានដង យ៉ាងនេះឡើយ ម្នាលអាវុសោកស្សប អ្នកត្រូវសួរអាត្មាថា បពិត្រព្រះពក្កុលៈមានអាយុ ចុះ ៨០ វស្សានេះ កាមសញ្ញារបស់លោកធ្លាប់កើតប៉ុន្មានដង យ៉ាងនេះវិញ ។ ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនដែលមានកាមសញ្ញា

កើតឡើងទេ ។ព្រះពក្កុលៈមានអាយុ មិនដែលមានកាមសញ្ញាកើតឡើង អស់៨០វស្សាហើយ ដោយហេតុណា យើងខ្ញុំចំណាំទុកនូវហេតុនេះថា ជាអច្ឆរិយព្ភូតធម៌របស់ព្រះពក្កុលៈមានអាយុ ។ ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនដែលមានព្យាបាទសញ្ញា ... មិនដែលមានវិហិង្សាសញ្ញាកើតឡើងទេ ។ព្រះពក្កុលៈមានអាយុ មិនដែលមានវិហិង្សាសញ្ញាកើតឡើងអស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំចំណាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌របស់ព្រះពក្កុលៈ ។ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនដែលមានកាមវិតក្កកើតឡើងទេ ។ព្រះពក្កុលៈមានអាយុ មិនដែលមានកាមវិតក្កកើតឡើងអស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំចំណាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌របស់ព្រះពក្កុលៈមានអាយុ ។ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនដែលមានព្យាបាទវិតក្ក... មិនដែលមានវិហិង្សាវិតក្កកើតឡើងទេ ។ ព្រះពក្កុលៈមានអាយុ មិនដែលមានវិហិង្សាវិតក្កកើតឡើងអស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំ

ចំណាំទុកនូវហេតុនេះថា ជាអច្ឆរិយព្ភូតធម៌របស់ព្រះពក្កុលៈ មានអាយុ ។ ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនធ្លាប់ត្រេកអរនឹងគហបតីចីវរទេ ។ ព្រះពក្កុលៈមានអាយុ មិនធ្លាប់ត្រេកអរនឹងគហបតីចីវរ អស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំចំណាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌របស់ព្រះពក្កុលៈមានអាយុ ។ ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនធ្លាប់កាត់ចីវរ ដោយកាំបិតទេ... អាត្មាមិនធ្លាប់ដេរចីវរដោយម្ជុលទេ... មិនធ្លាប់ជ្រលក់ចីវរ ដោយគ្រឿងជ្រលក់ទេ... មិនធ្លាប់ដេរចីវរលើឈើស្នឹងទេ... មិនធ្លាប់ចាត់ចែងចីវរកម្មរបស់សព្រហ្មចារីបុគ្គលទាំងឡាយទេ... មិនធ្លាប់ត្រេកអរនឹងការនិមន្តទេ... មិនធ្លាប់មានគំនិតឡើងថា ធ្វើដូចម្តេចហ្ន៎ បុគ្គលណាមួយ គប្បីមកនិមន្តអញទេ ។បេ។អាត្មាមិនដែលអង្គុយក្នុងចន្លោះផ្ទះទេ... មិនដែលឆាន់ក្នុងចន្លោះផ្ទះទេ... មិនដែលកាន់យកនិមិត្តរបស់មាតុគ្រាម ដោយអនុព្យញ្ជនៈទេ... មិនដែលសម្តែងធម៌ដល់មាតុគ្រាម ដោយហោចទៅសូម្បីត្រឹមតែគាថា ៤ បទទេ... មិនដែលចូលទៅកាន់សម្នាក់ភិក្ខុនីទេ...

មិនដែលសម្តែងធម៌ដល់ភិក្ខុនីទេ... មិនដែលសម្តែងធម៌ដល់សិក្ខមានាទេ... មិនដែលសម្តែងធម៌ដល់សាមណេរីទេ... មិនដែលបំបួសទេ... មិនដែលឲ្យឧបសម្បទាទេ... មិនដែលឲ្យនិស្ស័យទេ... មិនដែលឲ្យសាមណេរបម្រើទេ មិនដែលស្រប់កាយក្នុងផ្ទះសម្រាប់កម្តៅកាយទេ... មិនដែលស្រប់កាយដោយគ្រឿងលម្អិតទេ... មិនដែលត្រេកអរនឹងការគក់ប្របាច់ខ្លួន របស់សព្រហ្មចារីបុគ្គលទេ... មិនដែលមានអាពាធកើតឡើង ដោយហោចទៅ សូម្បីតែដំណួចពិសទេ... មិនដែលផ្អែកបង្អែកទេ... មិនដែលដេកទេ ។ ព្រះពក្កុលៈមានអាយុ មិនដែលដេកអស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំសូមចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌របស់ព្រះពក្កុលៈមានអាយុ ។

ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនដែលចូលវស្សាក្នុងទីសេនាសនៈ ក្នុងស្រុកទេ ។ព្រះពក្កុលៈមានអាយុ មិនដែលចូលវស្សាក្នុងទីសេនាសនៈក្នុងស្រុកអស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំសូមចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌របស់

ព្រះពក្កុលៈមានអាយុ ។ អាត្មាប្រកបដោយកិលេស ឆាន់បិណ្ឌបាត របស់អ្នកដែន តែ ៧ ថ្ងៃ លុះដល់ថ្ងៃទី ៨ អរហត្តផលក៏កើតឡើង ។ ព្រះពក្កុលៈមានអាយុ ប្រកបដោយកិលេស ឆាន់បិណ្ឌបាតរបស់អ្នក ដែនតែ ៧ ថ្ងៃ លុះដល់ថ្ងៃទី ៨ អរហត្តផលក៏កើតឡើង ដោយហេតុណា យើងខ្ញុំសូមចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈ មានអាយុ ។

បពិត្រព្រះពក្កុលៈមានអាយុ ខ្ញុំគប្បីបាននូវបព្វជ្ជា គប្បីបាននូវ ឧបសម្បទាក្នុងធម្មវិន័យនេះ ។ អចេលកស្សបក៏បាននូវបព្វជ្ជា បាននូវ ឧបសម្បទាក្នុងធម្មវិន័យនេះ ។ លុះព្រះកស្សបបានឧបសម្បទាមិនយូរ ប៉ុន្មានក៏ចៀសចេញទៅតែម្នាក់ឯង ជាអ្នកមិនប្រមាទ មានព្យាយាមដុត កម្ដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន កុលបុត្រទាំងឡាយ ចេញចាកផ្ទះ ទៅបួសក្នុងផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរ-ធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃ ព្រហ្មចរិយៈ ដោយប្រាជ្ញាដ៏ឧត្តម ចំពោះខ្លួនឯងក្នុងបច្ចុប្បន្ន ហើយ

សម្រាកសម្រាន្តនៅដោយឥរិយាបថទាំង ៤ រមែងដឹងថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបាននៅរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះកស្សបមានអាយុ ក៏ជាព្រះអរហន្តមួយរូបដែរ ។ លុះសម័យជាខាងក្រោយមក ព្រះពក្កុលៈមានអាយុ កាន់យកកូនសោ ចេញអំពីវិហារចូលទៅកាន់វិហារ ហើយពោលពាក្យយ៉ាងនេះថា សូមលោកមានអាយុទាំងឡាយ ថយចេញទៅសិន សូមលោកមានអាយុទាំងឡាយ ថយចេញទៅសិន ខ្ញុំនឹងបរិនិព្វានក្នុងថ្ងៃនេះ ។ ព្រះកស្សបពោលថា ព្រះពក្កុលៈមានអាយុបានកាន់យកកូនសោ ចេញអំពីវិហារចូលទៅកាន់វិហារ ហើយពោលយ៉ាងនេះថា សូមលោកមានអាយុទាំងឡាយ ថយចេញទៅសិន សូមលោកមានអាយុទាំងឡាយថយចេញទៅសិនខ្ញុំនឹងបរិនិព្វានក្នុងថ្ងៃនេះ ដោយហេតុណា ខ្ញុំចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌របស់ព្រះពក្កុលៈ មានអាយុ ។ ឯព្រះពក្កុលៈមានអាយុ អង្គុយបរិនិព្វាន ក្នុងទី

កណ្ដាលភិក្ខុសង្ឃ ។ព្រះពក្កុលៈមានអាយុ អង្គុយបរិនិព្វាន ក្នុងទីកណ្ដាលភិក្ខុសង្ឃ ដោយហេតុណា ខ្ញុំក៏ចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌របស់ព្រះពក្កុលៈមានអាយុ ។

មានរឿងដែលទាក់ទងនឹងអាយុវែង និងការរំលត់ខន្ធបរិនិព្វានរបស់ព្រះពក្កុលត្ថេរ ក្នុង **អដ្ឋកថាបបញ្ចសូទនី** ដែលអធិប្បាយសេចក្ដីព្រះបាលី **ពក្កុលត្ថេរច្ឆរិយព្ភូតសូត្រ** និង **គម្ពីរមជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ** ដូចមានសេចក្ដីថា ៖

ព្រះពក្កុលត្ថេរ រាប់ថាជាអ្នកមានអាយុវែងជាងគេមួយរូប ក្នុងបណ្ដាអសីតិមហាសាវកទាំងអស់ ព្រោះលោកមានអាយុបាន ១៦០ ឆ្នាំ ម្យ៉ាងទៀត មុននឹងលោកបរិនិព្វាន បានអធិដ្ឋានចិត្តថា កាលខ្ញុំព្រះករុណាមានជីវិតរស់នៅ ក៏មិនធ្លាប់ជាភារៈរបស់ភិក្ខុរូបណាមួយឡើយ កាលបើខ្ញុំព្រះករុណាបរិនិព្វានទៅ សូមកុំឲ្យសរីរៈរបស់ខ្ញុំព្រះករុណាជាភារៈស្មុគស្មាញ ធ្ងន់ធ្ងរដល់ភិក្ខុសង្ឃឡើយ ហើយទើបលោកអង្គុយចូលតេជោធាតុ បរិនិព្វានទៅ នៅក្នុងចំណោមទីប្រជុំសង្ឃនោះ ។

កាលបើលោកបរិនិព្វានទៅហើយ បានមានអណ្តាតភ្លើងចេញពីសរីរៈរបស់លោក ឆេះសរីរៈឲ្យសល់តែអដ្ឋិធាតុ ដែលមានសណ្ឋានស្រដៀងនឹងផ្កាម្លិះក្រពុំ ។៚

( ចប់ ជីវប្រវត្តិរបស់ព្រះពក្កុលត្ថេរ )

# ✍ ជីវប្រវត្តិរបស់ព្រះសោភិតត្ថេរ ✍

## " ដែលជាឯតទគ្គៈផ្នែកខាងរឭកឃើញនូវបុព្វេនិវាស "

*ព្រះសោភិតត្ថេរ ជាមហាពុទ្ធសាវកមួយរូបដ៏ឆ្នើម លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវក ថែមទាំងជាអ្នកទ្រទ្រង់នូវបុព្វេនិវាសានុស្សតិញ្ញាណ មានជំនាញក្នុងការរឭកជាតិកន្លងមកហើយបានរហូតដល់ព្រះសាស្ដាទ្រង់ត្រាស់សរសើរ ក្នុងកណ្ដាលបរិស័ទ ដូចដែលបានពោលទុកក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ថា ៖*

***ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ បុព្វេនិវាសំ អនុស្សរន្តានំ យទិទំ សោភិតោ*** *ម្នាលភិក្ខុទាំងឡាយ សោភិតៈ ជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវករបស់តថាគត ផ្នែកខាងរឭកនូវបុព្វេនិវាសានុស្សតិញ្ញាណ ។*

*ជីវប្រវត្តិរបស់ព្រះសោភិតត្ថេរ មានរឿងតំណាលប្រាកដនៅក្នុងអដ្ឋកថាមនោរថបូរណី និង អដ្ឋកថាបរមត្ថទីបនី ដែលបរិយាយសេចក្ដី*

ក្នុង គម្ពីរខុទ្ទកនិកាយ ថេរគាថា ដូចមានសេចក្តីថា ៖

ព្រះសោភិតៈ បានកសាងសន្សំបុណ្យកុសលជាច្រើនទុក តាំងពីសាសនានៃព្រះបទុមុត្តរៈមក ។ ដោយគ្រានោះ លោកបានមកចុះចាប់បដិសន្ធិនៅក្នុងត្រកូលមួយ នៅជិតក្រុងហង្សវតី ពេលដែលលោកធំដឹងក្តីហើយ ដែលអាចយល់ដឹងសេចក្តីល្អ និងអាក្រក់ក្នុងរឿងជីវិតបាន ។ ថ្ងៃមួយ សោភិតៈ បានទៅស្តាប់ព្រះធម៌ទេសនាព្រះបទុមុត្តរៈ នៅឯវត្តរួមជាមួយនឹងពួកមហាជនជាច្រើន ។ ចៃដន្យថ្ងៃនោះ ព្រះបទុមុត្តរៈទ្រង់សម្តែងធម៌ចប់ ព្រះអង្គទ្រង់ប្រកាសតែងតាំងព្រះថេរៈមួយរូប ទុកក្នុងតំណែងជាឯតទគ្គៈ គឺជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងរឭកនូវបុព្វេនិវាសានុស្សតិញ្ញាណ ។ សោភិតៈឃើញព្រះថេរៈរូបនោះ បានទទួលការប្រកាសឈ្មោះក្នុងកណ្តាលបរិស័ទទាំង ៤ គឺភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ថាជាអ្នកមានភាពជំនាញ ផ្នែកខាងរឭកជាតិបាន ក៏នឹកកើតការពេញចិត្តក្នុងតំណែងនោះ ហើយបានតាំងចិត្តធ្វើបុណ្យកុសលផ្សេងៗ ដោយសង្ឃឹមថា ផលនេះនឹងឲ្យបានសម្រេចតំណែងដូចព្រះថេរៈរូបនោះ

ដែរ ។ ហើយគិតថា បុណ្យ ឬអំពើល្អនេះ សមគួរដល់សេចក្តីប្រាថ្នារបស់ខ្លួនហើយ ទើបតាំងសេចក្តីប្រាថ្នាតំណែងនោះ នៅចំពោះព្រះភក្ត្រនៃព្រះបទុមុត្តរៈ គ្រានោះ ព្រះអង្គព្យាករថា សេចក្តីប្រាថ្នារបស់អ្នក នឹងបានសម្រេចក្នុងកាលជាអនាគត ។

តាំងអំពីពេលនោះមក លោកតែងតែព្យាយាមបំពេញនូវបុណ្យកុសលជារឿយៗ រហូតដល់អស់ជីវិត កាលលោកអស់ជីវិតទៅហើយ បានទៅកើតក្នុងសុគតិទេវលោក ទាំងនេះកើតឡើងដោយអំណាចសេចក្តីល្អផ្សេងៗ ដែលលោកបានធ្វើទុកហើយនោះឯង ។ លុះមកដល់ពុទ្ធសម័យនៃព្រះសុមេធៈ លោកបានត្រឡប់មកកើតនៅក្នុងត្រកូលព្រាហ្មណ៍ ។ ប៉ុន្តែក្នុងត្រកូលព្រាហ្មណ៍នោះ មានទំនៀមក្នុងការសិក្សាវិជ្ជាជាខាងដើម គឺវិជ្ជាត្រៃវេទ ពេលដែលសោភិតៈធំដឹងក្តីហើយ បានទៅរៀនវិជ្ជាត្រៃវេទរហូតដល់ចប់ ប៉ុន្តែលោកមិនបានយកវិជ្ជាទាំងនោះ ទៅប្រើប្រាស់ក្នុងការចិញ្ចឹមជីវិតទេ កាលបើសម្រេចវិជ្ជាត្រៃវេទរបស់ព្រាហ្មណ៍ហើយ លោកទើបចេញមកបួសជាតាបស សាងអាស្រមនៅក្បែរព្រៃហិមពាន្ត ចិញ្ចឹម

ជីវិតដោយផ្លែឈើ និងមើមឈើ ។ សោភិតតាបស បានតាំងចិត្តបំពេញផ្នួសនៅក្នុងព្រៃប្រមាណ ១៨ ឆ្នាំ ក៏មិនបានជ្រាបដំណឹងការកើតឡើងនៃព្រះសម្មាសម្ពុទ្ធ ។ ថ្ងៃមួយ សោភិតតាបសនោះបានធ្វើដំណើរមកដល់ក្រុងកទ្ទវតី ក៏បានជ្រាបដំណឹងថា ព្រះសុមេធសម្ពុទ្ធ ទ្រង់កើតឡើងក្នុងលោកហើយ ព្រះអង្គកំពុងតែសម្តែងប្រាប់នូវអមតធម៌ ដល់សត្វលោកឲ្យរួចផុតអំពីសេចក្តីទុក្ខ ដូច្នេះមានតែយើងចូលទៅគាល់ព្រះលោកនាថអង្គនោះ លុះបានចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមុនី ហើយពោលសរសើរថា ព្រះអង្គជាសាស្តារបស់ខ្ញុំ ព្រះអង្គជាទង់ជ័យនៃសត្វលោកដូច្នេះជាដើម ។

ព្រះសុមេធសម្ពុទ្ធទ្រង់ត្រាស់ព្យាករឡើងថា តាបសដែលពោលសរសើរតថាគតនេះ នឹងមានសេចក្តីសុខក្នុងសម្បរាយិកភព គឺក្នុងភពខាងមុខ ។ ដោយអំណាចបុញ្ញកម្មដែលសោភិតតាបស បានពោលសរសើរដោយសទ្ធាជ្រះថ្លានោះ ក៏ជួយឲ្យសោភិតតាបស មកកើតក្នុងមនុស្សលោកខ្លះ ទៅកើតក្នុងទេវលោកខ្លះ មានសេចក្តីសុខអស់កាល

ដ៏យូរអង្វែង ។ លុះមកដល់ពុទ្ធកាលរបស់ព្រះសមណគោតមនៃយើង តាបសនេះបានកើតនៅក្នុងវណ្ណព្រាហ្មណ៍ ក្នុងនគរសាវត្ថី មានឈ្មោះថា សោភិតៈ ។ ចំណែកមាតាបិតារបស់លោកនោះ មិនប្រាកដថា មានឈ្មោះអ្វីទេ ។ សោភិតៈ កាលចម្រើនវ័យធំដឹងក្តីហើយ ល្មមនឹងសិក្សាចំណេះដឹង ក៏បានទៅសិក្សានៅក្នុងលទ្ធិរបស់ព្រាហ្មណ៍ ។

ទាក់ទងនឹងមូលហេតុ ដែលសោភិតៈកើតនៅក្នុងត្រកូលព្រាហ្មណ៍ ហើយស្រាប់តែបានត្រឡប់មកជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។ ព្រោះក្នុងថ្ងៃមួយសោភិតមាណព បានចូលទៅកាន់ពុទ្ធសម្នាក់ និងបានទទួលការស្តាប់ធម្មកថា ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ កើតសេចក្តីជ្រះថ្លា និងមានការជឿយ៉ាងមុតមាំ ទើបបានចេញមកបព្វជ្ជាឧបសម្បទាជាភិក្ខុនៅក្នុងធម្មវិន័យនេះ កាលតាបសនោះបួសជាភិក្ខុហើយ លោកជាអ្នកមិនប្រមាទ ឧស្សាហ៍បំពេញសេចក្តីព្យាយាម ធ្វើសមណធម៌ តាំងចិត្តចម្រើនវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មានលោកក៏បានសម្រេចជាព្រះអរហន្ត ព្រមដោយអភិញ្ញា ៦ និងបដិសម្ភិទា ៤ ជាព្រះខីណាស្រពដ៏

ប្រសើរ និងជាអ្នកពេញចិត្តសន្សំនូវវសី គឺភាពជំនាញ មាន ៥ ប្រការ បានដល់ **១-អាវជ្ជវសី** ជំនាញក្នុងការនឹក **២-សមាបជ្ជនវសី** ជំនាញក្នុងការចូល **៣-អធិដ្ឋានវសី** ជំនាញក្នុងការរក្សា **៤-វុដ្ឋានវសី** ជំនាញក្នុងការចេញ **៥-បច្ចវេក្ខណវសី** ជំនាញក្នុងការពិចារណា ។

គោលទាំង ៥ ប្រការនេះ ជាគោលដែលព្រះយោគាវចរ អ្នកបានបឋមជ្ឈានហើយ លោកធ្វើឲ្យស្ទាត់ជំនាញជាកិច្ច ។ ចំណែកព្រះសោភិតៈ មានភាពជំនាញក្នុងការរឭកនូវបុព្វេនិវាសានុស្សតិញ្ញាណបានយ៉ាងរហ័សរហួន ព្រោះលោកអាចរឭកដល់ជាតិមុនបានដោយលំដាប់រហូតដល់ជាតិដែលកើតក្នុងអសញ្ញីព្រហ្ម បានដល់ព្រហ្មមួយពួកដែលមានត្រឹមតែរូបមិនមានសញ្ញា ។ ពេលដែលលោករឭកដល់ជាតិដែលកើតក្នុងអសញ្ញីព្រហ្ម មិនបានឃើញការប្រព្រឹត្តទៅនៃចិត្ត នៅរហូតអស់ ៥០០ កប្ប បានមកឃើញជាតិចុងក្រោយបំផុតប៉ុណ្ណោះ ទើបលោកនឹកថា កើតយ៉ាងណា ។ កាលនឹកយ៉ាងនេះហើយ ក៏យល់បានថា ភពដែលជាអសញ្ញី គឺជាភពដែលមិនមានសញ្ញា ។ ព្រោះដូច្នោះ ទើបព្រះ

មហាវីរៈទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដែលឈ្មោះថាអសញ្ញី គឺជាទេវតាដែលមានអាយុវែង សោភិតៈ ជាអ្នកចុតិចាកទេវតាចំពូកនោះហើយ មកកើតក្នុងជាតិនេះ សោភិតៈ ទើបរឭកបានត្រឹមតែភពមួយប៉ុណ្ណោះ ។

កាលតមក ព្រះទសពល ទ្រង់ប្រកាសតែងតាំងព្រះសោភិតត្ថេរ ដែលជាអ្នកជំនាញក្នុងការរឭកជាតិ ឲ្យជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងបាននូវបុព្វេនិវាសានុស្សតិញ្ញាណ គឺញាណដែលរឭកជាតិកន្លងមកហើយ ។ កាលព្រះសោភិតត្ថេរ ពិចារណាមើលនូវបុព្វេនិវាសានុស្សតិញ្ញាណរបស់ខ្លួន និងការបដិបត្តិដែលជាបច្ច័យបាននូវបុព្វេនិ-វាសានុស្សតិញ្ញាណនោះក៏កើតបីតិសោមនស្ស ទើបបន្លឺឧទានថា ភិក្ខុណាដែលមានសតិ មានបញ្ញា មានសេចក្ដីព្យាយាម គឺខ្លួនយើងរឭកជាតិកន្លងមកហើយ ក្នុងមួយយប់បានដល់ ៥០០ កប្ប យើងចម្រើនសតិប្បដ្ឋាន ៤ និងពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ហើយរឭកជាតិកន្លងមកហើយក្នុងមួយយប់បានដល់ ៥០០ កប្ប ។

ព្រះសោភិតៈ បានតំណាលជីវប្រវត្តិខ្លួនឯងទុក ទាំងអតីតជាតិ និងបច្ចុប្បន្នជាតិ ដែលមានប្រាកដនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដូចមានសេចក្តីថា ៖

ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ជាចម្បងក្នុងលោក ទ្រង់ជានរាសភៈ ទ្រង់សម្តែងធម៌ ជាចំណែកព្រះនិព្វាន ដល់ពួកជនច្រើន ។ កាលនោះ ខ្ញុំបានស្តាប់នូវព្រះពុទ្ធដីកា របស់ព្រះអង្គនោះ ដែលទ្រង់ពោលដោយវាចាដ៏អង់អាច ខ្ញុំផ្គងអញ្ជលី មានចិត្តនឹកក្នុងអារម្មណ៍តែមួយ ។សមុទ្រប្រសើរជាងស្ទឹងទាំងឡាយ ភ្នំព្រះសិនេរុប្រសើរជាងភ្នំទាំងឡាយ យ៉ាងណាមិញ ជនណាប្រព្រឹត្តដោយអំណាចចិត្ត ជននោះមិនដល់មួយចំណិតនៃពុទ្ធញ្ញាណឡើយ ក៏យ៉ាងនោះដែរ ។ លុះព្រះសម្ពុទ្ធជាឥសី ប្រកបដោយសេចក្តីករុណា ទ្រង់បញ្ឈប់នូវធម្មវិធី គង់ក្នុងកណ្តាលជំនុំសង្ឃ ហើយសម្តែងនូវគាថាទាំងឡាយនេះថា ជនណាបានសរសើរនូវញាណនៃព្រះពុទ្ធ ជាលោកនាយក ជននោះឯង រមែងមិនទៅកាន់ទុគ្គតិ អស់មួយសែនកប្ប នឹងជុតបំផ្លាញនូវកិលេសទាំង

ឡាយ មានចិត្តនឹកក្នុងអារម្មណ៍តែមួយ មានចិត្តតម្កល់មាំ និងបាននាម ថា សោភិតៈ ជាសាវកនៃព្រះសាស្តា ។

លុះមកដល់ពុទ្ធកាលនៃព្រះសុមេធសម្ពុទ្ធ ខ្ញុំបានកសាងអាស្រម ជាអ្នកស្វែងរកនូវប្រយោជន៍ នៅជិតព្រៃហិមពាន្ត ក្នុងកាលនោះ ខ្ញុំជាអ្នកសន្តោស មិនត្រេកអររីករាយ ក្នុងលាភសក្ការៈ បានចិញ្ចឹមជីវិតដោយផ្លែឈើ និងមើមឈើ ។ ព្រះពុទ្ធទ្រង់ព្រះនាមសុមេធៈ ស្តេចកើតឡើងក្នុងលោក ពេលនោះ សូម្បីព្រះពុទ្ធត្រាស់ដឹងកន្លងទៅ ១៨ ឆ្នាំហើយ ខ្ញុំព្រះអង្គក៏មិនបានជ្រាបដំណឹងនោះ ។ ថ្ងៃមួយ ខ្ញុំបានធ្វើដំណើរទៅកាន់ក្រុងកទ្ធវតី ។ ពេលនោះ ព្រះសុមេធសម្ពុទ្ធ ទ្រង់កំពុងសម្តែងព្រះធម៌ទេសនា កាលបើចប់ព្រះធម៌ទេសនាហើយ ម្នាក់ៗ ក៏ថ្វាយបង្គំលាព្រះសយម្ភូត្រឡប់ទៅវិញ គ្រានោះ ខ្ញុំព្រះអង្គបានជណ្តប់សំពត់ធៀងស្មាម្ខាង ចូលទៅក្រាបថ្វាយបង្គំព្រះយុគលបាទរបស់ព្រះអង្គ ហើយក្រាបទូលសរសើរថា ព្រះអង្គជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គជាប្រទីបរបស់មហាជន ទ្រង់ជាអ្នកប្រសើរជាងទេវតា និងមនុស្ស

ទាំងឡាយ ទ្រង់ជាអ្នកដឹកនាំសត្វលោក ឲ្យឆ្លងផុតអំពីសេចក្តីទុក្ខក្នុងលោកនេះ មិនមានអ្នកណាក្រៃលែងជាងព្រះអង្គឡើយ ថែមទាំងមិនមាននរណាក្នុងលោកនេះ អាចដឹងស្មើនឹងព្រះអង្គបាន ប្រៀបដូចទឹកក្នុងមហាសមុទ្រ មិនមានបុគ្គលណាអាចដឹងប្រមាណបាន ដូច្នោះ មិនមាននរណាអាចថ្លឹងថ្លែងការដឹងរបស់ព្រះអង្គបាន មិនមាននរណាអាចវាស់ការដឹងរបស់ព្រះអង្គបានដែរ ដូចគ្នានឹងមិនអាចវាស់អាកាសបានដូច្នោះ លុះពោលសរសើរចប់ហើយក៏នៅស្ងៀម ។

ព្រះសុមេធសម្ពុទ្ធ ទ្រង់ជាបរមគ្រូរបស់មហាជនក្នុងលោក គ្រានោះ ទើបទ្រង់ត្រាស់ឡើងថា តាបសដែលពោលសរសើរតថាគតនេះ ដោយអំណាចការជ្រះថ្លានោះ បានធ្វើឲ្យតាបសនេះ សោយនូវសេចក្តីសុខក្នុងទេវលោក រហូតអស់ ៧៧ កប្ប និងបានកើតជាព្រះឥន្ទ្រមួយពាន់ជាតិ ជាស្តេចចក្រពត្តិច្រើនរយជាតិទៀតផង ជាព្រះរាជាចំពោះប្រទេសនោះរាប់ជាតិមិនអស់ មិនថាកើតជាមនុស្ស ឬទេវតាទេ ជាអ្នកមានបញ្ញារហ័សរហួនជានិច្ចកាល ក្នុង ៣ម៉ឺនកប្បខាងមុខ នឹងមានព្រះ

សម្មាសម្ពុទ្ធ ទ្រង់ព្រះនាមគោតម ស្ដេចឧប្បត្តិឡើងក្នុងលោក ក្នុងរាជវង្ស ព្រះបាទឱក្កាករាជ តាបសនោះក៏បានចេញបព្វជ្ជា ថែមទាំងបានសម្រេច ជាព្រះអរហន្តតាំងពីអាយុ ៧ ខួបម៉្លេះ ។

ព្រះសោភិតត្ថេរ បានតំណាលតទៅទៀតថា ឥឡូវនេះខ្ញុំព្រះអង្គបានដុតបំផ្លាញកិលេសទាំងឡាយ ភពទាំងពួងខ្ញុំបានដកចេញហើយ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានបដិបត្តិហើយ ។ ក្នុងកប្បទី ៥ ម៉ឺន ខ្ញុំបានកើតជាស្ដេចចក្រពត្តិ ៧ ជាតិ ព្រះនាមសមុគ្គតៈដូចគ្នា ទ្រង់បរិបូណ៌ដោយកែវទាំង ៧ ប្រការ មាន មានកម្លាំងច្រើន ខ្ញុំបានសម្រេចបដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបាន បដិបត្តិហើយដែរ ។

ព្រះសោភិតត្ថេរ បានសម្រេចជាព្រះអរហន្ត លោកទ្រទ្រង់ទុក នូវបដិសម្ភិទា ៤ នោះគឺ

**១-អត្ថប្បដិសម្ភិទា** គឺការបែកធ្លាយក្នុងអត្ថ បានដល់ការយល់

អធិប្បាយអត្ថនៃភាសិតសង្ខេបឲ្យពិស្តារបាន ។

**២-ធម្មប្បដិសម្ភិទា** គឺបែកធ្លាយក្នុងធម៌ បានដល់ការយល់ ឬស្រាវជ្រាវរកហេតុផល ក្នុងធម៌ទាំងនោះ ។

**៣-និរុត្តិប្បដិសម្ភិទា** គឺបែកធ្លាយក្នុងភាសា បានដល់ ពាក្យដែលនិយាយឲ្យអ្នកដទៃយល់ រហូតទាំងយល់ភាសាប្រទេសផ្សេងៗ ។

**៤-បដិភាណប្បដិសម្ភិទា** គឺបែកធ្លាយក្នុងបដិភាណ បានដល់ការពលឈ្លាសវៃឆ្លើយតបបញ្ហាចំពោះមុខបានភ្លាមៗ ។

ព្រះសោភិតៈ លោកជាអ្នកទ្រទ្រង់ទុកនូវវិមោក្ខ ៨ គឺការរួចផុតស្រឡះចាកកិលេសដោយមគ្គ ៤ និងផល ៤ ឬបានដល់រូបជ្ឈាន ៤ និងអរូបជ្ឈាន ៤ ។

មគ្គប្រែថាផ្លូវ មាន ៤ ប្រការ បានដល់

**១-សោតាបត្តិមគ្គ** គឺផ្លូវបដិបត្តិ ដើម្បីឲ្យបានសម្រេចផល ជាព្រះសោតាបន្ន ។

**២-សកទាគាមិមគ្គ** គឺផ្លូវបដិបត្តិ ដើម្បីឲ្យបានសម្រេចផល

ជាព្រះសកទាគាមី ។

**៣-អនាគាមិមគ្គ** គឺផ្លូវបដិបត្តិ ដើម្បីឲ្យបានសម្រេចផល ជាព្រះអនាគាមី ។

**៤-អរហត្តមគ្គ** គឺផ្លូវបដិបត្តិ ដើម្បីឲ្យបានសម្រេចផល ជាព្រះអរហន្ត ។

ផល សំដៅដល់វត្ថុដែលកើតពីហេតុ ឬប្រយោជន៍ដែលមាន ៤ ប្រការនោះ បានដល់

**១-សោតាបត្តិផល** គឺផលនៃការចូលដល់ក្រសែនៃធម៌ ឬក្រសែនៃព្រះនិព្វាន ។

**២-សកទាគាមិផល** គឺផលរបស់អ្នកនឹងមកកើតម្តងទៀត ។

**៣-អនាគាមិផល** គឺផលរបស់អ្នកមិនមកកើតទៀត ។

**៤-អរហត្តផល** បានដល់ ផល គឺការសម្រេចជាព្រះអរហន្ត ។

រូបជ្ឈាន គឺឈានមានរូបធម៌ជាអារម្មណ៍ មាន ៤ យ៉ាង គឺ

**១-បឋមជ្ឈាន** បានដល់ ឈានទី ១ ឬឈានខាងដើម មាន អង្គ ៥ គឺវិតក្ក វិចារៈ បីតិ សុខ ឯកគ្គតា ។

**២-ទុតិយជ្ឈាន** បានដល់ ឈានទី ២ មានអង្គ ៣ គឺបីតិ សុខ ឯកគ្គតា ។

**៣-តតិយជ្ឈាន** បានដល់ឈានទី ៣ មានអង្គ ២ គឺសុខ ឯកគ្គតា ។

**៤-ចតុត្ថជ្ឈាន** បានដល់ ឈានទី ៤ មានអង្គ ២ គឺឧបេក្ខា ឯកគ្គតា ។

អរូបជ្ឈាន ៤ គឺឈានមានអរូបធម៌ជាអារម្មណ៍ មាន ៤ យ៉ាងគឺ

**១-អាកាសានញ្ចាយតនជ្ឈាន** គឺការកំណត់ដឹងអាកាសគ្មានទីបំផុតជាអារម្មណ៍ ។

**២-វិញ្ញាណញ្ចាយតនជ្ឈាន** គឺការកំណត់ដឹងវិញ្ញាណដែលគ្មានទីបំផុតជាអារម្មណ៍ ។

**៣-អាកិញ្ចញ្ញាយតនជ្ឈាន** គឺការកំណត់ដឹងការៈដែលមិនមានអ្វីជាអារម្មណ៍ ។

**៤-នេវសញ្ញានាសញ្ញាយតនជ្ឈាន** គឺការកំណត់ដឹងដល់ការៈមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន និងចូលដល់សញ្ញាវេទយិតនិរោធ គឺការរលត់សញ្ញា ការចាំដឹងសេចក្តី និងវេទនា ( ការដឹងអារម្មណ៍ ) ។

ព្រះសោភិតៈ លោកជាអ្នកបរិបូណ៌ដោយអភិញ្ញានោះ គឺការដឹងដ៏ក្រៃលែង មាន ៦ ប្រការ គឺ

**១-ឥទ្ធិវិធិ** សម្តែងឫទ្ធិផ្សេងៗ បាន ដូចមនុស្សម្នាក់និម្មិតឲ្យជាច្រើននាក់បាន មនុស្សច្រើននាក់និម្មិតឲ្យជាម្នាក់បានជាដើម ។

**២-ទិព្វសោត** បានដល់ ត្រចៀកទិព្វ គឺមានញាណពិសេសដែលអាចធ្វើឲ្យស្តាប់អ្វីៗ បានឮទាំងអស់ តាមសេចក្តីប្រាថ្នា ។

**៣-ចេតោបរិយញ្ញាណ** បានដល់ ការកំណត់ដឹងចិត្តរបស់អ្នក

ដទៃបាន ។

៤-បុព្វេនិវាសានុស្សតិញ្ញាណ បានដល់ ការរឭកជាតិដែលកន្លងមកហើយបាន ។

៥-ទិព្វចក្ខុ បានដល់ ភ្នែកទិព្វ គឺអាចក្រឡេកមើលទៅឃើញពួកសត្វដែលប្រព្រឹត្តទៅផ្សេងៗ គ្នា ព្រោះដោយអំណាចរបស់កម្ម ។

៦-អាសវក្ខយញ្ញាណ បានដល់ ការដឹងនូវការអស់ទៅនៃអាសវៈទាំងពួង ។

ដែលបានពោលថា លោកជាអ្នកទ្រទ្រង់នូវវិជ្ជា ៣ ប្រការនោះក៏រាប់រួមនៅក្នុងអភិញ្ញា ៦ ដោយសេចក្ដីដូចគ្នានឹងខ.ទី ៤-៥-៦ តែមានសេចក្ដីផ្សេងគ្នាដោយព្យញ្ជនៈថា បុព្វេនិវាសានុស្សតិញ្ញាណ ស្របគ្នានឹងបុព្វេនិវាសានុស្សតិ ចុតូបបាតិញ្ញាណ គឺដឹងការកើត និងការស្លាប់របស់សត្វទាំងឡាយ ស្របគ្នានឹងទិព្វចក្ខុ ចំណែកខ.ទី ៣ ស្របគ្នាទាំងដោយអត្ថ និងព្យញ្ជនៈ លោកហៅថា អាសវក្ខយញ្ញាណដូចគ្នា ។

ផលដែលជាប្រយោជន៍ ឲ្យព្រះសោភិតៈ បានសម្រេចគុណធម៌ដ៏ខ្ពង់ខ្ពស់នោះ ព្រោះអាស្រ័យបុណ្យបារមី ដែលលោកបានធ្វើទុកមកហើយ មានការពោលសរសើរគុណព្រះសម្មាសម្ពុទ្ធជាដើម ទើបធ្វើឲ្យលោកបានប្រសព្វសម្បត្តិមនុស្ស សម្បត្តិទេវតា និងសម្បត្តិព្រះនិព្វាន ។ ដូច្នេះគួរឲ្យយើងទាំងឡាយ ប្រញាប់ប្រញាល់ធ្វើសេចក្តីល្អផ្សេងៗ ទុក មិនត្រូវរវីរវល់ចាំឲ្យបុគ្គលដទៃធ្វើឲ្យទេ ការរវល់រាវរកអល់អែកអស់សង្ឃឹម ពឹងលើអ្នកដទៃ ក៏នឹងដូចការនៅរង់ចាំលេបដុំបាយដែលអ្នកដទៃគេបញ្ចុក ដោយមិនបានតាំងចិត្ត ឬមិនបានបញ្ចុកហើយ ពេលណាយើងនឹងបានឆ្អែត តើយើងនឹងបានអាហារសមតាមសេចក្តីប្រាថ្នា របស់យើងបានយ៉ាងណា កាលបើយើងមិនព្រមបរិភោគដោយខ្លួនឯងទេនោះ ។

ជីវប្រវត្តិរបស់ព្រះសោភិតត្ថេរ លោកជាអ្នកទ្រទ្រង់នូវភាពដ៏ប្រសើរយ៉ាងនេះ គឺការរឭកជាតិកន្លងទៅហើយបាននោះ ក៏ព្រោះមកអំពីការបំពេញបុណ្យកុសល ដែលប្រព្រឹត្តទៅជាបារមីញាណ ទើប

ធ្វើឲ្យលោកបានជួបប្រសព្វនូវហេតុដ៏អស្ចារ្យបែបនេះទៅបាន ដូច្នេះ បុណ្យដែលយើងបានធ្វើហើយ រមែងតែងតែធ្វើឲ្យយើងបានសម្រេចដូចបំណង ដូចជាព្រះសោភិតៈជាគម្រូ ឬជាគតិសម្រាប់យើងគ្រប់គ្នាហើយ ដែលសមគួរដល់យើងទាំងអស់គ្នា ញុំាងសេចក្តីជ្រះថ្លាចំពោះបុណ្យកុសលឲ្យក្រៃលែងឡើងថែមទៀត ។

កាលលោកទ្រទ្រង់អាយុសង្ខារ មកដល់កាលដ៏សមរម្យហើយ លោកក៏រំលត់ខន្ធបរិនិព្វានទៅ ។៚

( ជីវប្រវត្តិរបស់ព្រះសោភិតត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះឧបាលិត្ថេរ ✍

## " ដែលជាឯតទគ្គៈផ្នែកខាងទ្រទ្រង់ព្រះវិន័យ "

ព្រះឧបាលិត្ថេរ លោកជាកម្លាំងសំខាន់របស់ព្រះពុទ្ធសាសនាមួយរូបក្នុងឋានៈដែលតាំងនៅក្នុងតំណែងអ្នកទ្រទ្រង់ព្រះវិនយបិដកដែលជាឫសកែវរបស់ព្រះពុទ្ធសាសនា ហើយលោកតាំងចិត្តបដិបត្តិតាមយ៉ាងតឹងរ៉ឹង ព្រមទាំងទូន្មាន និងជម្រះអធិករណ៍ឲ្យមានយុត្តិធម៌ដល់គូជម្លោះទាំងអស់ ដើម្បីឲ្យព្រះពុទ្ធសាសនាចម្រើនរុងរឿងជាទីគោរពបូជារបស់មហាជនតទៅ រហូតបានទទួលនូវការលើកតម្កើងអំពីព្រះបរមសាស្តា ដូចបានទទួលនូវសញ្ញាប័ត្រថ្នាក់បណ្ឌិត និងកិត្តិយសដ៏ឧត្តមខ្ពង់ខ្ពស់បំផុតរបស់ពិភពលោក ដែលចាត់ជាកិត្តិគុណដ៏ថ្លៃថ្លាបំផុត ។

ជីវប្រវត្តិក្នុងអតីតជាតិរបស់ព្រះឧបាលិត្ថេរមានសម្ដែងនៅក្នុងអដ្ឋកថាគម្ពីរមនោរថបូរណី និងបាលី គម្ពីរខុទ្ទកនិកាយ អបទាន តែសេចក្ដីក្នុង គម្ពីរខុទ្ទកនិកាយ អបទាន ចាត់ទុកជាការប្រកាសបុព្វកម្ម

ដែលចងជាគាថាយ៉ាងពិស្ដារ ដោយការរៀបរាប់អំពីជីវប្រវត្តិផ្ទាល់ខ្លួន ហើយលោកបានសម្ដែង ក្រោយពេលលោកបានសម្រេចជាព្រះអរហន្ត តែប្រវត្តិរបស់លោក មានរឿងជាប់ទាក់ទង ក្នុងអតីតជាតិរបស់ព្រះបុណ្ណមន្តានីបុត្តត្ថេរផង ដែលមានសេចក្ដីដូចតទៅនេះ ៖

ក្នុងអតីតជាតិមួយ លោកបានកើតជាព្រាហ្មណ៍ឈ្មោះថា **សុជាត** ជាអ្នកមានទ្រព្យសម្បត្តិ ៨០ កោដិ នៅក្នុងក្រុងហង្សវតី រៀនសម្រេចវិជ្ជាត្រៃវេទ ព្រមទាំងគម្ពីរពិសេសច្រើនប្រភេទទៀតផ្នែកព្រហ្មញ្ញសាសនា។ កាលតមក ក្នុងពេលព្រះបទុមុត្តរសម្មាសម្ពុទ្ធទ្រង់ឧប្បត្តិឡើងក្នុងលោក ហើយយាងទៅប្រថាប់គង់នៅក្រុងហង្សវតី បានទ្រង់សម្ដែងធម៌ប្រោសព្រះពុទ្ធបិតាក្នុងកណ្ដាលប្រជុំជន ដែលនៅពេញត្រៀបត្រាក្នុងបរិវេណប្រមាណមួយយោជន៍ ក្នុងគ្រានោះ សុនន្ទតាបស ឬហៅឈ្មោះម្យ៉ាងទៀតថា **គោតមឥសី** បាននិម្មិតបាំពុំផ្កាឡើងគ្របប្រជាជនទាំងអស់ដែលនៅក្នុងទីនោះ ខណៈដែលព្រះបទុមុត្តរសម្មាសម្ពុទ្ធទ្រង់សម្ដែងសច្ចធម៌ ៤ ប្រការ នៅខាងក្នុងមណ្ឌបផ្កាឈើនោះ ។ មានសេចក្ដីថា មានទេវតានិងមនុស្សប្រមាណមួយសែនកោដិ បានសម្រេចប្រយោជន៍ដ៏ធំ គឺ

សម្រេចមគ្គផលព្រះនិព្វាន លុះព្រះបទុមុត្តរសម្មាសម្ពុទ្ធទ្រង់សម្តែងធម៌ ៧ យប់ ៧ ថ្ងៃ ព្រឹកថ្ងៃទី ៨ ទើបទ្រង់ព្យាករសុនន្ទតាបសថា សុនន្ទតាបសនេះកាលត្រាច់រន្ធាត់វិលវល់ស្លាប់ កើតក្នុងមនុស្សលោក និងទេវលោក ហើយក្នុងមួយសែនកប្បទៅអនាគត ជាអ្នកប្រសើរជាងទេវតា និងមនុស្សទាំងពួង បានជាសាវករបស់ព្រះគោតមសម្ពុទ្ធដែលមាននាមថា **បុណ្ណមន្តានីបុត្ត** ចំណែកសុជាតព្រាហ្មណ៍បានស្តាប់ព្រះពុទ្ធតម្រាស់ព្យាករសុនន្ទតាបសរបស់ព្រះបទុមុត្តរសម្មាសម្ពុទ្ធ ដូច្នេះហើយ ត្រូវការនឹងធ្វើបុណ្យខ្លះ កាលបានឃើញភិក្ខុមួយរូបជាអ្នកបានទទួលលើកតម្កើងពីព្រះបទុមុត្តរសម្មាសម្ពុទ្ធ ជាកំពូលខាងទ្រទ្រង់នូវព្រះវិន័យ ទើបធ្វើបុណ្យហើយប្រាថ្នា ឲ្យបានជាកំពូលផ្នែកទ្រទ្រង់ព្រះវិន័យ និងបានកសាងអារាមឈ្មោះថា **សោភណៈ** ប្រគេនចំពោះព្រះភិក្ខុសង្ឃទាំងឡាយ មានព្រះបទុមុត្តរសម្មាសម្ពុទ្ធទ្រង់ជាប្រធាន ។ លុះកសាងសោភណារាមស្រេចហើយ បានធ្វើការឆ្លងអស់ទ្រព្យជាច្រើនទៀត ព្រះសាស្តាទុមុត្តរសម្មាសម្ពុទ្ធទ្រង់ព្យាករថា សុជាតព្រាហ្មណ៍បានកសាងអារាមថ្វាយសង្ឃនេះ នឹងបានជាអ្នកប្រកបព្រមដោយសេចក្តី

សុខក្នុងមនុស្សលោក និងទេវលោកអស់កាលដ៏យូរ គឺនឹងបានជាសក្កទេវរាជមួយពាន់ជាតិ នឹងបានជាស្តេចចក្រពត្តិមួយពាន់ជាតិ នឹងបានជាព្រះរាជាក្នុងប្រទេសផ្សេងៗ ដោយរាប់ជាតិមិនបាន ហើយនឹងបានជាសាវ័ករបស់ព្រះសមណគោតមសម្មាសម្ពុទ្ធក្នុងកប្បទី ១ សែនទៅអនាគត ដោយមានឈ្មោះថា **ឧបាលី** ។

ចំណែកក្នុងបច្ចុប្បន្នជាតិនេះ ព្រះឧបាលី ឬសុជាតព្រាហ្មណ៍នោះ បានមកកើតជាបុត្ររបស់នាយជាងកោរកាត់ គឺជាងកាត់សក់ ឬកោរសក់ក្នុងនគរកបិលពស្តុ ហើយបានទទួលការជ្រើសរើសនាមថា **ឧបាលី** កាលឧបាលីចម្រើនវ័យឡើងហើយ បានទទួលតំណែងជានាយកូសាមាលានៃស្តេចសក្យវង្សទាំង ៥ គឺភទ្ទិយ: ១ អនុរុទ្ធ ១ អានន្ទ ១ ភគ្គុ ១ កិម្ពិល: ១ ហេតុដែលបានទទួលតំណែងនេះ ព្រោះជាទីជ្រះថ្លាពេញព្រះហឫទ័យនៃស្តេចសក្យវង្សទាំង ៥ ព្រះអង្គនោះ ។

តែការដែលព្រះឧបាលី ត្រូវមកកើតជាកូនរបស់នាយជាងកោរកាត់ដែលចាត់ទុកថា ជាត្រកូលមានឋានៈថោកទាបនោះ ដោយអាស្រ័យព្រះឧបាលីធ្លាប់បានធ្វើអំពើធ្គាំធ្គងចំពោះព្រះបវេតបច្ចេកពុទ្ធក្នុងអតីតជាតិ

ដូចមានរឿងដែលសម្តែងទុកក្នុងបាលី **គម្ពីរខុទ្ទកនិកាយ អបទាន** ថា ៖

ក្នុងកប្បទី ២ រាប់អំពីកប្បនេះទៅ មានក្សត្រឈ្មោះអញ្ចស្ស មានតេជៈរកទីបំផុតគ្មាន មានយសរាប់មិនបានជាម្ចាស់ផែនដី មានទ្រព្យច្រើន ។ ខ្ញុំជាព្រះរាជបុត្ររបស់ព្រះរាជានោះ ជាក្សត្រឈ្មោះចន្ទនៈ ជាអ្នករឹងត្អឹង ដោយស្រវឹងព្រោះជាតិផង ដោយស្រវឹងព្រោះយសសក្តិ និងភោគៈផង ។ មានពួកដំរីមាតង្គៈចំនួន ១ សែន សុទ្ធតែចុះប្រេងដោយហេតុ ៣ ប្រការ ដ៏ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ចោមរោមខ្ញុំសព្វៗ កាល វេលានោះ ខ្ញុំមានពួកពលរបស់ខ្លួនចោមរោមហើយប្រាថ្នាទៅកាន់ឧទ្យាន ឡើងជិះដំរីឈ្មោះ **សិរិកៈ** ចេញអំពីនគរទៅ ។ ស្រាប់តែមានព្រះបច្ចេកសម្ពុទ្ធព្រះនាមរេវតៈ ទ្រង់បរិបូណ៌ដោយចរណៈ មានទ្វារគ្រប់គ្រងសង្រួមល្អ បាននិមន្តមកចំពោះមុខខ្ញុំ ។ វេលានោះខ្ញុំបានបរដំរីឈ្មោះសិរិកៈទៅឲ្យបៀតបៀនព្រះបច្ចេកពុទ្ធ លំដាប់នោះដំរីក៏ក្រោធខឹងមិនលើកជើង ។ លុះខ្ញុំឃើញដំរី មានចិត្តខឹងក៏ក្រេវក្រោធនឹងព្រះបច្ចេកពុទ្ធជាម្ចាស់ បៀតបៀនព្រះបច្ចេកពុទ្ធ ហើយក៏ទៅក្នុងឧទ្យាន ។ ខ្ញុំមិនបាននូវសេចក្តីសុខស្រួលក្នុងឧទ្យាននោះ ក្បាលរបស់

ខ្ញុំហាក់ដូចជាភ្លើងឆេះខ្ញុំអន្ទះអន្ទែងដោយសេចក្តីក្រហល់ក្រហាយ ដូចត្រីជាប់សន្ទូច ។ ផែនដីដែលមានសាគរជាទីបំផុត ហាក់ដូចជាដុតកម្តៅខ្ញុំ ទើបខ្ញុំចូលទៅកាន់សម្នាក់នៃព្រះបិតា ហើយក្រាបបង្គំទូលថា យើងខ្ញុំបៀតបៀនព្រះបច្ចេកពុទ្ធ ដូចបុគ្គលបៀតបៀនអាសិរពិស ឬដូចបុគ្គលបៀតបៀនគំនរភ្លើង ឬក៏ដូចបុគ្គលបៀតបៀនដំរីមានភ្លុកដែលចុះប្រេង ។ ព្រះបច្ចេកពុទ្ធជាម្ចាស់អង្គនោះមានតបៈដ៏ខ្ពង់ខ្ពស់ក្លៀវក្លា ជាព្រះជិនស្រី យើងខ្ញុំបៀតបៀនហើយ យើងខ្ញុំទាំងអស់គ្នានឹងវិនាស យើងខ្ញុំនឹងញ៉ាំងព្រះសយម្ភូជាមុនីអង្គនោះឲ្យអត់ទោសឲ្យ ។ ប្រសិនបើយើងខ្ញុំមិនបានញ៉ាំងព្រះបច្ចេកពុទ្ធដែលមានខ្លួនទូន្មានហើយ មានព្រះហឫទ័យខ្ជាប់ខ្ជួននោះ ឲ្យអត់ទោសឲ្យទេ ដែនរបស់យើងខ្ញុំមុខជាវិនាស ក្នុងថ្ងៃទី ៧ មិនខាន ។ ក្សត្រ ៤ ព្រះអង្គ ព្រះនាមសុមេខលៈ ១ កោសិយៈ ១ សិគវៈ ១ សត្តកៈ ១ ជាមួយនឹងពួកសេនាបានបៀតបៀនឥសីទាំងឡាយ ហើយដល់នូវសេចក្តីវិនាស ។ ខ្ញុំបានប្រជុំពួកបុរសក្នុងទី ៣ ពាន់យោជន៍ បានចូលទៅគាល់ព្រះសយម្ភូដើម្បីនឹងសម្តែងទោស ពួកបុរសទាំងពួងស្លៀកសំពត់ទទឹក មានក្បាលទទឹក ធ្វើក្រពុំម្រាមដៃក្រាបទៀបព្រះ

បច្ចេកពុទ្ធហើយទូលថា បពិត្រព្រះអង្គ មានព្យាយាមធំ សូមព្រះអង្គអត់ទោស (ព្រោះ) ជនសូមទោសព្រះអង្គ សូមព្រះអង្គរម្ងាប់ក្រវល់ក្រវាយ សូមព្រះអង្គកុំធ្វើដែន (របស់យើងខ្ញុំ) ឲ្យវិនាសឡើយ ។ ពួកបុរសទាំងអស់ព្រមទាំងទេវតា និងមនុស្ស ទាំងអ្នកធ្វើទាន ទាំងអ្នកយាម គេនឹងយកញញួរដែកមកទម្លាយអំបែងក្បាលយើងខ្ញុំសព្វៗកាល (ប្រសិនបើព្រះអង្គមិនអនុគ្រោះទេ) ។

ព្រះបច្ចេកពុទ្ធត្រាស់ថា ភ្លើងមិនឋិតនៅក្នុងទឹក ពូជមិនដុះលើថ្មក្ដី ដង្កូវមិនឋិតនៅក្នុងឱសថ ការក្រោធមិនមានកើតក្នុងព្រះបច្ចេកពុទ្ធទេ ។ ផែនដីមិនកម្រើក សមុទ្រសាគរប្រមាណមិនបាន អាកាសរកទីបំផុតគ្មានយ៉ាងណាមិញ ព្រះបច្ចេកពុទ្ធទាំងឡាយ មានព្រះហឫទ័យមិនរំជួយញាប់ញ័រក៏យ៉ាងនោះដែរ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ មានព្យាយាមធំ មានខន្តីទូន្មាន អត់ធន់ មានតបៈ ពួកបុគ្គលអ្នកអំណត់អត់ធន់មិនមានលុះក្នុងអគតិ ព្រះបច្ចេកពុទ្ធទ្រង់ត្រាស់ដូច្នេះហើយ ទើបរម្ងាប់ក្រវល់ក្រវាយរបស់ខ្ញុំ ហើយហោះទៅតាមអាកាស ក្នុងទីចំពោះមុខមហាជនក្នុងកាលនោះ ។

ការដែលព្រះឧបាលិត្ថេរ មានសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា រហូតដល់ការចូលមកបព្វជ្ជាឧបសម្បទាប្រព្រឹត្តវត្តព្រហ្មចរិយៈ ក្នុងព្រះធម៌វិន័យ មានសម្តែងប្រាកដនៅក្នុង **គម្ពីរចុល្លវគ្គ** វិនយបិដកក្នុង **សង្ឃភេទក្ខន្ធកៈ** និងនៅក្នុង **អដ្ឋកថាគម្ពីរធម្មបទ** នៃ **យមកវគ្គ** រឿងទេវទត្ត មានសេចក្តីថា ៖

ការចេញបួសរបស់ព្រះឧបាលិ មានការទាក់ទងនឹងក្សត្រសក្យៈទាំង ៥ ព្រះអង្គ គឺ ១ ភទ្ទិយៈ ២ អនុរុទ្ធ ៣ អានន្ទ ៤ ភគ្គុ ៥ កិម្ពិលៈ និង ៦ នៅក្នុងកោលិយវង្ស គឺទេវទត្ត ក្សត្រទាំងអស់នេះមានបំណងនឹងបួសក្នុងព្រះពុទ្ធសាសនា ហើយបានបបួលឧបាលីជាងកោរកាត់ឲ្យជាប់តាមទៅដែរ ទើបរួមជា ៧ នាក់ ។ ក្សត្រទាំង ៦ ព្រះអង្គយាងចេញចាកព្រះនគរ ព្រមដោយចតុរង្គសេនា គឺមានពលសេះ ពលដំរី ពលរថ ពលថ្មើរជើងហាក់ដូចជាយាងទៅប្រពាតព្រះរាជឧទ្យានដូច្នោះ លុះយាងទៅដល់ព្រំប្រទល់របស់ក្សត្រដទៃហើយ ក៏ត្រាស់បញ្ជាឲ្យក្បួនចតុរង្គសេនាត្រឡប់វិញ ដើម្បីកុំឲ្យមានការយល់ខុសដល់ក្សត្រក្នុងដែននោះៗ ហើយនាំគ្នាយាងចូលទៅកាន់រាជធានីរបស់ក្សត្រដទៃ ដោយ

មិនឲ្យមានអ្នកណា មកការពាររក្សាមុននឹងយាងចូលអាណាចក្ររបស់ក្សត្រដទៃ ក្សត្រទាំង ៦ ព្រះអង្គ ទ្រង់ដោះគ្រឿងអាភរណៈចេញសិន ហើយនាំគ្នាប្រគល់គ្រឿងអលង្ការទាំងអស់ ឲ្យដល់ឧបាលីជាងកោរកាត់ ដោយត្រាស់ថា ម្នាលឧបាលី អ្នកចូរនាំយកគ្រឿងអាភរណៈទាំងនេះ ត្រឡប់ទៅព្រះនគរវិញចុះ របស់ទាំងអស់នេះមានតម្លៃច្រើន ល្មមចិញ្ចឹមជីវិតរបស់អ្នកបានអស់មួយជីវិត ឧបាលីជាងកោរកាត់ក្រាបចុះទៀបបាទមូលនៃក្សត្រទាំង ៦ ព្រះអង្គនោះ ហើយបានស្រែកយំ ដោយសេចក្តីអាល័យ មិនបំណងនឹងទទួលឡើយ តែចាំបាច់ត្រូវតែទទួល ព្រោះមិនអាចរឹងទទឹងចំពោះព្រះរាជបញ្ជាបាន ទើបទទួលយកកញ្ចប់គ្រឿងអាភរណៈនោះមក ក្រាបថ្វាយបង្គំលាធ្វើដំណើរត្រឡប់មកតែម្នាក់ឯង ខណៈដែលដើរមកតាមផ្លូវ ក៏គិតខ្លាចការយល់ខុសរបស់ពួកសក្យៈព្រះញាតិថា ក្សត្រសក្យរាជទាំងអស់ ឃើញយើងយកគ្រឿងអលង្ការទៅ នឹងគិតថាយើងសម្លាប់ពួករាជកុមារ ហើយដណ្តើមយកអលង្ការទាំងនោះ អាចនឹងដាក់ព្រះរាជអាជ្ញាដល់យើងដោយធ្ងន់ធ្ងរ គឺប្រហារជីវិតយើងយ៉ាងពិតប្រាកដ ទើបនឹកគិតថា ហេតុអ្វីហ្ន៎ ក្សត្រទាំង

អស់នេះលះសម្បត្តិដ៏ឱឡារ និងគ្រឿងអាភរណៈដ៏មានតម្លៃទាំងនេះបាន ដោយមិនមានអាល័យហួងហែង ដូចជាស្តោះទឹកមាត់ចោល ហើយចេញបួសនៅក្នុងព្រះសាសនាបាន តែយើងមិនមានសម្បត្តិត្រឹមតែបន្តិចសោះឡើយ ហេតុអ្វីក៏លះបង់មិនបាន ។ ឧបាលីជាងកោរកាត់ កាលគិតដូច្នេះហើយ ក៏ស្រាយកញ្ចប់គ្រឿងអលង្ការចេញនាំយកគ្រឿងអលង្ការទាំងនោះព្យួរទុកលើមែកឈើ ហើយពោលប្រកាសថា អ្នកណាប្រាថ្នាចូរយកទៅប្រើប្រាស់ជាប្រយោជន៍ចុះ ហើយប្រញាប់ជាប់តាមក្សត្រទាំងនោះទៅ លុះពួកក្សត្រទាំងនោះឃើញឧបាលីជាងកោរកាត់ ត្រឡប់មកក៏ត្រាស់ថា អ្នកត្រឡប់មកធ្វើអ្វីឧបាលី ឧបាលីជាងកោរកាត់ទូលប្រាប់នូវបំណងរបស់ខ្លួនឲ្យទ្រង់ជ្រាប ហើយក៏បានទទួលការយល់ព្រមអំពីក្សត្រទាំងនោះ ទីបំផុតអ្នកទាំង ៧ បាននាំគ្នាធ្វើដំណើរទៅកាន់ **មល្លរដ្ឋជនបទ** ចូលគាល់ព្រះមានជោគដែលគង់នៅក្នុងអនុបិយអម្ពវ័នថ្វាយបង្គំហើយក្រាបទូលសូមបព្វជ្ជាឧបសម្បទាក្នុងធម៌វិន័យ ។

តែមុនពេលដែលព្រះមានព្រះភាគ ប្រទានការបួសដល់បណ្តាក្សត្រទាំងនោះៗ បានក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពួកខ្ញុំព្រះអង្គ

ជាក្សត្រ ច្រើនដោយខត្តិយមានះដ៏ខ្លាំងក្លា ឧបាលីជាងកោរកាត់នេះជា អាមាត្យ អ្នកបម្រើជាប់តាមខ្ញុំព្រះអង្គមកជាយូរ សូមព្រះអង្គប្រទាន បព្វជ្ជាដល់ឧបាលីជាងកោរកាត់មុន ហើយសឹមឲ្យខ្ញុំព្រះអង្គទាំងឡាយ បានបួសក្នុងកាលជាខាងក្រោយ ដោយបំណងថា ឧបាលីជាងកោរកាត់ នឹងជារៀមច្បង ពួកខ្ញុំព្រះអង្គទាំងអស់ នឹងបានក្រាបថ្វាយបង្គំគោរព រាប់អាន ដើម្បីកម្ចាត់ខត្តិយមានះឲ្យអស់ទៅពីខន្ធសន្តាន ព្រះសាស្តា ទ្រង់ប្រោសប្រទាន បព្វជ្ជាឧបសម្បទាដល់ឧបាលីជាងកោរកាត់នោះមុន ហើយប្រោសប្រទានបព្វជ្ជាឧបសម្បទាដល់ក្សត្រទាំង ៦ ព្រះអង្គ ក្នុង កាលជាក្រោយ ។

រឿងដែលព្រះឧបាលិត្ថេរក្រាបទូលសូមអនុញ្ញាត ចំពោះព្រះ មានព្រះភាគ ដើម្បីចូលទៅនៅក្នុងព្រៃ ព្រះមានព្រះភាគបានត្រាស់ទូន្មាន ព្រះឧបាលិត្ថេរ មានសម្តែងក្នុងបាលី **ឧបាលីសូត្រ គម្ពីរអង្គុត្តរនិកាយ ទសកនិបាត** ថា ៖

គ្រានោះ ឧបាលិត្ថេរចូលទៅថ្វាយបង្គំគាល់ដល់ទីប្រថាប់ ហើយ បានក្រាបទូលថា បពិត្រព្រះមានជោគ ខ្ញុំព្រះអង្គបំណងនឹងទៅនៅក្នុង

សេនាសនៈដែលស្ងប់ស្ងាត់ក្នុងព្រៃធំ ព្រះមានព្រះភាគត្រាស់ថា ម្នាល ឧបាលិ សេនាសនៈដែលស្ងាត់ក្នុងព្រៃធំជាកន្លែងនៅបានដោយលំបាក ធ្វើសេចក្ដីស្ងប់ស្ងាត់បានដោយកម្រ ការនៅម្នាក់ឯងជាការត្រេកអរបាន ដោយកម្រ ព្រៃទាំងឡាយហាក់ដូចជានាំយកចិត្តរបស់ភិក្ខុអ្នកមិនមាន សមាធិទៅ ភិក្ខុឧបាលីណាពោលថា យើងជាអ្នកមិនបានសមាធិ នឹង នៅក្នុងទីសេនាសនៈដែលស្ងាត់ក្នុងព្រៃធំ ភិក្ខុនោះនឹងត្រូវលិចចុះ ឬ នឹងរវើរវាយ ។ ប្រៀបដូចជាអន្លង់ទឹកធំ មានដំរីកម្ពស់ ៧ ហត្ថ ឬ ៧ ហត្ថកន្លះ បានដើរមកដល់អន្លង់ទឹកធំនោះ ដំរីនោះគិតថា យើងនឹងចុះទៅ កាន់អន្លង់ទឹកនេះ ហើយគប្បីដុសត្រចៀក និងខ្នងខ្លះ លុះងូត ផឹកទឹក ហើយ ឡើងចាកអន្លង់ទឹកត្រឡប់ទៅតាមសេចក្ដីត្រូវការ សេចក្ដីនោះ ព្រោះហេតុអ្វី ព្រោះថាដំរីនោះមានរាងកាយធំ ជើងរមែងជាន់ដល់ផ្ទៃដី ឈរនៅក្នុងអន្លង់ទឹកជ្រៅបាន បើទន្សាយ ឬខ្លាត្រីមកដល់អន្លង់ទឹកនេះ ទន្សាយ ឬខ្លាត្រី គិតថា យើងជាស្អី ដំរីជាស្អី យើងក៏នឹងចុះទៅក្នុង អន្លង់ទឹកធំនេះ លាងត្រចៀក ត្រដុសខ្នងលេងឲ្យសប្បាយ ហើយងូត ផឹកទឹក និងឡើងចាកអន្លង់ទឹកត្រឡប់ទៅតាមសេចក្ដីត្រូវការ ទន្សាយ

ឬខ្លាត្រីនោះ ក៏ចុះទៅក្នុងអន្លង់ទឹកធំនោះដ៏ឆាប់រហ័ស ដោយមិនបាន ពិចារណា វានឹងត្រូវលិចចុះ ឬអណ្តែតទៅ សេចក្តីនោះព្រោះហេតុអ្វី ព្រោះថា ទន្សាយ ឬខ្លាត្រីនោះមានរាងកាយតូច ជើងជាន់មិនដល់ផ្ទៃដី ដែលនឹងឈរនៅក្នុងអន្លង់ទឹកជ្រៅបាន យ៉ាងណាមិញ ភិក្ខុឧបាលីណា ពោលថា កាលយើងមិនបានសមាធិ នឹងត្រូវនៅក្នុងសេនាសនៈដ៏ស្ងប់ស្ងាត់ក្នុងព្រៃធំ ភិក្ខុនោះនឹងត្រូវលិចចុះ ឬរាយមាយដូច្នោះឯង ឧបាលី ប្រៀបដូចក្មេងតូចដេកផ្ងារ រមែងលេងបស្សាវៈ និងឧច្ចារៈរបស់ខ្លួន អ្នកយល់សេចក្តីនោះយ៉ាងណា ក្មេងតូចនេះលេងតាមបែបក្មេងខ្ចីមិនមែនឬ ព្រះឧបាលិត្ថេរក្រាបទូលឆ្លើយថា បពិត្រព្រះមានព្រះភាគយ៉ាងនោះឯងព្រះអង្គ ! ព្រះមានព្រះភាគត្រាស់សួរថា ម្នាលឧបាលី តមកខាងក្រោយក្មេងតូចនោះក៏ធំឡើង រមែងលេងគ្រឿងលេងទាំងឡាយ ដែលជារបស់ក្មេងលេងតូចៗ គឺនង្គ័លតូច លេងវាយហ៊ឹង លេងកន្ត្រាឈើ លេងកន្ត្រាស្លឹកឈើ លេងវាល់ខ្សាច់ លេងរថតូចៗ លេងធ្នូតូចៗ អ្នកយល់យ៉ាងណា ការលេងនេះជាការលេ ងដែលល្អក្រៃលែង និងប្រណីតជាងការលេង ដែលមានក្នុងគ្រាមុនមិនមែនឬ ព្រះឧបាលិត្ថេរ

ក្រាបទូលឆ្លើយថា យ៉ាងនោះហើយ ព្រះអង្គ ព្រះមានព្រះភាគត្រាស់តទៅថា ម្នាលឧបាលី សម័យតមក ក្មេងនោះអាស្រ័យការចម្រើនធំធាត់ឡើងទៀត អាស្រ័យការរឹងប៉ឹងនៃរាងកាយ ជាអ្នកបម្រើខ្លួនប្រកបព្រមដោយកាមគុណ ៥គឺរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ដែលជាទីប្រាថ្នាជាទីត្រេកអរ ជាទីពេញចិត្ត នាំឲ្យមានសេចក្តីតម្រេក ម្នាលឧបាលី អ្នកយល់យ៉ាងណា ការលេងនេះជាការលេងដ៏ល្អក្រៃលែងជាង និងប្រណីតជាងការលេងដែលមានក្នុងពេលមុនមិនមែនឬ ព្រះឧបាលិត្ថេរក្រាបទូលឆ្លើយថា យ៉ាងនោះហើយព្រះអង្គ ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបាលី ព្រះតថាគតឧប្បត្តិឡើងក្នុងលោកនេះ ជាព្រះអរហន្ត ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គឯង ទ្រង់ដល់ព្រមដោយវិជ្ជា និងចរណៈ យាងទៅល្អហើយ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ជាសារថី ទូន្មានបុរសដែលគួរទូន្មានបាន ទ្រង់មិនមានបុគ្គលដទៃក្រៃលែងជាងដោយគុណ ជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ចទាំង ៤ ទ្រង់រីកហើយ ទ្រង់ចែកនូវធម៌ព្រះតថាគតអង្គនោះ ទ្រង់ដឹងច្បាស់នូវលោកនេះ ព្រមទាំងទេវលោក

មារលោក ព្រហ្មលោក ដោយព្រះបញ្ញាញាណដ៏ក្រៃលែង ហើយទ្រង់ទូន្មានពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទេវតា និងមនុស្សឲ្យដឹងតាមទ្រង់សម្តែងធម៌ដែលល្អបទដើម បទកណ្តាល និងបទចុង ប្រកាសព្រហ្មចរិយៈដ៏បរិសុទ្ធបរិបូណ៌ ដោយអត្ថ និងព្យញ្ជនៈ ។គហបតី បុត្រនៃគហបតីឬអ្នកកើតមកក្នុងខាងក្រោយក្នុងត្រកូលណាមួយ បានស្តាប់ធម៌នោះហើយក៏មានសទ្ធា គឺការជឿក្នុងព្រះតថាគតជាអ្នកប្រកបដោយសទ្ធា គឺការជឿ ហើយរមែងពិចារណាឃើញថា **ឃរាវាស** ( អ្នកនៅគ្រប់គ្រងផ្ទះ ) ជារបស់ចង្អៀត ជាផ្លូវមកនៃធូលី គឺកិលេស ចំណែកបព្វជ្ជាជាផ្លូវស្រឡះ ជាផ្លូវទំនេរ បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ នឹងប្រព្រឹត្តព្រហ្មចរិយៈ ឲ្យបរិសុទ្ធបរិបូណ៌ដោយចំណែកមួយ ដែលប្រៀបដូចជាស័ង្ខដែលខាត់ហើយ មិនមែនជាការធ្វើបានងាយ បើដូច្នោះយើងនឹងកោរសក់ ពុកមាត់ ស្លៀកដណ្តប់សំពត់កាសាវពស្ត្រ ចេញបួសជាបព្វជិត សម័យតមក ក៏លះទ្រព្យសម្បត្តិតិចច្រើន និងពួកញាតិតិចច្រើនកោរសក់ និងពុកមាត់ ហើយស្លៀកដណ្តប់សំពត់កាសាវពស្ត្រ ចេញចាកផ្ទះទៅបួស ក្នុងព្រះធម្មវិន័យ ជាអ្នកមិនមានកិច្ចដោយផ្ទះ កាលគេ

បានបួសជាបព្វជិតហើយ ជាអ្នករួមការសិក្សា និងអាជីពស្មើនឹងភិក្ខុទាំងឡាយ លះបាណាតិបាត វៀរស្រឡះចាកការសម្លាប់សត្វ ចោលដំបង ដាក់សស្ត្រា មានការខ្មាស មានចិត្តអាណិត មានសេចក្ដីករុណាប្រាថ្នាប្រយោជន៍អនុគ្រោះដល់សត្វទាំងពួងមិនរើសមុខ ។លះអទិន្នាទាន វៀរស្រឡះចាកការលួចទ្រព្យ ទទួលយករបស់ដែលគេឲ្យ ត្រូវការតែរបស់ដែលគេឲ្យមិនប្រព្រឹត្តខ្លួនជាចោរជាអ្នកនៅដោយសេចក្ដីបរិសុទ្ធិ លះអព្រហ្មចរិយៈ (គឺវៀរចាកការរួមមេថុនធម្ម) ប្រព្រឹត្តព្រហ្មចរិយៈប្រព្រឹត្តឲ្យឆ្ងាយ វៀរស្រឡះចាកមេថុន ដែលជាធម៌របស់អ្នកស្រុក លះមុសាវាទ វៀរស្រឡះចាកការនិយាយកុហក និយាយតែពាក្យពិតតាំងនៅក្នុងពាក្យសត្យ និយាយជាគោលដ្ឋានគួរជឿបាន មិននិយាយបោកប្រាសគេ ។

លះវាចាស៊ិកសៀត វៀរស្រឡះចាកវាចាស៊ិកសៀត ស្ដាប់ខាងនេះហើយមិនទៅប្រាប់ខាងនោះ ដើម្បីឲ្យមនុស្សពួកនេះបែកបាក់គ្នា ឬបានស្ដាប់អំពីឯណោះហើយ មិនមកប្រាប់ឯណេះ ដើម្បីឲ្យមនុស្សពួកនោះបែកបាក់គ្នា មានតែការបង្រួបបង្រួមអ្នកដែលបែកបាក់គ្នា

សរសើរអ្នកដែលព្រមព្រៀងគ្នា ហើយគាប់ចិត្តនឹងអ្នកដែលព្រមព្រៀងគ្នា ត្រេកអរក្នុងអ្នកដែលព្រមព្រៀងគ្នា រីករាយក្នុងអ្នកដែលព្រមព្រៀងគ្នា ពោលតែពាក្យដែលធ្វើឲ្យព្រមព្រៀងគ្នា ។

លះបោលវាចាទ្រគោះបោះបោក វៀរស្រឡះនូវវាចាគំរោះគម្រើយ ពោលតែពាក្យដែលមិនមានទោសពីរោះត្រចៀក ពោលតែពាក្យដែលជាទីស្រឡាញ់ ជាទីពេញចិត្ត ជាវាចារបស់អ្នកក្រុង ពាក្យដែលមនុស្សជាច្រើនគេគាប់ចិត្ត ។

លះបង់វាចារោយរាយ វៀរស្រឡះចាកវាចារោយរាយ និយាយត្រូវកាល និយាយតែពាក្យមានប្រយោជន៍ និយាយអាងអត្ថ និយាយអាងធម៌ និយាយអាងវិន័យ និយាយតែពាក្យមានលក្ខឋាន មានទីអាងមានទីកំណត់ ប្រកបដោយប្រយោជន៍ តាមកាលវេលាដែលគួរនិយាយ ។

ភិក្ខុនោះវៀរស្រឡះចាកការផ្តាច់ពីជគាម ភូតគាម ជាអ្នកឆាន់តែមួយពេល វៀរស្រឡះចាកការឆាន់ក្នុងវេលាយប់ វៀរស្រឡះចាកការឆាន់ក្នុងវេលាវិកាល វៀរស្រឡះចាកការរាំច្រៀង ការប្រគំតន្ត្រី និងការមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ វៀរស្រឡះចាកការ

ទ្រទ្រង់ស្អិតស្អាងរាងកាយដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ដែលជាលក្ខណៈនៃការតែងខ្លួន វៀរស្រឡះចាកការអង្គុយការដេកលើទីសេនាសនៈ ដែលខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ វៀរចាកការទទួលមាស និងប្រាក់ វៀរស្រឡះចាកការទទួលធញ្ញាហារឆៅ វៀរស្រឡះចាកការទទួលសាច់ឆៅ វៀរស្រឡះចាកការទទួលស្រី និងប្រុស ទាសី និងទាសា ពពែ និងចៀម ស្រែចម្ការ និងដីធ្លី វៀរស្រឡះចាកការធ្វើទូតកម្ម និងការបម្រើអ្នកដទៃ វៀរស្រឡះចាកការទិញដូរ វៀរស្រឡះចាកការឆបោកដោយក្អែកជញ្ជីង ឆបោកដោយរបស់ប្លម និងការឆបោកដោយគ្រឿងវាល់ និងគ្រឿងវាស់ វៀរស្រឡះចាកការទទួលសំណូក ការបោកប្រាស និងល្បិចកល វៀរស្រឡះចាកការកាត់ ការសម្លាប់ ការឃុំឃាំង ការវាយ ធ្នក់ ការប្លន់ការឆក់ ភិក្ខុនោះជាអ្នកសន្តោស គឺត្រេកអរដោយចីវរល្មម ជាគ្រឿងស្លៀកដណ្តប់បិទបាំងកាយ ត្រេកអរដោយអាហារបិណ្ឌបាតល្មមជាគ្រឿងចិញ្ចឹមផ្ទៃដែលខ្លួននឹងទៅទិសណាៗក៏កាន់យកទៅបានដោយខ្លួនឯងដូចជាបក្សីដែលហើរទៅបាន ដោយស្លាបតាមសេចក្តីប្រាថ្នាដូច្នោះ ភិក្ខុ

នោះ ជាអ្នកប្រកបដោយកងសីលដែលជាអរិយៈនេះ រមែងបានទទួលសេចក្តីសុខដែលប្រាសចាកទោស ភិក្ខុនោះឃើញរូបដោយភ្នែក ឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ លិទ្ធរសដោយអណ្តាត ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ដឹងច្បាស់ធម្មារម្មណ៍ដោយចិត្តហើយ មិនកាន់យកនូវនិមិត្ត និងអនុព្យញ្ជនៈ រមែងបដិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយ ដើម្បីសង្រួមសោតិន្ទ្រិយ. ឃានិន្ទ្រិយ. ជិវ្ហិន្ទ្រិយ. កាយិន្ទ្រិយ. ដើម្បីសង្រួមមនិន្ទ្រិយ បើមិនសង្រួមហើយ នឹងជាហេតុឲ្យអកុសលធម៌ដ៏លាមក គឺអភិជ្ឈា និងទោមនស្សគ្របសង្កត់បាន ឈ្មោះថា រមែងដល់នូវការរក្សា និងការសង្រួមចក្ខុន្ទ្រិយ សោតិន្ទ្រិយ ... មនិន្ទ្រិយ ។

ភិក្ខុនោះជាអ្នកប្រកបដោយឥន្ទ្រិយសំវរៈ ដែលជាអរិយៈនេះ រមែងបានសោយសុខ ដែលប្រាសចាកកិលេសចំពោះខ្លួន ភិក្ខុនោះរមែងមានសេចក្តីដឹងខ្លួន ទាំងក្នុងវេលាឈានទៅមុខ និងឈានថយក្រោយ ពេលក្រឡេកមើល ពេលបត់ចូល លាចេញ គ្រងសង្ឃាដី បាត្រ និងចីវរ ពេលឆាន់ ផឹក ទំពា លិទ្ធរស ពេលបន្ទោបង់ឧច្ចារៈ បស្សាវៈ ពេលដើរ ឈរ អង្គុយ ដេក ភ្ញាក់ឡើង និយាយ ស្ងៀម

ភិក្ខុនោះប្រកបដោយសីលក្ខន្ធជាអរិយៈនេះ ប្រកបដោយឥន្ទ្រិយសំវរៈ ជាអរិយៈដូច្នេះ និងប្រកបដោយសតិសម្បជញ្ញៈ ដែលជាអរិយៈនេះ រមែងនៅក្នុងសេនាសនៈដែលស្ងាត់ គឺព្រៃ គល់ឈើ ភ្នំ ញកភ្នំ ល្អាងភ្នំ ព្រៃស្មសាន ព្រៃស្ដុក ទីវាល ពំនូកចំបើង ភិក្ខុនោះនៅព្រៃ គល់ឈើ ឬផ្ទះស្ងាត់ រមែងអង្គុយពត់ភ្នែនតាំងកាយឲ្យត្រង់តម្រង់ស្មារតីឆ្ពោះមុខ ទៅរកកម្មដ្ឋាន ភិក្ខុនោះលះសេចក្ដីលោភក្នុងលោកហើយ នៅដោយចិត្តដែលប្រាសចាកលោភៈ រមែងជម្រះចិត្តឲ្យបរិសុទ្ធចាកលោភៈ លះសេចក្ដីទោមនស្ស គឺព្យាបាទ មិនប្រទូសរ៉ាយ មានចិត្តករុណា ប្រាថ្នាប្រយោជន៍ដល់សត្វទាំងពួង ជម្រះចិត្តឲ្យបរិសុទ្ធចាកសេចក្ដីប្រទូសរ៉ាយ គឺព្យាបាទ លះថីនមិទ្ធៈ ហើយជាអ្នកប្រាសចាកថីនមិទ្ធៈ ដាក់ចិត្តកំណត់យកនូវពន្លឺភ្លឺស្វាង មានសតិសម្បជញ្ញៈ ជម្រះចិត្តឲ្យបរិសុទ្ធចាកថីនមិទ្ធៈ លះឧទ្ធច្ចកុក្កុច្ចៈ ជាអ្នកមិនរាយមាយ មានចិត្តស្ងប់ក្នុងខាងក្នុង ជម្រះចិត្តឲ្យបរិសុទ្ធចាកឧទ្ធច្ចកុក្កុច្ចៈ ជាអ្នកឆ្លងផុតវិចិកិច្ឆា មិនមានសេចក្ដីសង្ស័យក្នុងកុសលធម៌ទាំងឡាយ ជម្រះចិត្តឲ្យបរិសុទ្ធចាកវិចិកិច្ឆា ។

ភិក្ខុនោះលុះលះនីវរណៈ ដែលជាគ្រឿងសៅហ្មងចិត្ត ធ្វើឲ្យទន់

ខ្សោយ ដល់កម្លាំងបញ្ញា ៥ ប្រការនេះបានហើយ ស្ងាត់ចាកកាម និង ស្ងាត់ចាកអកុសលធម៌ សម្រេចបឋមជ្ឈាន មានវិតក្ក វិចារៈ បីតិ សុខ និងឯកគ្គតា ម្នាលឧបាលីអ្នកយល់សេចក្តីនោះយ៉ាងណា ការនៅដូច្នេះ ជាការនៅដែលល្អក្រៃលែងជាង និងប្រណីតជាងការនៅដែលមានក្នុង កាលមុនមែនឬ ព្រះឧបាលិត្ថេរក្រាបទូលឆ្លើយថា យ៉ាងនោះហើយ ព្រះអង្គ ព្រះមានព្រះភាគ ត្រាស់តទៅទៀតថា ម្នាលឧបាលី សាវ័ក ទាំងឡាយរបស់តថាគតពិចារណាឃើញធម៌នេះ មាននៅក្នុងខ្លួន ទើប នៅក្នុងសេនាសនៈដែលស្ងាត់ក្នុងព្រៃធំតែថា សាវ័កទាំងនោះនៅមិនទាន់ ដល់ប្រយោជន៍ របស់ខ្លួនដោយលំដាប់នៅឡើយ ម្នាលឧបាលី ប្រការ មួយទៀតភិក្ខុសម្រេចទុតិយជ្ឈាន ខាងក្នុងចិត្តមានភាពផូរផង់ ជាធម៌ ដ៏ឯកផុសឡើង មិនមានវិតក្កវិចារៈ ព្រោះវិតក្ក វិចារៈស្ងប់ទៅ មានបីតិ និងសុខ ដែលកើតអំពីសមាធិ ម្នាលឧបាលី អ្នកយល់សេចក្តីនោះ យ៉ាងណា ការនៅដូច្នោះជាការនៅដែលល្អក្រៃលែងជាង និងប្រណីត ជាងការនៅ ដែលមានក្នុងកាលមុនមែនឬ ព្រះឧបាលិត្ថេរក្រាបទូល ឆ្លើយថា យ៉ាងនោះហើយ ព្រះអង្គ ។ ម្នាលឧបាលី ប្រការមួយទៀត

ភិក្ខុមានឧបេក្ខា មានសតិសម្បជញ្ញៈ សោយសុខដោយនាមកាយ ព្រោះបីតិអស់ទៅ សម្រេចតតិយជ្ឈាន ដែលព្រះអរិយៈទាំងឡាយសរសើរថា អ្នកណាបានឈានេះ ជាអ្នកមានឧបេក្ខា មានស្មារតីនៅជាសុខ ម្នាលឧបាលី អ្នកយល់សេចក្តីនោះយ៉ាងណា ការនៅដូច្នេះជាការនៅដែលល្អក្រៃលែងជាង និងប្រណីតជាងការនៅ ដែលមានក្នុងពេលមុនមែនឬ ព្រះឧបាលិត្ថេរក្រាបទូលថា យ៉ាងនោះហើយ ព្រះអង្គ... ។

ម្នាលឧបាលីម្យ៉ាងទៀត ភិក្ខុសម្រេចចតុត្ថជ្ឈាន មិនមានទុក្ខ មិនមានសុខ ព្រោះលះសុខលះទុក្ខ ព្រោះរំលត់សោមនស្ស និងរំលត់ទោមនស្សបានហើយ មានឧបេក្ខាជាហេតុឲ្យសតិបរិសុទ្ធ ម្នាលឧបាលី អ្នកយល់សេចក្តីនោះយ៉ាងណា ការនៅដូច្នេះជាការនៅដែលល្អក្រៃលែងជាង និងប្រណីតជាងការនៅដែលមានក្នុងកាលមុនមែនឬ ព្រះឧបាលិត្ថេរក្រាបទូលថា ពិតមែនហើយ ព្រះអង្គ ។ម្នាលឧបាលីម្យ៉ាងទៀត ព្រោះភិក្ខុឈានកន្លងរូបសញ្ញា ព្រោះរំលត់បដិឃសញ្ញាចេញបាន ព្រោះមិនដាក់ចិត្តដល់នានត្តសញ្ញា ដោយប្រការទាំងពួង ភិក្ខុសម្រេចអាកាសានញ្ចាយតនជ្ឈាន ដោយគិតពិចារណាថា អាកាសមិនមានទីបំផុត...

ៗលៗ...ម្នាលឧបាលីម្យ៉ាងទៀត ព្រោះភិក្ខុឈានកន្លងអាកាសានញ្ចាយ-តនជ្ឈាន ដោយប្រការទាំងពួង ទើបភិក្ខុសម្រេចវិញ្ញាណញ្ចាយតនជ្ឈាន ដោយគិតពិចារណាថា វិញ្ញាណមិនមានទីបំផុត...ព្រោះភិក្ខុឈានកន្លងវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ទើបភិក្ខុសម្រេចដល់អាកិញ្ចញ្ញាយតនជ្ឈាន ដោយគិតពិចារណាថា ភាវៈតិចតួចមិនមាន... ព្រោះភិក្ខុឈានកន្លងអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ទើបភិក្ខុសម្រេចដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយពិចារណាថា ធម្មជាតិនេះស្ងប់ពិត ប្រណីតពិត ម្នាលឧបាលី អ្នកនឹងយល់សេចក្តីនុ៎ះយ៉ាងណា ការនៅដូច្នេះជាការនៅដែលល្អក្រៃលែង ជាងការនៅដែលមានក្នុងពេលមុនមែនឬ ព្រះឧបាលិត្ថេរក្រាបទូលថា ពិតមែនហើយព្រះអង្គ ព្រះមានព្រះភាគត្រាស់តទៅទៀតថា ម្នាលឧបាលី សាវកទាំងឡាយរបស់តថាគត ពិចារណាឃើញធម៌នេះថាមាននៅក្នុងខ្លួន ទើបនៅក្នុងទីសេនាសនៈស្ងប់ស្ងាត់ក្នុងព្រៃធំ តែថា សាវកទាំងនោះ នៅមិនទាន់ដល់ប្រយោជន៍របស់ខ្លួនដោយលំដាប់នៅឡើយ ម្នាលឧបាលីម្យ៉ាងទៀត ភិក្ខុឈានកន្លងនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការ

ទាំងពួង ទើបភិក្ខុសម្រេចដល់សញ្ញាវេទយិតនិរោធសមាបត្តិ ឯអាសវក្កិលេសរបស់ភិក្ខុនោះអស់ទៅហើយ ព្រោះឃើញដោយបញ្ញាដ៏ប្រពៃតាមពិត ម្នាលឧបាលីអ្នកយល់សេចក្តីនុ៎ះយ៉ាងណា ការនៅដូច្នេះជាការនៅដែលល្អក្រៃលែងជាង និងប្រណីតជាងការដែលនៅក្នុងកាលមុនមែនឬ ព្រះឧបាលិត្ថេរក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពិតដូច្នោះហើយព្រះអង្គ ទើបព្រះមានព្រះភាគត្រាស់ប្រាប់ព្រះឧបាលិត្ថេរថា ម្នាលឧបាលីសាវ័កទាំងឡាយរបស់តថាគត ពិចារណាឃើញធម៌នេះថាមាននៅក្នុងខ្លួន ទើបនៅក្នុងទីសេនាសនៈដែលស្ងប់ស្ងាត់ តែថាសាវ័កទាំងនោះនៅមិនទាន់ដល់ប្រយោជន៍របស់ខ្លួនដោយលំដាប់នៅឡើយ ម្នាលឧបាលី អ្នកចូរនៅក្នុងពួកសង្ឃចុះ កាលអ្នកនៅក្នុងសង្ឃទើងមានការរស់នៅជាសុខ ។

មូលហេតុដែលព្រះមានព្រះភាគ មិនទ្រង់អនុញ្ញាតដល់ឧបាលិត្ថេរឲ្យទៅនៅក្នុងព្រៃ និងការបានសម្រេចព្រះអរហត្ត មានរឿងសម្តែងនៅក្នុង ***អដ្ឋកថាបរមត្ថទីបនី*** និង ***អដ្ឋកថាមនោរថបូរណី*** បញ្ជាក់ថា

លុះព្រះឧបាលិត្ថេរ បព្វជ្ជាឧបសម្បទាហើយ បានទទួលយកព្រះកម្មដ្ឋានក្នុងសម្នាក់របស់ព្រះមានព្រះភាគ ហើយក្រាបទូលថា បពិត្រ

ព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់អនុញ្ញាតដល់ខ្ញុំព្រះអង្គដើម្បីនៅក្នុងព្រៃចុះ ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបាលិ កាលអ្នកនៅក្នុងព្រៃអ្នកនឹងធ្វើវិបស្សនាធុរៈឲ្យចម្រើនតែម្យ៉ាង តែបើអ្នកបដិបត្តិនៅក្នុងសម្នាក់របស់តថាគត ទាំងគន្ថធុរៈ និងវិបស្សនាធុរៈនឹងបរិបូណ៌ ហើយអ្នកនឹងសម្រេចអរហត្តផល ទាំងបានជាប្រធានផ្នែកទ្រទ្រង់ព្រះវិនយបិដក ។ ព្រះឧបាលិត្ថេរថ្វាយបង្គំទទួលព្រះពុទ្ធតម្រាស់ ហើយតាំងចិត្តចម្រើនវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មានក៏បានសម្រេចព្រះអរហត្តផល ជាព្រះអរិយបុគ្គលដ៏ខ្ពង់ខ្ពស់ក្នុងព្រះពុទ្ធសាសនា គ្រានោះ ព្រះមានព្រះភាគបានត្រាស់ទូន្មានព្រះឧបាលិត្ថេរឲ្យសិក្សា រៀនសូត្រព្រះវិនយបិដកដោយព្រះអង្គឯងគ្រប់យ៉ាង ទើបជាហេតុធ្វើឲ្យព្រះឧបាលិមានការយល់ និងទ្រទ្រង់ព្រះវិនយបិដកបានយ៉ាងមាំទាំ និងមានភាពស្ទាត់ជំនាញយ៉ាងខ្លាំង ទាំងជាអ្នកអាចពិចារណារកហេតុផលទាក់ទងនឹងព្រះវិន័យបានយ៉ាងល្អត្រឹមត្រូវ សេចក្តីនេះ គប្បីមើលនូវកស្តុតាង ដែលលោកបានទទួលពុទ្ធានុញ្ញាតឲ្យជាអ្នកវិនិច្ឆ័យជម្រះអធិករណ៍ ៣ រឿងដូច្នេះ គឺរឿងរបស់ព្រះភារុកច្ឆកភិក្ខុ ១ ព្រះអជ្ជុកភិក្ខុ ១ និងព្រះថេរីជាញោមស្រីរបស់ព្រះ

កុមារកស្សបត្ថេរ ១ ការពិចារណារកហេតុផលក្នុងអធិករណ៍ ដែលកើតឡើងនោះ លោកធ្វើយ៉ាងល្អិតល្អន់ ទើបវិនិច្ឆ័យដោយយុត្តិធម៌ កាន់យកភាពខុស និងត្រូវជាគោលសំខាន់ មិនមានអគតិ គឺមិនលំអៀងទៅខាងនេះ មិនលំអៀងទៅខាងនោះ ដូចជាថ្លឹងដោយជញ្ជីង ដែលជាការត្រឹមត្រូវជាទីបំផុត ប្រៀបបាននឹងសព្វញ្ញុតញ្ញាណ ។

ព្រះមានព្រះភាគ ប្រទានសព្ទសាធុការរាល់លើក ដែលលោកវិនិច្ឆ័យអធិករណ៍សម្រេចមួយរឿងៗ ទើបព្រះអង្គទ្រង់លើកយកការវិនិច្ឆ័យអធិករណ៍ទាំង ៣ រឿងនេះ មកជាដើមហេតុ ហើយទ្រង់តាំងព្រះឧបាលិត្ថេរទុកក្នុងតំណែងដ៏កំពូលជាងភិក្ខុទាំងឡាយ ផ្នែកទ្រទ្រង់នូវព្រះវិន័យ ដូចមានសេចក្ដីក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ថា ៖

ម្នាលភិក្ខុទាំងឡាយ ឧបាលី ជាឯតទគ្គៈ គឺកំពូលអ្នកជាងភិក្ខុទាំងឡាយ ជាសាវ័ករបស់តថាគតផ្នែកខាងទ្រទ្រង់នូវព្រះវិន័យ **ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ វិនយធរានំ យទិទំ ឧបាលិ ។**

ពាក្យទូន្មាន ដែលឧបាលិត្ថេរពោលដាស់តឿនភិក្ខុទាំងឡាយ មានគោលជាគាថា គឺពាក្យចងក្រងជាភាសាបាលី នៅក្នុង **អដ្ឋកថា**

បរមត្ថទីបនី បញ្ជាក់ថា ៖

ក្រោយពេលដែលព្រះឧបាលី បានការលើកតម្កើងក្នុងតំណែងឯតទគ្គៈគឺជាកំពូលផ្នែកខាងទ្រទ្រង់ព្រះវិន័យ ហើយតមកថ្ងៃមួយដែលជាថ្ងៃឧបោសថ ពេលសម្តែងបាតិមោក្ខ កាលលោកពោលជាស់តឿនភិក្ខុទាំងឡាយ បានពោលជាគាថា ៣ គាថាថា

កុលបុត្រចេញចាកផ្ទះដោយសទ្ធា ហើយបួសថ្មីជានវភិក្ខុ គប្បីគប់រកកល្យាណមិត្តទាំងឡាយ ដែលជាអ្នកមានការចិញ្ចឹមជីវិតដោយបរិសុទ្ធ អ្នកមិនខ្ជិលច្រអូស ។ កុលបុត្រចេញចាកផ្ទះដោយសទ្ធា បួសថ្មីជានវភិក្ខុ អ្នកមានប្រាជ្ញា កាលនៅក្នុងពួក គប្បីសិក្សានូវព្រះវិន័យ ។ កុលបុត្រចេញចាកផ្ទះដោយសទ្ធា បួសថ្មី ជានវភិក្ខុ ជាអ្នកឈ្លាសក្នុងហេតុដែលគួរ និងមិនគួរទាំងឡាយ គប្បីប្រព្រឹត្តកុំឲ្យ ( ពួកកិលេសតណ្ហាជាដើម ) ប្រព្រឹត្តទៅក្នុងខាងមុខបាន ។

មូលហេតុ ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ដើម្បីប្រយោជន៍ដល់ព្រះពុទ្ធសាសនា ជួយឲ្យពួកយើងបានដឹង ក៏ព្រោះព្រះឧបាលីបានក្រាបទូលសួរព្រះមានព្រះភាគ ដូចមានសម្តែងនៅក្នុងព្រះ

បាលី ឧបាលិសូត្រ គម្ពីរអង្គុត្តរនិកាយ ទសកនិបាត មានសេចក្តីថា ៖

សម័យមួយ ព្រះឧបាលិត្ថេរ បានចូលទៅគាល់ក្រាបទូលសួរព្រះមានព្រះភាគថា បពិត្រព្រះសាស្តា ព្រះអង្គទ្រង់អាស្រ័យអំណាចប្រយោជន៍ប៉ុន្មានយ៉ាង ទើបទ្រង់បញ្ញត្តសិក្ខាបទ ទ្រង់សម្តែងព្រះ-បាតិមោក្ខដល់សាវកទាំងឡាយ ?

ព្រះមានព្រះភាគត្រាស់ឆ្លើយថា ម្នាលឧបាលី តថាគតអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង ទើបបញ្ញត្តសិក្ខាបទ សម្តែងបាតិមោក្ខដល់សាវកទាំងឡាយ អំណាចប្រយោជន៍ ១០ យ៉ាងនោះ គឺអ្វីខ្លះ ១-សង្ឃសុដ្ឋុតាយ ២- សង្ឃផាសុតាយ ៣- ទុម្មំកូនំ បុគ្គលានំ និគ្គហាយ ៤- បេសលានំ ភិក្ខូនំ ផាសុវិហារាយ ៥- ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ ៦-សម្បរាយិកានំ អាសវានំ បដិឃាតាយ ៧-អប្បសន្នានំ បសាទាយ ៨- បសន្នានំ វា ភិយ្យោភាវាយ ៩- សទ្ធម្មដ្ឋិតិយា ១០-វិនយានុគ្គហាយ ។

មានពាក្យអធិប្បាយអំណាចប្រយោជន៍ ១០ យ៉ាង ដើម្បីទ្រង់បញ្ញត្តព្រះវិន័យ ក្នុង អដ្ឋកថាមនោរថបូរណី បញ្ជាក់ថា ៖

ពាក្យថាដើម្បីសេចក្ដីល្អនៃសង្ឃ ( ទី ១ ) បានដល់ការទទួលដោយពាក្យពេចន៍ គួរឲ្យស្រឡាញ់ថា ល្អហើយព្រះអង្គ ! អ្នកណាទទួលពាក្យពេចន៍របស់ព្រះតថាគត អ្នកនោះរមែងបានទទួលប្រយោជន៍សុខអស់កាលដ៏យូរ ព្រោះហេតុដូច្នោះ ទើបព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទទុក តែមិនមែនទ្រង់បញ្ញត្តដើម្បីការគំរាមកំហែង ទើបត្រាស់បញ្ញត្តដើម្បីសេចក្ដីល្អដល់សង្ឃទេ ។ ពាក្យថា ដើម្បីការនៅជាសុខនៃសង្ឃនោះ ( ទី ២ ) គឺដើម្បីនៅសប្បាយនៃពួកសង្ឃ ពាក្យថាដើម្បីសង្កត់សង្កិននូវភិក្ខុដែលទ្រុស្តសីលនោះ ( ទី ៣ ) អធិប្បាយថា ភិក្ខុដែលមិនមានសីលឈ្មោះថា ភិក្ខុជាអ្នកទ្រុស្តសីល ភិក្ខុត្រូវសង្ឃធ្វើឲ្យជាអ្នកអៀនខ្មាសហើយ តែនៅតែមិនដឹងខ្លួន នៅតែចចេសប្រព្រឹត្តកន្លងល្មើសសិក្ខាបទ នៅតែធ្វើដោយមិនមានអៀនខ្មាស ព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ដើម្បីសង្កត់សង្កិននូវភិក្ខុទាំងនោះ ព្រោះបើមិនមានសិក្ខាបទ ភិក្ខុទាំងនោះក៏នឹងធ្វើឲ្យសង្ឃលំបាកដោយការពោលអាងថា ពួកលោកបានឃើញអ្វី បានឮយ៉ាងណា ពួកខ្ញុំធ្វើអ្វី ពួកលោកលើកអាបត្តិមួយណា ក្នុងរឿងអ្វីឡើង សង្កត់សង្កិនពួកយើង តែកាលមាន

សិក្ខាបទ សង្ឃក៏សម្តែងសិក្ខាបទដល់ភិក្ខុទាំងនោះ បានសង្កត់សង្កិន ភិក្ខុទាំងនោះ ដោយប្រពៃតាមធម៌ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគ ត្រាស់ថា តថាគតបញ្ញត្តសិក្ខាបទ ដើម្បីសង្កត់សង្កិនមនុស្សទ្រុស្តសីល ។

ពាក្យថា ដើម្បីការនៅជាសុខនៃភិក្ខុទាំងឡាយ អ្នកមានសីល ជាទីស្រឡាញ់នោះ (ទី ៤) គឺភិក្ខុអ្នកមានសីលជាទីស្រឡាញ់ទាំងឡាយ កាលមិនស្គាល់វត្ថុគួរ និងមិនគួរវត្ថុដែលមានទោស និងមិនមានទោស ព្រំដែនកំណត់ រមែងមានសេចក្តីលំបាកក្នុងការធ្វើត្រៃសិក្ខាឲ្យបរិបូណ៌ កាលភិក្ខុទាំងនោះស្គាល់វត្ថុដែលមានទោស និងមិនមានទោស ស្គាល់ ព្រំដែនកំណត់ហើយ រមែងមិនលំបាកក្នុងការធ្វើត្រៃសិក្ខាឲ្យបរិបូណ៌ ព្រោះដូច្នោះ ការបញ្ញត្តិសិក្ខាបទ ទើបប្រព្រឹត្តទៅដើម្បីការនៅសប្បាយ ដល់ភិក្ខុទាំងនោះ ការសង្កត់សង្កិនមនុស្សទ្រុស្តសីល ក៏ជាទីរីករាយ ដល់ភិក្ខុទាំងនោះ ការធ្វើឧបោសថ បវារណាកម្ម រមែងតាំងនៅមិនបាន ព្រោះអាស្រ័យអ្នកមិនមានសីល សង្ឃកម្មទាំងឡាយក៏មិនអាចប្រព្រឹត្ត ទៅបាន ព្រោះអាស្រ័យអ្នកមិនមានសីល ការសាមគ្គីក៏មិនមានព្រោះ អាស្រ័យអ្នកមិនមានសីល ភិក្ខុទាំងឡាយ អ្នកមានចិត្តមានអារម្មណ៍

តែមួយ ក៏មិនអាចប្រកបកិច្ច មានការរៀនសូត្រជាដើមបាន តែកាលសង្កត់សង្កិនអ្នកមិនមានសីលចេញបានហើយ ការស្មុគស្មាញទាំងពួងនេះក៏មិនមាន តពីនោះ ភិក្ខុទាំងឡាយ អ្នកមានសីលជាទីស្រឡាញ់រមែងនៅជាសុខ ។

ពាក្យថា ដើម្បីការពារអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ននោះ ( ទី ៥ ) មានអធិប្បាយថា ដែលថាអាសវៈទាំងឡាយក្នុងបច្ចុប្បន្ន ដែលភិក្ខុទាំងឡាយមិនមានការសង្រួម នឹងត្រូវបានទទួលក្នុងអត្តភាពនេះគឺទុក្ខផ្សេងៗមានការត្រូវវាយដោយដៃ ត្រូវវាយដោយដំបង ត្រូវប្រហារដោយសស្ត្រា ត្រូវកាត់ដៃ កាត់ជើង ខូចកេរ្តិ៍ឈ្មោះខូចយស និងកើតសេចក្តីក្តៅក្រហាយចិត្តជាដើម រមែងមានក្នុងបច្ចុប្បន្នព្រះមានព្រះភាគ ទ្រង់បញ្ញត្តសិក្ខាបទដើម្បីការពារទុក្ខផ្សេងៗ នោះមិនឲ្យមានដល់ភិក្ខុទាំងឡាយ ។

ពាក្យថា ដើម្បីកម្ចាត់អាសាវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងខាងមុខ ( ទី ៦ ) គឺដើម្បីការពារសេចក្តីទុក្ខ ដែលនឹងកើតក្នុងកាលខាងមុខ មានទុក្ខក្នុងនរកជាដើម ដោយមានការធ្វើអាក្រក់ជាមូល ដែល

កើតឡើងដល់ភិក្ខុមិនបានសង្រួម ។

ពាក្យថា បុគ្គលនៅមិនទាន់ជ្រះថ្លា គឺកាលសិក្ខាបទបញ្ញត្តហើយ (ទី ៧) មនុស្សឯណា ដែលជាអ្នកមានសតិបញ្ញា តែនៅមិនទាន់ជ្រះថ្លា លុះដឹងសិក្ខាបទបញ្ញត្ត ឬបានឃើញភិក្ខុទាំងឡាយអ្នកបដិបត្តិតាមបទបញ្ញត្តិ ក៏កើតសេចក្ដីជ្រះថ្លាថា សមណៈទាំងនេះបានលះបង់វត្ថុធ្វើឲ្យកើតសេចក្ដីវិកកាយត្រេកអរ និងការវង្វេង ដែលមានដល់មហាជនក្នុងលោក ជាការធ្វើកិច្ចដែលគេធ្វើបានដោយលំបាក ដូចជាពួកព្រាហ្មណ៍មិច្ឆាទិដ្ឋិ ( យល់ខុសចាកធម៌ ) បានឃើញគម្ពីរព្រះវិនយបិដកហើយកើតសេចក្ដីជ្រះថ្លាដូច្នោះ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថាតថាគតបញ្ញត្តិសិក្ខាបទទុក ដើម្បីសេចក្ដីជ្រះថ្លាដល់បុគ្គលនៅមិនទាន់ជ្រះថ្លា ។

ពាក្យថា ដល់បុគ្គលអ្នកជ្រះថ្លានោះ ( ទី ៨ ) គឺកុលបុត្រណាមានសេចក្ដីជ្រះថ្លាក្នុងព្រះពុទ្ធសាសនាហើយ កុលបុត្រនោះដឹងសិក្ខាបទដែលបញ្ញត្តហើយ ឬបានឃើញភិក្ខុទាំងឡាយ ដែលបដិបត្តិតាមបទបញ្ញត្តហើយ ក៏ជ្រះថ្លាក្រៃលែងឡើងថា លោកម្ចាស់ទាំងឡាយដែល

ឆាន់អាហារមួយថ្ងៃ មួយពេលរហូតមួយជីវិត រក្សាសម្រួមព្រហ្មចរិយៈ (ការប្រព្រឹត្តធម៌ដ៏ប្រសើរ) រហូតមួយជីវិតនេះ បានធ្វើកិច្ចដែលធ្វើបានដោយកម្រ ព្រោះដូច្នោះ ដើម្បីសេចក្តីជ្រះថ្លាក្រៃលែងឡើង ដល់បុគ្គលដែលមានការជ្រះថ្លាហើយ ។

ពាក្យថា ដើម្បីសេចក្តីតាំងមាំនៃព្រះសទ្ធម្មនោះ ( ទី ៩) មានពាក្យអធិប្បាយថា ព្រះសទ្ធម្មមាន ៣ ប្រការ គឺ

១- បរិយត្តិសទ្ធម្ម បានដល់សទ្ធម្ម គឺធម៌ដែលគប្បីរៀនសូត្រ សំដៅដល់ព្រះពុទ្ធវចនៈទាំងអស់ ក្នុងបិដក ។

២-បដិបត្តិសទ្ធម្ម បានដល់សទ្ធម្ម គឺធម៌ដែលគប្បីបដិបត្តិ សំដៅដល់ធុតង្គ ( អង្គជាគ្រឿងកម្ចាត់កិលេស ) ១៣ ប្រការ ចារិតសីល ( ការប្រព្រឹត្តដែលល្អ ) វារិតសីល ( ខដែលគួរវៀរចាក ) សមាធិ វិបស្សនា ( ឬសរុប បានដល់ត្រៃសិក្ខា ) ។

៣- អធិគមសទ្ធម្ម បានដល់សទ្ធម្ម គឺផលដែលគប្បីសម្រេច សំដៅដល់ លោកុត្តរធម៌ ៩ គឺមគ្គ ៤ ផល ៤ ព្រះនិព្វាន ១ ។

កាលសិក្ខាបទបញ្ញត្តហើយ ភិក្ខុទាំងឡាយ ក៏សិក្សារៀនសូត្រ

សិក្ខាបទ និងការចែកសិក្ខាបទ និងព្រះពុទ្ធវចនៈដទៃ ដើម្បីឲ្យជីងវត្ថុនោះៗ ភិក្ខុទាំងឡាយបដិបត្តិតាមដែលបញ្ញត្តទុកហើយ កាលបដិបត្តិឲ្យពេញបរិបូណ៌ហើយ ក៏បានលោកុត្តរធម៌ ( ធម៌ដែលផុតវិស័យនៃលោក ) ដែលគួរបានដោយវត្តបដិបត្តិ ព្រោះដូច្នោះ ព្រះសទ្ធម្មទើបតាំងនៅបានយូរដោយសិក្ខាបទបញ្ញត្ត ដោយហេតុនេះ ទើបព្រះមានព្រះភាគត្រាស់ថា ដើម្បីការតាំងនៅនៃព្រះសទ្ធម្ម ។

ពាក្យថា ដើម្បីការអនុគ្រោះព្រះវិន័យនោះ គឺកាលសិក្ខាបទបញ្ញត្តហើយ ក៏ជាការអនុគ្រោះដល់ព្រះវិន័យ ៤ យ៉ាង គឺ

១- សំវរវិន័យ បានដល់ វិន័យ គឺការសង្រួមរវាំង

២- បហានវិន័យ បានដល់ វិន័យ គឺការលះ

៣- សមថវិន័យ បានដល់ វិន័យ គឺការស្ងប់រម្ងាប់

៤- បញ្ញត្តិវិន័យ បានដល់ វិន័យ គឺការតាំងបញ្ញត្តិឡើង

ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ដើម្បីការអនុគ្រោះដល់ព្រះវិន័យ ( សិក្ខាបទរបស់ព្រះសង្ឃ ) ។

រឿងការបានសម្រេចក្នុងបច្ចុប្បន្នជាតិ របស់ព្រះឧបាលិត្ថេរបាន

ពោលនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** តទៅទៀតដោយសេចក្តីថា ៖

កាលព្រះឧបាលិត្ថេរបានជាព្រះអរហន្តហើយ លោកបានពោលដល់វាសនាបារមី និងការសម្រេចរបស់លោកទុកយ៉ាងពិស្តារ ចំណែករឿងអតីត ដូចបាននាំមករៀបរាប់ទុកក្នុងខាងដើមនោះហើយ ។ តែការសម្រេចសមដូចប្រាថ្នារបស់លោក មានការប្រាកដតាមដែលលោកក្រាបទូលចំពោះព្រះមានព្រះភាគទុកច្រើនវគ្គ ដោយនាំមកពោលចំពោះតែគតិខ្លឹមសារ ដើម្បីជាប្រយោជន៍ ពាក្យក្រាបទូលរបស់លោកមានសេចក្តីថា

បពិត្រព្រះអង្គ ខ្ញុំព្រះអង្គបានសម្រេចប្រយោជន៍របស់ខ្លួនហើយ បានអស់សញ្ញោជនៈ ( កិលេសជាគ្រឿងរួបរឹតចិត្ត ) ទាំងពួងហើយ បុរសដែលត្រូវដោតដោយស្នក័យខ្លាចដោយរាជអាជ្ញា រកសេចក្តីសុខគ្មាន ត្រូវការនឹងរួចផុតចាកស្ន យ៉ាងណាមិញ បពិត្រព្រះអង្គទ្រង់ជាព្រះមហាវីរៈ ខ្ញុំព្រះអង្គត្រូវអាជ្ញាក្នុងភពសង្សារវដ្តបៀតបៀន ត្រូវដោតដោយស្ន គឺកម្មធ្វើឲ្យកើតទុក្ខវេទនា រកសេចក្តីសុខគ្មាន ក្តៅរោលរាលដោយភ្លើងទាំងបី គឺរាគគ្គិ ភ្លើងគឺសេចក្តីត្រេកត្រអាលរីករាយ ទោសគ្គិ

បានដល់ភ្លើង គឺសេចក្ដីក្រោធ **មោហគ្គិ** បានដល់ ភ្លើង គឺសេចក្ដីវង្វេង ទើបស្វែងរកការរួចផុត ( ចាកកិលេស ) ដូចជាបុរសអ្នកស្វែងរកការរួចផុតចាករាជអាជ្ញា ដូច្នោះ ។

បុរសអ្នកក្ដៅក្លា ត្រូវថ្នាំពិសបៀតបៀន ( ឲ្យកើតទុក្ខក្ដៅក្រហាយ ) ហើយ ស្វែងរកថ្នាំដើម្បីព្យាបាល កាលស្វែងរកបានហើយ ក៏ផឹកថ្នាំនោះ ទើបមានសេចក្ដីសុខ ព្រោះអស់អំណាចពិស យ៉ាងណា បពិត្រព្រះមហាវីរបុរស ខ្ញុំព្រះអង្គក៏ដូច្នោះដែរ ។

នរជាតិដែលត្រូវថ្នាំពិសហើយយ៉ាងណា ខ្ញុំព្រះអង្គក៏ជាអ្នកត្រូវអវិជ្ជា គឺសេចក្ដីមិនដឹងបៀតបៀនហើយក៏ស្វែងរកថ្នាំ គឺព្រះសទ្ធម្មដូច្នោះ កាលខ្ញុំព្រះអង្គ ស្វែងរកថ្នាំ គឺព្រះសទ្ធម្ម ក៏បានឃើញព្រះសាសនារបស់ព្រះសក្យមុនី ដែលជាឱសថដ៏ល្អឯក ជាឱសថដ៏ប្រសើរ អាចកម្ចាត់បង់នូវកូនសរ គឺតណ្ហាទាំងពួង ខ្ញុំព្រះអង្គបានផឹកធម្មឱសថ ដកពិសទាំងពួងចេញ ខ្ញុំព្រះអង្គបានឃើញហើយនូវព្រះនិព្វាន ដែលជារបស់មិនចាស់ មិនស្លាប់ ជារបស់ត្រជាក់ជានិច្ច ។

អ្នកដែលត្រូវកូតបិសាចបៀតបៀនហើយ ស្វែងរកគ្រូខ្មោច

ដើម្បីឲ្យផុតចាកភូតបិសាច កាលជួបគ្រូខ្មោចដ៏ឆ្លាតហើយ ទើបកម្ចាត់ភូតបិសាចបាន យ៉ាងណា ព្រះមហាវីរបុរស ខ្ញុំព្រះអង្គត្រូវសភាពធងឹតគ្របសង្កត់ហើយ ក៏ស្វែងរកពន្លឺភ្លឺស្វាង គឺការដឹងដើម្បីឲ្យផុតចាកសភាពធងឹត ដូច្នោះ ខ្ញុំព្រះអង្គបានជួបព្រះសក្យមុនី ដែលទ្រង់កម្ចាត់សភាពធងឹត គឺកិលេស ព្រះសក្យមុនី ក៏បានទ្រង់កម្ចាត់សភាពធងឹតរបស់ខ្ញុំព្រះអង្គឲ្យអស់ទៅ ដូចគ្រូខ្មោចកម្ចាត់ភូតបិសាច ឲ្យចៀសចេញទៅដូច្នោះ ខ្ញុំព្រះអង្គបានកម្ចាត់ក្រសែសង្សារវដ្ត បានរារាំងក្រសែតណ្ហាហើយ បានដកនូវកពទាំងពួង ដូចជាគ្រូខ្មោចកម្ចាត់ភូតបិសាចចេញហើយ ដូច្នោះ ។

ផ្លែអាសាវតីត្រង់សួនចិត្តលតាវ័ន ក្នុងឋានតាវត្តិង្ស ដែលកើតផលមួយពាន់ឆ្នាំមួយផ្លែ ទេវតាទាំងឡាយ រមែងទៅចោមរោម ដើម្បីសង្ឃឹមបានផ្លែ ដែលកើតអំពីអាសាវតីនោះ ផ្លែអាសាវតីរមែងជាទីស្រឡាញ់ពេញចិត្តរបស់ទេវតាទាំងឡាយ ដោយមានផ្លែជាទីគាប់ចិត្តរបស់ទេវតា យ៉ាងណា ខ្ញុំព្រះអង្គក៏សង្ឃឹមចំពោះព្រះអង្គ ទ្រង់ជាអ្នកប្រាជ្ញ អស់កាលមួយសែនកប្បហើយ ត្រេកអរនមស្ការចំពោះព្រះអង្គ

រាល់ព្រឹកល្ងាច ដូចជាទេវតាទៅយាមរក្សាផ្ទៃអាសាវតី ដូច្នោះ ។

ការបដិបត្តិ និងការនមស្ការរបស់ខ្ញុំព្រះអង្គមិនមានផល ព្រោះសូម្បីជាវេលាយូរប៉ុនណាក៏ដោយ ខណៈសម័យក៏មិនឃ្លាតចាកខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គមិនសម្លឹងឃើញបដិសន្ធិ ( កើតថ្មី ) ទៀតឡើយ ខ្ញុំព្រះអង្គរួចផុតចាកឧបធិកិលេសទាំងពួងហើយ ផ្កាបទុមរមែងរីកដោយពន្លឺព្រះអាទិត្យយ៉ាងណា បពិត្រព្រះមហាវីរបុរស ខ្ញុំព្រះអង្គក៏រីកដោយព្រះពុទ្ធរស្មី ដូច្នោះ ។

កុកឈ្មោលមិនមានក្នុងកំណើតសត្វកុក កាលផ្គរលាន់មេកុកក៏តាំងគភ៌ ការតាំងគភ៌បើផ្គរមិនទាន់លាន់ដរាបណា ក៏នៅមិនទាន់តាំងគភ៌ដរាបនោះ កាលមេឃមានផ្គរ ទើបមានគភ៌យ៉ាងណា ខ្ញុំព្រះអង្គក៏មានគភ៌ គឺព្រះធម៌ដោយសំឡេងផ្គរលាន់ គឺសំឡេងសម្តែងធម៌របស់ព្រះបទុមុត្តរៈ សម្មាសម្ពុទ្ធជាម្ចាស់ ខ្ញុំព្រះអង្គមានគភ៌ គឺបុណ្យ រហូតអស់មួយសែនកប្ប តែនៅមិនទាន់ផុតចាកការមានគភ៌ ក្នុងកាលមេឃគឺធម៌នៅមិនទាន់គ្រហឹមលាន់ឮ កាលណាព្រះអង្គទ្រង់គ្រហឹមដោយសំឡេងមេឃ គឺធម៌ ក្នុងក្រុងកបិលពស្តុដ៏រីករាយ កាលនោះខ្ញុំព្រះអង្គ

ទើបផុតចាកការមានគតិ គឺសង្សារវដ្ត គឺថាព្រះអង្គបានសម្រេចសុញ្ញត សមាធិ អនិមិត្តសមាធិ អប្បណិហិតសមាធិ និងផល ៤ ប្រការហើយ ទាំងបានអះអាងក្នុងធម៌ទាំងពួង ។

ខ្ញុំព្រះអង្គ បានប្រាថ្នានូវពាក្យប្រៀនប្រដៅរបស់ព្រះអង្គមករហូត អស់មួយសែនកប្ប និងបានសម្រេចតាមសេចក្តីប្រាថ្នាហើយ បានដល់នូវភាពខ្ពង់ខ្ពស់ក្នុងព្រះវិន័យ ដូចជាភិក្ខុដែលជាសាវករបស់ព្រះបទុមុត្តរៈសម្មាសម្ពុទ្ធជាម្ចាស់ក្នុងអតីតកាលឯណោះ ដែលគ្មានអ្នកស្មើនឹងខ្ញុំព្រះអង្គ ផ្នែកព្រះវិន័យ ខ្ញុំព្រះអង្គទ្រទ្រង់ទុកនូវព្រះវិន័យក្នុងព្រះសាសនានេះ ទាំងមិនមានការងឿងឆ្ងល់សង្ស័យ ក្នុងអក្ខរៈ ឬព្យញ្ជនៈក្នុងព្រះវិន័យ ទាំង ៥ គម្ពីរ គឺ **១- អាទិកម្ម ២- បាចិត្តិយ ៣- មហាវគ្គ ៤- ចុល្លវគ្គ ៥- បរិវារ** ខ្ញុំព្រះអង្គយល់ច្បាស់ក្នុងព្រះវិន័យ ដែលពោលដោយការសង្កត់នូវភិក្ខុដែលគួរគាបសង្កត់ ពោលដោយការដោះស្រាយភិក្ខុអ្នកធ្វើខុស ពោលដោយរបស់គួរ និងមិនគួរ ពោលដោយការដាក់ទោសដល់ភិក្ខុ តាមព្រះវិន័យនោះ ខ្ញុំព្រះអង្គដល់នូវភាពខ្ពង់ខ្ពស់ និងយល់ច្បាស់ក្នុងព្រះវិន័យទាំងពួង ទាំងរបស់ភិក្ខុ និងភិក្ខុនី ។

បពិត្រព្រះមហាវីរៈ ខ្ញុំព្រះអង្គឈ្មោះថា ឧបាលី សូមថ្វាយបង្គំនូវព្រះយុគលបាទរបស់ព្រះអង្គ ក្នុងកាលឥឡូវនេះ ខ្ញុំព្រះអង្គនឹងចេញចាកស្រុកនេះទៅកាន់ស្រុកឯណោះ ចេញចាកក្រុងនេះទៅកាន់ក្រុងឯណោះ សូមនមស្ការព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាមុនហើយទើបទៅ ខ្ញុំព្រះអង្គបានដុតកិលេសាសវៈទាំងឡាយឲ្យអស់ទៅ បានដកកពទាំងពួងហើយ មិនមានការវិលវល់កើតស្លាប់តទៅទៀត ការដែលខ្ញុំព្រះអង្គ បានចូលទៅក្នុងព្រះពុទ្ធសាសនានេះ ចាត់ជាការប្រសើរពិត ព្រោះខ្ញុំព្រះអង្គបានសម្រេចវិជ្ជា ៣ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ ប្រការ ទាំងបានធ្វើតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធហើយ ។

លទ្ធផលរបស់ព្រះឧបាលិត្ថេរ ផ្នែកទ្រទ្រង់ព្រះវិន័យ លោកបានធ្វើប្រយោជន៍យ៉ាងច្រើន ក្នុងការវិនិច្ឆ័យអធិករណ៍ និងប្រៀនប្រដៅភិក្ខុទាំងឡាយឲ្យយល់ផ្នែកព្រះវិន័យ ។

តែលទ្ធផលរបស់ព្រះឧបាលិត្ថេរ ដែលរាប់ថាជាទី ១ និងគង់វង្សជាសេចក្តីសំខាន់ជាប់តមកដល់បច្ចុប្បន្ននេះ គឺការដែលលោកបានរួមជាមួយព្រះអរិយសង្ឃចំនួន ៤៩៩ រូប ធ្វើ **បឋមសង្គាយនា** គឺការ

ប្រជុំសង្ឃរួបរួមព្រះធម៌វិន័យជាគ្រាដំបូង មានព្រះមហាកស្សបត្ថេរជាប្រធានដឹកនាំឲ្យលោកចូលរួម ក្រោយពីព្រះមានព្រះភាគស្តេចរំលត់ខន្ធបរិនិព្វាន និងបូជាភ្លើងព្រះបរមសពស្រេចហើយ ។

ព្រះឧបាលិត្ថេរ បានទទួលនាទីពីអរិយសង្ឃក្នុងទីប្រជុំគណៈសង្ឃដើម្បីធ្វើសង្គាយនាព្រះត្រៃបិដក គឺបិដក ៣ បានដល់ ១- ព្រះវិនយបិដក ២- ព្រះសុត្តន្តបិដក ៣- ព្រះអភិធម្មបិដក ដែលបានប្រជុំសង្ឃសកាសម្រេចឲ្យលោកជាសង្គាហកត្ថេរ គឺឲ្យលោកមាននាទីវិសជ្ជនា (ឆ្លើយឬដោះស្រាយ) ព្រះវិនយបិដក (ព្រះវិនយបិដក ប្រមូលព្រះពុទ្ធវចនៈផ្នែកខាងព្រះវិន័យ គឺព្រះពុទ្ធបញ្ញត្តិ ដែលជាការហាមការអនុញ្ញាតនិងអភិសមាចារសម្រាប់ភិក្ខុ រួមហៅថា ព្រះវិន័យ ឬសីល) កណ្តាលព្រះអរហន្តសាវកដែលបានវិជ្ជា ៣ និងអភិញ្ញា ៦ ចំនួន ៤៩៩ រូប ។

ការដែលព្រះឧបាលិត្ថេរ បានទទួលនាទីពីសង្ឃសកាឲ្យជាអ្នកវិសជ្ជនាព្រះវិន័យបិដក ព្រោះលោកជាអ្នកមានការចេះដឹង គឺមានភាពអង់អាច ឬមានភាពក្លាហានក្នុងផ្នែកនេះ រហូតព្រះសាស្តាជាម្ចាស់ទ្រង់លើកសរសើរលោក ឲ្យជាអ្នកលើសជាងគេផ្នែកទ្រទ្រង់ព្រះវិន័យ ។

រឿងធ្វើនាទីវិសជ្ជនាព្រះវិន័យរបស់ព្រះឧបាលិត្ថេរ មានប្រកាសទុកក្នុង **អដ្ឋកថាបឋមសមន្តប្បាសាទិកា** និង **អដ្ឋកថាសុមង្គលវិលាសិនី** សេចក្តីថា ៖

កាលព្រះអានន្ទត្ថេរ ឡើងគង់លើអាសនៈព្រះសង្ឃកំណត់ឲ្យហើយ ទើបព្រះមហាកស្សបត្ថេរប្រឹក្សានឹងភិក្ខុទាំងឡាយថា អាវុសោ អ្នកមានអាយុទាំងឡាយ ពួកយើងនឹងសង្គាយនាអ្វី តើព្រះធម៌ ឬព្រះវិន័យមុនហ្ន៎ ។

ពួកភិក្ខុទាំងឡាយឆ្លើយថា បពិត្រព្រះមហាកស្សប ព្រះវិន័យគឺជាអាយុព្រះពុទ្ធសាសនា កាលព្រះវិន័យតាំងនៅមាំ ព្រះពុទ្ធសាសនាក៏តាំងនៅ ព្រោះដូច្នោះ ពួកយើងសង្គាយនាព្រះវិន័យមុនចុះ ។

ព្រះមហាកស្សបត្ថេរសួរថា នឹងឲ្យលោករូបណាទទួលភារៈផ្នែកនេះហ្ន៎ ភិក្ខុទាំងឡាយឆ្លើយថា ឲ្យព្រះឧបាលិត្ថេរទទួលភារៈផ្នែកនេះ ។

ព្រះមហាកស្សបត្ថេរសួរថា ព្រះអានន្ទមិនអាចទទួលភារៈផ្នែកនេះបានឬ ?

ភិក្ខុទាំងឡាយឆ្លើយថា ព្រះអានន្ទ មានភាពជំនាញយ៉ាងពិត

ប្រាកដ តែមានហេតុផលម្យ៉ាង កាលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់គង់ព្រះជន្មនៅឡើយ ព្រោះទ្រង់អាស្រ័យព្រះវិន័យបរិយត្តិ ( ការរៀនព្រះវិន័យ ) នេះ បានស្ថាបនាព្រះឧបាលីទុកក្នុងតំណែងឯតទគ្គៈ ព្រោះដូច្នោះ ទើបភិក្ខុទាំងឡាយប្រឹក្សាគ្នាថា ពួកយើងនឹងសួរព្រះឧបាលីដើម្បីសង្គាយនាព្រះវិន័យ ។

លំដាប់នោះ ទើបព្រះមហាកស្សបត្ថេរបានសន្មតខ្លួនដោយខ្លួនឯងដើម្បីនឹងសួរនូវព្រះវិន័យ ។

ចំណែកព្រះឧបាលិត្ថេរ ក៏បានសន្មតខ្លួនដើម្បីប្រយោជន៍ដល់ការធ្វើនាទីក្នុងការវិសជ្ជនា លុះលោកបានសន្មតខ្លួនយ៉ាងនេះហើយ ទើបក្រោកចាកអាសនៈ គ្រងចីវរ ថ្វាយបង្គំព្រះថេរៈទាំងឡាយហើយ ឡើងគង់លើធម្មាសនៈ ( ទីសម្រាប់សម្ដែងធម៌ ) ចាប់ផ្ចិតវាលវីជនី មានដងធ្វើដោយភ្លុក យ៉ាងល្អវិចិត្រ ។

ការធ្វើនាទីជាអ្នកវិសជ្ជនា ព្រះវិន័យបិដករបស់ព្រះឧបាលិត្ថេរ មានក្នុងបាលី គម្ពីរចុល្លវគ្គ ព្រះវិនយបិដក នៃ បញ្ចសតិកក្ខន្ធកៈ ក្នុងអដ្ឋកថាសមន្តប្បាសាទិកា និងក្នុង អដ្ឋកថាសុមង្គលវិលាសិនី ថា ៖

គ្រានោះ ព្រះមហាកស្សបត្ថេរប្រកាសឲ្យព្រះសង្ឃបានជ្រាបហើយ ក៏ផ្ដើមសួរព្រះវិន័យនឹងព្រះឧបាលី ។

ចំណែកព្រះឧបាលិត្ថេរ បានប្រកាសឲ្យព្រះសង្ឃជ្រាបហើយ ទើបផ្ដើមវិសជ្ជនាព្រះវិន័យ ។

ម្នាលឧបាលី បឋមបារាជិកសិក្ខាបទ គឺបារាជិកទី ១ ព្រះសាស្ដាទ្រង់បញ្ញត្តនៅទីណា ?

ព្រះឧបាលិត្ថេរវិសជ្ជនាថា ព្រះមានព្រះភាគទ្រង់បញ្ញត្តនៅក្នុងនគរវេសាលី លោកម្ចាស់ !

ព្រះមហាកស្សបត្ថេរ. ព្រះមានព្រះភាគទ្រង់ប្រារព្ធបុគ្គលណា ?

ព្រះឧបាលិត្ថេរ. ព្រះមានព្រះភាគទ្រង់ប្រារព្ធភិក្ខុសុទិន្នកលន្ទកបុត្តលោកម្ចាស់ !

ព្រះមហាកស្សបត្ថេរ. ព្រោះមានរឿងអ្វី ?

ព្រះឧបាលិត្ថេរ. ព្រោះមានរឿងសេពមេថុនធម្ម លោកម្ចាស់ !

បន្ទាប់មក ព្រះមហាកស្សបត្ថេរបានសួរព្រះឧបាលិត្ថេរដល់ វត្ថុ និទាន បុគ្គល បញ្ញត្តិ អនុប្បញ្ញត្តិ អាបត្តិ អនាបត្តិ នៃបឋមបារាជិក

សិក្ខាបទនឹងព្រះឧបាលិត្ថេរ ហើយសួរតទៅដល់ទុតិយបារាជិកសិក្ខាបទ គឺបារាជិកទី ២-៣-៤ ថា ព្រះមានព្រះភាគទ្រង់បញ្ញត្តិទីណា...។ល។

បន្ទាប់មក ព្រះមហាកស្សបត្ថេរបានសួរដល់វត្ថុ ។ល។ អនាបត្តិនៃបារាជិកសិក្ខាបទទី ២-៣-៤ នឹងព្រះឧបាលិត្ថេរ ហើយទើបសួរឧភតោវិភង្គវិន័យទាំងពីរចំណែក គឺចំណែកភិក្ខុនិងចំណែកភិក្ខុនីដោយវិធីនោះឯង ។

ព្រះឧបាលី បានវិសជ្ជនានូវពាក្យបុច្ឆារបស់ព្រះមហាកស្សបដែលបានសួរហើយដែរ ។

ការរួបរួមព្រះវិនយបិដកដែលព្រះថេរៈទាំងឡាយធ្វើឡើង មានការពោលទុកក្នុង **អដ្ឋកថាបឋមសមន្តប្បាសាទិកា** និងក្នុង **អដ្ឋកថាសុមង្គលវិលាសិនី** មានសេចក្តីថា ៖

លំដាប់នោះ ព្រះថេរៈទាំងឡាយលើកបារាជិក ( **បារាជិក** អ្នកចាលចាញ់ **សង្ឃាទិសេស** អាបត្តិដែលត្រូវអាស្រ័យសង្ឃក្នុងកម្មខាងដើម និងកម្មដ៏សេស **អនិយត** មិនទៀងទាត់ **និស្សគ្គិយបាចិត្តិយ** អាបត្តិដែលត្រូវលះវត្ថុមុនសម្តែងអាបត្តិ **បាចិត្តិយ** គឺការល្មើសដែល

ញ៉ាំងកុសលឲ្យធ្លាក់ចុះ **បាដិទេសនីយ** គឺគប្បីសម្ដែងចេញ **សេក្ខិយ** គួរសិក្សា **អធិករណសមថ:** សម្រាប់រម្ងាប់រឿងដែលកើតឡើង ។ **អាបត្តិបារាជិក** ធ្វើឲ្យអ្នកត្រូវដាច់ការ:ជាភិក្ខុ **សង្ឃាទិសេស** ជាអាបត្តិធ្ងន់រងពីបារាជិកសង្ឃជាអ្នកវិនិច្ឆ័យទោសឲ្យនៅបរិវាសកម្មគឺការជម្រះទោសស្មើចំនួនថ្ងៃដែលបិទបាំង នឹងត្រូវអាស្រ័យសង្ឃរហូតអស់កិច្ច ទើបផុតចាកទោស ចំណែកអាបត្តិក្រៅពីនោះចាត់ជាពួកអាបត្តិស្រាល និងផុតចាកទោសបាន ដោយការសម្ដែងរបស់ខ្លួនដល់សង្ឃ ឬភិក្ខុដទៃ ) ៤ សិក្ខាបទ ឡើងកាន់ការសង្គាយនា រួបរួមថានេះឈ្មោះ បារាជិកកណ្ឌ លើកសង្ឃាទិសេស សិក្ខាបទថា តេរសកណ្ឌ លើក ២ សិក្ខាបទថា អនិយត លើក ៣០ សិក្ខាបទថា និស្សគ្គិយបាចិត្តិយ តាំង ៩២ សិក្ខាបទថា បាចិត្តិយ តាំង ៤ សិក្ខាបទថា បាដិទេសនីយ លើក ៧៥ សិក្ខាបទថា សេក្ខិយ និងតាំងធម៌ ៧ ប្រការថា អធិករណសមថ: ហើយប្រកាសសិក្ខាបទ ២២៧ សិក្ខាបទថា គម្ពីរមហាវិភង្គ ។

លុះព្រះថេរ:ទាំងឡាយលើកមហាវិភង្គ (បានដល់ការបែងចែកជាឈ្មោះមួយក្នុង ៥ ចំណែករបស់ព្រះវិន័យ ) ឡើងកាន់សង្គាយនា

យ៉ាងនេះហើយ លំដាប់តពីនោះ ទើបបានធ្វើការសង្គាយនាភិក្ខុនីវិភង្គ ស្រេចហើយ ទើបតាំងបារាជិក ៨ សិក្ខាបទក្នុងភិក្ខុនីវិភង្គ ឈ្មោះ បារាជិកកណ្ឌ តាំង ១៧ សិក្ខាបទថា សត្តរសកណ្ឌ លើក ៣០ សិក្ខាបទថា និស្សគ្គិយបាចិត្តិយ តាំង ១៦៦ សិក្ខាបទថា បាចិត្តិយ តាំង ៨ សិក្ខាបទថា បាដិទេសនីយ តាំង ៧៥ សិក្ខាបទថា សេក្ខិយ និងលើកធម៌ ៧ ប្រការថា អធិករណសមថៈ ប្រកាសសិក្ខាបទ ៣១១ សិក្ខាបទថា ភិក្ខុនីវិភង្គ ហើយតាំងឈ្មោះវិភង្គថា ឧភតោវិភង្គ ( ការ បែកសិក្ខាបទទាំងពីរចំណែក ) ។

កាលព្រះថេរៈទាំងឡាយធ្វើសង្គាយនាព្រះត្រៃបិដក លើកគម្ពីរ ខន្ធកៈ គឺមហាវគ្គ ចុល្លវគ្គ និងគម្ពីរបរិវារ (ឈ្មោះគម្ពីរព្រះវិនយបិដក ចុងក្រោយ ) ឡើងកាន់សង្គាយនាដោយកិច្ចនេះហើយ ទើបប្រកាស ឈ្មោះបិដកនេះថា ព្រះវិនយបិដក ។

ព្រះមហាកស្សបៈ បានសួរព្រះវិនយបិដកទាំងអស់ ព្រះឧបាលី ក៏បានវិសជ្ជនាហើយដែរ ។ ក្នុងទីបំផុតនៃការបុច្ឆា និងវិសជ្ជនា ព្រះ អរហន្ត ៥០០ រូប បានធ្វើការសជ្ឈាយន៍ ( ការសូធ្យ ) ជាគណៈ

ដោយន័យដែលលើកឡើងសង្គាយនានោះ ។

ក្នុងអវសាននៃការសង្គាយនាព្រះវិន័យ ព្រះឧបាលីដាក់ផ្ចិតវាលវីជនីដ៏វិចិត្រដោយភ្លុក ហើយចុះចាកធម្មាសនៈ លោកបានថ្វាយបង្គំភិក្ខុទាំងឡាយ ដែលចាស់វស្សាជាងលោក ទើបអង្គុយលើអាសនៈដែលសមគួរដល់ខ្លួន ។

ព្រះវិនយបិដក ដែលព្រះឧបាលិត្ថេរវិសជ្ជនាហើយ បើរាប់ជាគម្ពីរ មាន **៥ គម្ពីរ** គឺ

១- **អាទិកម្ម** គឺអ្នកធ្វើ ឬភិក្ខុអ្នកធ្វើហេតុជាខាងដើមបញ្ញត្តិក្នុងសិក្ខាបទនោះៗ ពោលដោយសិក្ខាបទ ដែលទាក់ទងជាមួយនឹងអាបត្តិធ្ងន់របស់ភិក្ខុសង្ឃ តាំងពីបារាជិករហូតដល់អនិយត ។

២- **បាចិត្តិយ** គឺការប្រព្រឹត្តល្មើសដែលញុំាងកុសលធម៌ឲ្យធ្លាក់ចុះ ពោលដោយសិក្ខាបទ ដែលទាក់ទងជាមួយនឹងអាបត្តិស្រាល តាំងពីនិស្សគ្គិយបាចិត្តិយ រហូតដល់សេខិយវត្ត រួមទាំងភិក្ខុនីវិភង្គផង ។

៣- **មហាវគ្គ** គឺវគ្គធំ ឬពួកធំ ដែលពោលដោយសិក្ខាបទក្រៅពីបាតិមោក្ខខាងដើម ១០ ខន្ធកៈ ឬវគ្គ ១០ ។

៤- **ចុល្លវគ្គ** គឺវគ្គតូច ឬពួកតូច ដែលពោលដោយសិក្ខាបទខាងចុង ១២ ខន្ធកៈ ឬ ១២ វគ្គ ។

៥- **បរិវារវគ្គ** គឺពួកដែលជាចំណែកប្រកបដោយពាក្យសួរពាក្យឆ្លើយបង្កើនចំណេះដឹងផ្នែកព្រះវិន័យ ។ បើរាប់រួមទាំង ៥ គម្ពីរ ត្រូវជាព្រះធម្មក្ខន្ធ ២១០០០ ព្រះធម្មក្ខន្ធ ឯឈ្មោះទាំង ៥ គម្ពីរនោះ មានពាក្យហៅ ដោយសង្ខេបថា **អា. បា. ម. ចុ. ប.** ។តែថា ព្រះវិនយបិដកនេះមានការចែកជាគម្ពីរមួយបែបទៀតជា ៥ គម្ពីរដូចគ្នា ដោយចាត់ជាពីរចំណុចខាងដើមនោះជាថ្មី គឺ

១- **មហាវិភង្គ ឬភិក្ខុវិភង្គ** ពោលដោយសិក្ខាបទក្នុងបាតិមោក្ខ ( សីល ២២៧ ចំណុច ) របស់ភិក្ខុសង្ឃ ។

២- **ភិក្ខុនីវិភង្គ** ពោលដោយសិក្ខាបទក្នុងបាតិមោក្ខ ( សីល ៣១១ ចំណុច ) របស់ភិក្ខុនីសង្ឃ ។

៣- មហាវគ្គ ៤- ចុល្លវគ្គ ៥- បរិវារ ។

ម្យ៉ាងទៀត ព្រះវិន័យប្រៀបដូចជា **ធម្មនុញ្ញ** ឬច្បាប់របស់សត្វលោក ព្រោះប្រើជាច្បាប់សម្រាប់គ្រប់គ្រងគណៈសង្ឃ ឲ្យមាន

កាពស្មើគ្នា កើតជារបៀបរៀបរយដោយឯកន្ត: បើខ្វះវិន័យដែលជាច្បាប់គ្រប់គ្រងហើយ ពួកគណៈនឹងតាំងនៅមិនបាន បើអ្នកដទៃនឹងកំណត់ច្បាប់ឡើងតាមការពេញចិត្តរបស់ខ្លួន ឬរបស់សង្គមនៃពួកខ្លួន ដោយមិនបានប្រកាន់គោលសេចក្ដីពិត ឬសេចក្ដីត្រឹមត្រូវតាមហេតុផលដែលល្អជាបន្ទាត់ការបញ្ញត្តិឡើង រមែងខ្វះធម៌ទៀងតែងតែមានអគតិ គឺការលំអៀងលាក់បាំង ។

ចំណែកព្រះវិនយបិដកជាច្បាប់បញ្ញត្តិដែលមានហេតុផលមានតួលេខដែលត្រឹមត្រូវ មានគតិយុត្តិធម៌ ទើបមានអាយុវែងជាសច្ចធម៌មករហូតដល់បច្ចុប្បន្ននេះ ហើយមានសភាពស្ថិតស្ថេរគង់វង់តទៅអនាគតអស់កាលដ៏យូរ ។៚

( ជីវប្រវត្តិរបស់ព្រះឧបាលិត្ថេរ ចប់ )

8888888888888888888888888888888888888888888888888

# ✍ ជីវប្រវត្តិរបស់ព្រះនន្ទកត្ថេរ ✍

## “ ដែលជាឯតទគ្គៈផ្នែកខាងឱ្យឱវាទដល់ពួកភិក្ខុនី ”

*ព្រះនន្ទកត្ថេរ លោកជាមហាសាវ័កមួយរូប ដែលមានតំណែងជាឯតទគ្គៈផ្នែកខាងឲ្យឱវាទដល់ពួកភិក្ខុនីថែមទាំងមានការសម្តែងធម៌ធ្វើចិត្តបរិស័ទទាំង ៤ ជំពូកឲ្យកើតសេចក្តីជ្រះថ្លា និងមានភាពអង់អាចដ៏ខ្ពង់ខ្ពស់ក្នុងព្រះសាសនានេះ ព្រោះលោកជាព្រះអរហន្ត ដែលមានជំនាញក្នុងការរឭកជាតិបានផងដែរ ។*

*ជីវប្រវត្តិរបស់ព្រះនន្ទកត្ថេរ មានសម្តែងនៅក្នុង **អដ្ឋកថា គម្ពីរមនោរថបូរណី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលី ក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ដូចមានសេចក្តីថា ៖*

*ព្រះនន្ទកៈកើតនៅក្នុងត្រកូលព្រាហ្មណ៍ ដែលស្ថិតនៅក្នុងក្រុងសាវត្ថី ពេលចម្រើនវ័យធំឡើង លោកបានទៅស្តាប់ធម៌ទេសនា ក្នុងសម្នាក់ព្រះសម្ពុទ្ធជាម្ចាស់ ក៏កើតមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា*

ទើបក្រាបទូលសូមបព្វជ្ជាឧបសម្បទា ។

កាលបានបព្វជ្ជាឧបសម្បទាជាភិក្ខុ ក្នុងសាសនព្រហ្មចរិយធម៌នេះហើយ តាំងចិត្តចម្រើនវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មានក៏បានសម្រេចនូវព្រះអរហត្តផល ( ផល គឺភាពជាអ្នកឆ្ងាយចាកសត្រូវ គឺកិលេស ឬជាអ្នកមិនមានកិលេស ) ថែមទាំងបានជាព្រះអសេក្ខបុគ្គល ( គឺបុគ្គលមិនមានការសិក្សាជាបន្តទៅទៀត ) ។

ព្រះនន្ទកៈ លោកមានភាពជំនាញក្នុងបុព្វេនិវាសានុស្សតិញ្ញាណ គឺអាចរឭកដឹងដល់ការកើតក្នុងអតីតជាតិរបស់លោក និងសត្វដទៃទៀតបាន លោកជាអ្នកឈ្លាសវៃក្នុងការសម្តែងធម៌ ធ្វើឲ្យចិត្តបរិស័ទទាំង ៤ ជំពូក ឲ្យកើតមានសេចក្តីជ្រះថ្លាក្នុងព្រះសាសនានេះ គឺសម្តែងព្រះធម៌ពន្យល់នូវហេតុផលឲ្យជាទីពេញចិត្ត និងយល់បានងាយ ទើបលោកបានទទួលនាមថា **ព្រះនន្ទកៈ** បានដល់ភាពជាអ្នកមានការសម្តែងព្រះធម៌ ធ្វើឲ្យជាទីសប្បាយពេញចិត្តដល់អ្នកស្តាប់ ។

ការសម្តែងធម៌របស់ព្រះនន្ទកត្ថេរ ដែលរាប់ថាគួរឲ្យអស្ចារ្យនោះ

បានដល់ ការសម្ដែងធម៌ដល់ពួកភិក្ខុនីចំនួន ៥០០ រូប ឲ្យបានសម្រេចជាព្រះអរហន្តីទាំងអស់អង្គ ។

ដូចមានរឿងប្រាកដដូច្នេះថា ពួកសក្យកុមារ៥០០នាក់ បានចូលមកបួសក្នុងព្រះសាសនាហើយ កើតការមិនត្រេកអរក្នុងការប្រព្រឹត្តព្រហ្មចរិយធម៌ឡើយ ។

ព្រះភគវាជាម្ចាស់ ទើបទ្រង់នាំភិក្ខុទាំងនោះទៅកាន់ស្រះកុណាលដែលជាស្រះធំ តាំងនៅក្នុងព្រៃហិមពាន្ត ហើយទ្រង់សម្ដែងកុណាល-ជាតក គឺជាតកដែលសម្ដែងដល់សត្វតាវៅ និងទ្រង់ជ្រាបថា ភិក្ខុទាំង ៥០០ រូប កើតមានការរន្ធត់ចិត្ត ទើបទ្រង់សម្ដែងចតុរារិយសច្ច គឺការពិតដ៏ប្រសើរ ៤ ប្រការ អនុគ្រោះឲ្យភិក្ខុទាំង ៥០០ រូបនោះ បានតាំងនៅក្នុងសោតាបត្តិផល លុះកាលជាខាងក្រោយមក ព្រះសាស្ដាជាម្ចាស់ទ្រង់សម្ដែង **មហាសមយសូត្រ** អនុគ្រោះភិក្ខុទាំងនោះ ឲ្យបានសម្រេចជាព្រះអរហន្ត ដែលជាទីបំផុតនៃការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងព្រះសាសនានេះ ។

ចំណែកកកិរិយាចាស់របស់ភិក្ខុទាំងនោះ លុះបានជ្រាបថា ស្វាមីរបស់ខ្លួនបួសហើយ ទើបប្រឹក្សាគ្នាថា ឥឡូវនេះ ពួកយើងរស់នៅក្នុងភាពជាឃរាវាសបានប្រយោជន៍អ្វី ហើយព្រមព្រៀងគ្នាទៅរកព្រះនាងមហាបជាបតិគោតមីថេរី ដើម្បីសូមបព្វជ្ជាឧបសម្បទាជាភិក្ខុនី ព្រះនាងមហាបជាបតិគោតមីក៏ព្រមឲ្យឧបសម្បទា ដោយមានសង្ឃទាំងពីរចំណែក គឺភិក្ខុសង្ឃមួយចំណែក ភិក្ខុនីមួយចំណែក ជាអ្នកឲ្យឧបសម្បទា ។

ដូចមានរឿងសម្តែងទាក់ទងនឹងពួកភិក្ខុនីទាំង ៥០០ រូបនោះថា ក្នុងអតីតកាល ពួកនាងទាំងនោះធ្លាប់បានធ្វើជាអ្នកបម្រើរបស់ព្រះថេរៈកាលដែលលោកកើតជាព្រះរាជា ដែលមានរឿងប្រាកដនៅក្នុង **អដ្ឋកថាបបញ្ចសូទនី** ដែលអធិប្បាយសេចក្តីព្រះបាលីក្នុង **គម្ពីរមជ្ឈិមនិកាយឧបរិបណ្ណាសកៈ** ក្នុង **នន្ទកោវាទសូត្រ** ដូចមានសេចក្តីថា ៖

ក្នុងអតីតជាតិ លោកកើតនៅក្រុងពារាណសី មានពួកទាសា និងទាសីមួយចំណែកៗ ៥០០ នាក់ដូចគ្នា បានរួមការងារស្នាក់អាស្រ័យនៅជាមួយគ្នា ។ចំណែកព្រះនន្ទកត្ថេរនោះបានជាអ្នកគ្រប់គ្រងផ្ទែកខាង

ទាសា ក្នុងកាលនោះ ព្រះនាងមហាបជាបតិគោតមីថេរី បានជាអ្នកគ្រប់គ្រងផ្នែកខាងទាសី ព្រោះនាងជាភរិយារបស់ទាសាដែលជាធំ ប៉ុន្តែអ្នកទាំងពីរនាក់នោះ ជាអ្នកមានបញ្ញាឈ្លាសវៃក្នុងការគ្រប់គ្រងពួកទាសា ទាសីទាំង ១០០០ នាក់នោះ ដូចមានការធ្វើបុណ្យរួមគ្នា ប្រាថ្នាឲ្យកើតជាតិណាជួបគ្នា ដូច្នេះជាដើម ។

នៅក្នុងថ្ងៃមួយ ដែលជារដូវចូលព្រះវស្សា មានព្រះបច្ចេកពុទ្ធ ៥០០ អង្គ បាននិមន្តមកអំពីភ្នំនន្ទមូលកៈ មកគង់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន នៅក្នុងក្រុងពារាណសី ហើយបានពោលនឹងគ្នាថា ពួកយើងទាំងឡាយនឹងត្រាច់ទៅបិណ្ឌបាតក្នុងក្រុង ហើយនឹងសូមការជួយពីអ្នកស្រុក ដើម្បីឲ្យធ្វើទីអាស្រ័យ សម្រាប់ចាំវស្សាត្រង់ព្រៃឥសិបតនមិគទាយវ័ននេះ ។

ដល់ពេលល្ងាច ព្រះបច្ចេកពុទ្ធជាម្ចាស់បាននាំគ្នានិមន្តចូលទៅកាន់ក្រុងពារាណសី បានចូលទៅឈរនៅទៀបមាត់ទ្វារផ្ទះរបស់សេដ្ឋីម្នាក់ ។ ក្នុងពេលនោះ ជាពេលដែលទាសីជាធំ បានចុះទៅកាន់កំពង់ទឹក

ដើម្បីដងទឹក ចៃដន្យល្អណាស់ បានជួបព្រះបច្ចេកពុទ្ធកំពុងនិមន្តចូលទៅកាន់ក្រុងពារាណសី ។

ចំណែកសេដ្ឋីម្ចាស់ស្រុកនោះបានជ្រាបនូវបំណងព្រះបច្ចេកពុទ្ធទាំងនោះហើយ ទើបប្រាប់ដល់ព្រះបច្ចេកពុទ្ធទាំងនោះថា ខ្ញុំព្រះករុណាមិនមានពេល សូមលោកម្ចាស់ទាំងឡាយនិមន្តត្រឡប់ទៅវិញចុះ ។

ព្រះបច្ចេកពុទ្ធជាម្ចាស់ កាលបើបានស្តាប់ពាក្យបដិសេធរបស់សេដ្ឋីហើយបាននាំគ្នានិមន្តត្រឡប់ទៅវិញក្នុងពេលដែលព្រះបច្ចេកពុទ្ធទាំងឡាយនិមន្តត្រឡប់ចេញអំពីក្រុងពារាណសី ក៏ជាពេលដែលទាសីជាធំកំពុងត្រឡប់មកអំពីដងទឹកវិញដែរ គេបានឃើញព្រះបច្ចេកពុទ្ធទាំងនោះហើយ ទើបដាក់ក្អមទឹកចុះ លើកដៃឡើងថ្វាយបង្គំ រួចហើយសួរថា បពិត្រលោកម្ចាស់ទាំងឡាយ លោកនិមន្តចូលទៅកាន់ក្រុងអម្បាញ់មិញនេះ ហេតុអ្វីទើបប្រញាប់និមន្តត្រឡប់ចេញមកវិញម្ល៉េះ ។

ព្រះបច្ចេកពុទ្ធជាម្ចាស់ប្រាប់នូវបំណង ឲ្យនាងទាសីជាធំដឹងថា នែ៎ នាងដ៏ចម្រើន ពួកអាត្មាបាននិមន្តចូលទៅកាន់ក្រុងនោះ ក៏ដើម្បីនឹង

សូមឲ្យមនុស្សទាំងឡាយធ្វើទីអាស្រ័យក្នុងការចាំវស្សាឲ្យ ។ ទាសីជាធំសួរថា លោកម្ចាស់ទាំងឡាយបានទទួលការជួយឬទេ ព្រះបច្ចេកពុទ្ធជាម្ចាស់ឆ្លើយថា ពួកអាត្មាមិនទាន់មានអ្នកជួយទេ ។

បពិត្រលោកម្ចាស់ តើទីអាស្រ័យនោះ អាចធ្វើបានតែចំពោះអ្នកមានស្តុកស្តម្ភទេឬ ឬអ្នកទីទ័លក្រក៏នឹងអាចធ្វើបានដែរលោកម្ចាស់ ព្រះបច្ចេកពុទ្ធឆ្លើយថា នាងដ៏ចម្រើន អ្នកណាៗ ក៏នឹងអាចធ្វើបានដែរ ទាសីជាធំក៏ឆ្លើយថា ប្រសិនបើដូច្នោះ ល្អហើយលោកម្ចាស់ ពួកនាងខ្ញុំទាំងអស់គ្នា នឹងនាំគ្នាទៅធ្វើក្នុងថ្ងៃស្អែកនេះ សូមលោកម្ចាស់និមន្តមកទទួលភិក្ខាក្នុងផ្ទះរបស់នាងខ្ញុំម្ចាស់ ក្នុងថ្ងៃស្អែកនេះផងណា កាលទាសីជាធំ ពោលដូច្នេះហើយ បានប្រញាប់រូតរះត្រឡប់ទៅផ្ទះ ហើយបានប្រញាប់ត្រឡប់ចេញមកវិញ ដើម្បីប្រាប់ដល់ពួកទាសី ដែលមកដងទឹកទាំងនោះថា នាងទាំងអស់គ្នាចូរឈប់នៅទីនេះសិនហើយពោលសួរថា ពួកនាងសុខចិត្តព្រមធ្វើជាទាសីរបស់អ្នកដទៃជានិច្ចយ៉ាងនេះរហូតទៅឬ ឬថាចង់រួចផុតពីភាពជាទាសីរបស់អ្នកដទៃដែរឬទេ ? ទាសី

ទាំងនោះឆ្លើយថា ពួកខ្ញុំម្ចាស់ចង់រួចផុតចាកភាពជាទាសីរបស់អ្នកដទៃ ក្នុងថ្ងៃនេះតែម្តងឯង ។

ពេលនោះ ទាសីជាធំពោលថា ល្អហើយ យើងក៏បាននិមន្តព្រះបច្ចេកពុទ្ធឲ្យមកទទួលចង្ហាន់បិណ្ឌបាត នៅផ្ទះរបស់ពួកយើងក្នុងថ្ងៃស្អែកនេះដែរ ប៉ុន្តែអ្នកទាំងអស់គ្នា ចូរប្រាប់ឲ្យស្វាមីរបស់ពួកនាងទៅជួយធ្វើទីស្នាក់អាស្រ័យ សម្រាប់ចាំព្រះវស្សាប្រគេនចំពោះលោកម្ចាស់ ក្នុងថ្ងៃស្អែកផងណា ។

កាលបើទាសីជាធំ បានបបួលទាសីទាំងនោះយ៉ាងនេះហើយ ក៏ទទួលថា ល្អហើយ ទើបប្រាប់ដល់ស្វាមីរបស់ខ្លួនរៀងៗ ខ្លួន ក្នុងពេលដែលស្វាមីរបស់ខ្លួនត្រឡប់មកអំពីព្រៃវិញ ។ក្នុងពេលប្រជុំព្រមព្រៀងគ្នានោះ ទាសីជាធំទើបប្រាប់ថា ព្រឹកស្អែកនេះ អ្នកទាំងឡាយចូរជួយគ្នាទៅធ្វើទីស្នាក់អាស្រ័យថ្វាយព្រះបច្ចេកពុទ្ធ ហើយបបួលណែនាំបុគ្គលដែលមិនប្រាថ្នាជួយធ្វើ ឲ្យកើតសេចក្តីត្រេកអរដោយហេតុផល ដែលមានសារៈខ្លឹមសារគួរជឿបាន ។លុះព្រឹកស្អែកឡើងបានរៀបចំការថ្វាយ

កិក្ខាដល់ព្រះបច្ចេកពុទ្ធ ហើយថែមទាំងពោលជាមួយនឹងបុត្រទាសាទាំងពួង ឲ្យចេញទៅជួយធ្វើការកិច្ចការនោះដែរ ។

ពួកបុត្ររបស់ទាសាប្រមាណ ៥០០ នាក់បានព្រមព្រៀងគ្នាចេញទៅព្រៃរកឈើមកធ្វើកុដិ និងទីចង្ក្រមជាដើម ឲ្យរួចស្រេចរៀបរយល្អហើយ ចាត់ចែងរកគ្រឿងប្រើប្រាស់ មានគ្រែ តាំង ក្អមដាក់ទឹក និងគ្រឿងប្រើសព្វគ្រប់ហើយ ។ បន្ទាប់មក ទើបនិមន្តព្រះបច្ចេកពុទ្ធឲ្យគង់ចាំព្រះវស្សាត្រង់ព្រៃឥសិបតនមិគទាយវ័ននោះហើយប្តូរវេនដាក់បាត្រកាលបើវេនមកដល់នរណា អ្នកនោះក៏ត្រូវចាត់ចែងកិក្ខាដាក់បាត្រ រីឯទាសីជាធំនោះបាននាំយកកិក្ខាពីផ្ទះរបស់ខ្លួនទៅថ្វាយផងដែរ ។

លុះមកដល់ពេលចេញវស្សាហើយ ទាសីជាធំនោះបានឲ្យទាសីម្នាក់ៗ ថ្វាយសំពត់ដល់ព្រះបច្ចេកពុទ្ធមួយអង្គៗ មួយផ្ទាំង រួមជាសំពត់ ៥០០ ផ្ទាំង ។ ព្រះបច្ចេកពុទ្ធជាម្ចាស់បានទទួលសំពត់អំពីទាសីទាំងនោះហើយ ពោលសុំលាចេញចាកព្រៃឥសិបតនមិគទាយវ័ន ។ លុះទាសានិងទាសីទាំងអស់ស្លាប់អំពីជាតិនេះទៅហើយ បានទៅកើតក្នុងស្ថានសួគ៌

ពេលចុតិចាកស្ថានសួគ៌មកវិញ បានជាស្វាមីភរិយានឹងគ្នាទៀត ។

ចំណែកទាសាជាធំបានមកកើតនៅក្នុងរាជត្រកូល ចំពោះនាងទេពធីតាទាំង ៥០០ នោះ បានមកកើតនៅក្នុងត្រកូលអ្នកមានស្តុកស្តម្ភហើយ បានជាភរិយានៃបុត្ររបស់ទាសាជាធំៗ លោកបានជាក្សត្រក្នុងជាតិនោះ ។ កាលបើនាងទាំង ៥០០ នាក់នោះស្លាប់កើតៗ ក្នុងមនុស្សទេវតាដូច្នេះហើយ លុះមកដល់សាសនាព្រះពុទ្ធជាម្ចាស់នៃយើង ពួកនាងក៏បានមកកើតក្នុងត្រកូលក្សត្រសក្យរាជ នៅក្នុងកោលិយនគរ និងទេវទហនគរ ។

ចំណែកទាសាជាធំនោះ ដែលធ្លាប់បានកើតជាក្សត្រមកពីមុនក៏បានមកជាព្រះនន្ទកត្ថេរ ។ចំណែកទាសីជាធំ បានមកជាព្រះនាងមហាបជាបតិគោតមី ជាអគ្គមហេសីរបស់ព្រះបាទសុទ្ធោទនមហារាជ ហើយក្នុងកាលជាទីបំផុតក៏ចូលមកបួសជាភិក្ខុនី ។ចំណែកទាសាដែលជាស្វាមីពីជាតិមុន បានមកកើតជាព្រះរាជកុមារទាំង ៥០០ អង្គ ហើយថែមទាំងបានចេញបួសក្នុងព្រះសាសនា រួចក៏បានសម្រេចជាព្រះអរហន្តគ្រប់ៗ

ព្រះអង្គ ។ ទាសីដែលជាកិរិយាទាំងនោះ បានមកកើតជាខត្តិយកញ្ញា ក៏បានចេញបព្វជ្ជាជាភិក្ខុនីតាមស្វាមីផងដែរ នៅក្នុងសម្នាក់របស់ព្រះនាងមហាបជាបតិគោតមីថេរី ។ នេះជារឿងអតីតជាតិរបស់ព្រះនន្ទកត្ថេរ និងភិក្ខុនីទាំង ៥០០ រូបនោះ ។

ចំណែកជីវប្រវត្តិបច្ចុប្បន្នជាតិរបស់លោក ដែលមានប្រាកដនៅក្នុងព្រះបាលី **នន្ទកោវាទសូត្រ គម្ពីរមជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ** ដូចមានសេចក្តីថា ៖

សម័យថ្ងៃមួយ ព្រះសក្យមុនីជាម្ចាស់ទ្រង់សម្រេចព្រះឥរិយាបថនៅក្នុងវត្តជេតពនមហាវិហារ ដែលជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋីសាងថ្វាយ តាំងនៅក្បែរក្រុងសាវត្ថី គ្រានោះ ព្រះនាងមហាបជាបតិគោតមីថេរី ព្រមទាំងភិក្ខុនីប្រមាណ ៥០០ រូប ចូលទៅគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយ ឈរនៅក្នុងទីដ៏សមគួរដល់ខ្លួន ទើបព្រះនាងមហាបជាបតិគោតមីថេរីទូលថា បពិត្រព្រះសាស្តាជាម្ចាស់ សូមព្រះអង្គ ទ្រង់មេត្តាសម្តែងធម៌ឲ្យដល់ភិក្ខុនីទាំងឡាយផង គ្រានោះ ព្រះ

មុនីបានត្រាស់ប្រាប់ភិក្ខុទាំងឡាយ ឲ្យទៅឲ្យឱវាទដល់ភិក្ខុនីទាំងឡាយដោយប្តូរវេនគ្នាទៅ ។ កាលតមក ព្រះថេរៈទាំងឡាយបានសម្តែងធម៌ឲ្យភិក្ខុនីបានស្តាប់ដោយអនេកបរិយាយ គឺប្តូរគ្នាទៅតាមលំដាប់ថេរៈ ។ កាលបើមកដល់វារៈព្រះនន្ទកត្ថេរ លោករឭកមើលក្នុងអតីតជាតិក៏ជ្រាបថា ភិក្ខុនីទាំងនោះធ្លាប់ធ្វើជាអ្នកបម្រើរបស់ខ្លួនរៀងមក ទើបលោកគិតថា ប្រសិនបើព្រះថេរៈអង្គដទៃៗ ដែលលោកបានបុព្វេនិវាសានុស្សតិញ្ញាណ មើលឃើញយើងអង្គុយសម្តែងធម៌នៅក្នុងចំណោមពួកភិក្ខុនី ប្រាកដជាយល់ថា ព្រះនន្ទកត្ថេរនេះ នៅមិនទាន់លះបង់នាងស្រីស្នំរបស់ខ្លួនសោះ រហូតដល់ថ្ងៃនេះក៏នៅតែហែហមទៅដោយនាងស្រីស្នំចាស់ៗទាំងនោះនៅឡើយ ។

ព្រោះដូច្នោះ កាលដល់វារៈព្រះនន្ទកត្ថេរទៅឲ្យឱវាទដល់ភិក្ខុនី ទើបលោកឲ្យភិក្ខុអង្គដទៃទៅជំនួសវិញ ប៉ុន្តែភិក្ខុនីទាំង ៥០០ រូបនោះមានសេចក្តីត្រូវការនឹងទទួលស្តាប់ឱវាទរបស់លោក ប៉ុន្តែក៏ត្រូវខុសក្តីសង្ឃឹម ។ ដោយហេតុនោះ ព្រះភគវា ទើបត្រាស់សួរព្រះអានន្ទកត្ថេរ

ថា ម្នាលអានន្ទ ភារៈនេះជានាទីរបស់នរណាក្នុងការឲ្យឱវាទភិក្ខុនី ព្រះអានន្ទត្ថេរក្រាបបង្គំទូលតាមសេចក្តីពិតថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំងពួងបានដាក់វេន ទៅឲ្យឱវាទដល់ពួកភិក្ខុនីមកជារៀងរហូតហើយ ប៉ុន្តែថ្ងៃនេះជាវេនរបស់ព្រះនន្ទកត្ថេរ តែព្រះនន្ទកៈមិនប្រាថ្នានឹងទៅឲ្យឱវាទភិក្ខុនីទាំងនោះទេ ព្រះអង្គ ព្រះសាស្តាត្រាស់ប្រាប់ព្រះនន្ទកត្ថេរថា ម្នាលនន្ទកៈ អ្នកកុំឲ្យភិក្ខុដទៃទៅជំនួសឡើយ ចូរអ្នកទៅឲ្យឱវាទភិក្ខុនីដោយខ្លួនឯងចុះ ។

ព្រះនន្ទកត្ថេរក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ លុះដល់ពេលដែលត្រូវថ្ងៃលោកឲ្យឱវាទភិក្ខុនី ពេលព្រឹកឡើងលោកនិមន្តទៅបិណ្ឌ-បាតក្រុងសាវត្ថី កាលត្រឡប់ពីបិណ្ឌបាត ពេលក្រោយភត្តកិច្ចស្រេចហើយ ទើបចៀងចូលទៅកាន់ទីវត្តរាជការាម ។ វត្តរាជការាម ជាវត្តដែលព្រះបាទបសេនទិកោសលទ្រង់កសាង ដែលតាំងនៅទិសខាងត្បូងក្រុងវេសាលី ។ភិក្ខុនីទាំងឡាយ ក្រឡេកឃើញព្រះនន្ទកត្ថេរអំពីចម្ងាយក៏ត្រៀមរៀបចំតាំងអាសនៈ និងចាត់ចែងទឹកសម្រាប់លាងជើង លុះព្រះ

នន្ទកត្ថេរមកដល់ ទើបនិមន្តឲ្យគង់លើអាសនៈដែលគេក្រាលថ្វាយ ។

ចំណែកភិក្ខុនីទាំងនោះ នាំគ្នាថ្វាយបង្គំព្រះថេរៈ ហើយអង្គុយក្នុងទីដ៏សមគួរ ទើបព្រះនន្ទកត្ថេរ ពោលជាមួយនឹងភិក្ខុនីទាំងនោះថា ម្នាលប្អូនស្រីទាំងឡាយ ប្រសិនបើយើងសួរអ្នកហើយ ដឹងចូរឆ្លើយថាដឹង មិនដឹងចូរឆ្លើយថាមិនដឹង ឬមានសេចក្តីសង្ស័យ ស្មាក់ស្មើរចូរសួរមកចុះ ភិក្ខុនីទាំងនោះត្រេកអរពេញចិត្តចំពោះព្រះនន្ទកត្ថេរថា បពិត្រលោកម្ចាស់បើលោកម្ចាស់អនុញ្ញាតទុកដូច្នេះហើយ ធ្វើឲ្យខ្ញុំព្រះករុណាទាំងឡាយ មានសេចក្តីត្រេកអរពេញចិត្តណាស់ ។

ព្រះនន្ទកត្ថេរចាប់ផ្តើមសួរថា នាងទាំងឡាយយល់ថា **ចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយ ចិត្ត ទៀង ឬមិនទៀង ?** មិនទៀងទេ លោកម្ចាស់ វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ ឬជាសុខ ? ជាទុក្ខ លោកម្ចាស់ វត្ថុណាមិនទៀងជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា នាងទាំងឡាយគួរយល់ឃើញថា វត្ថុនោះជារបស់យើងជាយើងជាខ្លួនរបស់យើងឬ ?មិនគួរទេលោកម្ចាស់ នុ៎ះព្រោះហេតុអ្វី ? បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះ

កាលពីមុនខ្ញុំម្ចាស់ទាំងឡាយ មិនបានឃើញដោយបញ្ញាតាមសេចក្តីពិតថា សូម្បីដោយហេតុដូចនេះ អាយតនៈខាងក្នុង ៦ គឺភ្នែក ត្រចៀក ប្រមុះ អណ្តាត កាយ ចិត្ត ជារបស់មិនទៀង ( ពាក្យថា អាយតនៈ បានដល់គ្រឿងដឹង និងវត្ថុដែលគួរដឹង ឬគ្រឿងជាប់បន្តគ្នាជាមួយនឹងអាយតនៈខាងក្រៅ ) ។

ព្រះថេរៈឆ្លើយថា ត្រូវហើយៗ ប្អូនស្រីទាំងឡាយ ការយល់យ៉ាងនេះ រមែងមានដល់ព្រះអរិយសាវក អ្នកឃើញដោយបញ្ញាដ៏ប្រពៃតាមសេចក្តីពិត គឺយល់យ៉ាងច្បាស់ដោយវិបស្សនាបញ្ញា ( បានដល់បញ្ញាដែលឃើញច្បាស់លាស់ គឺឃើញថា វត្ថុទាំងពួងដែលមានបច្ច័យប្រជុំតាក់តែងមិនទៀង ជាទុក្ខ មិនមែនតួខ្លួន ) ដោយប្រការដូចនេះ កាលបើព្រះថេរៈបានពោលរាប់រងដូច្នេះហើយ ក៏នឹងតាំងបញ្ហាសួរភិក្ខុនីទាំងនោះ តទៅទៀតថា ម្នាលប្អូនស្រីទាំងឡាយ ពួកនាងយល់ថា រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ទាំងឡាយទៀងឬមិនទៀង ? មិនទៀងទេលោកម្ចាស់ ! វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ ឬជាសុខ ?

ជាទុក្ខ លោកម្ចាស់ ! វត្ថុណាមិនទៀងជាទុក្ខ មានសេចក្ដីប្រែប្រួលទៅជាធម្មតា នាងគួរយល់ឃើញថា វត្ថុនោះជារបស់យើង ជាយើង ជាតួខ្លួនរបស់យើងឬ ? មិនគួរទេលោកម្ចាស់ ព្រោះហេតុអ្វី ? ព្រោះថា កាលមុននោះ នាងខ្ញុំម្ចាស់ទាំងឡាយមិនបានឃើញយ៉ាងនេះ ដោយបញ្ញាដ៏ប្រពៃតាមពិតថា សូម្បីដោយហេតុនេះៗ អាយតនៈខាងក្រៅ ៦ គឺរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ទាំងឡាយនោះរបស់យើង ទើបឈ្មោះថាមិនទៀង លោកម្ចាស់ ល្អហើយៗ ម្នាលប្អូនស្រីទាំងឡាយ ព្រះអរិយសាវករមែងឃើញយ៉ាងនេះ ដោយបញ្ញាតាមសេចក្ដីពិតដូច្នេះឯង ។ កាលបើលោកពោលដូច្នេះហើយ បានសួរភិក្ខុនីទាំងនោះតទៅទៀតថា ម្នាលប្អូនស្រីទាំងឡាយ ពួកនាងយល់ឃើញថា ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ និងមនោ-វិញ្ញាណ ទៀង ឬមិនទៀង ? មិនទៀងទេលោកម្ចាស់ វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ ឬជាសុខ ? ជាទុក្ខ លោកម្ចាស់ វត្ថុណាមិនទៀងជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា នាងគួរយល់ឃើញថា វត្ថុនោះជារបស់

យើង ជាយើង ជាខ្លួនរបស់យើងឬ ? មិនគួរទេ លោកម្ចាស់ ព្រោះហេតុអ្វី ? បពិត្រលោកម្ចាស់ដ៏ចម្រើន កាលខ្ញុំម្ចាស់មិនបានឃើញដោយបញ្ញាដ៏ប្រពៃតាមសេចក្តីពិតថា សូម្បីដោយហេតុនេះៗ វិញ្ញាណទាំង ៦ នោះ របស់យើង ទើបឈ្មោះថា មិនទៀងតាមពិតទេ លោកម្ចាស់ ។

ត្រូវល្អហើយ ប្អូនស្រីទាំងឡាយ ព្រះអរិយសាវករមែងឃើញដោយវិបស្សនាបញ្ញា គឺឃើញយ៉ាងជាក់ច្បាស់តាមសេចក្តីពិតយ៉ាងនេះឯង ។ កាលបើព្រះនន្ទកត្ថេរពោលដូច្នេះហើយ ទើបពោលជាមួយនឹងភិក្ខុនីទាំងនោះដោយធ្វើសេចក្តីឧបមា និងតាំងជាពាក្យសួរថា

ម្នាលប្អូនស្រីទាំងឡាយ កាលបុគ្គលដុតប្រទីបប្រេង ដែលមានប្រេងក៏ល្អ ប្រឆេះក៏ល្អ អណ្តាតប្រទីបក៏ល្អ ពន្លឺប្រទីបក៏ល្អ សុទ្ធតែជារបស់មិនទៀង មានការប្រែប្រួលទៅជាធម្មតា អ្នកណានឹងពោលថាប្រទីបប្រេងបែបនេះ កាលបើត្រូវឆេះ ប្រេងក្តី ប្រឆេះក្តី អណ្តាតប្រទីបក្តី សុទ្ធតែជារបស់មិនទៀង មានការប្រែប្រួលទៅ ជាធម្មតា វៀរតែពន្លឺ

នៃប្រទីបនោះជារបស់ទៀង មានការស្ថិតស្ថេរនៅដដែល មិនប្រែសភាព ទៅជាយ៉ាងដទៃ នឹងហៅបុគ្គលនោះថា ជាអ្នកពោលត្រឹមត្រូវឬ ? បពិត្រ លោកម្ចាស់ អ្នកនោះពោលមិនត្រឹមត្រូវទេ ម្នាលប្អូនស្រីទាំងឡាយ សេចក្តីនេះព្រោះហេតុអ្វី ? ព្រោះហេតុថា ប្រទីបប្រេងដែលឆេះនោះ ប្រេងក្តី ប្រឆេះក្តី អណ្តាតប្រទីបក្តី សុទ្ធតែមិនទៀង មានការប្រែប្រួល ជាធម្មតា មិនចាំបាច់ពោលថ្វីដល់ពន្លឺនៃប្រទីបនោះ ក៏ជារបស់មិនទៀង មានការប្រែប្រួលជាធម្មតាដូចគ្នា លោកម្ចាស់ ( ពន្លឺនៃប្រទីបមានការ អាស្រ័យប្រឆេះ និងប្រេងនោះ ) ។

សេចក្តីឧបមាក៏ដូច្នោះដែរ ប្អូនស្រីទាំងឡាយ គឺអ្នកណាពោលថា អាយតនៈខាងក្នុង ៦ របស់យើង ជារបស់មិនទៀង តែទុក្ខ ឬសុខ ឬមិនទុក្ខមិនសុខ ដែលយើងបានទទួល ព្រោះអាស្រ័យអាយតនៈខាង ក្នុងនោះជារបស់ទៀង គឺមានការស្ថិតស្ថេរនៅដដែលមិនប្រែប្រួល ដូច្នេះ នឹងហៅអ្នកនោះថា ជាអ្នកពោលត្រឹមត្រូវឬទេ ? មិនត្រឹមត្រូវទេ សេចក្តី នោះព្រោះហេតុអ្វី ? បពិត្រលោកម្ចាស់ ពីព្រោះវេទនាដែលកើតអំពី

អាយតនៈខាងក្នុងនោះៗ ដែលអាស្រ័យបច្ច័យទើបកើតឡើងពីអាយតនៈខាងក្នុងនោះៗ ហើយ ទើបកើតឡើងបាន កាលកើតឡើងហើយក៏រលត់ទៅវិញជាធម្មតា ។ ត្រូវល្អហើយ ប្អូនស្រីទាំងឡាយ ការឃើញដូច្នេះ រមែងមានដល់ព្រះអរិយសាវក ដែលលោកឃើញច្បាស់ ដោយបញ្ញាដ៏ប្រពៃតាមសេចក្តីពិត ។ លុះព្រះនន្ទកត្ថេរពោលយ៉ាងនេះហើយ ទើបពោលប្រៀបធៀបតទៅទៀតថា ម្នាលប្អូនស្រីទាំងឡាយ ឫស ដើម មែក ស្លឹក និងស្រមោលនៃដើមឈើធំជាដើម ឈើមានខ្លឹម សុទ្ធតែជារបស់មិនទៀង មានការប្រែប្រួលទៅជាធម្មតា នឹងមាននរណាមកពោលថា ឫស ដើម មែក ស្លឹកនៃដើមឈើធំនោះក្តី ជារបស់មិនទៀង មានការប្រែប្រួលទៅជាធម្មតា តែថាស្រមោលនៃដើមនោះជារបស់ទៀង គឺជារបស់ស្ថិតស្ថេរនៅដដែលមិនប្រែប្រួលដូច្នេះ ឬនឹងហៅអ្នកនោះថាជាអ្នកពោលត្រូវឬទេ ? អ្នកនោះពោលមិនត្រឹមត្រូវទេ លោកម្ចាស់ សេចក្តីនោះព្រោះហេតុអ្វី ម្នាលប្អូនស្រី ព្រោះហេតុថា ឫស ដើម មែក ស្លឹក រហូតដល់ស្រមោលនៃដើមឈើធំនោះ សុទ្ធតែជារបស់មិនទៀង

ទាំងអស់ មានការផ្លាស់ប្តូរប្រែប្រួលជាធម្មតា ( កាលបើដើមឈើនោះមិនទៀង ស្រមោលនៃដើមឈើនោះ នឹងទៀងមកពីណា ) ។

ព្រះនន្ទកត្ថេរពោលថា សេចក្តីនោះក៏ដូច្នោះដែរ ហើយទើបលើកយកអាយតនៈខាងក្រៅមកសាកសួរទៀតថា នែ៎ប្អូនស្រីទាំងឡាយ អ្នកណានិយាយថា អាយតនៈខាងក្រៅ ៦ របស់យើងជារបស់មិនទៀង ប៉ុន្តែទុក្ខ និងសុខ ឬមិនមែនទុក្ខមិនមែនសុខ ដែលយើងបានទទួលព្រោះអាស្រ័យអាយតនៈខាងក្រៅ ៦ នោះជារបស់ទៀង ជារបស់ស្ថិតស្ថេរតាំងនៅជាដែលមាំមួនមិនប្រែប្រួលដូច្នេះ នឹងថាអ្នកនោះនិយាយត្រូវដែរឬទេ ? មិនត្រូវទេលោកម្ចាស់ សេចក្តីនោះព្រោះហេតុអ្វី ម្នាលប្អូនស្រី ? បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះវេទនាដែលកើតឡើងពីអាយតនៈខាងក្រៅ ៦ នោះ អាស្រ័យបច្ច័យដែលកើតពីអាយតនៈខាងក្រៅទាំង ៦ នោះហើយ ទើបកើតឡើងបាន កាលកើតឡើងហើយ ក៏រលត់ទៅវិញជាធម្មតា ។ ត្រូវល្អហើយ ប្អូនស្រីទាំងឡាយ ការឃើញដូច្នេះ រមែងមានដល់ព្រះអរិយសាវកដែលលោកឃើញច្បាស់ដោយបញ្ញាដ៏ប្រពៃ

តាមសេចក្ដីពិត ដូចបានពោលរួចមកហើយ ។ កាលបើព្រះថេរៈពោលយ៉ាងនេះហើយ ទើបពោលឧបមាដោយន័យដទៃទៀតថា ម្នាលប្អូនស្រីទាំងឡាយ អ្នកសម្លាប់គោ ឬកូនឈ្នួលអ្នកដែលសម្លាប់គោដ៏ឈ្លាសវៃ ពន្លះស្បែកខាងក្រៅទុកមួយចំណែក ពន្លះសាច់ទុកមួយចំណែក សរសៃគ្រឿងចងរឹតខាងក្នុងទុកមួយចំណែកៗ បន្ទាប់មក លាតចំណែកស្បែកខាងក្រៅនោះគ្របដណ្ដប់សាច់គោនោះទុក ហើយគេពោលថា ខ្លួនគោនេះផ្សំដោយស្បែកផ្ទាំងនេះដូចដើមនោះឯង ម្នាលប្អូនស្រីទាំងឡាយ អ្នកសម្លាប់គោ ឬកូនឈ្នួលសម្លាប់គោដែលពោលនោះ ឈ្មោះថា ត្រឹមត្រូវឬទេ ? មិនត្រូវទេលោកម្ចាស់ សេចក្ដីនោះព្រោះហេតុអ្វី ប្អូនស្រីទាំងឡាយ ព្រោះហេតុថា អ្នកសម្លាប់គោ ឬកូនឈ្នួលសម្លាប់គោដ៏ឈ្លាសវៃនោះ កាលសម្លាប់គោស្លាប់ហើយ ក៏យកកាំបិតដ៏មុតមកពន្លះសាច់ខាងក្នុងទុកមួយចំណែក ស្បែកទុកមួយចំណែក សរសៃគ្រឿងចងរឹតខាងក្នុងចេញមកជាចំណែកៗ ហើយយកស្បែកគ្របដណ្ដប់គោទុក សូម្បីអ្នកនោះនឹងពោលថា គោនេះនឹងនៅមានស្បែកគ្របដណ្ដប់ដូចដើមក៏ដោយ គោ

នោះក៏បែកគ្នាចាកស្បែកជាផ្ទាំងគ្របដណ្តប់នោះហើយ លោកម្ចាស់ ។

ម្នាលប្អូនស្រីទាំងឡាយ យើងបានលើកការឧបមានេះមកសម្តែង ដើម្បីនឹងឲ្យជ្រាបសេចក្តីនៃពាក្យពន្យល់ ពាក្យថា ដុំសាច់ខាងក្នុងនោះ បានដល់ អាយតនៈខាងក្នុង ៦ ពាក្យថា ស្បែកខាងក្រៅនោះ បានដល់ អាយតនៈខាងក្រៅ ៦ សាច់ដែលជាប់នឹងស្បែកខាងក្នុង សរសៃខាងក្នុង គ្រឿងចងរឹតខាងក្នុងនោះ បានដល់ រាគៈ និងកាំបិតដ៏មុតនោះ បានដល់ បញ្ញារបស់ព្រះអរិយបុគ្គល ប្រើកាត់ផ្តាច់នូវកិលេសខាងក្នុង កាត់ផ្តាច់ សំយោជនៈ (កិលេសដែលចងរឹតចិត្តសត្វទុកក្នុងវដ្តសង្សារ) ខាងក្នុង និងកាត់ផ្តាច់គ្រឿងចងរឹតខាងក្នុង ។ លំដាប់តមក ព្រះនន្ទកត្ថេរ ពោល អំពីពោជ្ឈង្គ គឺអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងដល់ភិក្ខុនីទាំងនោះថា

ម្នាលប្អូនស្រីទាំងឡាយ ពោជ្ឈង្គ ៧ ប្រការ ដែលភិក្ខុបានអប់រំ ឲ្យច្រើនហើយ ក៏បានសម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមាន អាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយការដឹងដ៏ក្រៃលែងដោយ ខ្លួនឯង ។ ពោជ្ឈង្គ ៧ ប្រការនោះបានដល់អ្វីខ្លះ សតិ គឺការរឭកបាន

ធម្មវិចយៈ គឺការយកចិត្តទុកដាក់នូវធម៌ **វិរិយៈ** គឺការព្យាយាម **បីតិ** គឺការឆ្អែតចិត្ត **បស្សទ្ធិ** គឺការស្ងប់ក្នុងអារម្មណ៍ **សមាធិ** គឺការតាំងចិត្តមាំ **ឧបេក្ខា** គឺភាពព្រងើយៗ ដែលត្រូវអាស្រ័យវិវេក គឺភាពស្ងប់ស្ងាត់ ការរលត់ បង្អោនទៅក្នុងការលះបង់ដូច្នេះ ។

កាលព្រះថេរៈ បានសម្តែងពន្យល់ធម៌ដល់ពួកនាងភិក្ខុនីទាំងនោះ ដោយឱវាទដូចបានសម្តែងរួចមកហើយទាំងអស់ ទើបលោកប្រាប់ភិក្ខុនីទាំងនោះថា ពួកនាងចូរត្រឡប់ទៅវិញចុះ ព្រោះដល់កាលដ៏សមគួរហើយ ។ភិក្ខុនីទាំងនោះ បានសម្តែងអាការកោតសរសើរត្រេកអរចំពោះឱវាទ ដែលព្រះនន្ទកត្ថេរបានសម្តែងរួចហើយ ក៏ថ្វាយបង្គំលារួចក៏ចូលទៅគាល់ព្រះសម្ពុទ្ធជាម្ចាស់ថ្វាយបង្គំរួចហើយទើបឈរក្នុងទីដ៏សមគួរ ដោយសេចក្តីគោរពកោតក្រែង កាលបានស្តាប់នូវព្រះតម្រាស់ថា នាងទាំងឡាយចូរទៅចុះ ដល់កាលដ៏សមគួរហើយ ភិក្ខុនីទាំងអស់ក៏ថ្វាយបង្គំលាព្រះភគវាត្រឡប់ទៅវិញ ។ក្រោយភិក្ខុនីទាំងនោះត្រឡប់ទៅវិញមិនយូរប៉ុន្មាន ព្រះលោកនាថជាម្ចាស់ត្រាស់ជាមួយនឹងភិក្ខុទាំងឡាយថា

ការងឿងឆ្ងល់ ឬការសង្ស័យរបស់បុថុជ្ជន រមែងមិនមាននៅក្នុងថ្ងៃឧបោសថទី ១៤ ពាក្យថា ខែរនោច ឬខ្នើត ប៉ុន្តែព្រះចន្ទក៏នៅតែរនោចយ៉ាងណា ម្នាលភិក្ខុ ភិក្ខុនីទាំងឡាយ សូម្បីនឹងមានសេចក្តីត្រេកអរចំពោះការសម្តែងធម៌របស់ព្រះនន្ទកៈក៏ពិតមែន ប៉ុន្តែនៅមិនទាន់ពេញចិត្តតាមសេចក្តីប្រាថ្នា គឺនៅមិនទាន់បានសម្រេចអរហត្តផលដូច្នោះ។កាលបើព្រះអង្គត្រាស់ដូច្នេះហើយ ទើបត្រាស់ប្រាប់ព្រះនន្ទកត្ថេរថា ម្នាលនន្ទកៈ ព្រឹកស្អែកនេះ អ្នកចូរសម្តែងធម៌ដល់ភិក្ខុនីទាំងនោះ ដោយធម្មោវាទនោះទៀត ។ ព្រះនន្ទកត្ថេរក្រាបទូលទទួលព្រះពុទ្ធដីកាថាព្រះករុណា ព្រះអង្គ លុះព្រឹកស្អែកឡើង ទើបលោកទៅសម្តែងធម៌ដល់ភិក្ខុនីទាំងនោះ ដូចសម្តែងរួចមកហើយកាលពីម្សិលមិញ លើកយកមកសម្តែងម្តងទៀត តាមព្រះពុទ្ធបំណង ។ ភិក្ខុនីទាំងនោះ បានស្តាប់ធម្មកថារបស់ព្រះនន្ទកៈ ដែលសម្តែងម្តងទៀត ក៏បានសម្រេចនូវអរហត្តផល ជាព្រះអរហន្តីខីណាស្រេពគ្រប់ៗ អង្គ ហើយបានចូលទៅគាល់ព្រះបរមសាស្តា ។

កាលបើភិក្ខុនីទាំងនោះ ចេញអំពីកន្លែងស្តាប់ធម៌ មិនយូរប៉ុន្មាន ក៏ព្រះសាស្តាជាម្ចាស់ ព្រះអង្គទ្រង់ត្រាស់ជាមួយនឹងភិក្ខុទាំងឡាយថា ការជឿងឆ្ងល់ ឬការសង្ស័យរបស់មនុស្សភាគច្រើន រមែងមិនមានក្នុង ថ្ងៃ ១៥ រោចថា ព្រះចន្ទរះខាងរនោច ឬរះខាងខ្នើតក៏ដោយ ប៉ុន្តែព្រះចន្ទ រះពេញវង់ យ៉ាងណា ភិក្ខុនីទាំងនោះក៏មានការកោតសរសើរ ត្រេកអរ ចំពោះភាសិតរបស់ព្រះនន្ទកៈដូច្នោះដែរ ។ ប្រសិនបើសរុបពុទ្ធតម្រាស់ ដែលបានត្រាស់សរសើរព្រះនន្ទកត្ថេរ ក្នុងថ្ងៃដែលព្រះភិក្ខុនីទាំងនោះ បានសម្រេចព្រះអរហត្តផល ព្រះមានព្រះភាគជាម្ចាស់ទ្រង់ជ្រាបថា ភិក្ខុនីទាំងនោះ បានសម្រេចជាព្រះអរហន្តីហើយ ព្រោះបានស្តាប់ព្រះ ធម៌ទេសនារបស់ព្រះនន្ទកត្ថេរ ទើបត្រាស់ថា ព្រះធម៌ទេសនារបស់ ព្រះនន្ទកៈ កាលពីម្សិលមិញនោះ មានដូចគ្នានឹងព្រះចន្ទរះក្នុងថ្ងៃ ១៤ កើត ចំណែកព្រះធម៌ក្នុងថ្ងៃនេះ ដូចជាព្រះចន្ទរះក្នុងថ្ងៃ ១៥ កើត ហើយ ព្រះអង្គអាស្រ័យគុណសម្បត្តិនេះឲ្យជាដើមហេតុ ទើបទ្រង់តែងតាំង ព្រះនន្ទកត្ថេរ ទុកក្នុងតំណែងជាឯតទគ្គៈមួយអង្គដែរ ។

ដូចមានសេចក្តីនៅក្នុងព្រះបាលី **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ **ននុក:** ប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវករបស់តថាគត ផ្នែកខាងឲ្យឱវាទដល់ពួកភិក្ខុនី ។

គុណសម្បត្តិដ៏ខ្ពង់ខ្ពស់ដែលព្រះននុកត្ថេរបានទទួលនោះ កើតអំពីការកសាងនូវសេចក្តីល្អគ្រប់យ៉ាងក្នុងជាតិបច្ចុប្បន្ននេះ ដូចពោលមកហើយ ក៏នៅមានសេចក្តីល្អរបស់លោកទៀត ក្នុងអតីតជាតិមួយផ្នែកទៀតផងដែរ ដូចមានរឿងតំណាលទុកក្នុង **អដ្ឋកថាមនោរថបូរណី** ពោលដោយការកសាងបុណ្យកុសល និងបុព្វចរិយារបស់ព្រះននុកត្ថេរ ដូចមានសេចក្តីថា

ក្នុងពុទ្ធសម័យនៃព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ លោកបានកើតជាកុលបុត្រនៅក្នុងត្រកូលអ្នកមានធនធានម្នាក់ (ក្នុងគម្ពីរខ្លះថា កើតក្នុងត្រកូលសេដ្ឋី) ក្នុងក្រុងហង្សវតី ។ ថ្ងៃមួយ លោកបានទៅស្តាប់ព្រះធម៌ទេសនារបស់ព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ កុលបុត្រនោះបានឃើញ

ព្រះបទុមុត្តរៈជាម្ចាស់ ទ្រង់ប្រកាសតែងតាំងភិក្ខុមួយរូបទុកក្នុងតំណែង ដ៏ប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងឲ្យឱវាទដល់ពួកភិក្ខុនី ក៏កើតមាន សេចក្តីពេញចិត្តក្នុងតំណែងនោះ ទើបធ្វើអធិការកុសល (មានគម្ពីរ មួយថា បានថ្វាយសំពត់តម្លៃមួយសែន) ចំពោះព្រះបទុមុត្តរៈ ហើយ ប្រាថ្នាតំណែងនោះ និងបានបូជាដើមពោធិ៍ដែលព្រះអង្គត្រាស់ដឹងដោយ ប្រទីបទៀតផង ទាំងធ្វើកុសលវត្តរហូតអស់ជីវិត ។ ពេលដែលកុលបុត្រ នោះអស់ជីវិតទៅហើយ ក៏បានទៅកើតក្នុងស្ថានសួគ៌ កាលបើចុតិចាក ស្ថានសួគ៌មកវិញ ក៏បានមកកើតជាមនុស្ស វិលកើត វិលស្លាប់ដូច្នេះ អស់កាលដ៏យូរ ប្រមាណមួយសែនកប្ប ទើបបានមកកើតជានន្ទកៈ នៅក្នុងត្រកូលអ្នកមានធនធានក្នុងក្រុងសាវត្ថី ដែលជាជាតិចុងក្រោយ បំផុតរបស់លោក ។

ចំណែកអដ្ឋកថាបរមត្ថទីបនី ដែលអធិប្បាយសេចក្តីបាលី **គម្ពីរ ខុទ្ទកនិកាយ នន្ទកត្ថេរគាថា** បានពោលដល់ការកសាងបុញ្ញកុសល ដែល ឲ្យកើតជាបារមីរបស់ព្រះនន្ទកត្ថេរថា ៖

ព្រះនន្ទកត្ថេររូបនេះ ធ្លាប់ធ្វើអធិការកុសលទុកក្នុងសម្នាក់នៃព្រះពុទ្ធជាម្ចាស់ទាំងឡាយក្នុងកាលមុនតរៀងមក ។ជាតិមួយ លោកបានកើតជានាយព្រានទៅបច្ចន្តប្រទេស ដែលស្របគ្នានឹងពុទ្ធកាលរបស់ព្រះសិខីសម្មាសម្ពុទ្ធជាម្ចាស់ ។ នៅថ្ងៃមួយ ខណៈដែលគេត្រាច់ទៅក្នុងពនាលី (ជាយព្រៃ ឬជួរព្រៃ) បានទៅជួបទីចង្រ្កមនៃព្រះសម្មាសម្ពុទ្ធសិខី ក៏កើតមានសេចក្តីជ្រះថ្លា ទើបទៅស្វែងរកដីខ្សាច់មករោយរាយពាសពេញក្នុងទីចង្រ្កមនោះ លុះគេស្លាប់ទៅ បានត្រាច់រង្គាត់ទៅក្នុងមនុស្ស និងទេវតាដោយបុញ្ញកម្មនោះ ។ លុះមកដល់កាលនៃព្រះសម្ពុទ្ធជាម្ចាស់នៃយើង លោកបានមកកើតក្នុងត្រកូលគហបតី នៅក្នុងក្រុងចម្ប៉ា មានឈ្មោះថា **នន្ទកៈ** មានបងប្រុសម្នាក់ឈ្មោះ **ភារតៈ** ។ ដើមហេតុដែលបងប្អូនទាំងពីរនោះចេញបួស ព្រោះជ្រាបដំណឹងថា ព្រះសោណកោឡិវិសត្ថេរបួសជាភិក្ខុរួចហើយ ទើបប្រឹក្សាគ្នាថា **សោណកោឡិវិសៈ** ជាអ្នកមានសុខុមាលជាតិ នៅតែអាចបួសបាន រឿងអ្វីយើងបួសមិនបាន ប្រឹក្សាគ្នាដូច្នេះហើយ ក៏នាំគ្នាចេញបួស ។ ព្រះភារតៈជាបងប្រុស បានសម្រេច

ជាព្រះអរហន្ត ព្រមដោយអភិញ្ញា ៦មុន ទើបប្រៀនប្រដៅព្រះនន្ទកត្ថេរ ឲ្យបានសម្រេចជាព្រះអរហន្តក្នុងកាលជាខាងក្រោយ ។

កាលបើព្រះនន្ទកត្ថេរពោលអះអាងភាពជាព្រះអរហន្តរបស់ខ្លួន ទើបលោកពោលគាថា ២ គាថា តាមដែលមានសេចក្តីប្រាកដនៅក្នុង **គម្ពីរខុទ្ទកនិកាយ ថេរគាថា** ដូចមានសេចក្តីថា ៖

សេះអាជានេយ្យដ៏ចម្រើន ភ្លាត់ភ្លាំងហើយ រមែងឈរស៊ប់ឡើងវិញ ទោះបីបាននូវសេចក្តីតក់ស្លុត ក៏ជាសត្វមានចិត្តមិនរួញរា រមែងនាំនូវធុរៈទៅបាន យ៉ាងណាមិញ អ្នកទាំងឡាយសូមជ្រាបនូវខ្ញុំ ថាជាអាជានេយ្យ បរិបូណ៌ដោយទស្សនៈ ជាសាវ័ករបស់ព្រះសម្ពុទ្ធ ជាបុត្រជាឱរសរបស់ព្រះពុទ្ធ ក៏យ៉ាងនោះដែរ ។

សេចក្តីក្នុងគម្ពីរដែលពោលរួចមកហើយនេះ មានរឿងផ្សេងគ្នាដែលទាក់ទងនឹងត្រកូល និងក្រុងដែលកើតព្រម ទាំងដើមហេតុនៃការចេញបួសផងដែរ ។ដូចមានរឿងពោលនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដូច្នេះថា ៖

កាលព្រះនន្ទកត្ថេរ ជាព្រះអរហន្តហើយ លោកបានប្រកាសបុព្វចរិយារបស់លោកទុកថា ខ្ញុំព្រះករុណាម្ចាស់ឈ្មោះនន្ទកៈ ធ្លាប់បានកើតជានាយព្រានក្នុងកាលមុន កាលបើដើរត្រាច់ទៅស្វែងរកម្រឹគនៅក្នុងព្រៃ បានទៅជួបព្រះអនុរុទ្ធសម្ពុទ្ធជាម្ចាស់ ព្រះអង្គស្តេចចូលទៅប្រថាប់នៅក្នុងព្រៃ ដើម្បីទ្រង់ត្រូវការវិវេក ខ្ញុំម្ចាស់បានរៀបចំការតាំងមូលដ្ឋាន ៤ មូលដ្ឋាន ធ្វើបារាំប្រក់ដោយផ្កាឈូកថ្វាយដល់ព្រះអនុរុទ្ធសម្ពុទ្ធជាម្ចាស់ លុះធ្វើបារាំរួចហើយ ក៏បោះបោលធ្នូក្នុងទីនោះ ហើយក៏បព្វជ្ជាជាភិក្ខុក្នុងព្រះពុទ្ធសាសនា ។ ក្រោយពីបានបព្វជ្ជារួចហើយមិនយូរប៉ុន្មាន ក៏មានរោគាពាធកើតឡើងដល់ខ្ញុំម្ចាស់ ប៉ុន្តែរឭកចាំនូវបុណ្យកុសលដែលខ្លួនបានធ្វើហើយនោះដរាបដល់ថ្ងៃស្លាប់ ទើបបានទៅកើតនៅក្នុងស្ថានតុសិតទេវលោក និងពេលដែលខ្ញុំម្ចាស់កើតនៅក្នុងស្ថានតុសិតទេវលោកនោះ មានរថទិព្វទឹមដោយសេះមួយពាន់ ជាពាហនៈរបស់ខ្ញុំ ពេលណាដែលខ្ញុំត្រូវការទៅទីណា ក៏ឡើងជិះរថនោះទៅតាមសេចក្តីប្រាថ្នារបស់ខ្ញុំ ក៏មានមណ្ឌបលាតសន្ធឹង បាំងដល់ខ្ញុំរហូតដល់

មួយរយយោជន៍ សូម្បីពេលដេកក៏ដេក នៅលើកន្ទេលដែលសម្រេចដោយផ្កា មានទាំងផ្កាឈូកធំធ្លាក់ចុះមកបូជាខ្ញុំផងដែរអស់កាលជានិច្ច ។

ចំណែកក្នុងបច្ចុប្បន្នជាតិនេះ ខ្ញុំម្ចាស់មិនធ្លាប់ត្រូវកម្តៅថ្ងៃក្តៅដូចភ្លើងឡើយ មូលហេតុនេះមានដោយអំណាចអានិសង្សដែលខ្ញុំម្ចាស់បានធ្វើបារាំថ្វាយដល់ព្រះអនុរុទ្ធសម្ពុទ្ធជាម្ចាស់ និងមិនមែនមានផលល្អប្រាកដត្រឹមតែប៉ុណ្ណោះទេ ទាំងអាចបិទទ្វារទុគ្គតិអបាយភូមិបានផងដែរ ការក្តៅក្រហាយ រមែងមិនមានដល់ខ្ញុំម្ចាស់ ពេលដែលនៅក្នុងទីណាក៏ដោយ ។ ខ្ញុំម្ចាស់អធិដ្ឋានសមុទ្រឲ្យជាផែនដីក៏បាន អធិដ្ឋានផ្ទៃមេឃឲ្យជាផ្លូវដើរទៅមកក៏បាន ខ្ញុំម្ចាស់មានទិព្វចក្ខុ ដឹងនូវបុព្វេនិវាសានុស្សតិ ( ទីនៅជាតិមុន ) បានដោយល្អ ទាំងបានជាពុទ្ធបុត្រអ្នកទទួលធម្មមត៌កជាអ្នកទ្រទ្រង់ធម៌ ព្រមទាំងបានបដិបត្តិព្រះពុទ្ធជាម្ចាស់ ដែលព្រះអង្គទ្រង់ជាលោកនាយកទៀតផង ។ព្រះមានជោគជាម្ចាស់ទ្រង់សម្តែងធម៌ដ៏គម្ភីរភាព គឺភាពដ៏ជ្រាលជ្រៅ ឲ្យខ្ញុំម្ចាស់ស្តាប់រហូតដល់ខ្ញុំបានសម្រេចធម៌ ដែលធ្វើឲ្យអស់អាសវក្កិលេស ខ្ញុំម្ចាស់មិនមានការកើតតទៅទៀត

បានទម្លាយជាតិកំណើតចេញអស់ហើយ ដោយការផ្តាច់ផ្តិលគ្រឿងចង ឲ្យដាច់អស់ ដូចដំរីដែលរើខ្លួនចាកកក់បានហើយ ។ កាលដែលខ្ញុំម្ចាស់ចូលមកក្នុងព្រះសាសនានេះ ជាវត្ថុដ៏ប្រសើរក្រៃលែង ពីព្រោះខ្ញុំម្ចាស់បានសម្រេចវិជ្ជា ៣ បានធ្វើឲ្យជាក់ច្បាស់នូវបដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ ហើយ ។

កាលព្រះនន្ទកត្ថេរ លោកទ្រទ្រង់អាយុសង្ខាររបស់លោកមកដល់កាលសមគួរហើយ ក៏រំលត់ខន្ធបរិនិព្វានទៅហោង ។

( ជីវប្រវត្តិរបស់ព្រះនន្ទកត្ថេរ ចប់ )

❋❋❋❋❋❋

# ✍ ជីវប្រវត្តិរបស់ព្រះនន្ទត្ថេរ ✍

## “ ដែលជាឯតទគ្គៈផ្នែកខាងអ្នករក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ ”

*ព្រះនន្ទត្ថេរ ជាមហាថេរៈ លោកទ្រទ្រង់គុណធម៌ពិសេស ផ្នែកខាងសង្រួមឥន្ទ្រិយ ៦ ជាអ្នកទទួលនូវតំណែងដ៏ខ្ពង់ខ្ពស់ នៅក្នុងចំណោមអសីតិមហាសាវកមួយរូបផងដែរ ប៉ុន្តែការចេញបព្វជ្ជាឧបសម្បទារបស់លោកប្លែកពីព្រះអរហន្តសាវកអង្គដទៃ ព្រោះអាស្រ័យការគោរព និងកោតក្រែងចំពោះព្រះពុទ្ធជាម្ចាស់ ទើបបួស ប៉ុន្តែការបួសនេះ មិនមែនពេញចិត្តទេ គឺបួសទាំងការបង្ខំចិត្តតែប៉ុណ្ណោះ ។*

*ជីវប្រវត្តិរបស់លោក មានសម្តែងប្រាកដនៅក្នុង* ***គម្ពីរអដ្ឋកថាមនោរថបូរណី*** *ដូចមានសេចក្តីថា ៖*

*ព្រះនន្ទត្ថេរកើតក្នុងត្រកូលសក្យៈ ក្នុងរាជវង្ស* ***គោតមវង្ស*** *ជាព្រះរាជឱរសរបស់ព្រះបាទសុទ្ធោទនមហារាជ ជាមួយនឹងព្រះនាងមហាបជាបតិគោតមី ទ្រង់គ្រប់គ្រងរាជសម្បត្តិនៅក្នុងនគរកបិលពស្តុ ប្រសិន*

បើរាប់តាមលំដាប់នៃព្រះញាតិវង្សជាមួយនឹងព្រះភគវា លោកក៏ជាព្រះអនុជរបស់ព្រះមានជោគផងដែរ រួមព្រះបិតាជាមួយគ្នា ប៉ុន្តែព្រះមាតាផ្សេងគ្នា ។ កាលលោកកើតមកមានឈ្មោះថា **នន្ទៈ** នោះ មានរឿងតំណាលថា ពេលលោកនៅក្នុងព្រះគភ៌របស់ព្រះមាតា ធ្វើឲ្យព្រះញាតិវង្សទាំងឡាយ មានសេចក្តីត្រេកអររីករាយ ក្រោយពីលោកប្រសូតហើយ ក្នុងថ្ងៃដែលនឹងកំណត់ព្រះនាមឲ្យព្រះរាជកុមារនោះ ក៏ធ្វើឲ្យពពួកញាតិវង្សកើតសេចក្តីត្រេកអររីករាយ បរមោជ្ជម្តងទៀត ។

សមណព្រាហ្មណាចារ្យ និងហោរាព្រឹទ្ធាមាត្យទាំងឡាយ ទើបកាន់យកនិមិត្តទាំងនោះ ថ្វាយព្រះនាមឲ្យថា **នន្ទរាជកុមារ** សំដៅរាជកុមារដែលធ្វើឲ្យពពួកញាតិវង្សកើតសេចក្តីត្រេកអររីករាយ មូលហេតុដែលនន្ទរាជកុមារចេញបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនានោះ មានរឿងតំណាលក្នុង **អដ្ឋកថាគម្ពីរធម្មបទ** នៃ **យមកវគ្គ** ក្នុងរឿងព្រះនន្ទត្ថេរ ដូចមានសេចក្តីថា ៖

កាលព្រះបរមសាស្តា ទ្រង់ត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធហើយ

ស្តេចចារិកទៅដើម្បីសម្តែងធម៌ប្រោសពុទ្ធវេនេយ្យសត្វ ( បុគ្គលដែលព្រះពុទ្ធជាម្ចាស់គួរណែនាំប្រៀនប្រដៅបាន ) ទៅដោយលំដាប់ ដរាបដល់ក្រុងរាជគ្រឹះព្រះបាទសុទ្ធោទនមហារាជព្រះពុទ្ធបិតាប្រើកាឡុទាយីអាមាត្យ ដែលជាអាមាត្យចុងក្រោយក្នុងការទៅអារាធនាព្រះសម្មាសម្ពុទ្ធឲ្យព្រះអង្គស្តេចយាងមកកាន់ក្រុងកបិលពស្តុ ។ព្រះសាស្តាព្រមដោយភិក្ខុសង្ឃ ២០.០០០ រូប ជាយសបរិវារ ស្តេចចេញចាកក្រុងរាជគ្រឹះទ្រង់ចារិកមកតាមផ្លូវមួយថ្ងៃៗ១យោជន៍ ទ្រង់ប្រើពេលព្រះពុទ្ធដំណើរអស់៦០ថ្ងៃ ទើបស្តេចដល់ក្រុងកបិលពស្តុហើយធ្វើឲ្យភ្លៀងបោក្ខរព័ស៌គឺភ្លៀងដូចទឹកដែលធ្លាក់ចុះក្នុងស្លឹកឈូក និងមានពណ៌ដូចជើងព្រាបភ្លៀងបែបនេះនរណាៗ ប្រាថ្នាឲ្យទទឹក ទើបទទឹក ប្រសិនបើមិនប្រាថ្នាឲ្យទទឹកក៏មិនទទឹកឡើយ ហើយទ្រង់សម្តែងមហាវេស្សន្តរជាតកប្រោសដល់ពពួកញាតិ ។ លុះព្រឹកឡើងព្រះជិនស្រី ស្តេចចូលទៅបិណ្ឌបាតតាមលំដាប់ផ្ទះ គ្រានោះ ព្រះបាទសុទ្ធោទនៈឃើញ ក៏ទៅអារាធនាព្រះសម្មាសម្ពុទ្ធឲ្យមកទទួលចង្ហាន់នៅក្នុងរាជនិវេសន៍ ព្រមដោយភិក្ខុសង្ឃ

រួចហើយ ទ្រង់សម្ដែងធម៌ប្រោសព្រះបាទសុទ្ធោទនមហារាជ ឲ្យបានសម្រេចសោតាបត្តិផល ហើយក៏អារាធនាព្រះភគវា ព្រមដោយភិក្ខុសង្ឃទទួលចង្ហាន់នៅក្នុងថ្ងៃទី ២ ទៀត ស្ដេចទៅទទួលភត្តាហារនៅក្នុងរាជវាំង ទ្រង់ធ្វើភត្តកិច្ចរួចហើយ ទ្រង់សម្ដែងព្រះធម៌ទេសនាប្រោស ព្រះនាងមហាបជាបតិគោតមី ឲ្យបានសម្រេចសោតាបត្តិផល និងព្រះពុទ្ធបិតាឲ្យបានសម្រេចសកទាគាមិផល ។ ដល់ថ្ងៃទី ៣ ព្រះវិជិតមារ ទ្រង់សម្ដែងធម្មបាលជាតកប្រោសព្រះពុទ្ធបិតា ឲ្យបានសម្រេចអនាគាមិផល និងទ្រង់សម្ដែង **កិន្នរីជាតក** ប្រោសដល់ព្រះនាងពិម្ពាយសោធរា ឲ្យបានសម្រេចសោតាបត្តិផលផងដែរ ។ លុះដល់ព្រឹកថ្ងៃទី ៤ ព្រះបរមសាស្ដាស្ដេចទៅកាន់ប្រាសាទថ្មី ជាថ្ងៃដែលព្រះនន្ទរាជកុមារអភិសេក ជាមួយនឹងនាងជនបទកល្យាណី តាម **អដ្ឋកថា គម្ពីរខុទ្ទកនិកាយ ថេរគាថា** ពោលថា គឺនាងរូបនន្ទា កាលព្រះអង្គទ្រង់ទទួលភត្តរួចស្រេចហើយ ទើបប្រទានបាត្រឲ្យដល់នន្ទរាជកុមារ ក៏បានត្រាស់ប្រសិទ្ធិពរសិរីសួស្ដីមង្គលរួចហើយ ស្ដេចក្រោកចាកទីប្រថាប់ត្រឡប់ទៅកាន់វត្តវិញ ប៉ុន្តែ

ទ្រង់មិនទទួលបាត្រពីនន្ទរាជកុមារឡើយ ។ ចំណែកនន្ទរាជកុមារមិនអាចក្រាបទូលថា សូមព្រះអង្គទ្រង់ទទួលបាត្រអំពីខ្ញុំព្រះអង្គវិញចុះ ព្រោះមានការគោរពចំពោះព្រះសាស្តាបានគិតថា ព្រះអង្គប្រាកដជាទទួលយកបាត្រអំពីយើងត្រង់ក្បាលជណ្តើរមិនខាន ទៅដល់ក្បាលជណ្តើរហើយ ព្រះសម្មាសម្ពុទ្ធ ក៏មិនបានទទួល ក៏គិតតទៅទៀតថា ក៏គង់នឹងទ្រង់ទទួលនៅត្រង់មុខព្រះរាជវាំង ប៉ុន្តែក៏ទ្រង់មិនទទួលទៀត ។

នន្ទរាជកុមារគិតនឹងត្រឡប់វិញគ្រប់ៗ ខណៈ ប៉ុន្តែត្រូវបង្ខំចិត្តទៅមិនអាចក្រាបទូល ឲ្យព្រះបរមសាស្តាទ្រង់ទទួលបាត្របាន ព្រោះការគោរព បានត្រឹមតែគិតស្មានថា នឹងទ្រង់ទទួលទីនេះ នឹងទ្រង់ទទួលទីនោះប៉ុណ្ណោះ ក្នុងខណៈនោះ ពួកស្រីជនកំនៃក្រឡេកឃើញនន្ទរាជកុមារកាន់បាត្រតាមព្រះមហាវីរៈទៅ ទើបប្រាប់ដល់នាងជនបទកល្យាណីថា បពិត្រព្រះម៉ែម្ចាស់ ព្រះសាស្តាទ្រង់នាំនន្ទរាជកុមារទៅហើយ ទ្រង់គង់នឹងព្រាត់ប្រាសចាកព្រះម៉ែម្ចាស់មិនខានឡើយ ។ ចំណែកនាងជនបទកល្យាណីបានស្តាប់ហើយ ប្រញាប់ក្រោកទៅទូលផ្តាំថា បពិត្រព្រះ

អយ្យបុត្រជាម្ចាស់ សូមព្រះអយ្យបុត្រស្តេចប្រញាប់ត្រឡប់មកវិញណា ព្រះអយ្យបុត្រ ។ កាលបើនន្ទរាជកុមារ បានស្តាប់សំឡេងស្រែកផ្តាំរបស់នាងជនបទកល្យាណីហើយ ក៏ងាកមុខឡើងសម្លឹងមើលដោយការសម្តែងមនោសញ្ចេតនាស្រឡាញ់ ប៉ុន្តែមិនអាចសម្តែងអាការយ៉ាងណានីមួយចេញមកក្នុងខណៈនោះបាន ព្រោះគោរពដល់ព្រះសាស្តា សូម្បីអត់ទ្រាំអាការតាមផ្លូវកាយបាន តែមិនអាចអត់ទ្រាំតាមផ្លូវចិត្តបាន ចិត្តតែងនឹកដល់សំឡេងដែលស្រែកផ្តាំជារឿយៗ របស់នាងជនបទកល្យាណីរហូតដល់វិហារជាទីប្រថាប់របស់ព្រះអង្គ កាលព្រះសាស្តាស្តេចយាងដល់វិហារហើយ ទើបត្រាស់សួរនន្ទរាជកុមារថា នន្ទ អ្នកបួសឬទេ ? នន្ទរាជកុមារ សូម្បីមានចិត្តមិនស្មោះនឹងបួសបន្តិចបន្តួចសោះ ប៉ុន្តែមិនហ៊ាននឹងទូលជំទាស់បាន ព្រោះមានការគោរពចំពោះព្រះអង្គ ទើបក្រាបទូលដោយអាការមិនពេញចិត្តថា ខ្ញុំព្រះអង្គនឹងបួស ។ព្រះសាស្តាឲ្យនន្ទរាជកុមារបួសមួយរំពេចក្នុងពេលនោះឯង ។

ជីវប្រវត្តិរបស់លោក បានពោលទុកក្នុង **អដ្ឋកថា គម្ពីរធម្មបទ**

ហើយនៅមានរឿងប្រាកដក្នុងព្រះបាលី នន្ទសូត្រ គម្ពីរខុទ្ទកនិកាយ ឧទាន ដូចមានសេចក្តីថា ៖

ចាប់តាំងពីព្រះនន្ទបានបួសហើយ មិនមានការបដិបត្តិសមណធម៌ឡើយ ព្រោះបានទឹកឃើញតែពាក្យស្រែកផ្តាំរបស់នាងជនបទកល្យាណីជារឿយៗ មិនស្រាកស្បើយទាល់តែសោះ ហាក់បីដូចថា នាងជនបទ-កល្យាណីនោះ មកឈរនៅជិតជានិច្ចៗការនឹកដល់នាងជនបទកល្យាណីនោះ ជាដើមហេតុឲ្យកើតការត្រេកត្រអាលក្នុងកាម ចង់សឹក គ្រាំគ្រាដួងចិត្តកើតទុក្ខយ៉ាងក្រៃលែង ចិត្តក៏មិនបង្អោនទៅនៅក្នុងការប្រព្រឹត្តព្រហ្មចរិយធម៌ឡើយ ។ ប៉ុន្តែពេលដែលព្រះនន្ទនិមន្តចូលមកម្លុំព្រៃឈើឬជិតដង្គត់ឈើផ្សេងៗ ក្បែរវិហារនោះ មើលទៅហាក់បីដូចជាព្រះសម្ពុទ្ធប្រថាប់ឈរនៅចំពោះមុខ ហើយលោកក៏វិលត្រឡប់ទៅកុដិវិញ ដោយចិត្តថយត្រឡប់ក្រោយ ដូចគ្នានឹងស្លាបមាន់ត្រូវភ្លើងឆេះហើយរួញចូលដូច្នោះ ( ចិត្តរបស់លោកមិនគិតឈានទៅមុខ ដើម្បីប្រកបសមណកិច្ចឡើយ ) ។

ព្រះមហាមុនី ទ្រង់ជ្រាបដល់ចិត្តរបស់ព្រះនន្ទហើយ ទ្រង់ត្រិះរិះថា នន្ទកំពុងមានចិត្តមួម៉ៅណាស់ មិនអាចរម្ងាប់ភាពក្រវល់ក្រវាយក្នុងចិត្តខ្លួនឯងបាន ទើបទ្រង់ត្រិះរិះដូច្នេះហើយ ត្រាស់ថា ម្នាលនន្ទ អ្នកចូរមក យើងនឹងទៅស្ថានសួគ៌ជាមួយគ្នា ។ ព្រះនន្ទក្រាបទូលតបថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គមិនអាចនឹងទៅកាន់ស្ថានសួគ៌បានទេ ព្រោះស្ថានសួគ៌អាចទៅបាននោះ លុះត្រាតែមានឫទ្ធិ ប៉ុន្តែខ្ញុំព្រះអង្គមិនមានឫទ្ធិទៅម្តេចនឹងបាន ។ ព្រះសម្ពុទ្ធត្រាស់បង្ហាញផ្លូវ ដែលនឹងអាចទៅកាន់ស្ថានសួគ៌ថា ម្នាលនន្ទ អ្នកចូរនឹកតែក្នុងចិត្តត្រឹមតែថា នឹងទៅកាន់ស្ថានសួគ៌ប៉ុណ្ណឹងទៅ អ្នកក៏នឹងទៅបានហើយ ត្រាស់ដូច្នេះហើយ ទើបព្រះសាស្តានាំព្រះនន្ទឡើងទៅកាន់ស្ថានសួគ៌ជាន់តាវត្តិង្ស ដោយពុទ្ធានុភាព និងទ្រង់នាំព្រះនន្ទទៅមើលនាងទេពអប្សរដ៏ស្អាតល្អក្រៃលែងចំនួន ៥០០ នាក់ដែលជាបរិវាររបស់ព្រះឥន្ទ្រ ។

កាលព្រះលោកនាថទ្រង់យល់ថា ព្រះនន្ទស្រឡាញ់ពេញចិត្តចំពោះស្រីទេពអប្សរទាំងនោះហើយ ទើបត្រាស់សួរថា នែ៎ នន្ទ នាង

ទេពអប្សរទាំងនោះ ជាមួយនឹងនាងជនបទកល្យាណីនោះ អ្នកណាស្អាតជាង ? ព្រះនន្ទក្រាបទូលថា កាលបើនាំយកមកប្រៀបធៀបគ្នាហើយ នាងជនបទកល្យាណី ក៏ដូចគ្នានឹងនាងពានរ ( ស្វា ) ដែលមានស្លឹកត្រចៀកកំបុត ប្រមុះកញ្ចែប ព្រះអង្គ ម្នាលនន្ទ អ្នកតាំងចិត្តបំពេញសមណធម៌ទៅ រមែងបាននាងទេពអប្សរទាំងនោះដោយមិនលំបាក ព្រះភគវាត្រាស់ប្រាប់ដល់ហេតុ ដែលនឹងឲ្យបាននាងទេពអប្សរទាំងនោះហើយ ដោយមានព្រះពុទ្ធបំណង ដើម្បីឲ្យព្រះនន្ទបំភ្លេចសេចក្ដីស្រឡាញ់ដល់នាងជនបទកល្យាណីចោល ។

បពិត្រព្រះសាស្ដា ប្រសិនបើថាព្រះអង្គធានារ៉ាប់រងឲ្យខ្ញុំម្ចាស់បាននាងទេពអប្សរទាំងនោះ ខ្ញុំព្រះអង្គនឹងតាំងចិត្ត បំពេញសមណធម៌ ព្រះអង្គក៏ធានាយល់ព្រម ម្នាលនន្ទ អ្នកចូរបំពេញសមណធម៌ចុះ តថាគតនឹងធានារ៉ាប់រងនឹងជួយឲ្យអ្នកបាននាងទេពអប្សរទាំងនោះ ។ កាលបើព្រះជិនស្រីត្រាស់ធានារ៉ាប់រងជាមួយនឹងព្រះនន្ទដូច្នេះហើយ ក៏ទ្រង់នាំព្រះនន្ទដើរមើលស្ថានសួគ៌ តាមកាលដ៏សមគួរហើយ ទើបស្ដេចនាំត្រឡប់មកកាន់

វត្តជេតពនមហាវិហារ នាក្រុងសាវត្ថីវិញ ។ ចាប់ផ្ដើមតាំងតែអំពីដែលព្រះនន្ទបានទៅឃើញនាងទេពអប្សរមក ព្រះនន្ទក៏តាំងចិត្តបំពេញសមណធម៌ទាំងថ្ងៃទាំងយប់ ព្រោះចង់បានស្រីទេពអប្សរទាំងនោះ ។

នេះជាវិធីមួយដែលជាគ្រឿងបញ្ឆោតចិត្តរបស់ព្រះនន្ទឲ្យតាំងមាំក្នុងសមណធម៌ ព្រះភគវា ទើបប្រាប់រឿងនេះដល់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ព្រះនន្ទធ្វើសមណធម៌ព្រោះដើម្បីចង់បាននាងទេពអប្សរដែលតថាគតជាអ្នកធានារ៉ាប់រង ។ ភិក្ខុទាំងឡាយក៏នាំគ្នាទៅពោលបោះពាក្យសម្ដីឡើងក្នុងសម្នាក់របស់ព្រះនន្ទថា ឮដំណឹងថា ព្រះនន្ទជាកូនឈ្នួល ជាអ្នកដែលព្រះសាស្ដាជាម្ចាស់ទ្រង់លោះមក ដោយហេតុថាព្រះនន្ទប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះចង់បាននាងទេពអប្សរពិតមែនឬ ទាំងឮដំណឹងថា ព្រះសម្មាសម្ពុទ្ធទ្រង់ជាអ្នកទទួលរ៉ាប់រងថា នឹងឲ្យព្រះនន្ទបាននាងទេពអប្សរទាំង ៥០០ នាក់ ដែលមានជើងសម្បុរក្រហមប្រហែលគ្នានឹងជើងនៃសត្វព្រាប ។

ព្រះនន្ទបានស្ដាប់ពាក្យសម្ដីរបស់ភិក្ខុទាំងនោះ ដែលនាំគ្នាមក

ពោលទំនងជាចំអកឡកឡឺយដល់ខ្លួន ក៏គិតក្នុងចិត្តថា ភិក្ខុទាំងនេះគង់មិននិយាយពាក្យសម្ដីដល់អ្នកដទៃគឺនិយាយសំដៅមកដល់យើងទេតើ អំពើរបស់យើងមិនសមគួរទេ នឹកគិតដូច្នេះហើយក៏កើតការអៀនខ្មាសចំពោះភិក្ខុទាំងឡាយ ទើបគេចចេញទៅនៅតែម្នាក់ឯង កើតការត្រិះរិះឡើងក្នុងចិត្តថា សេចក្ដីស្រឡាញ់មិនមានទីបំផុត ក្នុងពេលនោះសេចក្ដីសង្វេគក៏កើតឡើងក្នុងចិត្ត ទើបបន្ទោបង់នូវការស្រឡាញ់ចេញ ជាអ្នកមិនប្រមាទ ខំចម្រើនវិបស្សនាកម្មដ្ឋានរហូតបានសម្រេចអរហន្ត ជាព្រះអរិយបុគ្គលថ្នាក់ខ្ពង់ខ្ពស់បំផុតក្នុងព្រះពុទ្ធសាសនា បានសម្រេចកិច្ចនៃបព្វជ្ជាដែលនឹងត្រូវសិក្សា ដែលហៅថាព្រះអសេក្ខៈ ប្រែថា អ្នកដែលមិនមានការសិក្សាជាបន្តទៀត ។ ព្រះសក្យមុនី ទ្រង់ពិចារណាដោយព្រះចក្ខុញ្ញាណ ក៏ទ្រង់ជ្រាបថា ព្រះនន្ទត្ថេរបានសម្រេចចេតោវិមុត្តិ គឺការរួចផុតដោយអំណាចនៃចិត្ត បញ្ញាវិមុត្តិ គឺដោយការរួចផុតដោយអំណាចនៃបញ្ញា ជាអ្នកអស់អាសវក្កិលេសទាំងឡាយហើយ ។ លុះព្រឹកឡើង ព្រះនន្ទត្ថេរចូលទៅគាល់ព្រះមានព្រះភាគថា បពិត្រព្រះអង្គ

ដ៏ចម្រើន ព្រះអង្គ ជាអ្នកធានារ៉ាប់រងឲ្យខ្ញុំព្រះអង្គបាននាងទេពអប្សរទាំង ៥០០ ដែលមានជើងក្រហមដូចជាជើងព្រាប ឥឡូវនេះ សូមព្រះអង្គទ្រង់ផុតអំពីភាពជាអ្នករ៉ាប់រងទាំងនោះចុះ ។ព្រះសាស្ដាត្រាស់តបថាម្នាលនន្ទ សូម្បីតថាគតក៏ដឹងចិត្តរបស់អ្នកដែរ អ្នកបានសម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលជាការអស់ទៅនៃអាសវក្កិលេសទាំងឡាយ ក្នុងអត្តភាពនេះ ហើយទេវតាក៏បាននាំដំណឹងនេះមកប្រាប់ដល់តថាគតហើយ នែននន្ទ ចិត្តរបស់អ្នកផុតស្រឡះហើយ ចាកអាសវក្កិលេសទាំងឡាយ តថាគតក៏រួចផុតអំពីការធានារ៉ាប់រងនោះដែរ ។

គ្រានោះ ព្រះភគវាទ្រង់ជ្រាបរឿងនេះហើយ ទ្រង់បន្លឺព្រះឧទានឡើងក្នុងពេលនោះថា

បុគ្គលណាឆ្លងភក់ គឺកាមបានហើយ ញាំញីបន្លា គឺកាមបានហើយ បុគ្គលនោះសម្រេចការអស់ទៅនៃមោហៈ ( គឺការវង្វេងល្ងង់ ) រមែងមិនញាប់ញ័រក្នុងសុខ និងទុក្ខ ។

ជីវប្រវត្តិរបស់ព្រះនន្ទត្ថេរ មានរឿងតំណាលទៀត ដែលមាន

មកក្នុង អដ្ឋកថា គម្ពីរធម្មបទ នៃ យមកវគ្គ ដូចមានសេចក្ដីថា ៖

ថ្ងៃមួយ ភិក្ខុទាំងឡាយ សួរព្រះនន្ទត្ថេរថា កាលមុនលោកម្ចាស់តូញត្អែរថាចង់សឹក ឥឡូវនេះលោកម្ចាស់មិនចង់សឹកទេឬ ? ព្រះនន្ទត្ថេរតបថា លោកម្ចាស់ទាំងឡាយ ខ្ញុំព្រះករុណាអស់ការអាល័យ ដែលនឹងត្រឡប់ទៅកាន់ភេទជាគ្រហស្ថហើយ ចំណែកភិក្ខុទាំងឡាយ បានស្ដាប់ពាក្យនោះហើយក៏ពោលថា ព្រះនន្ទត្ថេរនិយាយរឿងដែលមិនពិតបានពោលព្យាករព្រះអរហត្តផលខ្លួនឯង កាលបើមិនជឿការនិយាយរបស់ព្រះនន្ទត្ថេរ ទើបនាំគ្នាចូលទៅគាល់ព្រះសាស្ដា ហើយក្រាបទូលសេចក្ដីនោះចំពោះព្រះអង្គ ទើបព្រះបរមសាស្ដាត្រាស់ជាមួយនឹងភិក្ខុទាំងឡាយនោះថា ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃដែលកន្លងមកហើយអត្តភាពរបស់ព្រះនន្ទ រមែងដូចជាផ្ទះដែលប្រក់មិនល្អ ប៉ុន្តែឥឡូវនេះដូចជាផ្ទះដែលបានប្រក់ល្អហើយ ព្រោះចាប់ផ្ដើមពីព្រះនន្ទបានទៅឃើញនាងទេពអប្សរមក ជាអ្នកព្យាយាមដើម្បីនឹងឲ្យបានសម្រេចដល់ទីបំផុតកិច្ចនៃបព្វជ្ជា ហើយក៏បានសម្រេចតាមសេចក្ដីប្រាថ្នាមែន លុះព្រះអង្គ

ត្រាស់ជានាអះអាងព្រះនន្ទត្ថេរដូច្នេះហើយ ទើបត្រាស់ព្រះគាថាទាំងនោះ

ថា យថា អគារំ ទុច្ឆន្នំ ជាដើម មានពាក្យប្រែថា

ទឹកភ្លៀង រមែងលិចស្រោចផ្ទះដែលប្រក់មិនបានល្អ យ៉ាងណាមិញ រាគៈរមែងរួបរឹតចិត្ត ដែលមិនបានអប់រំដោយល្អ ក៏ដូច្នោះ ទឹកភ្លៀងរមែងលិចស្រោចផ្ទះដែលប្រក់ល្អហើយមិនបាន យ៉ាងណាមិញ រាគៈ ក៏រមែងមិនរួបរឹតចិត្ត ដែលបុគ្គលបានអប់រំល្អហើយក៏ដូច្នោះដែរ ។

ថ្ងៃបន្ទាប់មក ភិក្ខុទាំងឡាយបានសន្ទនាគ្នាក្នុងធម្មសភាថា ម្នាលអាវុសោទាំងឡាយ អស្ចារ្យណាស់ ព្រះមានព្រះភាគ ព្រះអង្គជ្រាបដល់ចិត្តរបស់ព្រះនន្ទ ព្រោះសេចក្តីស្រឡាញ់ ចំពោះនាងជនបទកល្យាណី ប៉ុន្តែព្រះអង្គ ទ្រង់ណែនាំដោយវិធីយកនាងទេពអប្សរមកជាគ្រឿងបោកបញ្ឆោតចិត្តរបស់ព្រះនន្ទទៅវិញ ។ ព្រះសាស្តា ស្តេចយាងមកដល់ក៏ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកប្រជុំសន្ទនាគ្នាក្នុងរឿងអ្វី ? លុះទ្រង់ជ្រាបរឿងពីការក្រាបទូលរបស់ភិក្ខុទាំងនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រឿងនេះមិនមែនមានតែក្នុងកាលឥឡូវនេះ

ប៉ុណ្ណោះទេ សូម្បីក្នុងអតីតជាតិ តថាគតក៏ធ្លាប់បានណែនាំនន្ទដែរ ដោយប្រើមាតុគ្រាមមកល្បួងលួងលោមដូចគ្នា ។ ភិក្ខុទាំងនោះ ទូលអារាធនាឲ្យព្រះអង្គសម្តែងអតីតនិទានឡើង ព្រះមានជោគត្រាស់តំណាលរឿងក្នុងអតីតជាតិរបស់ព្រះនន្ទត្ថេរថា

ក្នុងកាលកន្លងទៅហើយ ក្នុងសម័យរបស់ព្រះបាទព្រហ្មទត្ត គ្រប់គ្រងសោយរាជសម្បត្តិ នៅក្នុងក្រុងពារាណសី ។ មានឈ្មួញម្នាក់ឈ្មោះកប្បៈ អាស្រ័យនៅក្នុងក្រុងពារាណសីនោះ កប្បពាណិជមានសត្វលាមួយក្បាល សម្រាប់ប្រើក្នុងការនាំអីវ៉ាន់ផ្សេងៗ សត្វលារបស់គាត់ធ្វើដំណើរមួយថ្ងៃៗ បាន ៧ យោជន៍ ។ ក្នុងថ្ងៃមួយ កប្បពាណិជបានដាក់ទំនិញផ្សេងៗ នាំយកទៅលក់នៅនគរតក្កសិលា លុះទៅដល់ទីសម្រាកហើយ ទើបដោះលាឲ្យដើរទៅស៊ីស្មៅ រហូតដល់លក់ទំនិញអស់ ។ លារបស់គាត់ដើរទៅបានឃើញលាញីមួយទៀត ក៏ចូលទៅរកលាញីនោះៗ ប្រាស្រ័យសាកសួរលារបស់កប្បពាណិជមុនថា តើអ្នកមកពីទីណា ? លាឈ្មោលឆ្លើយថា ខ្ញុំមកពីក្រុងពារាណសី លាញីសួរ

ថា អ្នកមកធ្វើអ្វី ? លាឈ្មោលឆ្លើយថា ខ្ញុំមកធ្វើជំនួញ លាញីសួរថា អ្នកនាំអ្វីមកខ្លះ ? លាឈ្មោលឆ្លើយថា ខ្ញុំនាំរបស់ធ្ងន់មក មានភាជនៈផ្សេងៗ លាញីសួរថា កាលបើអ្នកនាំរបស់ធ្ងន់មកដូច្នេះ តើអ្នកដើរបានប៉ុន្មានយោជន៍ក្នុងមួយថ្ងៃ ? លាឈ្មោលឆ្លើយថា ដើរមួយថ្ងៃៗ បាន ៧ យោជន៍ លាញីក៏សួរទៀតថា ក្នុងស្ថានទីដែលអ្នកទៅដល់ហើយនោះ មានអ្នកណាប្របាច់ជើង គក់ខ្នងឲ្យខ្លះទេ ? បានជាលាញីសួរដូច្នេះ ក៏ព្រោះតែសេចក្តីស្រឡាញ់ ចំពោះលារបស់កប្បពាណិជ ។

លាឈ្មោលតបថា មិនមានទេ លាញីពោលថា កាលបើដូច្នោះ អ្នកប្រហែលជាលំបាកណាស់ ហើយធ្វើឫកម៉ិកម៉ក់ ។ លារបស់កប្បពាណិជក៏ជាប់ចិត្ត ដោយពាក្យសម្តីរបស់លាញី ដែលអាណិតអាសូរចំពោះខ្លួន ។ ចំណែកកប្បពាណិជជញ្ជូនទំនិញអស់ហើយ ក៏ត្រឡប់ទៅរកលារបស់ខ្លួន ហើយប្រាប់ថា កូនអើយយើងត្រឡប់ទៅវិញ លាតបថា សូមនាយទៅមុនចុះ ខ្ញុំមិនទាន់ទៅទេ កប្បពាណិជបានស្តាប់ពាក្យឆ្លើយរបស់លាហើយ សង្កេតឃើញអាការមិនល្អ ទើបនិយាយអង្វរហើយ

អង្វរទៀត ប៉ុន្តែលាមិនព្រមទៅ ទើបគិតថា យើងនឹងគម្រាមលានេះ ឲ្យខ្លាចទាល់តែបាន ហើយពោលនឹងលាទៀតថា ប្រសិនបើអ្នកមិនទៅទេ យើងនឹងធ្វើជន្ទញដែលមានប្រវែង ១៦ ធ្នាប់ ទុកចាក់កាយរបស់អ្នក អ្នកចូរដឹងចុះ លាបានស្តាប់ហើយក៏ឆ្លើយតបកប្បពាណិជថា ប្រសិនបើនាយធ្វើដូច្នោះ ខ្ញុំនឹងសងសឹកលោក ពេលលោកចាក់ខ្ញុំដោយជន្ទញ ខ្ញុំនឹងទប់ជើងខាងមុខឲ្យមាំ ហើយលើកជើងខាងក្រោយឡើង ធ្វើឲ្យរបស់របរលោកខ្ចាត់ខ្ចាយទៅ សូមនាយដឹងយ៉ាងនោះចុះ ។

កប្បពាណិជបានស្តាប់ពាក្យឆ្លើយរបស់លាហើយ សញ្ជឹងគិតថា ហេតុអ្វីហ្ន៎ ទើបលានេះនិយាយជាមួយយើងយ៉ាងនេះ មិនដែលធ្លាប់មានឡើយ ទើបក្រឡេកមើលខាងនេះខាងនោះ ក៏ឃើញលាញីនោះ ទើបពិនិត្យមើលថា លារបស់យើងប្រហែលជាទទួលការញុះញង់ពីលាញីនេះមិនខាន ប្រសិនបើយ៉ាងនេះ យើងនឹងនិយាយលួងលោមលារបស់យើង ដោយប្រាប់ថា យើងនឹងនាំលាញីក្រមុំមានមុខដូចសង្ខ ស្អាតសព្វសព៌ាង្គកាយឲ្យមកធ្វើជាភរិយារបស់អ្នក ។ ចំណែកលា លុះបានស្តាប់

ពាក្យនោះហើយ ក៏សប្បាយចិត្ត ទើបពោលថា ប្រសិនបើលោកនឹងធ្វើយ៉ាងនោះពិតមែន ខ្ញុំនឹងដើរឲ្យរហ័ស ក្នុងមួយថ្ងៃ ១៤ យោជន៍ ។ កប្បពាណិជដឹងថាលា ព្រមធ្វើតាមពាក្យរបស់ខ្លួនហើយ ទើបបបួលឲ្យត្រឡប់ ទៅទីលំនៅរបស់ខ្លួនវិញ ។ កាលកន្លងទៅបាន ២-៣ ថ្ងៃ លានោះឃើញនាយរបស់ខ្លួននៅស្ងៀម មិនព្រមធ្វើតាមពាក្យសន្យា ទើបនិយាយជាមួយនឹងកប្បពាណិជថា លោកបានសន្យាជាមួយខ្ញុំថា នឹងនាំលាញីក្រមុំឲ្យមកធ្វើជាភរិយារបស់ខ្ញុំពិតមែនឬ ? កប្បពាណិជឆ្លើយតបថា ពិតមែនហើយ យើងមិនភ្លេចពាក្យសន្យាទេ យើងនឹងរកលាញីក្រមុំមកឲ្យអ្នកធ្វើជាភរិយា ប៉ុន្តែថា យើងនឹងឲ្យអាហារត្រឹមតែម្នាក់ប៉ុណ្ណោះ ចំណែកភរិយារបស់អ្នកនឹងមានអាហារស៊ីឬអត់ យើងមិនដឹងទេ នេះជាតួនាទីរបស់អ្នក កាលនៅរួមជាមួយគ្នាហើយ ក៏នឹងមានកូន អ្នកនឹងត្រូវរកអាហារឲ្យកូនរបស់អ្នកទៀត ។

កាលបើកប្បពាណិជ និយាយជាមួយនឹងលាយ៉ាងនេះហើយ លាក៏អស់សង្ឃឹម ឈប់គិតចង់បានលាញីតទៅទៀត ។ កាលបើព្រះ

មានព្រះភាគ ទ្រង់នាំរឿងនោះមកត្រាស់តំណាលរួចហើយ ក៏ទ្រង់ប្រជុំជាតក ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាញីបានមកជានាងជនបទកល្យាណី លាឈ្មោលបានមកជានន្ទ ចំណែកកប្បពាណិជបានមកជាតថាគត នន្ទ តថាគតធ្លាប់បញ្ឆោតដោយមាតុគ្រាម និងណែនាំហើយយ៉ាងនេះ ។ព្រះនន្ទត្ថេរ កាលបានសម្រេចជាព្រះអរហន្តហើយ ជាអ្នកបរិបូណ៌ដោយការសង្រួមឥន្ទ្រិយទាំង ៦ រហូតដីងទូទៅ។ ក្នុង **គម្ពីរមហាវិភង្គ ព្រះវិនយបិដក** លោកពោលប្រៀងធៀបកម្ពស់រវាងព្រះបរមសាស្តាជាមួយនឹងព្រះនន្ទត្ថេរទុកដូច្នេះថា

ព្រះនន្ទត្ថេរ មានរាងកាយទាបជាងព្រះសម្ពុទ្ធ ៤ ធ្នាប់ ( ឬ ៤ អង្គុលី ) មានរាងកាយល្អស្អាត ជាទីគាប់ចិត្តរបស់អ្នកជួប ឬឃើញលោកមានបុគ្គលិកលក្ខណៈ ស្រដៀងព្រះបរមសាស្តា ទាំងលោកអាចប្រើចីវរបានស្មើនឹងចីវររបស់ព្រះមានជោគ ។ គ្រាមួយ ភិក្ខុទាំងឡាយឃើញលោកនិមន្តមកអំពីចម្ងាយ ទើបនាំគ្នាក្រោកចាកអាសនៈមកទទួលដោយគិតថា ព្រះសាស្តាយាងមក លុះលោកនិមន្តមកដល់ជិត ទើប

ចាំបានថា មិនមែនព្រះមានព្រះភាគទេ គឺព្រះនន្ទទេតើ ។

ចំណែករឿងកិត្តិគុណ និងសេចក្ដីល្អរបស់ព្រះនន្ទត្ថេរ មានសម្ដែងទុកថា ក្នុងសម័យតមក កាលព្រះសាស្ដាទ្រង់ប្រថាប់នៅវត្តជេតពនមហាវិហារ នាក្រុងសាវត្ថីនោះ ទ្រង់ប្រកាសតែងតាំងព្រះនន្ទត្ថេរទុកក្នុងតំណែងជាឯតទគ្គៈ ដែលមានសម្ដែងនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ដូចមានសេចក្ដីថា ៖

***ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ឥន្ទ្រិយេសុ គុត្តទ្វារានំ យទិទំ នន្ទោ*** ម្នាលភិក្ខុទាំងឡាយ នន្ទ ជាឯតទគ្គៈ គឺជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវករបស់តថាគត ផ្នែកខាងសង្រួមឥន្ទ្រិយទាំងឡាយ ។

**អដ្ឋកថាមនោរថបូរណី** អធិប្បាយសេចក្ដីនៃព្រះបាលីនោះថា

ព្រះនន្ទត្ថេរនេះ ជាអ្នកបានទទួលការលើកតម្កើងពីព្រះសាស្ដាថាប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងសង្រួមឥន្ទ្រិយនោះសំដៅដល់ការរក្សាឥន្ទ្រិយទាំង ៦ គឺភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត ដោយ

មានសតិ គឺការរឭកបាន សម្បជញ្ញៈ គឺការដឹងខ្លួនជាប់ជានិច្ច ។

ពាក្យថា **សតិ** គឺការរឭកបាន សំដៅដល់ ឲ្យរឭកមុនធ្វើ មុននិយាយ មុនគិត និងអាចចងចាំនូវវត្ថុដែលធ្វើ ពាក្យដែលនិយាយរួចហើយក៏ចាំបាន ។ ពាក្យថា **សម្បជញ្ញៈ** គឺការដឹងខ្លួនទាន់ បានដល់ការដឹងខ្លួនថា វត្ថុណាជាប្រយោជន៍ ១ វត្ថុណាជាទីសប្បាយដល់ខ្លួន ១ កម្មដ្ឋានអ្វីដែលត្រូវចិត្តរបស់ខ្លួន ១ និងការដឹងខ្លួនចំពោះធម្មជាតិដើម្បីមិនឲ្យវង្វេងល្ងីល្ងើ ១ ។

មានពាក្យសួរថា សាវកទាំងឡាយរបស់ព្រះពុទ្ធ សុទ្ធតែជាអ្នករក្សាឥន្ទ្រិយទាំងឡាយដូចគ្នា ដូចម្តេចទើបបានទទួលការលើកតម្កើងចំពោះតែព្រះនន្ទត្ថេរមួយរូបប៉ុណ្ណោះ ។

មានពាក្យឆ្លើយថា ព្រះនន្ទត្ថេរ កាលបើមានបំណងនឹងក្រឡេកមើលទិសណាៗ ក្នុងទិសទាំង ១០ ក៏ក្រឡេកមើលទិសនោះៗ ដោយមានសតិ និងសម្បជញ្ញៈ ទើបបានទទួលការលើកតម្កើងឲ្យជាអ្នកប្រសើរជាងភិក្ខុទាំងឡាយក្នុងការរក្សាឥន្ទ្រិយ និងមានហេតុមួយទៀត ព្រោះ

លោកបានធ្លាប់ធ្វើបុណ្យកុសលហើយ តាំងសេចក្តីប្រាថ្នាឲ្យបានតំណែងយ៉ាងនោះក្នុងអតីតជាតិ ដូចមានរឿងតំណាលក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** មានសេចក្តីថា ក្រោយពីព្រះនន្ទត្ថេរ បានជាព្រះអរហន្ត បានតំណែងដ៏ប្រសើរយ៉ាងនេះហើយ ក៏រឭកដល់បុព្វកម្មរបស់ខ្លួន មានបីតិសោមនស្សរីករាយ ទើបប្រកាសបុព្វចរិយាបទានឡើងថា

ខ្ញុំបានថ្វាយសំពត់សំម្បកឈើ ចំពោះព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ជាចម្បងក្នុងលោក ទ្រង់ប្រកបដោយតាទិគុណ ជាព្រះសយម្ភូ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ព្រះពុទ្ធជានាយក ព្រះនាមបទុមុត្តរៈ ទ្រង់ព្យាករណ៍រឿងនោះប្រាប់ខ្ញុំថា

អ្នកនឹងមានពណ៌សម្បុរដូចមាស ដោយការថ្វាយសំពត់នេះ ។ អ្នកនឹងបានទទួលសម្បត្តិទាំងពីរប្រការ ត្រូវកុសលមូលដាស់តឿនហើយ នឹងបានជាប្អូននៃព្រះមានជោគ ព្រះនាមគោតម ។ អ្នកនឹងមានសេចក្តីត្រេកអរដោយរាគៈ មានសេចក្តីសុខជាប្រក្រតី មានសេចក្តីជាប់ជំពាក់ដោយចំណង់ក្នុងកាមទាំងឡាយ តែលុះព្រះពុទ្ធទ្រង់ដាស់តឿន នឹងប្រែ

ជាបុគ្គលស្ងប់ ហើយចេញបួសក្នុងកាលនោះ ។ អ្នកលុះបួសហើយ ត្រូវកុសលមូលជាស់តឿន នឹងកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វានក្នុងទីនោះ ។ក្នុងកប្បទីមួយសែន អ្នកនឹងបានជាព្រះរាជា ព្រះនាមចេលៈ ៤ ដង ក្នុងកប្បទី ៦០ ពាន់ នឹងបានកើតជាជន ឈ្មោះឧបចេលៈ ៤ ដង ។ ក្នុងកប្បទី ៥ ពាន់ នឹងបានជាជន ឈ្មោះចេលៈ ៤ ដងទៀត ជាធំក្នុងទ្វីបទាំង ៤ បរិបូណ៌ដោយកែវ ៧ ប្រការ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

សេចក្តីតាម **គម្ពីរខុទ្ទកនិកាយ អបទាន** ដូចដែលបានពោលមកនេះ ពោលទុកត្រឹមតែថា ព្រះនន្ទត្ថេរ បានធ្វើបុណ្យទុកក្នុងពុទ្ធសម័យនៃព្រះសមុទ្ទបទុមុត្តរៈប៉ុណ្ណោះ ប៉ុន្តែប្រសិនបើរាប់អំពីជាតិដែលថ្វាយសំពត់សម្បកឈើនោះ មករហូតមួយសែនកប្ប ក៏មានព្រះពុទ្ធស្តេចឧប្បត្តិឡើងក្នុងលោក ១៥ ព្រះអង្គ គឺ

១ព្រះបទុមុត្តរៈ ២ព្រះសុមេធ ៣ព្រះសុជាត ៤ព្រះបិយទស្សី ៥ ព្រះអត្ថទស្សី ៦ ព្រះធម្មទស្សី ៧ ព្រះសិទ្ធត្ថៈ ៨ ព្រះតិស្សៈ ៩ ព្រះផុស្សៈ ១០ ព្រះវិបស្សី ១១ ព្រះសិខី ១២ ព្រះវេស្សភូ ១៣ ព្រះកកុសន្ធោ ១៤ ព្រះកោនាគមនោ ១៥ ព្រះកស្សបៈ ហើយទើបមកដល់ព្រះសមណគោតមជាម្ចាស់នៃយើងទាំងឡាយ ។

ព្រះនន្ទុត្តរ កាលលោកត្រាច់រង្គាត់កើតស្លាប់ៗ ជាតិផ្សេងៗ មុនដែលនឹងមកដល់ជាតិបច្ចុប្បន្ននេះ លោកធ្លាប់បានអប់រំកសាងសន្សំគុណគឺសេចក្ដីល្អផ្សេងៗ ទុក ដើម្បីឲ្យបានជាបុញ្ញសម្បត្តិ ជាឧបនិស្សយ-ប្បច្ច័យក្នុងកាលជាអនាគត ដូចមានរឿងនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលអធិប្បាយសេចក្ដីបាលី **គម្ពីរខុទ្ទនិកាយ នន្ទុត្តរគាថា** បានពោលដល់ការបំពេញបុណ្យបារមី ក្នុងអតីតជាតិរបស់លោកថា ៖

ព្រះនន្ទុត្តរនេះ បានកើតក្នុងត្រកូលមួយក្នុងក្រុងហង្សវតី ស្របគ្នានឹងពុទ្ធកាលរបស់ព្រះបទុមុត្តរសម្ពុទ្ធ កាលបើលោកចម្រើនវ័យធំឡើងបានទៅស្ដាប់ធម៌ទេសនាក្នុងសម្នាក់ព្រះសម្ពុទ្ធបទុមុត្តរៈ ក៏បានឃើញ

ភិក្ខុមួយរូប ដែលព្រះអង្គទ្រង់លើកតម្កើងថា ជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងសង្រួមឥន្ទ្រិយ ៦ ។

កាលបើកុលបុត្រនោះ បានឃើញភិក្ខុរូបនោះបានទទួលតំណែងក្នុងឋានៈជាអ្នកទ្រទ្រង់នូវគុណដ៏ប្រសើរបំផុត ផ្នែកខាងសង្រួមឥន្ទ្រិយ ក៏កើតមានការពេញចិត្តក្នុងតំណែងនោះ ទើបរៀបចំថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះសម្មាសម្ពុទ្ធបទុមុត្តរៈជាប្រធាន ហើយតាំងសេចក្តីប្រាថ្នាថា សូមឲ្យខ្ញុំព្រះអង្គបាននូវតំណែងដ៏ប្រសើរ ផ្នែកខាងរក្សាឥន្ទ្រិយទាំងឡាយ ដូចភិក្ខុរូបនេះក្នុងសាសនាព្រះពុទ្ធអង្គណាទីមួយ នាកាលអនាគតកុំបីខានឡើយ ។

កាលកុលបុត្រនោះអស់ជីវិតទៅហើយ ក៏ត្រាច់រង្គាត់សោយសុខក្នុងមនុស្សទេវតា អស់កាលជាយូរអង្វែង រហូតមកដល់ពុទ្ធកាលនៃព្រះពុទ្ធអត្ថទស្សី ។ កុលបុត្រនោះ ( នន្ទ ) លោកធ្លាប់ធ្វើបាបកម្មអំពីជាតិណាៗ គ្រាណាក៏មិនអាចដឹងបាន ព្រោះមានរឿងមិនប្រាកដ ដោយលោកត្រឡប់មកកើតជាអណ្តើកធំនៅទឹងស្ទឹងវិតកតានទី ថ្ងៃមួយ

អណ្តើកនោះ បានឃើញព្រះអត្ថទស្សីសម្ពុទ្ធ ទ្រង់មានបំណងនឹងយាង ឆ្លងស្ទឹងទៅខាងត្រើយម្ខាង ទើបបណ្តែតខ្លួនឡើងអំពីទឹក ឲ្យព្រះពុទ្ធ អត្ថទស្សី ទ្រង់ឈរប្រថាប់លើខ្នងរបស់ខ្លួន ហើយនាំដំណើរទ្រង់ឲ្យឆ្លង ដល់ត្រើយដោយសួស្តី ។ ដោយបុញ្ញកម្មដែលអណ្តើកយកខ្លួនជាពាហនៈ លុះអស់ជីវិតទៅ ក៏បាននូវមនុស្សសម្បត្តិ និងទិព្វសម្បត្តិរហូតអស់ កាលដ៏យូរ ច្រើនជួរពុទ្ធកាល រហូតមកដល់ពុទ្ធកាលព្រះសមណគោតម នៃយើងនេះ ក៏បានមកកើតជាព្រះរាជឱរសរបស់ព្រះនាងមហាបជា-បតិគោតមី ជាអគ្គមហេសីរបស់ព្រះបាទសុទ្ធោទនមហារាជ មានព្រះនាម ថា នន្ទរាជកុមារនឹងបានចេញបួស ក្នុងគ្រាដែលព្រះមានជោគជាម្ចាស់ ស្តេចនិវត្តន៍ទៅកាន់ក្រុងកបិលពស្តុគ្រាដំបូង នឹងបានសម្រេចនូវធម៌ ពិសេសជាព្រះអរហន្ត ( បុគ្គលឆ្ងាយចាកសត្រូវ គឺកិលេស ឬបុគ្គល មិនមានកិលេស រាប់ជាព្រះអរិយបុគ្គលជាន់ខ្ពស់បំផុត ក្នុងចំនួនព្រះ អរិយបុគ្គល ៤ ជំពូក ) ។

ព្រះនន្ទត្ថេរ កាលបានសម្រេចជាព្រះអរហន្តហើយ លោកបាន

ពោលគាថា ២ គាថា ដោយប្រារព្ធរឿងរបស់លោកផ្ទាល់ ដូចមានសេចក្តីនៅក្នុងព្រះបាលី គម្ពីរខុទ្ទកនិកាយ ថេរគាថា មានន័យថា ៖

ខ្ញុំកាលប្រកបនូវគ្រឿងប្រដាប់ (កាយ) ជាបុគ្គលអណ្តែតអណ្តូងឃ្លេងឃ្លោង ត្រូវកាមរាគៈបៀតបៀន ព្រោះមិនមានយោនិសោមនសិការ ។ ( ឥឡូវនេះ ) ខ្ញុំដកចិត្តក្នុងភពបានហើយ ព្រោះប្រតិបត្តិដោយយោនិសោមនសិការ តាមព្រះពុទ្ធជាអាទិច្ចពន្ធុ ព្រះអង្គមានកុសលោបាយ ( ឧបាយល្អ ) ។

នេះជាឧទាហរណ៍ដ៏ល្អរបស់ព្រះនន្ទត្ថេរ ដែលជាអ្នកសង្រួមរាំងឥន្ទ្រិយ ៦ មិនឲ្យកើតសេចក្តីត្រេកអររីករាយ ឬមិនបណ្តែតបណ្តោយចិត្តឲ្យធ្លាក់ទៅក្នុងអំណាចនៃលោកធម៌ ទាំងជាអ្នកបរិបូណ៌ដោយបដិភាណ ទាំងជាកម្លាំងដ៏សំខាន់ក្នុងការផ្សព្វផ្សាយព្រះពុទ្ធសាសនា ។

( ជីវប្រវត្តិរបស់ព្រះនន្ទត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះមហាកប្បិនត្ថេរ ✍

## " ដែលជាឯតទគ្គៈផ្នែកខាងឱ្យឱវាទដល់ពួកភិក្ខុ "

*ជីវប្រវត្តិរបស់ព្រះកប្បិនត្ថេរនេះ ព្រះមានព្រះភាគទ្រង់សម្តែង កាលដែលព្រះអង្គគង់ប្រថាប់នៅវត្តជេតពន នាក្រុងសាវត្ថី ដែលមាន មកនៅក្នុង **អដ្ឋកថាគម្ពីរធម្មបទ** នៃ **បណ្ឌិតវគ្គ** ក្នុងរឿងព្រះមហាកប្បិន មានក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលអធិប្បាយសេចក្តីព្រះបាលី **គម្ពីរខុទ្ទកនិកាយ ថេរគាថា** និងមានក្នុង **អដ្ឋកថាមនោរថបូរណី** ដែល អធិប្បាយសេចក្តីព្រះបាលី **គម្ពីរខុទ្ទកនិកាយ ឯកនិបាត** ថា ៖*

*ការកសាងបុណ្យបារមីក្នុងអតីតជាតិ ដែលកន្លងមកប្រមាណរាប់ តាំងអំពីបច្ចុប្បន្នត្រឡប់ថយក្រោយទៅបានមួយសែនកប្ប ក្នុងពុទ្ធកាល នៃព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ កប្បិនកុលបុត្រនោះ បានកើតនៅក្នុងនគរ ហង្សវតី ថ្ងៃមួយ កប្បិនកុលបុត្រ បានទៅស្តាប់ព្រះធម៌ទេសនានៅឯវត្ត បានឃើញព្រះបទុមុត្តរៈទ្រង់តែងតាំងភិក្ខុមួយរូប ទុកក្នុងតំណែងប្រសើរ*

ជាឥកិក្ខុសាវកទាំងឡាយ ផ្នែកខាងឲ្យឱវាទដល់ភិក្ខុ ក៏នឹកចង់បាននូវតំណែងដូចភិក្ខុរូបនោះដែរ ទើបធ្វើអធិការកុសល គឺរៀបចំការប្រគេនចង្ហាន់ដល់ភិក្ខុសង្ឃទាំងឡាយ មានព្រះបទុមុត្តរសម្ពុទ្ធជាប្រធានដរាបអស់ ៧ ថ្ងៃ លុះដល់ថ្ងៃទី ៧ ក៏បានប្រាថ្នាតំណែងនោះចំពោះព្រះភក្ត្រនៃព្រះបទុមុត្តរៈអង្គនោះ ។

ចាប់ផ្តើមតាំងពីពេលនោះមក លោកព្យាយាមបំពេញបុណ្យកុសលរហូតអស់ជីវិត កាលកប្បិនស្លាប់អំពីជាតិនេះទៅ ដោយអំណាចបុណ្យកុសលដែលលោកបានធ្វើហើយ ធ្វើឲ្យកប្បិនមានការត្រាច់រង្គាត់ជាមនុស្សទេវតាអស់កាលដ៏យូរអង្វែង ប៉ុន្តែការប្រព្រឹត្តទៅនៃជីវិតរបស់លោក សូម្បីយូរយ៉ាងហ្នឹងក៏ដោយ កប្បិនមិនធ្លាប់ទៅកើតក្នុងទុគ្គតិ គឺស្ថានទីដែលលំបាកឡើយ នេះកើតឡើងដោយផលនៃសេចក្តីល្អ ដែលលោកធ្វើទុកនោះឯង ត្រង់នេះសមនឹងពុទ្ធតម្រាស់ថា ធ្វើល្អបានល្អ ។

ព្រះមហាកប្បិនត្ថេរ កាលដែលត្រាច់រង្គាត់ក្នុងសង្សារវដ្ត កើតស្លាប់ៗ មានជាតិមួយ លោកបានកើតជាជាងតម្បាញ ដែលស្ថិតនៅក្បែរ

ក្រុងពារាណសី ។ ក្នុងយុគសម័យនោះ មានព្រះបច្ចេកពុទ្ធកើតឡើងក្នុងលោកប្រមាណមួយពាន់រូប អាស្រ័យនៅក្នុងព្រៃហិមពាន្តអស់ ៨ ខែ ហើយនាំគ្នានិមន្តមករកទីអាស្រ័យនៅក្បែរផ្ទះ របស់អ្នកស្រុកអស់ ៤ ខែ ក្នុងរដូវភ្លៀង ដូច្នេះឯងជានិច្ច ។

ថ្ងៃមួយ ព្រះបច្ចេកពុទ្ធទាំងនោះ ហោះមកចុះក្បែរក្រុងពារាណសី ហើយបញ្ជូនព្រះបច្ចេកពុទ្ធប្រមាណ ៨ រូប ទៅកាន់សម្នាក់របស់ព្រះបាទពារាណសី ដើម្បីទូលសូមឲ្យព្រះរាជាទ្រង់ជួយចាត់ចែង ក្នុងការកសាងសេនាសនៈនោះ ។ ថ្ងៃដែលព្រះបច្ចេកពុទ្ធ ៨ រូប និមន្តចូលទៅរកព្រះបាទពារាណសីនោះ ជាថ្ងៃដែលត្រៀមក្នុងការប្រត់ព្រះនង្គ័ល ដែលនឹងប្រព្រឹត្តទៅក្នុងថ្ងៃស្អែក ។ ព្រះបាទពារាណសី ទ្រង់ជ្រាបដំណឹងថា ព្រះបច្ចេកពុទ្ធទាំងឡាយនិមន្តមក ទើបស្តេចចេញទៅទទួល និងត្រាស់សួរថា លោកម្ចាស់គ្រប់អង្គនិមន្តមកមានការអ្វី ? ព្រះបច្ចេកពុទ្ធទាំងនោះពោលថា មហាបពិត្រ អាត្មាមកនេះ ដើម្បីទូលសូមឲ្យមហាបពិត្រជួយចាត់ចែងទីសេនាសនៈសម្រាប់ស្នាក់អាស្រ័យ ដល់ព្រះបច្ចេកពុទ្ធទាំង

ឡាយប្រមាណមួយពាន់រូប ។

ព្រះបាទពារាណសី កាលបើទ្រង់ជ្រាបនូវរឿងនោះហើយ ទើបត្រាស់ថា លោកម្ចាស់ទាំងឡាយ ថ្ងៃនេះ ខ្ញុំព្រះអង្គមិនមានឱកាសនឹងទៅជួយធ្វើធុរៈឲ្យដល់លោកម្ចាស់ទាំងឡាយបានទេ ព្រោះថ្ងៃស្អែកនេះនឹងមានវប្បមង្គល គឺការច្រត់ព្រះនង្គ័ល និងជាកិច្ចធុរៈដែលខ្ញុំព្រះអង្គត្រូវធ្វើបុណ្យប្រចាំឆ្នាំ ប៉ុន្តែ ៣ ថ្ងៃទៀត ទើបហើយធុរៈ កាលបើព្រះរាជាត្រាស់យ៉ាងនេះហើយ ក៏មិនបាននិមន្តព្រះបច្ចេកពុទ្ធទាំងឡាយទុក ។ ព្រះបច្ចេកពុទ្ធទាំងនោះ ទើបនាំគ្នានិមន្តចេញចាកអំពីទីនោះទៅ ដើម្បីទៅកាន់ស្រុកដទៃ ជិតគ្នានឹងក្រុងពារាណសីដែរ ។

គ្រានោះឯង កិរិយារបស់ជាងតម្បាញ ដែលត្រូវមានធុរៈទៅកាន់ក្រុងពារាណសី បានជួបនឹងព្រះបច្ចេកពុទ្ធទាំងនោះ ទើបលើកដៃសំពះ ហើយសាកសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ទាំងឡាយនិមន្តមកស្រុកនេះ មានបំណងអ្វីឬ ? ព្រះបច្ចេកពុទ្ធទាំងនោះតបថា ម្នាលឧបាសិកា ពួកអាត្មានិមន្តមកទីនេះ ដើម្បីរកទីស្នាក់អាស្រ័យ

នៅក្បែរស្រុក ក្នុងរដូវភ្លៀងដែលមានរយៈពេល ៤ ខែ ព្រោះការនៅក្នុងព្រៃ ក្នុងរដូវនេះមានសេចក្ដីលំបាកច្រើន ទើបនាំគ្នានិមន្តចេញអំពីព្រៃមកស្វែងរកទីស្នាក់អាស្រ័យ ។ ភរិយារបស់ជាងតម្បាញ ជ្រាបបំណងរបស់ព្រះបច្ចេកពុទ្ធទាំងឡាយហើយ កើតសេចក្ដីជ្រះថ្លា ក៏បាននិមន្តថា បពិត្រលោកម្ចាស់ដ៏ចម្រើនទាំងឡាយ ថ្ងៃស្អែកនេះ សូមលោកម្ចាស់និមន្តមកទទួលភិក្ខារបស់ខ្ញុំព្រះករុណា ។

ព្រះបច្ចេកពុទ្ធប្រាប់ថា ពួកអាត្មាមានច្រើនរូបណាស់ ភរិយាជាងតម្បាញសួរថា លោកម្ចាស់ទាំងអស់មានប៉ុន្មានរូប ? ពួកអាត្មាមានមួយពាន់រូប ។ ភរិយាជាងតម្បាញស្ដាប់ហើយ ក៏សប្បាយចិត្ត ទើបពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើនទាំងឡាយ ចំនួនលោកម្ចាស់ទាំងឡាយស្មើនឹងចំនួនផ្ទះ ដែលនៅក្នុងស្រុកនេះគ្រប់គ្រាន់ចំនួនមួយពាន់រូបល្មម ហេតុនេះសូមលោកម្ចាស់ទាំងឡាយនិមន្តទទួលនូវភិក្ខារបស់ខ្ញុំក្នុងថ្ងៃស្អែកនេះ សូមឱ្យទីស្នាក់អាស្រ័យរបស់លោកម្ចាស់ទាំងឡាយ ពួកខ្ញុំនឹងរៀបចំធ្វើប្រគេនឲ្យគ្រប់រូប ។ ព្រះបច្ចេកពុទ្ធទាំងនោះព្រមទទួល

ការនិមន្តដោយអាការស្ងៀម ។ កិរិយារបស់ជាងតម្បាញ ក្រោយពីបាននិមន្តព្រះបច្ចេកពុទ្ធហើយ ទើបប្រញាប់ប្រញាល់ចូលទៅកាន់ស្រុក ដើរបន្លឺប្រកាស អំពាវនាវ ឲ្យអ្នកស្រុកទាំងនោះដឹងថា យើងបានជួបព្រះបច្ចេកពុទ្ធប្រមាណមួយពាន់រូប ហើយយើងបាននិមន្តលោកទុក សូមអ្នកទាំងឡាយជួយគ្នារៀបចំអាសនៈ រៀបចំចង្ហាន់បិណ្ឌបាតជាដើម ដើម្បីប្រគេនលោកម្ចាស់ក្នុងថ្ងៃស្អែកនេះ ហើយនាងឲ្យស្វាមីជួយគ្នាសង់បារាំឡើងក្នុងទីពាក់កណ្តាលភូមិ ទាំងឲ្យគេត្រៀមអាសនៈរៀបរយ រង់ចាំទទួលព្រះបច្ចេកពុទ្ធទាំងឡាយនិមន្តមក ។

ថ្ងៃស្អែកឡើង ព្រះបច្ចេកពុទ្ធទាំងអស់ និមន្តមកដល់រោងបារាំនោះ ពួកអ្នកស្រុកនិមន្តលោកឲ្យគង់លើអាសនៈដែលរៀបចំទុក ហើយនាំយកចង្ហាន់បិណ្ឌបាតមកប្រគេនលោក ។ កាលបើរួចស្រេចសព្វកិច្ចការក្នុងការឧបត្ថម្ភនោះហើយ កិរិយារបស់ជាងតម្បាញ នាំពួកស្ត្រីទាំងឡាយក្នុងស្រុកនោះ ចូលទៅរកព្រះបច្ចេកពុទ្ធ ហើយថ្វាយបង្គំអារាធនាព្រះបច្ចេកពុទ្ធទាំងនោះ ដើម្បីឲ្យចាំវស្សា នៅក្បែរស្រុករបស់ខ្លួន ។

លំដាប់តទៅ ភរិយារបស់ជាងតម្បាញ បានសូមសំណូមពរឲ្យស្វាមីគ្រប់រូបជួយចាត់ចែងទីសេនាសនៈ ប្រគេនចំពោះព្រះបច្ចេកពុទ្ធទាំងឡាយ ។

ពួកអ្នកស្រុក បានព្រមព្រៀងគ្នា ចាត់ចែងទីសេនាសនៈប្រគេនគ្រប់ៗ ព្រះអង្គ ថែមទាំងបានទំនុកបម្រុង និងប្រព្រឹត្តប្រតិបត្តិយ៉ាងល្អរហូតអស់ត្រៃមាស ។លុះដល់ពេលចេញវស្សាហើយ ឧបាសិកាដែលជាភរិយារបស់ជាងតម្បាញ បានដឹកនាំឲ្យមិត្តសម្លាញ់ ថ្វាយសំពត់សម្រាប់ធ្វើចីវរដល់ព្រះបច្ចេកពុទ្ធទាំងឡាយ ។ មិត្តសម្លាញ់ទាំងនោះបានថ្វាយសំពត់ដែលមានតម្លៃមួយផ្ទាំង មួយពាន់កហាបណៈ ប្រគេនដល់ព្រះបច្ចេកពុទ្ធគ្រប់ៗ រូប ដោយសទ្ធាជ្រះថ្លា ។ចំណែកព្រះបច្ចេកពុទ្ធទាំងឡាយ អនុមោទនាគាថាហើយ ក៏លាពួកអ្នកស្រុកទាំងនោះទៅវិញ ។ ចំណែកអ្នកស្រុកទាំងនោះ កាលបើស្លាប់អំពីជាតិនេះទៅហើយ បានទៅកើតនៅក្នុងស្ថានតាវត្តិង្ស មានឈ្មោះថា គណទេវបុត្រសោយទិព្វសម្បត្តិរហូតអស់កាលយូរអង្វែង ។

មកដល់កាលនៃព្រះសម្មាសម្ពុទ្ធកស្សបៈ ស្តេចឧប្បត្តិឡើងក្នុង

លោក គណទេវបុត្រទាំងនោះ ចុតិមកកើតនៅក្នុងត្រកូលកុដុម្ពិកៈនាក្រុងពារាណសី ឯជាងតម្បាញបានមកកើតជាបុត្ររបស់កុដុម្ពិកៈ ចំណែកឯភរិយារបស់ជាងតម្បាញ បានមកកើតជាធីតារបស់កុដុម្ពិកៈ ត្រកូលមួយទៀត ។កាលបើជនទាំងនោះធំពេញវ័យហើយ ត្រកូលទាំងពីរនោះក៏បានរៀបចំឲ្យបានគ្នាជាស្វាមីភរិយាទៅ ។ ថ្ងៃមួយ មានអ្នកមកបង្កូកប្រកាសឲ្យទៅស្តាប់ព្រះធម៌ទេសនានៅឯវត្ត ពួកកុដុម្ពិកៈទាំងនោះ បានឮពាក្យអំពាវនាវថា ព្រះកស្សបសម្មាសម្ពុទ្ធទ្រង់សម្តែងធម៌ទេសនា ទើបនាំគ្នាទៅវត្តព្រមជាមួយនឹងភរិយា ដោយតាំងចិត្តនឹងទៅស្តាប់ធម៌ទេសនា។

ពេលដែលពួកកុដុម្ពិកៈទាំងនេះ ចូរទៅដល់ពាក់កណ្តាលវត្តភ្លៀងក៏បង្អុរចុះមកល្មម ។ ពួកអ្នកណាមកដល់វត្តមុនហើយ អ្នកដែលមានភិក្ខុសាមណេរជាញាតិមិត្ត ក៏នាំគ្នាចូលទៅរកដើម្បីជ្រកភ្លៀង កុំឲ្យទទឹកនៅក្នុងសម្នាក់ភិក្ខុសាមណេរនោះឯង ។ ចំណែកពួកកុដុម្ពិកៈទាំងនោះបានឈរនៅហាលភ្លៀង មិនដឹងចូលទៅជ្រកនៅក្នុងទីណា ព្រោះមិនស្គាល់ភិក្ខុសាមណេរនៅក្នុងវត្តនេះឡើយ ។ទើបនាំគ្នាគិតថា ពួកយើង

នឹងកសាងទីសេនាសនៈប្រគេនចំពោះភិក្ខុសង្ឃ មានព្រះកស្សបសម្មុទ្ធ ជាប្រធាន ខ្លួនឯងជាប្រធានបានបរិច្ចាគទ្រព្យសម្បត្តិមួយពាន់កហាបណៈ មុនគេ កុដុម្ពិកៈជាបន្ទាប់បានបរិច្ចាគម្នាក់ៗ ប្រាំរយកហាបណៈ ពួកករិយា បានបរិច្ចាគម្នាក់ៗ ពីររយហាសិបកហាបណៈ ទ្រព្យសម្បត្តិ ទាំងអស់ ត្រូវប្រមូលមកកសាងបរិវេណទីសម្រាកធំ ដែលមានផ្ទះ កំពូលមួយពាន់ខ្នងជាបរិវារ ដើម្បីថ្វាយដល់ព្រះកស្សបសម្មាសម្មុទ្ធ ជាម្ចាស់ ។

ប៉ុន្តែកាលបើធ្វើការកសាងទៅ ទ្រព្យមិនគ្រប់ចំណាយ ព្រោះ ការកសាងបរិវេណទីសម្រាកធំពេក ទើបសម្រេចគ្នាជួយបរិច្ចាគម្នាក់ៗ ពាក់កណ្តាលនៃចំនួនដែលបរិច្ចាគក្នុងគ្រាដំបូង ទ្រព្យក៏គ្រប់គ្រាន់ក្នុង ការចំណាយការកសាងទីសេនាសនៈនោះ ។ កាលបើកសាងសម្រេច រៀបរយ ពួកកុដុម្ពិកៈទាំងនោះ ទើបនាំគ្នាថ្វាយមហាទានដល់ភិក្ខុសង្ឃ ទាំងឡាយ មានព្រះកស្សបជាប្រធាន ក្នុងការឆ្លងនវកម្មដែលសាងសង់

ថ្មីៗ នោះទៅរហូតអស់ប្រាំពីរថ្ងៃ លុះដល់ថ្ងៃទីប្រាំពីរបានរៀបចំថ្វាយចីវរដល់ភិក្ខុសង្ឃពីរម៉ឺនរូប ។

ចំណែកកិរិយារបស់កុដុម្ពិកៈ ជាអ្នកមានបញ្ញា បានធ្វើវត្ថុដែលពិសេសជាងគេ ដោយគិតថា យើងនឹងបូជាព្រះកស្សបឲ្យក្រៃលែងជាងពួកជនទាំងនោះ ទើបកាន់យកផ្កាននោងបង្អោនចូលទៅប្រគេនចំពោះព្រះកស្សបសម្មាសម្ពុទ្ធ ហើយតាំងសេចក្តីប្រាថ្នាថា សូមឲ្យសម្បុរកាយរបស់ខ្ញុំមានពណ៌ដូចផ្កានោងនេះគ្រប់ៗ ជាតិ ព្រះកស្សបសម្ពុទ្ធទ្រង់ធ្វើការអនុមោទនាថា ចូរឲ្យនាងបានសម្រេចដូចសេចក្តីប្រាថ្នា ។ កាលបើជនទាំងនោះស្លាប់អំពីជាតិនេះទៅហើយ បានទៅកើតក្នុងទេវលោក ។

មកដល់ពុទ្ធសម័យនៃព្រះសមណគោតមយើងនេះ ពួកជនទាំងនោះ ក៏ចុតិអំពីទេវលោកមកកើតជាមនុស្ស ។ កុដុម្ពិកៈក៏បានកើតនៅក្នុងរាជត្រកូលនគរកុក្កុដវតី ពេលចម្រើនវ័យធំឡើង បានជាព្រះរាជាទ្រង់ព្រះនាមថា មហាកប្បិន និងពួកកុដុម្ពិកៈជាបរិវារ បានមកកើតនៅក្នុងត្រកូលអាមាត្យទាំងឡាយ ចំណែកកិរិយារបស់កុដុម្ពិកៈ កើតនៅក្នុង

ត្រកូលក្សត្រ ក្នុងសាគលនគរ ដែនមទ្ទរដ្ឋ មានពណ៌សម្បុរកាយដូចជាផ្កានទោង ទើបឈ្មោះថា ព្រះនាងអនោជា ពាក្យថា **អនោជា** ប្រែថា ផ្កានទោង កាលព្រះនាងចម្រើនវ័យធំឡើង បានជាអគ្គមហេសីរបស់ព្រះរាជាមហាកប្បិន ។ ចំណែកស្រីក្រៅពីនោះ ទៅកើតក្នុងត្រកូលអាមាត្យទាំងឡាយ កាលចម្រើនវ័យហើយ បានជាភរិយារបស់បុត្រនៃអាមាត្យទាំងនោះ ពួកជនទាំងអស់នោះ សូម្បីនឹងមិនបានជាព្រះរាជា ប៉ុន្តែជាអ្នកសម្បូណ៌ទៅដោយទ្រព្យសម្បត្តិ ប្រើប្រាស់ប្រហាក់ប្រហែលនឹងព្រះរាជា ពេលណាព្រះរាជាទ្រង់គ្រឿងអលង្ការ គឺទ្រង់គ្រឿងរបស់ព្រះរាជា ហើយស្តេចឡើងកាន់រាជរថយាងចេញទៅ ពេលនោះពួកជនទាំងនោះ ក៏ជិះសេះ ជិះដំរីទៅតាមព្រះរាជា ទាំងនេះដោយអានុភាពនៃបុណ្យកុសល ដែលខ្លួនធ្វើទុកក្នុងអតីតជាតិ ។

ព្រះបាទមហាកប្បិន ទ្រង់មានព្រះទីន័ងសេះប្រាំ មានឈ្មោះដូចនេះ ១ ពលៈ ២ ពលវាហនៈ ៣ បុប្ផៈ ៤ បុប្ផវាហនៈ ៥ សុបត្តៈ ។ សេះទាំង ៥ នេះ ព្រះរាជាទ្រង់គង់ប្រថាប់តែសេះសុបត្តៈ ហើយសេះ

៤ ទៀត ទ្រង់ឲ្យហ្មសេះជិះទៅស៊ើបដំណឹង ។ រៀងរាល់ពេលព្រឹក ព្រះរាជាទ្រង់អនុញ្ញាតឲ្យពួកហ្មសេះ បរិភោគអាហារតាំងពីពេលព្រឹក ហើយត្រាស់ថា ពួកអ្នកចូរនាំគ្នាទៅស៊ើបដំណឹងឲ្យបានដឹងថា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃកើតឡើងហើយឬនៅ ចូរប្រញាប់នាំដំណឹងទាំងនោះ មកប្រាប់ដល់យើងផង ។

ពួកហ្មសេះទាំង ៤ នាក់ បាននាំគ្នាចេញទៅស៊ើបដំណឹងតាមទ្វារក្រុងទាំង ៤ ទិស បំបែកគ្នាម្នាក់ៗ មួយទិស ដោយធ្វើដំណើរទៅរហូតអស់រយៈផ្លូវ ២-៣ យោជន៍ ប៉ុន្តែមិនបានដំណឹងអ្វីត្រឡប់មកវិញឡើយ ។ ថ្ងៃមួយ ព្រះបាទមហាកប្បិន ទ្រង់គង់លើព្រះទីន័ង សេះឈ្មោះសុបត្តៈ មានពួកអាមាត្យមួយពាន់នាក់ហែហម ទៅកាន់ព្រះរាជឧទ្យាន បានជួបពួកឈ្មួញរទេះ ៥០០ នាក់ បាននាំគ្នាយកគ្រឿងបណ្ណាការទៅថ្វាយព្រះរាជា ក៏ទ្រង់ត្រិះរិះថា ពួកជនទាំងនេះគង់មានសេចក្ដីលំបាក ដោយការធ្វើដំណើរផ្លូវឆ្ងាយ យើងអាចនឹងបានស្ដាប់ដំណឹងល្អ សូម្បីរឿងអ្វីមួយពីជនទាំងនេះ ទើបមានព្រះរាជតម្រាស់ ឲ្យពួកឈ្មួញទាំងនោះចូលមក

គាល់ ហើយត្រាស់សួរថា ពួកអ្នកមកពីទីណា ? ពួកឈ្មួញទេះឆ្លើយថា មហាបពិត្រព្រះសម្មតិទេព ពួកខ្ញុំព្រះអង្គមកពីក្រុងសាវត្ថី ដែលមានចម្ងាយផ្លូវប្រមាណ ១២០ យោជន៍ ព្រះរាជាត្រាស់សួរទៀតថា ព្រះរាជាក្នុងក្រុងរបស់ពួកលោកសុខសប្បាយជាទេ ជាអ្នកតាំងនៅក្នុងសីលឬទេ ? ពួកឈ្មួញតបថា សុខសប្បាយជាទេ ទាំងព្រះរាជាក៏ទ្រង់តាំងនៅក្នុងសីលយ៉ាងល្អ ។

ព្រះរាជាសួរថា នៃអ្នកទាំងឡាយ មានដំណឹងអ្វីកើតឡើងក្នុងក្រុងរបស់ពួកលោកខ្លះឬទេ ? ពួកឈ្មួញមុននឹងក្រាបបង្គំទូលតបចំពោះសេចក្ដីនោះ បានសូមការអនុញ្ញាតពីព្រះរាជាថា បើពួកខ្ញុំមិនទាន់បានខ្ពុរមាត់ជាមុនទេ មិនអាចនឹងក្រាបបង្គំទូលដំណឹងក្នុងរឿងនេះបានទេ ព្រោះថារឿងនេះសំខាន់ណាស់ ។ ព្រះបាទមហាកប្បិន ទើបព្រះរាជទានទឹកក្នុងឃ្លោកមាសរបស់ព្រះអង្គ ឲ្យពួកឈ្មួញទាំងនោះ ។ ពួកឈ្មួញទាំងនោះ បាននាំគ្នាខ្ពុរមាត់រួចជាស្រេចហើយ ទើបថ្វាយបង្គំឆ្ពោះមុខទៅកាន់ទិសដែលព្រះសម្ពុទ្ធទ្រង់គង់ប្រថាប់នៅ ហើយក្រាបបង្គំទូលថា បពិត្រ

ព្រះសម្មតិទេព **ពុទ្ធរតនំ នាម ឧប្បន្នំ** ប្រែថា ព្រះពុទ្ធរតនៈកើតឡើងហើយក្នុងលោក នៅនាក្រុងសាវត្ថី ។ កាលព្រះបាទមហាកប្បិនទ្រង់សណ្ដាប់ថា ព្រះពុទ្ធឧប្បត្តិឡើងក្នុងលោកហើយ ក៏មានសេចក្ដីជ្រះថ្លាសោមនស្សរីករាយ ប្រកបដោយបីតិ បានផ្សព្វផ្សាយ ពេញសរីរៈរហូតទាល់តែបាត់បង់ស្មារតី លុះទ្រង់ភ្ញាក់ស្មារតីវិញ ហើយត្រាស់សួរថា ពួកលោកនិយាយអ្វីអម្បាញ់មិញនេះ ពួកឈ្មួញឆ្លើយថា ព្រះពុទ្ធ-រតនៈកើតឡើងក្នុងលោកហើយ ។

ព្រះបាទមហាកប្បិន ទ្រង់សណ្ដាប់ហើយ ក៏បាត់ស្មារតីជាពីរលើកបីលើក ពេលដែលទ្រង់មានស្មារតីឡើងវិញ ទើបបានព្រះរាជទានទ្រព្យមួយសែនកហាបណៈឲ្យជារង្វាន់ ទ្រង់ត្រាស់សួរតទៀតថា មានដំណឹងអ្វីល្អទៀតដែរឬទេ ? ពួកឈ្មួញក្រាបបង្គំទូលថា មាន **ធម្មរតនំ នាម ឧប្បន្នំ** ព្រះធម្មរតនៈកើតឡើងក្នុងលោកហើយ ព្រះរាជាទ្រង់សណ្ដាប់ហើយ មានអាការដូចគ្នានឹងទ្រង់សណ្ដាប់ថា ព្រះពុទ្ធកើតឡើងក្នុងលោក ហើយក៏បានព្រះរាជទានទ្រព្យមួយសែនកហាបណៈជារង្វាន់ទៀត

ហើយត្រាស់សួរទៀតថា អ្នកទាំងឡាយ មានដំណឹងអ្វីល្អទៀតដែរឬទេ ? ពួកឈ្នួញក្រាបបង្គំទូលថា មាន **សង្ឃរតនំ នាម ឧប្បន្នំ** ព្រះសង្ឃរតនៈកើតឡើងក្នុងលោកហើយ ។ ព្រះរាជាទ្រង់ស្តាប់ហើយ ទ្រង់មានអាការដូចពេលមុន ហើយបានព្រះរាជទានទ្រព្យ ជារង្វាន់ឲ្យដល់ពួកឈ្នួញមួយសែនកហាបណៈទៀត ទើបទ្រង់ទតមើលពួកអាមាត្យមួយពាន់នាក់នោះ ហើយត្រាស់សួរថា នែអាមាត្យទាំងឡាយ ពួកលោកធ្វើយ៉ាងណាទាក់ទងនឹងដំណឹងដែលបានជ្រាបនេះ ។

ចំណែកពួកអាមាត្យ មិនដឹងធ្វើយ៉ាងណាឲ្យល្អក្នុងរឿងនេះ ទើបនាំគ្នាក្រាបបង្គំទូលសួរព្រះរាជាថា បពិត្រព្រះសម្មតិទេព តើព្រះអង្គទ្រង់ធ្វើយ៉ាងណាក្នុងរឿងដំណឹងនេះ ។ ព្រះរាជាត្រាស់ថា នែពួកអាមាត្យទាំងឡាយ ខ្ញុំបានឮថា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃកើតឡើងហើយក្នុងលោក ដូច្នេះ នឹងមិនត្រឡប់ទៅកាន់ព្រះរាជវាំងវិញទេ ខ្ញុំនឹងទៅគាល់ព្រះភគវា ដើម្បីបព្វជ្ជាក្នុងសម្នាក់របស់ព្រះអង្គ ។ ពួកអាមាត្យព្រមគ្នាក្រាបបង្គំទូលឡើងថា សូម្បីខ្ញុំព្រះអង្គក៏នឹងបានបព្វជ្ជាជាមួយនឹងព្រះអង្គដែរ ។

ព្រះរាជាត្រាស់ឲ្យសរសេរព្រះរាជសារ ក្នុងការព្រះរាជទានរង្វាន់ឲ្យដល់ពួកឈ្មួញ ហើយឲ្យរាជសារនោះដល់ពួកឈ្មួញដោយត្រាស់ថា

នែអ្នកទាំងឡាយៗ ចូរនាំយករាជសារនេះទៅថ្វាយដល់ព្រះនាងអនោជាទេវីៗ នឹងព្រះរាជទានរង្វាន់ប្រាក់ ៣ សែនកហាបណៈដល់ពួកលោកមិនខាន ពួកលោកចូរក្រាបបង្គំទូលថា ព្រះរាជាទ្រង់លះបង់ភាពជាធំថ្វាយដល់ព្រះមេម្ចាស់ហើយ សូមព្រះមេម្ចាស់ទ្រង់សោយរាជសម្បត្តិតាមសប្បាយចុះ ប៉ុន្តែប្រសិនបើព្រះរាជទេវីមានព្រះរាជតម្រាស់សួរថា ព្រះរាជាទ្រង់ស្ដេចយាងទៅណា ពួកលោកចូរក្រាបបង្គំតបថា ព្រះរាជាត្រាស់ថា ទ្រង់តាំងព្រះទ័យទៅបព្វជ្ជាក្នុងសម្នាក់ព្រះសក្យមុនី ។ចំណែកពួកអាមាត្យ ក៏បានបញ្ជូនដំណឹងការចេញទៅបួសឲ្យករិយារៀងៗ ខ្លួនបានដឹងដូចគ្នាដែរ ។

ពួកឈ្មួញទទួលព្រះរាជសាសន៍ហើយ ក៏នាំគ្នាចូលទៅគាល់ព្រះនាងអនោជាទេវី ក្រោយពីបានក្រាបបង្គំទូលហើយ ទើបថ្វាយព្រះរាជ-សាសន៍ដែលចារឹករង្វាន់ ៣សែនកហាបណៈ និងក្រាបបង្គំទូលថា សូម

ព្រះមេម្ចាស់ព្រះរាជទានទ្រព្យ ៣ សែនកហាបណៈដល់ពួកខ្ញុំផង ។ ព្រះនាងអនោជាទេវី កាលទ្រង់ទទួលព្រះរាជសាសន៍រួចហើយ ទើបមានព្រះរាជតម្រាស់ត្រាស់សួរថា ពួកអ្នកធ្វើអ្វី បានជាព្រះមហាក្សត្រព្រះទានទ្រព្យដល់ពួកលោក ? ពួកឈ្មួញក្រាបបង្គំទូលថា បពិត្រព្រះមេម្ចាស់ ខ្ញុំព្រះអង្គទាំងឡាយបាននាំដំណឹង ដែលជាទីពេញចិត្តមកក្រាបទូលឲ្យដល់ព្រះរាជាជ្រាប ។ ព្រះនាងអនោជាទេវីត្រាស់សួរថា ពួកអ្នកនាំរឿងអ្វីអាចប្រាប់ខ្ញុំបានខ្លះដែរឬទេ ? ពួកឈ្មួញក្រាបបង្គំទូលថា បានព្រះមេម្ចាស់ ប៉ុន្តែខ្ញុំព្រះអង្គមិនអាចក្រាបបង្គំទូល ដោយមាត់មិនទាន់ខ្ពុរទេ ។ ទើបព្រះនាងអនោជាទេវី ព្រះរាជទានទឹកក្នុងឃ្លោកមាសឲ្យខ្ពុរមាត់ចេញ កាលបើពួកពាណិជបានខ្ពុរមាត់រួចហើយ ក៏ក្រាបបង្គំទូលដំណឹងព្រះរតនត្រ័យ ថ្វាយដល់ព្រះនាងអនោជាទេវី ដូចដែលបានក្រាបបង្គំទូលដល់ព្រះរាជាមុនដែរ ។

ព្រះនាងអនោជា ទ្រង់សណ្តាប់ដំណឹងទាក់ទងនឹងព្រះរតនត្រ័យហើយ ក៏ទ្រង់កើតសេចក្តីត្រេកអររីករាយយ៉ាងខ្លាំង ក៏បានព្រះរាជទាន

ទ្រព្យជារង្វាន់ ៩ សែនកហាបណៈ ។ រួមប្រាក់រង្វាន់ដែលពួកឈ្នួញបាន ទទួលព្រះរាជទានពីព្រះរាជា និងព្រះនាងអនោជាទាំងអស់ ១២ សែន កហាបណៈ ។ ព្រះនាងអនោជាទេវី មានព្រះរាជតម្រាស់ត្រាស់សួរពួក ឈ្នួញតទៅទៀតថា ពេលនេះ ព្រះមហាក្សត្រទ្រង់គង់នៅក្នុងទីណា ? ពួកឈ្នួញក្រាបបង្គំទូលថា ព្រះមហាក្សត្រស្តេចយាងចេញទៅបួសក្នុង សម្នាក់ព្រះសម្ពុទ្ធហើយ ។

ព្រះនាងអនោជាទេវី មានព្រះរាជសវនីយ៍អនុញ្ញាតឲ្យពួកឈ្នួញ ត្រឡប់ទៅវិញ កាលបើពួកឈ្នួញត្រឡប់ទៅហើយ ទើបមានព្រះរាជ សវនីយ៍ត្រាស់ទៅរកស្រីទាំងឡាយ ដែលជាភរិយារបស់ពួកអាមាត្យ តាមព្រះរាជាទៅ ហើយបាននិយាយជាមួយនឹងស្រីទាំងនោះថា អ្នកទាំង ឡាយជ្រាបដំណឹងកន្លែង ដែលស្វាមីរបស់ពួកនាងនៅឬទេ ? ពួកភរិយា របស់ពួកអាមាត្យក្រាបបង្គំទូលថា បពិត្រព្រះមេម្ចាស់ ខ្ញុំមិនបានជ្រាប ដំណឹងទេ ត្រឹមតែដឹងថា ព្រះមហាក្សត្រទៅកាន់ព្រះរាជឧទ្យានប៉ុណ្ណោះ ប៉ុន្តែស្តេចយាងដំណើរបន្តទៅទៀតក្នុងស្ថានទីណា មិនបានដឹងទេ ។ ព្រះ

នាងអនោជាទេវី ត្រាស់សួរថា ខណៈនេះ ព្រះមហាក្សត្រ និងស្វាមី របស់ពួកនាងទាំងឡាយ នាំគ្នាទៅរកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃដែល កើតក្នុងលោកហើយ ថែមទាំងតាំងចិត្តបួសក្នុងសម្នាក់ព្រះពុទ្ធអង្គផង តើពួកនាងគិតយ៉ាងណាក្នុងរឿងនេះ ។

ពួកកិរិយាទាំងនោះ នៅមិនទាន់ក្រាបបង្គំទូលតបទេ ប៉ុន្តែក្រាប បង្គំទូលសួរថា ព្រះមេម្ចាស់ ទ្រង់សម្រេចព្រះទ័យក្នុងរឿងនេះ យ៉ាង ណា ? ព្រះនាងអនោជាទេវីត្រាស់ថា នែនាងទាំងឡាយ យើងបានស្តាប់ ដំណឹងព្រះរតនត្រ័យហើយ បានបូជាទ្រព្យ ៩ សែនកហាបណៈ រាជ-សម្បត្តិនេះជាកំហាករបស់ព្រះរាជាប្រទានឲ្យយើង យើងមិនលុតជង្គង់ លិទ្ធកំហាកដែលព្រះរាជាទ្រង់ស្តោះចោលទេ យើងសម្រេចចិត្តហើយថា នឹងទៅបព្វជ្ជាក្នុងសម្នាក់ព្រះពុទ្ធដែរ ពួកកិរិយារបស់ពួកអាមាត្យទាំងនោះ ក្រាបបង្គំទូលថា បពិត្រព្រះមេម្ចាស់ យើងខ្ញុំទាំងអស់គ្នា ក៏នឹងចេញទៅ បព្វជ្ជាជាមួយព្រះមេដែរ ។ កាលបើព្រះនាងអនោជា និងពួកកិរិយារបស់ អាមាត្យទាំងនោះ បានព្រមព្រៀងគ្នាជាឯកច្ឆ័នហើយ ទើបត្រាស់ឲ្យត្រៀម

រាជរថ រួចហើយក៏នាំគ្នាឡើងជិះរាជរថចេញចាកព្រះនគរទៅរកព្រះពុទ្ធ ។ ចំណែកព្រះមហាកប្បិន ស្តេចនាំពួកអាមាត្យមួយពាន់ធ្វើដំណើរទៅ រហូតដល់ច្រាំងនៃស្ទឹង អរវច្ឆា ( ឬអបរច្ឆា ) ពេលនោះទឹកកំពុងតែ ឡើងប្រៀបច្រាំង មិនដឹងធ្វើយ៉ាងណា អាចទៅកាន់ត្រើយនាយបាន ទើបទ្រង់ធ្វើការអធិដ្ឋានថា

ប្រសិនបើព្រះសាស្តា ជាព្រះសម្មាសម្ពុទ្ធត្រាស់ដឹងក្នុងលោកពិត ប្រាកដមែន សូមឲ្យសេះរត់លើផ្ទៃទឹក ដូចរត់លើផែនថ្ម ដោយអំណាច ការអធិដ្ឋានរបស់ព្រះរាជា ដែលយកគុណព្រះពុទ្ធមកជាអារម្មណ៍ ក៏បាន ឆ្លងស្ទឹងផុតទៅព្រមទាំងបរិវាររបស់ខ្លួន សូម្បីជើងសេះក៏មិនទទឹកផង ។ ព្រះបាទមហាកប្បិន ស្តេចយាងបន្តបន្ទាប់រហូតមកដល់ស្ទឹងទីពីរ ឈ្មោះ ថា **នីលវាហនា** ជាស្ទឹងដែលមានទទឹងទូលំទូលាយ និងមានជម្រៅ ប្រមាណកន្លះយោជន៍ ព្រះរាជាទ្រង់អធិដ្ឋានដូចមុន ក៏ស្តេចឆ្លងស្ទឹងទៅ បានតាមសប្បាយ ដោយអំណាចនឹករឭកដល់គុណព្រះធម៌ ។ ពេល ស្តេចយាងមកដល់ស្ទឹងទីបីឈ្មោះថា **ចន្ទភាគា** ដែលមានទទឹងទូលំ-

ទូលាយ និងមានជម្រៅប្រមាណមួយយោជន៍ ព្រះរាជាក៏នាំពួកអាមាត្យ ឆ្លងស្ទឹងទៅបានដោយសុវត្ថិភាពទាំងនេះដោយអំណាចការអធិដ្ឋានរបស់ ព្រះរាជា ដែលនឹករឭកដល់គុណព្រះសង្ឃ ។

ក្នុងពេលជិតភ្លឺ ព្រះលោកនាយក ស្តេចចេញចាកមហាករុណាសមាបត្តិហើយ ទ្រង់ប្រមើលមើលសត្វលោក ដែលជាពុទ្ធកិច្ចត្រូវធ្វើជាប្រចាំរៀលរាល់ថ្ងៃ ដើម្បីអនុគ្រោះដល់សត្វលោក គ្រានោះ ក៏ទ្រង់ឃើញឧបនិស្ស័យរបស់ព្រះមហាកប្បិន ជាមួយនឹងពួកអាមាត្យមួយពាន់នាក់ កំពុងតែធ្វើដំណើរមកកាន់សម្នាក់របស់ព្រះអង្គ កាលបើព្រះសម្ពុទ្ធបាន់ចង្ហាន់រួចហើយ ទើបទ្រង់ហោះទៅគង់ប្រថាប់ទៀបគល់ដើមនិគ្រោធមួយដើម ដែលតាំងនៅក្បែរប្រាំងនៃស្ទឹងចន្ទភាគានោះ ។

ព្រះភគវាទ្រង់បញ្ចេញរស្មី ៦ ពណ៌ ចេញអំពីព្រះវរកាយរបស់ព្រះអង្គ ដែលគង់ប្រថាប់នោះ ។ កាលបើព្រះមហាកប្បិន ព្រមទាំងពួកអាមាត្យ ស្តេចឆ្លងស្ទឹងចន្ទភាគារួចហើយ បានក្រឡេកឃើញព្រះរស្មីទាំងនោះ ធ្វើឲ្យដើមនិគ្រោធដ៏ធំមានពណ៌ដូចមាស ទាំងស្លឹក ទាំងមែក

ក៏កើតការឆ្ងល់ឡើងថា រស្មីនេះកើតមកពីអ្វី ? ព្រះបាទមហាកប្បិន ទ្រង់ត្រិះរិះថា ពន្លឺនេះ មិនមែនជាពន្លឺព្រះចន្ទ ឬព្រះអាទិត្យទេ ទាំងមិនមែនរស្មីរបស់ទេវតា ព្រហ្ម មារ នាគ គ្រុឌ ឬរបស់អ្នកណាមួយឡើយ ប៉ុន្តែដែលយើងមកនេះ ដោយការតាំងចិត្តមករកព្រះសមណគោតមប៉ុណ្ណោះ មុខជានឹងមានហេតុ ដែលព្រះសមណគោតម ទ្រង់ឃើញការប្រព្រឹត្តទៅរបស់ពួកយើងជាពិតប្រាកដ ។

កាលបើព្រះរាជា ទ្រង់ត្រិះរិះដូច្នេះហើយ ទើបស្ដេចចុះពីខ្នងសេះ ក្នុងពេលនោះ ទ្រង់ក៏បានឃើញរស្មីព្រះសម្ពុទ្ធ ទើបបានចូលទៅគាល់ព្រះមានព្រះភាគ ព្រមដោយពួកអាមាត្យមួយពាន់នាក់ ថ្វាយបង្គំព្រះអង្គហើយ គង់ប្រថាប់ក្នុងទីដ៏សមគួរ ។ ប៉ុន្តែព្រះបាទមហាកប្បិន ទ្រង់សម្ដែងអាការត្រេកអររីករាយជ្រះថ្លាក្រៃលែងណាស់ ហើយស្ដេចស្ទុះទៅចាប់ព្រះយុគលបាទទាំងគូនៃព្រះសាស្ដា ទ្រង់ថ្វាយបង្គំរួចហើយ ទើបគង់ប្រថាប់ក្នុងទីដ៏សមគួរ ។ ព្រះសាស្ដា ទ្រង់សម្ដែងអនុបុព្វីកថា គឺព្រះពុទ្ធដីកា ដែលពោលទៅតាមលំដាប់ ចាប់ផ្ដើមអំពីទាន សីល ស្ថានសួគ៌

ទោសរបស់កាម និងអានិសង្សការចេញចាកកាម ទាំងអានិសង្សនៃការបព្វជ្ជា កាលបើចប់ព្រះធម៌ទេសនា ព្រះរាជា និងបរិវារទាំងអស់បានសម្រេចសោតាបត្តិផល ។

លំដាប់នោះ ជនទាំងនោះ មានព្រះមហាកប្បិនទ្រង់ជាប្រធាន នាំគ្នាក្រោកឡើង ក្រាបបង្គំទូលសូមបព្វជ្ជាចំពោះព្រះទសពល ព្រះអង្គទ្រង់ពិចារណាក្នុងការអនុញ្ញាតឲ្យបព្វជ្ជាថា កុលបុត្រទាំងនេះមានបាត្រចីវរដែលសម្រេចដោយបុញ្ញឫទ្ធិឬទេ ក៏ទ្រង់ជ្រាបថា កុលបុត្រទាំងនេះធ្លាប់បានថ្វាយចីវរមួយពាន់ផ្ទាំង ដល់ព្រះបច្ចេកពុទ្ធមួយពាន់រូបមកហើយ ថែមទាំងបានថ្វាយចីវរពីរម៉ឺនផ្ទាំងដល់ភិក្ខុសង្ឃ ក្នុងសាសនាព្រះកស្សបសម្មាសម្ពុទ្ធទៀតផង ។ កាលដែលព្រះអង្គទ្រង់ពិចារណាឃើញយ៉ាងនេះហើយ ទើបត្រាស់ថា

អ្នកចូរមកជាភិក្ខុចុះ ចូរអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវទីបំផុតនៃសេចក្តីទុក្ខដោយប្រពៃចុះ នេះជាវិធីនៃការបំបួសជាឯហិភិក្ខុ-ឧបសម្បទា ។មួយរំពេចនោះ កុលបុត្រទាំងនោះ ក៏ក្លាយជាភិក្ខុទាំងអស់

ព្រមទាំងមានបរិក្ខារគ្រប់គ្រាន់ ដូចជាព្រះថេរៈដែលមានវស្សា ១០០ ហើយនាំគ្នាចូលមកថ្វាយបង្គំព្រះបរមសាស្តា រួចហើយក៏គង់នៅក្នុងទីដ៏សមគួររៀងៗ ខ្លួន ។ ចំណែកព្រះនាងអនោជាទេវី ព្រមទាំងបរិវារមួយពាន់ ស្តេចយាងមកដល់ស្ទឹងអរវច្ឆា ( ឬអបរច្ឆា ) ហើយ ព្រះនាងទ្រង់ត្រិះរិះថា ទឹកដ៏ជ្រៅ និងស្ទឹងដ៏ធំ ពាហនៈមិនអាចឆ្លងបានទេ តើព្រះមហាក្សត្រ ទ្រង់ធ្វើយ៉ាងណាទើបឆ្លងទៅបាន ប្រាកដជាទ្រង់ធ្វើសច្ចកិរិយាហើយ ទើបទ្រង់អាចឆ្លងទៅបាន ។ការឧប្បត្តិឡើងក្នុងលោកនៃព្រះពុទ្ធ មិនមែនជាប្រយោជន៍ដល់កុលបុត្រ មួយពួកប៉ុណ្ណោះទេ ជាប្រយោជន៍ដល់ជនច្រើនក្នុងលោក កាលបើព្រះនាងទ្រង់ត្រិះរិះដូច្នេះហើយ ទើបទ្រង់ធ្វើសច្ចកិរិយាថា

ប្រសិនបើ ព្រះសាស្តា ទ្រង់ជាព្រះសម្មាសម្ពុទ្ធពិតមែន សូមកុំឲ្យរថរបស់ខ្ញុំទាំងឡាយ លិចចូលទៅក្នុងស្ទឹងនេះឡើយ ។កាលបើព្រះរាជទេវី ទ្រង់ពោលសច្ចកិរិយាដូច្នេះហើយ ទើបព្រះនាងរឭកដល់គុណព្រះរតនត្រ័យជាទីពឹង ក៏បានឆ្លងផុតអំពីស្ទឹងនោះទៅ ។ ការឆ្លងស្ទឹង

នីលវាហនា ស្ទឹងទីពីរ និងស្ទឹងទីបី ព្រះនាងក៏ទ្រង់ធ្វើសច្ចកិរិយា នាំបរិវារឆ្លងស្ទឹងទៅបានដោយសុវត្ថិភាព ដោយសារនឹករឭកដល់គុណព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។

ព្រះបរមសាស្តា ទ្រង់ជ្រាបការយាងមកនៃព្រះនាងអនោជាទេវី ព្រមទាំងបរិវាររបស់ខ្លួនហើយ ទើបទ្រង់សម្តែងឫទ្ធិមិនឲ្យភិក្ខុទាំងឡាយដែលគង់ក្នុងទីនោះបានឃើញស្ត្រីទាំងនោះ ទាំងស្ត្រីទាំងនោះក៏មិនបានឲ្យឃើញភិក្ខុដែរ ។ ចំណែកព្រះនាងអនោជាទេវី កាលបើយាងទៅដោយលំដាប់ ក៏បានឃើញព្រះរស្មី ៦ ពណ៌ ផ្សាយចេញអំពីសរីរៈរបស់ព្រះអង្គ ព្រះនាងត្រិះរិះដូចជាព្រះមហាកប្បិនដែរ ហើយទើបនាំបរិវារចុះចាករាជរថ យាងចូលទៅគាល់ព្រះលោកនាថតាមរស្មីនោះ កាលដល់ទីគង់ប្រថាប់ ទើបក្រាបទូលសួរថា

បពិត្រព្រះបរមសាស្តា ព្រះបាទមហាកប្បិន ព្រមដោយបរិវារប្រមាណមួយពាន់នាក់ ស្តេចយាងមករកព្រះអង្គ តើពេលនេះស្តេចនៅទីណា ? ព្រះភគវាត្រាស់ថា ព្រះនាងគង់ប្រថាប់សិនចុះ មុខជានឹងបាន

ឃើញជនទាំងនោះមិនខានឡើយ ។ ព្រះនាងអនោជាទេវី ព្រមទាំងបរិវារ ក៏សប្បាយចិត្ត ទើបនាំគ្នាគង់ប្រថាប់ដោយគិតថា នឹងបានឃើញស្វាមីរបស់ខ្លួនរៀងៗ ខ្លួន ។ ព្រះសម្ពុទ្ធទ្រង់ទតឃើញស្ត្រីទាំងនោះ គង់ប្រថាប់រៀបរយល្អហើយ ទើបព្រះអង្គសម្តែងអនុបុព្វីកថាឲ្យបានស្តាប់ ពេលដែលចប់អនុបុព្វីកថា ព្រះនាងអនោជាទេវីព្រមទាំងបរិវារ បានសម្រេចសោតាបត្តិផលគ្រប់ៗ គ្នា ។

ចំណែកព្រះមហាកប្បិនត្ថេរ និងបរិវារ កាលបើបានស្តាប់អនុបុព្វីកថា ដែលព្រះអង្គទ្រង់សម្តែងឲ្យដល់ស្ត្រីទាំងនោះបានស្តាប់ហើយ ក៏បានសម្រេចជាព្រះអរហន្ត ព្រមទាំងបដិសម្ភិទា ។ ខណៈពេលនោះ ព្រះសក្យមុនី ទ្រង់រំសាយឫទ្ធិឲ្យស្ត្រីទាំងនោះបានឃើញភិក្ខុទាំងឡាយ ។ ម្យ៉ាងទៀត កាលដែលព្រះសាស្តាទ្រង់សម្តែងឫទ្ធិបិទបាំង មិនឲ្យពួកស្ត្រីទាំងនោះឃើញភិក្ខុដែលជាស្វាមីមានលក្ខណៈប្លែក ដោយការទ្រទ្រង់សំពត់ពណ៌លឿង មានសីសៈត្រងោលដូច្នេះ ព្រោះបើពួកស្ត្រីទាំងនោះបានឃើញហើយ ចិត្តក៏មិនតាំងមាំ ឆន្ទរាគៈក៏កើតឡើង មិនអាចនឹង

ស្តាប់ធម៌បាន ពេលដែលបានសម្រេចធម៌ហើយ ទើបព្រះសាស្តាទ្រង់រំសាយឫទ្ធិ ឲ្យស្រ្តីទាំងនោះបានឃើញភិក្ខុដែលជាស្វាមី ក្នុងពេលដែលស្រ្តីទាំងនោះតាំងនៅក្នុងអចលសទ្ធា គឺសទ្ធាមិនញាប់ញ័រ ។ ព្រះនាងអនោជាទេវី និងបរិវារទាំងអស់បានឃើញព្រះថេរៈដែលជាស្វាមីហើយ ក៏នាំគ្នាថ្វាយបង្គំព្រះលោកនាយកទូលសូមដើម្បីបព្វជ្ជា ។

ព្រះលោកនាយក ទ្រង់រំពឹងដល់ព្រះនាងឧប្បលវណ្ណាថេរីៗ ដឹងវារៈចិត្តនៃការត្រិះរិះរបស់ព្រះសម្ពុទ្ធថា ត្រូវឲ្យព្រះថេរីនិមន្តទៅកាន់ស្ថានទីនោះ ដោយចេតោបរិយញ្ញាណ គឺការដឹងចិត្តរបស់អ្នកដទៃ ទើបព្រះថេរីហោះទៅកាន់ស្ថានទី ដែលព្រះអង្គគង់ប្រថាប់នៅនោះ ។ ព្រះភគវាទ្រង់ត្រាស់ប្រាប់ឧបាសិកាទាំងនោះថា ពួកនាងចូរទៅកាន់ក្រុងសាវត្ថី ចូរបព្វជ្ជានៅក្នុងសម្នាក់ព្រះថេរីចុះ ។ ព្រះនាងឧប្បលវណ្ណាថេរី បាននាំឧបាសិកាទាំងឡាយ មានព្រះនាងអនោជាទេវីជាដើម បានធ្វើដំណើរទៅដោយលំដាប់ ក្នុងរវាងផ្លូវពួកមហាជន បានបូជាដោយគ្រឿងសក្ការៈជាច្រើន កាលធ្វើដំណើរមកអស់រយៈផ្លូវ ១២០ យោជន៍ ក៏បានមកដល់

សម្នាក់ភិក្ខុនីទាំងឡាយ ហើយក៏បានបព្វជ្ជាក្នុងសម្នាក់ព្រះថេរីទាំងនោះ មិនយូរប៉ុន្មានក៏បានសម្រេចជាព្រះអរហន្តីគ្រប់ៗ រូប ។

ព្រះមានព្រះភាគ ទ្រង់នាំភិក្ខុមួយពាន់រូបផ្លោះទៅកាន់វត្តជេតពនមហាវិហារ តាមផ្លូវអាកាស ។ ព្រះមហាកប្បិនត្ថេរ ខណៈពេលដែលលោកគង់ក្នុងវត្តជេតពននោះ បានបន្លឺឧទានឡើងថា **សុខណាស់ហ្ន៎ ! សុខណាស់ហ្ន៎ !** ជានិច្ច ទាំងថ្ងៃ ទាំងយប់ ។ កាលបើភិក្ខុទាំងឡាយបានឮព្រះមហាកប្បិនត្ថេរបន្លឺឧទានយ៉ាងនេះរឿយៗ ក៏មានសេចក្តីសង្ស័យក្នុងពាក្យទាំងនោះ ទើបក្រាបបង្គំទូលព្រះជិនស្រីថា បពិត្រព្រះសាស្តា ព្រះមហាកប្បិនត្ថេរតែងបន្លឺឧទានថា សុខណាស់ហ្ន៎ សុខណាស់ហ្ន៎ តើសំដៅដល់សេចក្តីសុខក្នុងរាជសម្បត្តិរបស់លោកឬ ? ព្រះសម្ពុទ្ធ ទ្រង់ត្រាស់ឲ្យភិក្ខុទៅហៅព្រះមហាកប្បិនត្ថេរចូលមកគាល់ ហើយទ្រង់ត្រាស់សួរថា ម្នាលកប្បិន បានឮថា អ្នកតែងតែបន្លឺឧទានថា សុខណាស់ហ្ន៎ សុខណាស់ហ្ន៎ ដូច្នេះពិតមែនឬ ? តើសំដៅដល់សេចក្តីសុខក្នុងរាជ-សម្បត្តិរបស់អ្នកពិតមែនឬ ? ព្រះមហាកប្បិនត្ថេរក្រាបទូលថា បពិត្រ

ព្រះលោកនាយក ព្រះអង្គតែងតែទ្រង់ជ្រាបហើយថា ដែលខ្ញុំព្រះអង្គបន្លឺឧទានសុខណាស់ហ្ន៎ សុខណាស់ហ្ន៎នោះ មិនមែនសំដៅដល់សុខក្នុងកាមគុណ ឬសុខនៅក្នុងរាជសម្បត្តិនោះទេ ។

ព្រះសក្យមុនីត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគតមិនបានបន្លឺឧទាន សុខណាស់ហ្ន៎ សុខណាស់ហ្ន៎នោះ សំដៅដល់កាម-គុណ ឬក្នុងរាជសម្បត្តិទេ ប៉ុន្តែជាអ្នកមានបីតិក្នុងធម៌ ទើបបន្លឺឧទានយ៉ាងនេះ កាលបើព្រះអង្គទ្រង់ត្រាស់រ៉ាប់រងព្រះមហាកប្បិនដូច្នេះហើយទើបត្រាស់គាថាធម្មបទថា

បុគ្គលដែលមាននូវធម្មប្បីតិ មានចិត្តថ្លាស្អាត រមែងនៅជាសុខបណ្ឌិតរមែងតែងតែត្រេកអរនៅក្នុងព្រះធម៌ ដែលព្រះអរិយៈជាម្ចាស់បានប្រកាសហើយសព្វៗ កាល ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់សរសើរព្រះមហាកប្បិនត្ថេរថា ជាអ្នកមានភាពស្អាតហ្មត់ហ្មង មានឫទ្ធិច្រើន មានអានុភាពច្រើន និងមានសមត្ថភាព ដែលមានរឿងពោលចារឹកទុកក្នុងបាលី **គម្ពីរសំយុត្តនិកាយ**

និទានវគ្គ នៃ ភិក្ខុសំយុត្ត ក្នុង កប្បិនសូត្រ ដែលពោលដល់រឿងព្រះមហាកប្បិនត្ថេរ ដោយមានសេចក្តីថា ៖

សម័យមួយ ព្រះមានជោគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុពីររូបជាសម្លាញ់នឹងគ្នា ជាសទ្ធិវិហារិករបស់ព្រះមហាកប្បិនមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ ។

ព្រះសាស្តា បានទតឃើញភិក្ខុទាំងនោះ កំពុងមកអំពីចម្ងាយលុះទតឃើញហើយ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញភិក្ខុទាំងពីររូបនុ៎ះ ជាសម្លាញ់នឹងគ្នាកំពុងដើរមកជាសទ្ធិវិហារិករបស់មហាកប្បិនឬទេ ?ភិក្ខុទាំងឡាយក្រាបទូលថា ព្រះករុណាព្រះអង្គ ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះឯង មានឫទ្ធិច្រើន មានអានុភាពច្រើន សមាបត្តិណា ដែលភិក្ខុទាំងនោះមិនធ្លាប់ចូលសមាបត្តិនោះ បុគ្គលដទៃមិនបានដោយងាយឡើយ មួយទៀត ពួកកុលបុត្រ ដែលចេញចាកផ្ទះចូលមកកាន់ផ្នួស

ដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ភិក្ខុទាំងនោះបាន ត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយធម៌នោះ ។

ព្រះមានព្រះភាគលុះត្រាស់ដូច្នេះហើយ ទើបទ្រង់ត្រាស់ព្រះពុទ្ធ ដីកានេះតទៅទៀតថា

ភិក្ខុទាំងនេះ ជាសម្លាញ់នឹងគ្នា ជាអ្នកមានលទ្ធិត្រូវគ្នា ជាយូរ ហើយ ទាំងព្រះសទ្ធម្មរបស់ភិក្ខុទាំងនោះ ក៏ត្រូវគ្នាក្នុងធម៌ដែលព្រះពុទ្ធ សម្តែងហើយ ( ភិក្ខុទាំងនោះ ) កប្បិនភិក្ខុ បានទូន្មានហើយ ក្នុងធម៌ ដែលព្រះអរិយៈសម្តែងហើយ ភិក្ខុទាំងនោះ ទ្រទ្រង់នូវអត្តភាពជាទីបំផុត បានឈ្នះមារ ព្រមទាំងសេនាមារ ។

មានរឿងក្នុងការឲ្យឱវាទដល់ភិក្ខុទាំងឡាយ របស់ព្រះមហា កប្បិនត្ថេរ នៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដូចមានសេចក្តីថា ៖

ថ្ងៃមួយ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ហៅភិក្ខុមួយពាន់រូប ដែលជាបរិវាររបស់ព្រះមហាកប្បិនត្ថេរ ចូលមកគាល់ព្រមគ្នា ហើយ

ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ មហាកប្បិនដែលជាអាចារ្យរបស់អ្នក ធ្លាប់សម្តែងធម៌ឲ្យពួកអ្នកស្តាប់ខ្លះឬទេ ?

ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះមានព្រះភាគ អាចារ្យរបស់ពួកខ្ញុំព្រះអង្គ មិនធ្លាប់សម្តែងធម៌ណាមួយដល់ពួកខ្ញុំព្រះអង្គឡើយ ព្រោះលោកជាអ្នកមានការខ្វល់ខ្វាយតិច ប្រកបតែក្នុងទិដ្ឋធម្មសុខវិហារ គឺនៅជាសុខសប្បាយក្នុងធម៌ដែលលោកឃើញហើយ មិនដែលឲ្យឱវាទដល់អ្នកណាមួយឡើយព្រះអង្គ ។ ព្រះមានព្រះភាគ កាលត្រាស់ហៅព្រះមហាកប្បិនត្ថេរចូលមកគាល់ហើយ ក៏ត្រាស់សួរថា ម្នាលកប្បិន អ្នកមិនធ្លាប់បានឲ្យឱវាទ ដល់ពួកអន្តេវាសិកទាំងនោះពិតមែនឬ ? ព្រះមហាកប្បិនត្ថេរក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពិតមែនព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា អ្នកជាព្រះខីណាស្រព អ្នកកុំធ្វើយ៉ាងនេះឡើយ ពីពេលនេះទៅ អ្នកចូរសម្តែងធម៌ដល់ភិក្ខុទាំងឡាយចុះ ។ ព្រះមហាកប្បិនត្ថេរក៏ទទួលព្រះពុទ្ធដីកាថា ព្រះករុណាព្រះអង្គ ។

ក្នុងកាលជាខាងក្រោយមក ព្រះមានព្រះភាគជាម្ចាស់ ទ្រង់តែង តាំងព្រះមហាកប្បិនត្ថេរទុកក្នុងតំណែងឯតទគ្គៈ ដូចមានសេចក្តីក្នុងបាលី **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** មានន័យថា

ម្នាលភិក្ខុទាំងឡាយ មហាកប្បិនប្រសើរជាងភិក្ខុទាំងឡាយ ដែល ជាសាវករបស់តថាគត ផ្នែកខាងឲ្យឱវាទដល់ពួកភិក្ខុ ។ ការឲ្យឱវាទ ដល់ភិក្ខុទាំងឡាយ របស់ព្រះមហាកប្បិនត្ថេរ មានក្នុង **គម្ពីរខុទ្ទកនិកាយ ថេរគាថា នៃ ទសកនិបាត** ដូចមានសេចក្តីថា ៖

នៅថ្ងៃមួយ ព្រះថេរៈបានឲ្យឱវាទដល់ពួកភិក្ខុនី ដោយពោលគាថា ១០ គាថា ដូចមានសេចក្តីថា

បុគ្គលណា ពិចារណាឃើញនូវកិច្ចជាប្រយោជន៍ និងមិនជា ប្រយោជន៍ទាំងពីរនោះ ដែលមិនទាន់មកដល់ទុកជាមុន ជនទាំងឡាយ ជាសត្រូវក្តី ជាអ្នកស្វែងរកប្រយោជន៍ក្តី កាលគយគន់មើល រមែង មិនឃើញនូវទោសនៃបុគ្គលនោះឡើយ ។ អានាបានស្សតិ ដែលព្រះ

យោគាវចរណា បានចម្រើនល្អគ្រប់គ្រាន់ហើយ បានសន្សំហើយ តាមលំដាប់ ដូចព្រះពុទ្ធទ្រង់សម្ដែងមក ព្រះយោគាវចរនោះ រមែងញុំាងលោកនេះ ឲ្យភ្លឺច្បាស់ ដូចព្រះចន្ទផុតចាកពពក ។ ឱ ! ចិត្តរបស់អញ ស.រកប្រមាណមិនបាន អាត្មាអញ បានអប់រំល្អហើយផង បានផ្គងជានិច្ចផង ញុំាងទិសទាំងពួងឲ្យភ្លឺផង ។ បុគ្គលប្រកបដោយប្រាជ្ញា បើទុកជាអស់ទ្រព្យរលីង ក៏ឈ្មោះថា រស់នៅ ឯបុគ្គលអ្នកមានទ្រព្យ មិនឈ្មោះថារស់នៅ ព្រោះកិរិយាមិនបាននូវប្រាជ្ញា ។ ប្រាជ្ញាជាគ្រឿងវិនិច្ឆ័យនូវសុតៈ ប្រាជ្ញាជាគ្រឿងញុំាងកិត្តិស័ព្ទ និងសេចក្ដីសរសើរឲ្យចម្រើន នរជនប្រកបដោយប្រាជ្ញា រមែងបាននូវសេចក្ដីសុខ សូម្បីក្នុងសភាវៈដែលជាទុក្ខ ។

ធម៌នេះមិនមែនជាធម៌ទើបនឹងមាន ក្នុងថ្ងៃនេះទេ ជាធម៌មិនអស្ចារ្យ មិនមែនជាធម៌ចម្លែកទេ សត្វកើតស្លាប់ ក្នុងលោកណា ហេតុតិចតួច ក៏មិនចម្លែកក្នុងលោកនោះ ។ សេចក្ដីពិតថា បន្ទាប់អំពីការ

កើតមក មានសេចក្តីស្លាប់ចាកជីវិត ជាធម្មជាតទៀងទាត់ សត្វទាំងឡាយ ដែលកើតមកហើយៗ រមែងស្លាប់ក្នុងលោកនេះ ព្រោះថា សត្វទាំងឡាយ មានសភាពយ៉ាងនេះឯង ។សេចក្តីសោកស្តាយណា របស់បុរសបុគ្គលទាំងឡាយដទៃ ដើម្បីជីវិត សេចក្តីសោកស្តាយនុ៎ះ មិនមែនដើម្បីប្រយោជន៍ ដល់សត្វដែលស្លាប់ទៅហើយទេ ការយំចំពោះសត្វដែលស្លាប់ហើយ មិនមែនជាយស មិនមែនជាការល្អទេ សមណព្រាហ្មណ៍ទាំងឡាយ មិនសរសើរការយំឡើយ ។ការយំ រមែងបៀតបៀននូវចក្ខុ និងសរីរៈ ( របស់បុគ្គលអ្នកយំ ) ពណ៌សម្បុរក្តី កម្លាំងក្តី ប្រាជ្ញាក្តី នៃអ្នកយំរមែងសាបសូន្យ ពួកសត្រូវរបស់បុគ្គលអ្នកយំនោះ ក៏មានសេចក្តីត្រេកអរ ពួកបុគ្គលអ្នកស្វែងរកប្រយោជន៍ ឲ្យបុគ្គលអ្នកយំនោះ បាននូវសេចក្តីទុក្ខ ។ព្រោះហេតុនោះ ពួកជនធ្វើនូវកិច្ច ( របស់ខ្លួន ) ដោយកម្លាំងប្រាជ្ញា របស់អ្នកប្រាជ្ញទាំងឡាយណា ដូចពួកជនអ្នកធ្វើនូវទន្លេមានទឹកពេញដោយទូក បុគ្គលគប្បីប្រាថ្នា នូវអ្នកប្រាជ្ញ

ជាពហូសូតនោះ ឲ្យនៅក្នុងត្រកូល ( របស់ខ្លួន ) ។

កាលបើភិក្ខុនីទាំងនោះ បានស្តាប់ឱវាទព្រះថេរៈយ៉ាងនេះហើយ ក៏បានបន្ទោបង់នូវសេចក្តីសោកហើយ បដិបត្តិយ៉ាងត្រឹមត្រូវល្អ មិនយូរប៉ុន្មានក៏បានញុំាងប្រយោជន៍របស់ខ្លួនឲ្យសម្រេច ។

ព្រះមហាកប្បិនត្ថេរ កាលបើលោកទ្រទ្រង់អាយុសង្ខារមកដល់កាលដ៏សមគួរហើយលោកក៏បានរំលត់ខន្ធបរិនិព្វានទៅកាន់ទីបរមសុខពោល គឺព្រះនិព្វាននោះឯងហោង ។៚

( ជីវប្រវត្តិរបស់ព្រះមហាកប្បិនត្ថេរ ចប់ )

# ជីវប្រវត្តិរបស់ព្រះសាគតត្ថេរ

## " ដែលជាឯតទគ្គៈផ្នែកខាងឈ្លាសវៃក្នុងតេជោធាតុ "

ព្រះសាគតត្ថេរ លោកជាអ្នកសាងវីរកម្ម ដើម្បីព្រះពុទ្ធសាសនា រហូតបានទទួលការលើកតម្កើង ឲ្យជាអ្នកឈ្លាសវៃក្នុងតេជោកសិណសមាបត្តិ កំពូលជាងព្រះអរហន្តទាំងឡាយ តាមដែលព្រះមុនីទ្រង់ត្រាស់សរសើរដល់លោក ដូចមាននៅក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ថា

**ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ តេជោធាតុកុសលានំ យទិទំ សាគតោ** ម្នាលភិក្ខុទាំងឡាយ សាគតៈ ជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវ័ករបស់តថាគត ផ្នែកខាងជាអ្នកឈ្លាសវៃក្នុងតេជោធាតុ ។

ជីវប្រវត្តិរបស់ព្រះសាគតត្ថេរ មានសម្តែងនៅក្នុង **អដ្ឋកថាគម្ពីរមនោរថបូរណី** ដូចមានសេចក្តីថា ៖

ព្រះសាគតត្ថេរ មកកើតនៅក្នុងត្រកូលព្រាហ្មណ៍ នៅក្នុងនគរ

ហង្សវតី មាតាបិតាដាក់ឈ្មោះឲ្យលោកថា សាគតៈ ។ ចំណែកឈ្មោះរបស់មាតាបិតាលោកវិញ មិនឃើញមានសម្ដែងថាមានឈ្មោះអ្វីទេ ។ កាលសាគតមាណពចម្រើនវ័យធំហើយ បានទៅស្ដាប់ធម៌ទេសនាក្នុងសម្នាក់ព្រះមានបុណ្យ ហើយក៏កើតសទ្ធាជ្រះថ្លានៅក្នុងព្រះពុទ្ធសាសនា ទើបសម្រេចចិត្តបួស ពេលដែលលោកបួសរួចហើយ មានការតាំងចិត្តបំពេញសមណកិច្ច រហូតបានសម្រេចសមាបត្តិ ៨ ដែលជាលោកិយ ថែមទាំងជាអ្នកមានភាពស្ទាត់ជំនាញ រហ័សរហួនក្នុងសមាបត្តិ ៨ នោះ។ ថ្ងៃមួយ ព្រះមានព្រះភាគ ស្ដេចយាងទៅដល់កន្លែងមួយក្បែរនឹងក្រុងកោសម្ពី ដែលមានព្រះសាគតត្រេរទៅជាមួយផង ។ គ្រានោះ មនុស្សជាច្រើននាក់បាននាំគ្នាទៅកាន់កំពង់ចម្លងអម្ពៈ ហើយបានទាស់គ្នាជាមួយអ្នកចម្លងនោះ ។ការឈ្លោះប្រកែកគ្នារវាងអ្នកធ្វើដំណើរ ជាមួយនឹងអ្នកចម្លងយ៉ាងខ្លាំងក្លា រហូតដល់ពួកអ្នកទាំងអស់នោះ នាំគ្នាវាយអ្នកចម្លងនោះទាល់តែអស់ជីវិត ។ ប៉ុន្តែមុនពេលអ្នកចម្លងជិតស្លាប់នោះ ក៏បានតាំងសេចក្ដីប្រាថ្នាទុកដោយចិត្តក្រោធ ចងអាឃាតចំពោះអ្នកទាំងអស់

នោះ ហើយស្លាប់ទៅកើតជាស្តេចនាគ ដែលមានអានុភាពច្រើន នៅនឹងកំពង់ចម្លងនោះឯង ។ ពេលជិតនឹងស្លាប់ ប្រសិនបើបុគ្គលមានចិត្តជាប់ជំពាក់ជាមួយនឹងអ្វី នឹងធ្វើឲ្យបុគ្គលនោះទៅកើតក្នុងភព ឬស្ថាននោះ ។ ឧបមាដូចមនុស្សដែលធ្វើបុណ្យផ្សេងៗ កាលបើគេនឹករឭកនូវសេចក្តីល្អនោះជារឿយៗ ទើបធ្វើឲ្យគេទៅកើតក្នុងសុគតិភព ដោយអំណាចបុណ្យកុសលដែលគេធ្វើហើយហ្នឹងឯង ។ ចំណែកបុគ្គលធ្វើអាក្រក់វិញ មិនធ្លាប់ធ្វើសេចក្តីល្អទាល់តែសោះ ការនឹកគិតដល់រឿងអាក្រក់របស់គេនោះក៏ធ្វើឲ្យចិត្តក្តៅក្រហាយ ចំពោះអំពើអាក្រក់របស់គេ កាលបើសេចក្តីស្លាប់មកដល់ហើយ ធ្វើឲ្យបុគ្គលនោះទៅកើតក្នុងទុគ្គតិ មាននរក ប្រេតតិរច្ឆាន និងអសុរកាយ ឬត្រឡប់មកកើតជាមនុស្សវិញ ជាអ្នកមានរាងកាយពិការពិកិន គ្ររហេមរហាម ថែមទាំងជាអ្នកមានជំងឺតម្កាត់ច្រើនទៀតផង និងជាមនុស្សអនាថា មិនមានទីពឹងទៀតផង ។

ចំណែកស្តេចនាគនោះ នៅតែមានចិត្តគិតចងអាឃាត ចំពោះអ្នកទាំងនោះជានិច្ច បានបណ្តាលឲ្យមានភ្លៀងខុសរដូវកាល ដូចជារដូវភ្លៀង

ធ្វើមិនឲ្យមានភ្លៀង ដំណាំរបស់កសិករទាំងឡាយ ក៏ដល់នូវការវិនាស ខូចខាតទៅ មិនអាចដុះលូតលាស់បានឡើយ ។ មនុស្សទាំងអស់ក្នុងដែន កាលបើជួបប្រសព្វនឹងភ័យ ដែលមិនមានភ្លៀង ថែមទាំងរាំងស្ងួតហួត ហែង ដូច្នេះហើយ ទើបនាំគ្នាធ្វើពលិកម្មបួងសួងរាល់ៗ ឆ្នាំ ដើម្បីឲ្យមាន ភ្លៀងធ្លាក់ត្រូវកាលក៏បាន នាំគ្នាសង់សាលាមួយខ្នង ឲ្យស្តេចនាគនោះ ។

ការទូន្មានស្តេចនាគ ជាដើមបញ្ញត្តិ ការហាមផឹកសុរាមេរ័យរបស់ ព្រះសាគតត្ថេរ ដូចមានរឿងប្រាកដក្នុង **គម្ពីរមហាវគ្គ ព្រះវិនយបិដក** នៃ **សុរាបានវគ្គ សិក្ខាបទទី ១** និងនៅក្នុងអដ្ឋកថាដែលអធិប្បាយសេចក្តី នៃ **សុរាបានជាតក** ក្នុង **គម្ពីរខុទ្ទកនិកាយជាតក** ដូចមានសេចក្តីថា ៖

សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលទ្រង់ពុទ្ធដំណើរទៅកាន់ ចារិក ក្នុងចេតិយជនបទ ហើយយាងចូលទៅកាន់ស្រុកភទ្ទវតិកា ។ ពួកអ្នកឃ្វាលគោ ពួកអ្នកបសុសត្វ ( សត្វសម្រាប់ចិញ្ចឹមជាអាហារ ) ពួកអ្នកស្រែ ពួកអ្នកដើរផ្លូវ បានឃើញព្រះសាស្តាយាងមកអំពីចម្ងាយ លុះឃើញហើយ ក៏នាំគ្នាក្រាបទូលព្រះសម្ពុទ្ធ ដូច្នេះថា បពិត្រព្រះអង្គ

ដ៏ចម្រើន សូមព្រះមានព្រះភាគ កុំយាងទៅកាន់កំពង់ឈ្មោះអម្ពះឡើយ បពិត្រព្រះវិជិតមារដ៏ចម្រើន នាគមានឫទ្ធិជាសត្វអាសិរពិស មានពិសដ៏ក្លៀវក្លា អាស្រ័យនៅក្នុងអាស្រម របស់ជដិលទៀបកំពង់ឈ្មោះអម្ពះ កុំឲ្យនាគនោះ បៀតបៀនព្រះសក្យមុនីឡើយ ។ កាលបើពួកជនទាំងនោះក្រាបទូលយ៉ាងនេះហើយ ព្រះមានជោគក៏ទ្រង់នៅស្ងៀម ។ ពួកអ្នកឃ្វាលគោ អ្នកឃ្វាលបសុសត្វ អ្នកស្រែ អ្នកដើរផ្លូវ បានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះជិនស្រី ជាគម្រប់ពីរដងផង ។បេ។ បីដងផងថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គកុំយាងទៅកាន់កំពង់ឈ្មោះអម្ពះនោះឡើយ ព្រោះមាននាគមានឫទ្ធិច្រើន ជាសត្វអាសិរពិស មានពិសដ៏ក្លៀវក្លា អាស្រ័យនៅក្នុងអាស្រមរបស់ជដិល ទៀបកំពង់អម្ពះ កុំឲ្យនាគនោះបៀតបៀនព្រះមហាវីរៈបានឡើយ ។ ព្រះលោកនាថ ក៏ទ្រង់នៅស្ងៀម ជាគម្រប់បីដង ។លំដាប់នោះ ព្រះសយម្ភូ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិកដោយលំដាប់ ក៏បានយាងទៅដល់ស្រុកភទ្ទវតិកា ។មានដំណឹងល្បីទៅថា ព្រះលោកនាយកគង់នៅក្នុងស្រុកភទ្ទវតិកានោះ ។ គ្រានោះឯង ព្រះ

សាគតៈដ៏មានអាយុ បានចូលទៅកាន់អាស្រម របស់ជដិលទៀបកំពង់អម្ពៈ លុះចូលទៅដល់ហើយ ក៏ដើរចូលទៅក្នុងរោងភ្លើង ក្រាលកម្រាលស្មៅ ហើយក៏អង្គុយពត់ភ្នែន តាំងកាយដ៏ត្រង់ តម្កល់សតិផ្ចិតផ្ចង់ ។ ឯនាគនោះ បានឃើញព្រះសាគតៈដ៏មានអាយុចូលមកហើយ លុះឃើញហើយ ក៏កើតទុក្ខទោមនស្សប្រផ្នួយផ្សែង ( ពិសចំពោះសាគតត្ថេរ ) ។ ចំណែកខាងព្រះសាគតៈដ៏មានអាយុ ក៏បផ្នួយផ្សែងតបទៅវិញ ។ គ្រានោះ នាគនោះខឹងអត់ទ្រាំនូវសេចក្តីរំលោភលើនោះមិនបាន ក៏បណ្តាលឲ្យកើតភ្លើងឡើង ។ ឯព្រះសាគតៈ ក៏បានចូលតេជោធាតុ ហើយបណ្តាលភ្លើងតបទៅវិញ ។ លំដាប់នោះឯង ព្រះសាគតៈក៏បានគ្របសង្កត់តេជៈរបស់នាគនោះ ដោយតេជៈរបស់លោក ស្តេចនាគទើបគិតថា ភិក្ខុរូបនេះមានតេជៈច្រើន ជាអ្នកប្រសើរដោយពិត ហើយក៏ព្រមចាញ់ បានចូលទៅរកព្រះថេរៈ ទើបពោលថា

បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំម្ចាស់សូមគោរពលោកម្ចាស់ជាសរណៈ ជាទីពឹង ជាទីរឭក គ្រានោះ ព្រះសាគតៈមានថេរវាចាណែនាំ

ស្ដេចនាគដោយប្រការផ្សេងៗ ហើយទើបពោលថា អ្នកកុំយកយើងជាសរណៈអី អ្នកចូរយកព្រះសម្មាសម្ពុទ្ធជាទីពឹងទីរឭកវិញចុះ ។ ក្នុងទីបំផុតស្ដេចនាគព្រមទទួលថា ល្អហើយ និងបានពោលវាចាសូមដល់ព្រះពុទ្ធជាទីពឹង ទីរឭកស្មើដោយជីវិត ។ ការគោរពព្រះរតនត្រ័យជាទីពឹងសំដៅដល់មានត្រៃសរណគមន៍ ប្រចាំចិត្តរបស់ស្ដេចនាគនោះ និងមានសញ្ញាលក្ខណៈប្រចាំនៅក្នុងចំណែកផ្សេងៗ របស់រាងកាយ ដែលជានិមិត្តប្លែកអំពីមនុស្សយើងច្រើន ។ព្រះត្រៃសរណគមន៍ដែលស្ដេចនាគគោរពនោះ មានព្រះសព្វញ្ញុតញ្ញាណដ៏ប្រសើរ ជាសិរសា មានអារម្មណ៍ដ៏ប្រសើរ គឺព្រះនិព្វាន ជាសក់ មានចតុត្ថជ្ឈានដ៏ប្រសើរ ជាថ្ងាស មានសមាបត្តិដ៏ប្រសើរ ជារោមឧណ្ណាលោម មាននីលកសិណ បីតកសិណដ៏ប្រសើរ ជាចិញ្ចើមទាំងគូ មានទិព្វចក្ខុ បញ្ញាចក្ខុ សមន្តចក្ខុដ៏ប្រសើរជាចក្ខុទាំងពីរខាង មានទិព្វសោតដ៏ប្រសើរ ជាត្រចៀកឆ្វេងស្ដាំ មានគោត្រភូញាណដ៏ប្រសើរ ជាច្រមុះ មានមគ្គញ្ញាណ ផលញ្ញាណ វិមុត្តិ-ញ្ញាណដ៏ប្រសើរ ជាកំពូលទាំងពីរខាង មានលោកិយញ្ញាណ លោកុត្តរ-

ញ្ញាណដ៏ប្រសើរ ជាបបូរមាត់ មានពោធិបក្ខិយញ្ញាណដ៏ប្រសើរ ៣៧ ប្រការ ជាធ្មេញដ៏ស្អាត មានមគ្គញ្ញាណ ៤ ដ៏ប្រសើរ ជាចង្កូមទាំង ៤ មានសច្ចញ្ញាណទាំង ៤ ដ៏ប្រសើរ ជាអណ្តាត មានញាណដែលមិនមានវត្ថុណាជំទាស់ ជាចង្កា មានញាណជាគ្រឿងសម្រេចវិមោក្ខយ៉ាងខ្ពស់ ជាដើម.ក មានត្រៃលក្ខណ៍ដ៏ប្រសើរ ជាបំពង់.ក មានវេសារជ្ជញ្ញាណ ៤ ដ៏ប្រសើរ ជាដៃទាំងពីរ មានអនុស្សតិញ្ញាណ ១០ ប្រការដ៏ប្រសើរ ជាទ្រូង មានអាសយានុសយញ្ញាណដ៏ប្រសើរ ជាដោះទាំងពីរ មានទសពលញ្ញាណដ៏ប្រសើរ ជាដងខ្លួន មានញាណដែលដឹងនូវបដិច្ចសមុប្បាទធម៌ដ៏ប្រសើរ ជាផ្ចិត មានឥន្ទ្រិយ ៥ ពលៈ ៥ ដ៏ប្រសើរ ជាជង្គង់ មានការព្យាយាមត្រូវ ៥ ប្រការ ជាជើង មានកុសលកម្មបថ ១០ ប្រការ ជាស្មងជើងទាំងពីរ មានឥទ្ធិបាទ ជាបាទជើងទាំងពីរ មានសីល សមាធិ បញ្ញា ជាសំពត់ស្លៀក មានហិរិឱត្តប្បៈ ជាសំពត់ដណ្តប់ មានអដ្ឋង្គិក-មគ្គញ្ញាណ ជាស្បែក មានសតិប្បដ្ឋាន ៤ ជាវត្ថពន្ធចង្កេះ ។ចាប់ពីថ្ងៃនេះតទៅ ខ្ញុំព្រះអង្គមិនបៀតបៀននរណាៗ ទៀតឡើយខ្ញុំព្រះអង្គនឹងធ្វើ

ឲ្យមានភ្លៀងធ្លាក់ត្រូវរដូវកាលវិញ ។

ក្រោយពីស្តេចនាគ បានទទួលយកព្រះរតនត្រ័យជាទីពឹង ទីរឮក ហើយមនុស្សក្នុងដែននោះក៏ប្រកបដំណាំដាំដុះបានដូចដើមវិញទាំងនេះ កើតឡើងដោយអានុភាពរបស់ស្តេចនាគនោះ ។ ព្រះសាគតត្ថេរ កាលបើទូន្មានស្តេចនាគបានដូច្នេះហើយ ក៏ត្រឡប់ទៅកាន់សម្នាក់ព្រះភគវា ដែលគង់ប្រថាប់ក្នុងស្រុកភទ្ទវតិកា ។ កាលដែលព្រះមានបុណ្យគង់នៅក្នុងស្រុកភទ្ទវតិកា តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ក៏ទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ឯក្រុងកោសម្ពី ។ ពួកឧបាសកនៅក្នុងក្រុងកោសម្ពី បានឮគេនិយាយថា លោកម្ចាស់សាគតៈ បានច្បាំងគ្នានឹងនាគឈ្មោះអម្ពតិត្ថកៈ ។ គ្រានោះព្រះមានជោគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិកដោយលំដាប់ ហើយទ្រង់សំដៅទៅឯក្រុងកោសម្ពីនោះ ។ គ្រានោះឯង ពួកឧបាសកនៅក្នុងក្រុងកោសម្ពី នាំគ្នាទៅទទួលព្រះភគវា ហើយចូលទៅរកព្រះសាគតៈ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះសាគតៈ ហើយក៏ស្ថិតនៅក្នុងទីដ៏សមគួរ ។ ពួកឧបាសកនៅក្នុងក្រុងកោសម្ពី លុះស្ថិត

នៅក្នុងទីដ៏សមគួរហើយ ទើបនិយាយពាក្យនេះនឹងព្រះសាគតៈថា បពិត្រលោកម្ចាស់ដ៏ចម្រើន វត្ថុអ្វីដែលលោកម្ចាស់បានដោយកម្រផង ជាទីគាប់ចិត្តផង ពួកយើងខ្ញុំនឹងតាក់តែងវត្ថុអ្វីប្រគេន លុះឧបាសកទាំងនោះបានពោលពាក្យយ៉ាងនេះហើយ ពួកឆព្វគ្គិយភិក្ខុ បាននិយាយពាក្យនេះនឹងពួកឧបាសកនោះថា ម្នាលអ្នកទាំងឡាយ សុរាថ្លាឈ្មោះកាបោតិកា ( មានពណ៌ក្រហមដូចជើងព្រាប ) ដែលភិក្ខុទាំងឡាយរកបានដោយកម្រផង ជាទីគាប់ចិត្តរបស់ពួកភិក្ខុផង ពួកអ្នកឯងចូរតាក់តែងវត្ថុនោះប្រគេនលោកចុះ ។ លំដាប់នោះឯង ពួកឧបាសកនៅក្នុងក្រុងកោសម្ពី នាំគ្នាតាក់តែងសុរាថ្លាឈ្មោះកាបោតិកាគ្រប់ៗ ផ្ទះ បានឃើញព្រះសាគតៈកំពុងនិមន្តបិណ្ឌបាតហើយ និយាយពាក្យនេះនឹងព្រះសាគតៈថា បពិត្រលោកដ៏ចម្រើន សូមលោកម្ចាស់សាគតៈ និមន្តឆាន់សុរាថ្លា ឈ្មោះកាបោតិកាចុះ ។ គ្រានោះ ព្រះសាគតៈដ៏មានអាយុ លុះបានឆាន់សុរាគ្រប់ៗ ផ្ទះហើយ ចេញពីនគរទៅ ក៏ដួលដេកទៀបទ្វារនគរ ។ គ្រានោះព្រះសម្ពុទ្ធ កាលចេញចាកនគរជាមួយនឹងភិក្ខុជាច្រើនអង្គ បានទតឃើញ

ព្រះសាគតៈដួលដេកនៅទៀបទ្វារនគរ លុះទ្រង់ឃើញហើយ ក៏ត្រាស់បង្គាប់ពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរគ្រាហ៍សាគតភិក្ខុឡើង ។ ភិក្ខុទាំងនោះក៏ទទួលព្រះពុទ្ធដីការបស់ព្រះមុនី ដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងហ្នឹងហើយៗ ក៏គ្រាហ៍ព្រះសាគតៈទៅកាន់អារាមហើយ ផ្ដេកបែរក្បាលទៅរកព្រះវិជិតមារ ។

លំដាប់នោះ ព្រះសាគតៈ ប្រែត្រឡប់ដេកដាក់ជើងទៅរកព្រះជិនស្រីវិញ ។ គ្រានោះ ព្រះមហាវីរៈ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពីដើមមកសាគតភិក្ខុ មានសេចក្ដីគោរពកោតក្រែងដល់តថាគតពិតមែនឬទេ ? ពួកភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោសពិតយ៉ាងហ្នឹងហើយ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ចុះឥឡូវនេះសាគតភិក្ខុ មានសេចក្ដីគោរពកោតក្រែងដល់តថាគតឬទេ ? ពួកភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស មិនគោរពទេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា សាគតភិក្ខុបានច្បាំងនឹងអម្ពតិត្ថកនាគពិតមែនឬទេ ? ពួកភិក្ខុក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះអង្គ

ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ចុះឥឡូវនេះ សាគតភិក្ខុ (ដែលដួលដេកមិនដឹងខ្លួនយ៉ាងនេះ) អាចប្រយុទ្ធនឹងពស់ទឹកបានឬទេ ?ពួកភិក្ខុក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស មិនបានទេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រាសចាកសញ្ញា ព្រោះផឹកទឹកណា ទឹកនោះ ភិក្ខុគួរផឹកឬ ? ពួកភិក្ខុក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស មិនគួរផឹកទេ ។ព្រះលោកនាថទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កម្មរបស់សាគតភិក្ខុមិនសមគួរ មិនទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើ ម្នាលភិក្ខុទាំងឡាយ សាគតភិក្ខុ មិនគួរនឹងផឹកទឹកស្រវឹងសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេដែរ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសម្ដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាផឹកសុរា និងមេរ័យត្រូវ **អាបត្តិបាចិត្តិយ** ។

រាប់ថា ជាពុទ្ធប្បញ្ញត្តិ គឺការហាម តាំងពីថ្ងៃនោះជាដើមមក ភិក្ខុ

ទាំងឡាយណា ធ្វើដូចជាព្រះសាគតៈមិនបានឡើយ ។ ចំណែកព្រះសាគតៈផឹកសុរាហើយ មានអាការស្រវឹងដូច្នោះ រាប់យកថាមុនព្រះពុទ្ធជាម្ចាស់ទ្រង់បញ្ញត្តសិក្ខាបទនេះ ដែលនៅមិនទាន់ចាត់ថាខុសក្នុងសិក្ខាបទដែលទ្រង់បញ្ញត្តនេះ និងបានទទួលការលើកលែងទោស ព្រោះជាដើមបញ្ញត្តិ ។ ជាខាងក្រោយមក ភិក្ខុទាំងឡាយ បានប្រជុំសន្ទនាគ្នាក្នុងសាលាធម្មសភា ដល់ទោសនៃការផឹកសុរាថា ការផឹកសុរាមានទោសច្រើន មើលតួយ៉ាងដូចជាព្រះសាគតៈ ជាអ្នកមានបញ្ញា និងឫទ្ធិ កាលផឹកសុរាចូលទៅហើយ ក៏ដល់នូវការវិនាសសតិ មិនអាចគ្រប់គ្រងខ្លួនបាន សូម្បីព្រះសុគតសាស្ដាមានគុណ ក៏មិនអាចដឹងបាន ។ កាលបើព្រះសាស្ដាទ្រង់សណ្ដាប់ពាក្យសន្ទនា របស់ភិក្ខុទាំងឡាយដោយទិព្វសោតហើយ ទើបស្ដេចយាងទៅកាន់សាលាធម្មសភា ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បព្វជិតដែលផឹកសុរាហើយ វិនាសចាកសតិដូច្នេះ មិនមែនមានតែក្នុងបច្ចុប្បន្ននេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏ធ្លាប់មានរឿងមកហើយដែរ ។

កាលត្រាស់ដូច្នេះហើយ ទើបទ្រង់ត្រាស់សម្ដែងរឿងអតីតនិទាន មានក្នុងអដ្ឋកថា ដែលអធិប្បាយសេចក្ដីនៃ **សុរាបានជាតក** ក្នុង **គម្ពីរខុទ្ទកនិកាយ ជាតក** ដូចមានសេចក្ដីថា ៖

កាលកន្លងមកហើយ ព្រះបាទព្រហ្មទត្ត គ្រប់គ្រងរាជសម្បត្តិនៅក្នុងក្រុងពារាណសី ។ មានកុលបុត្រម្នាក់ ជាបុត្ររបស់ព្រាហ្មណ៍ ជាអ្នកកើតនៅក្នុងត្រកូលខ្ពង់ខ្ពស់ កាលធំឡើង បានចេញបួសជាឥសីហើយ បានសម្រេចអភិញ្ញាសមាបត្តិ នៅក្នុងព្រៃហិមពាន្ត ថែមទាំងមានកូនសិស្ស ៥០០ នាក់ជាបរិវារ ។ ថ្ងៃមួយ កូនសិស្សទាំង ៥០០ នាក់នោះ បាននាំគ្នាលាអាចារ្យ ដើម្បីទៅចាំវស្សានៅក្នុងក្រុងពារាណសី គ្រានោះ ព្រះបាទពារាណសី ទ្រង់និមន្តឲ្យទៅចាំវស្សានៅក្នុងព្រះរាជឧទ្យានហើយទ្រង់អារាធនា ឲ្យទៅឆាន់ក្នុងព្រះរាជវាំងជាប្រចាំ ។លុះតមកដល់ថ្ងៃនក្ខត្តឫក្ស ព្រះបាទពារាណសី ត្រាស់ឲ្យចាត់ចែងសុរាយ៉ាងល្អ ថ្វាយដល់ឥសីទាំងនោះ ។ ចំណែកឥសីទាំងនោះ ក៏នាំគ្នាផឹកសុរាទាល់តែស្រវឹង ហើយត្រឡប់ទៅកាន់កន្លែងព្រះរាជឧទ្យានវិញ

ដើម្បីសម្រាក ។ កាលបើឥសីទាំងនោះ បានត្រឡប់មកដល់ទីសម្រាក ហើយ ឫទ្ធិរបស់សុរាសម្តែងតេជះ ឥសីខ្លះក្រោកឡើងរាំ ខ្លះច្រៀង ខ្លះកំពុងតែដុនដាប មានអាការដូចមនុស្សស្រវឹងស្រា ធ្វើបានគ្រប់យ៉ាង មិនមានការអៀនខ្មាសឡើយ ។ កាលឥសីទាំងនោះស្វាងស្រាហើយ ត្រឡប់មានសតិឡើងវិញ ក៏កើតការខូចចិត្ត ថែមទាំងប្រាប់ដល់គ្នា និងគ្នាថា ពួកយើងទាំងអស់គ្នា ចាប់ពីថ្ងៃនេះតទៅឈប់ផឹកសុរាទៀត កាលដែលពួកយើងទៅ ជួបអាចារ្យវិញ ត្រូវទទួលសារភាពទោស របស់ខ្លួន ពេលដែលឥសីទាំងនោះទៅជួបហើយ ទើបនាំគ្នាពោលឡើង ថា បពិត្រលោកអាចារ្យ ពួកខ្ញុំទាំងឡាយធ្លាប់តែនៅក្នុងព្រៃ កាលបើ បានផឹកសុរាហើយ ម្នាក់ៗ នាំគ្នារាំច្រៀង ដោយគ្មានការអៀនខ្មាស ឡើយ ។

កាលផឹកសុរាទាល់តែស្រវឹង វិនាសសតិហើយ ត្រឡប់ឃើញល្អ ថាជាអាក្រក់និងឃើញអាក្រក់ថាជាល្អ មិនប្រព្រឹត្តប្រតិបត្តិដូចនៅក្នុង សម្នាក់របស់អាចារ្យឡើយ ។ ចំណែកឥសីជាអាចារ្យ បានស្តាប់ពាក្យ

សារកាពកំហុសនៃសិស្សទាំងឡាយហើយ ទើបពោលប្រៀនប្រដៅថា អ្នកធ្វើនូវអំពើនេះ មិនសមគួរដល់ពួកយើង ជាឥសីនៅក្នុងព្រៃឡើយ ។ ឥសីទាំងនោះ បានជឿស្តាប់ពាក្យប្រៀនប្រដៅរបស់លោកអាចារ្យ ក៏នាំគ្នាតាំងចិត្តប្រតិបត្តិតាមរបៀបនៃឥសីរហូតដល់អស់ជីវិត ក៏បានទៅកើតក្នុងព្រហ្មលោក ។កាលព្រះបរមគ្រូ ត្រាស់សុរាបានជាតកចប់ ទើបទ្រង់ប្រជុំជាតកថា ឥសីទាំង ៥០០ នាក់នោះ ត្រឡប់មកកើតជាបរិវាររបស់តថាគតក្នុងកាលឥឡូវនេះ ចំណែកឥសីជាអាចារ្យ គឺតថាគតនេះឯង ជាតកនេះ បង្ហាញឲ្យឃើញទោសរបស់សុរាថា សុរាមេរ័យនេះឲ្យទោសមនុស្សដែលផឹកដោយមិនរើសភេទ ជាតិ ថ្នាក់ វណ្ណៈឡើយ ។លុះព្រឹកឡើង ព្រះសាគតត្ថេរដឹងខ្លួន មានស្មារតី បានស្តាប់នូវហេតុការណ៍ដែលលោកធ្វើរួចហើយ បានកើតការសង្វេគ ទើបចូលទៅសូមខមាទោសចំពោះព្រះសម្មាសម្ពុទ្ធ ព្រះអង្គក៏អភ័យទោសឲ្យ ។ការដឹងខ្លួនថាខុសហើយ សូមទោសចេញ ដោយមិនប្រើភាពរឹងរូស ទើបបណ្ឌិតពោលសរសើរបុគ្គលប្រភេទនេះ ដូចមានពាក្យបុរាណថា ខុសហើយ ព្រម

ទទួលកំហុស ជាបណ្ឌិតដោយពិត ។

ក្រោយពីព្រះសាគតត្ថេរ បានដឹងកំហុសហើយ ទើបកែខ្លួនសាជាថ្មី ដោយតាំងចិត្តព្យាយាមចម្រើនវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មានក៏បានសម្រេចជាព្រះអរហន្ត ។ តមក ព្រះបរមគ្រូ ទ្រង់តែងតាំងព្រះសាគតៈទុកក្នុងតំណែងដ៏ប្រសើរជាងភិក្ខុសាវកទាំងឡាយ ផ្នែកខាងជាអ្នកឈ្លាសវៃក្នុងតេជោធាតុ មានធាតុភ្លើងជាអារម្មណ៍ ធ្វើឲ្យកើតធាតុភ្លើងឡើងបាន ។ ព្រះសាគតត្ថេរ ធ្លាប់ទទួលនាទីជាឧបដ្ឋាកព្រះមានព្រះភាគមុនព្រះអានន្ទត្ថេរចូលមកទទួលនាទីជាប់លាប់ តែបានជាពុទ្ធុបដ្ឋាកនៅត្រឹមតែមួយខណៈមួយពេលនោះ កាលមិនទាន់មានព្រះសាវកណាមួយទទួលនាទីពុទ្ធុបដ្ឋាកជាប្រចាំ កាលមានព្រះអានន្ទត្ថេរចូលមកទទួលនាទីជាប្រចាំហើយ លោកក៏ឈប់ទៅ ។ ដូចមានរឿងនៅក្នុង **គម្ពីរមហាវគ្គ ព្រះវិនយបិដក ត្រង់ចម្មក្ខន្ធកៈ** ដូចមានសេចក្ដីថា ៖

ព្រះសាគតត្ថេរ ធ្លាប់បានបដិបត្តិបម្រើព្រះមានព្រះភាគ ក្នុងកាលដែលព្រះអង្គប្រថាប់នៅភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង មាន

ពួកអ្នកស្រុកទាំង៨ម៉ឺនបាននាំគ្នាទៅកាន់ភ្នំគិជ្ឈកូដនោះដើម្បីចូលគាល់ព្រះមានព្រះភាគតាមព្រះបាទពិម្ពិសារ ។ ក្នុងសម័យនោះ ព្រះសាគតៈបានទទួលនាទីជាអ្នកបម្រើព្រះមានព្រះភាគ ។ វេលានោះ ពួកអ្នកស្រុកទាំង ៨ ម៉ឺននោះ បានចូលទៅរកព្រះសាគតៈ លុះចូលទៅដល់ហើយក៏បាននិយាយពាក្យនេះនឹងព្រះសាគតៈថា បពិត្រលោកដ៏ចម្រើន ឥឡូវពួកអ្នកស្រុកទាំង ៨ ម៉ឺននេះ បានចូលមកក្នុងទីនេះ ដើម្បីឃើញព្រះសម្ពុទ្ធ បពិត្រលោកដ៏ចម្រើន យើងខ្ញុំគួរបានឃើញព្រះភគវា ទើបជាការប្រពៃ ។ ព្រះសាគតកិក្ខុតបទៅវិញថា នែអ្នកដ៏មានអាយុទាំងឡាយបើដូច្នោះ អ្នករាល់គ្នាឈប់បង្អង់ចាំអាត្មានៅទីនេះមួយស្របក់ចុះ ចាំអាត្មាក្រាបទូលព្រះវិជិតមារសិន ។ គ្រានោះឯង កាលបើពួកអ្នកស្រុកទាំង ៨ ម៉ឺននោះ កំពុងតែសម្លឹងមើលក្នុងទីចំពោះមុខ ព្រះសាគតៈក៏ជ្រែកចុះចំផែនថ្ម ហើយទៅផុសក្នុងទីចំពោះព្រះភក្ត្រព្រះមហាវីរៈ រួចបានពោលពាក្យនេះនឹងព្រះលោកនាថថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវមានពួកអ្នកស្រុកទាំង ៨ ម៉ឺននេះ បានចូលមកក្នុងទីនេះដើម្បីឃើញព្រះសយម្ភូ

បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ រមែងជ្រាបនូវកាលគួរ ជាប្រយោជន៍ក្នុងកាល ឥឡូវនេះ ។ ព្រះលោកនាយកតបថា នែសាគតៈ បើដូច្នោះ អ្នកចូរទៅរៀបចំក្រាលអាសនៈត្រង់ម្លប់នៃវិហារចុះ ។ ព្រះសាគតៈដ៏មានអាយុ បានទទួលព្រះពុទ្ធដីកាព្រះមានបុណ្យថា ព្រះករុណាព្រះអង្គ ហើយក៏នាំយកតាំង ជ្រែកចុះក្នុងទីចំពោះព្រះភក្ត្រព្រះភគវាកាលអ្នកស្រុកទាំង ៨ ម៉ឺននោះ កំពុងសម្លឹងមើលក្នុងទីចំពោះមុខក៏ស្រាប់តែទៅផុសត្រង់ថ្ម ហើយក្រាលអាសនៈត្រង់ម្លប់នៃវិហារ ។ វេលានោះ ព្រះសាស្តា ទ្រង់យាងចេញពីវិហារទៅគង់នៅលើអាសនៈដែលព្រះសាគតត្ថេរបានក្រាលត្រង់ម្លប់នៃវិហារ ។ លំដាប់នោះឯង ពួកអ្នកស្រុកទាំង ៨ ម៉ឺននោះ បានចូលទៅគាល់ព្រះសុគត លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះសាស្តា រួចអង្គុយនៅក្នុងទីដ៏សមគួរ ។ គ្រានោះ ពួកអ្នកស្រុកទាំង៨ម៉ឺននោះ ក៏អបអររាក់ទាក់នឹងព្រះសាគតៈទៅវិញ មិនបានអបអររាក់ទាក់នឹងព្រះបរមគ្រូឡើយ ។

វេលានោះឯងព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបនូវបរិវិតក្កក្នុងចិត្តរបស់

ពួកអ្នកស្រុកទាំងនោះ ដោយព្រះទ័យនោះហើយ ទើបទ្រង់ត្រាស់ហៅព្រះសាគតៈមកថា នែសាគតៈ បើដូច្នោះ អ្នកចូរសម្តែងឥទ្ធិប្បាដិហារ្យ ដែលជាធម៌របស់មនុស្សជាន់ខ្ពស់ ឲ្យក្រៃលែងឡើងទៅទៀត ។ ព្រះសាគតៈ បានទទួលស្តាប់ព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ហោះទៅលើវេហាស៍ ចង្ក្រម គឺដើរខ្លះ ឈរខ្លះ គង់ខ្លះ សិងខ្លះ បណ្តាលឲ្យកើតផ្សែងខ្លះ បណ្តាលឲ្យកើតភ្លើងខ្លះ បាត់ខ្លួនទៅខ្លះ ក្នុងប្រទេសទំនេរ គឺអាកាស ។ ក្នុងឱកាសពេលនោះ ព្រះសាគតៈលុះបានសម្តែងឥទ្ធិប្បាដិហារ្យ ជាធម៌របស់មនុស្សជាន់ខ្ពស់ មានប្រការច្រើនយ៉ាង នៅលើប្រទេសទំនេរ គឺអាកាសរួចហើយ ក៏មកក្រាបសិរសា ទៀបព្រះបាទានៃព្រះទសពល ហើយក៏ក្រាបបង្គំទូលពាក្យនេះនឹងព្រះសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះសក្យមុនីជាគ្រូរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវក បពិត្រព្រះអង្គដ៏ចម្រើន ព្រះភគវាជាគ្រូរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវក ។ ខណៈនោះ អ្នកស្រុកទាំង ៨ ម៉ឺននោះ ក៏ពោលថា នែគ្នាយើងដ៏ចម្រើន អស្ចារ្យពេកណាស់ នែគ្នា

ឃើញដ៏ចម្រើន ហេតុដែលមិនធ្លាប់កើតៗ ឡើងហើយតើ អម្បាល សាវ័កមានឫទ្ធិដ៏ខ្លាំងក្លា មានអានុភាពច្រើនម្ល៉ោះទៅហើយ ចំណង់បើគ្រូគង់មានឫទ្ធានុភាពក្រៃលែងជាងនេះពិតប្រាកដ ហើយបែរមកអបអរពាក់ទាក់នឹងព្រះជិនស្រីវិញ លែងអបអរពាក់ទាក់នឹងព្រះសាគតៈ ដូច្នោះទៀតឡើយ ។ វេលានោះ ព្រះភគវាទ្រង់ជ្រាបនូវបរិវិតក្កក្នុងចិត្តរបស់អ្នកស្រុកទាំងនោះ ដោយព្រះទ័យហើយ ទើបទ្រង់សម្ដែងអនុបុព្វីកថា ឯអនុបុព្វីកថានោះ តើដូចម្ដេចខ្លះ គឺព្រះអង្គទ្រង់សម្ដែង **ទានកថា សីលកថា សគ្គកថា** សម្ដែងពីទោសរបស់កាម ដែលជារបស់លាមកសៅហ្មង និងអានិសង្សក្នុងកិរិយាចេញបួស ។ ព្រះលោកនាថទ្រង់បានជ្រាបថា ពួកជនទាំងនោះ មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តអណ្ដែតឡើង មានចិត្តជ្រះថ្លា ក្នុងវេលាណាហើយក៏ទ្រង់សម្ដែងនូវធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ តែងលើកឡើងសម្ដែងដោយព្រះអង្គឯង គឺសម្ដែងពីកងទុក្ខ ហេតុដែលនាំឲ្យកើតកងទុក្ខ សេចក្ដីរំលត់នូវកងទុក្ខ និងផ្លូវដែលដល់នូវសេចក្ដីរំលត់កងទុក្ខក្នុង

វេលានោះ ៗ សំពត់ស្អាត ប្រាសចាកវត្ថុមានពណ៌ខ្មៅ គួរទទួលយកគ្រឿងជ្រលក់ដោយល្អ យ៉ាងណាមិញ ធម្មចក្ខុ ( គឺសោតាបត្តិមគ្គ ) ឥតមានធូលី ឥតមានមន្ទិល ក៏កើតឡើងដល់ពួកអ្នកស្រុកទាំង ៨ ម៉ឺននោះ នៅហ្នឹងអាសនៈនោះថា ធម្មជាតឯណានីមួយ មានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ ក៏មានការរលត់ទៅវិញជាធម្មតា យ៉ាងនោះឯង ៗ ពួកជនទាំងនោះ ក៏បានយល់នូវអរិយសច្ចធម៌ ហើយបានដល់នូវអរិយសច្ចធម៌ហើយ បានដឹងច្បាស់នូវអរិយសច្ចធម៌ ហើយបានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្តីសង្ស័យ ប្រាសចេញពីសេចក្តីងឿងឆ្ងល់ ដល់នូវសេចក្តីក្លៀវក្លា មិនបានជឿបុគ្គលដទៃក្នុងសាសនានៃព្រះសយម្ភូ ក៏បានក្រាបបង្គំទូលពាក្យនេះនឹងព្រះភគវាថា បពិត្រព្រះអង្គដ៏ចម្រើន ច្បាស់ណាស់ហើយ ដូចបុគ្គលផ្ងារឡើងនូវភាជនៈដែលគេផ្កាប់ចុះ ឬបើកឡើងនូវវត្ថុដែលកំបាំង ឬប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ឬទ្រោលបំភ្លឺប្រទីបប្រេងក្នុងទីងងឹត ដោយគិតថា ពួកជនដែលមានចក្ខុ នឹងបានឃើញនូវរូបទាំងឡាយ យ៉ាងណាមិញ ធម៌ដែល

ព្រះសាស្តាបានសម្តែងដោយអនេកបរិយាយ ក៏ដូច្នោះឯង បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងឡាយនេះ សូមដល់នូវព្រះមានជោគផង ព្រះធម៌ផង ព្រះសង្ឃផង ថាជាទីពឹក សូមព្រះភគវាចាំទុកនូវយើងខ្ញុំថាជាឧបាសក បានដល់នូវព្រះរតនត្រ័យថាជាទីពឹក ស្មើដោយជីវិតចាប់ផ្តើមតាំងពីថ្ងៃនេះតទៅ ។

ចំណែកជីវប្រវត្តិអតីតជាតិ របស់ព្រះសាគតត្ថេរ មានសម្តែងប្រាកដក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដោយលោកបានឧទាន ដោយខ្លួនឯងផ្ទាល់ អំពីការកសាងបុណ្យបារមីផ្សេងៗ រហូតឲ្យបានជាបច្ច័យធ្វើឲ្យលោកបានសម្រេចជាព្រះអរហន្ត ដូចមានសេចក្តីថា ៖

គ្រានោះ ខ្ញុំកើតជាព្រាហ្មណ៍ ឈ្មោះសោភិតៈ មានពួកសិស្សហែហម ដើរទៅកាន់អារាម ។ សម័យនោះ ព្រះភគវា ជាឧត្តមបុរស មានពួកភិក្ខុចោមរោម ស្តេចចេញអំពីទ្វារអារាម ហើយស្ថិតនៅ ។ ខ្ញុំបានឃើញព្រះសុគតអង្គនោះ ព្រះអង្គមានឥន្ទ្រិយទូន្មានហើយ មានសាវកដែលមានឥន្ទ្រិយទូន្មានហើយដែរ ជាបរិវារ ខ្ញុំក៏ញុំាងចិត្តរបស់ខ្លួន

ឲ្យជ្រះថ្លា ហើយពោលសរសើរព្រះសាស្ដាថា ពួកឈើទាំងអស់ណាមួយ ពួកឈើទាំងនោះ រមែងដុះលូតលាស់លើផែនដី យ៉ាងណាមិញ សត្វទាំងឡាយជាអ្នកមានប្រាជ្ញា តែងចម្រើនលូតលាស់ឡើង ក្នុងសាសនារបស់ព្រះបរមគ្រូ ក៏យ៉ាងនោះ ។ ព្រះអង្គជាអ្នកដឹកនាំពួក ជាសព្វញ្ញូ ស្វែងរកនូវគុណធំ ទ្រង់ស្រោចស្រង់នូវពួកជនជាច្រើនអំពីផ្លូវខុស ហើយប្រាប់ផ្លូវត្រូវ ។ ព្រះអង្គមានឥន្ទ្រិយទូន្មានហើយ ទាំងមានសាវកដែលមានឥន្ទ្រិយទូន្មានហើយចោមរោម ព្រះអង្គមានឈាន មានពួកអ្នកត្រេកអរក្នុងឈាន អ្នកមានព្យាយាម និងអ្នកមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន អ្នកមានចិត្តស្ងប់រម្ងាប់ អ្នកមិនញាប់ញ័រដោយលោកធម៌ ចោមរោម ។ ព្រះអង្គប្រដាប់ហើយដោយពួកបរិស័ទ ទ្រង់ល្អដោយបុណ្យនិងញាណ រស្មីរបស់ព្រះអង្គផ្សាយចេញ ដូចព្រះអាទិត្យ ដែលទើបនឹងរះឡើង ។ ព្រះមហេសី ជាសាស្ដា ព្រះនាមបទុមុត្តរៈ ទ្រង់ស្ថិតនៅក្នុងភិក្ខុសង្ឃ ឃើញខ្ញុំមានចិត្តជ្រះថ្លាហើយ ត្រាស់នូវគាថាទាំងឡាយនេះថា

ព្រាហ្មណ៍ណា ញុំាងសេចក្តីរីករាយឲ្យកើតឡើងហើយ ពោលសរសើរតថាគត ព្រាហ្មណ៍នោះនឹងរីករាយ ក្នុងទេវលោកអស់សែននៃកប្បទាំងឡាយ ។ ព្រាហ្មណ៍នោះលុះច្យុតចាកឋានតុសិតមក ត្រូវកុសលមូលដាស់តឿន នឹងបួសក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមគោតម ។ ព្រាហ្មណ៍នោះ បួសក្នុងសាសនាហើយ នឹងបាននូវសេចក្តីត្រេកអររីករាយ មាននាមថាសាគតៈ នឹងបានជាសាវករបស់ព្រះសាស្តានោះ ។ ខ្ញុំលុះបួសរួចហើយ ក៏វៀរចាកបាបកម្ម ដោយកាយ លះបង់នូវវចីទុច្ចរិត ជម្រះសម្អាតនូវអាជីវបារិសុទ្ធិសីល ។ ខ្ញុំកាលនៅយ៉ាងនេះ ជាអ្នកឈ្លាសវៃក្នុងតេជោធាតុ កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមាននូវអាសវៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

សរុបអំពើល្អក្នុងអតីតជាតិរបស់លោក មានការបំពេញបុណ្យកុសលក្នុងសម្នាក់ព្រះបទុមុត្តរៈ ហើយថែមទាំងមានសេចក្តីជ្រះថ្លា បាន

ពោលសរសើរគុណព្រះបទុមុត្តរៈនោះ ធ្វើឲ្យលោកបានជួបប្រទះនូវសេចក្ដីសុខ តាំងពីជាតិនោះមករហូតអស់មួយសែនកប្ប ទើបជាតិចុងក្រោយនេះ បានមកកើតជាព្រះសាគតត្ថេរ ។

ចំណែកការរំលត់ខន្ធបរិនិព្វានរបស់លោកវិញ មិនបានឃើញមានសម្ដែងប្រាកដទុកក្នុងគម្ពីរណាថា លោកបរិនិព្វាននៅក្នុងទីណាទេ ឃើញមានត្រឹមតែពោលថា កាលព្រះសាគតត្ថេរទ្រទ្រង់អាយុសង្ខារមកដល់កាលដ៏សមគួរហើយ លោកក៏បានរំលត់ខន្ធបរិនិព្វានទៅ ។l៚

( ជីវប្រវត្តិរបស់ព្រះសាគតត្ថេរ ចប់ )

អាស្រមព្រះគន្ធកុដិ ថ្ងៃ ៨ កើត ខែពិសាខ ព.ស.២៥៥៥

**ដោយប្រធានសមាគមធម្មទានអរិយទ្រព្យចំរុងផល**

# ឈ្មោះសប្បុរសប្រគេនសម្ភារៈ មានតុំព្យួរជាដើម ក្នុងកិច្ចការទារជាធម្មទាន

❋ ឧបាសិកា ហម យិម

ឧបាសក អុឹង ប៊ុនហួរ ឧបាសិកា បួ ម៉ាឡា ព្រមទាំងកូនចៅ

ឧបាសក បួ ស៊ីផូ ឧបាសិកា ប៉ែ ស៊ីវន ព្រមទាំងបុត្រ

ឧបាសិកា បួ ចន្ទា និងស្វាមី ព្រមទាំងបុត្រ

កញ្ញា បួ ដាវី កញ្ញា អុឹង មុយហៀក

❋លោកម្ចាស់ សោម ហួន

លោកគ្រូធម្មាចារ្យ អឿ សៅ ( ទក្ខប្បញ្ញោ )

ឧបាសក ប៊ូ ហោនាង ឧបាសិកា អុឹង រិទ្ធារី ព្រមទាំងបុត្រធីតា

ឧបាសក យឹម សំណាង ឧបាសិកា យឹម ច័ន្ទថូ(LAURA) +បុត្រធីតា

ឧបាសិកា លីប៉ុលីន ស៊ីមប៉ូ កូនក្មួយ ប៊ុន ឡុង,សេង ឈិនដាទេត

លោកអាចារ្យ ផាត សាវឿយ ឧបាសិកា វ៉ាត់ អម +បុត្រធីតា

ឧបាសក សៅ ហ៊ាន ឧបាសិកា មាស មូនីកា +បុត្រធីតា

ឧបាសក សួស ចាន់ធី ឧបាសិកា ឡុង សេង +បុត្រធីតា

ឧបាសក ម៉ៅ វង្ស ឧបាសិកា ឆាន់ កាន់ជួន +បុត្រធីតា

ឧបាសក ម៉ៅ ផុន+សាបូរ៉ាក់ សុខ ( SABOREAK SOK )

ឧបាសក យក់ ស៊ីមូ៉រ៉ា ឧបាសិកា តាន់ រ៉ាណា

ឧបាសក អ៊ុឹង រិទ្ធី ឧបាសិកា ជូធារី

ឧបាសក មាស សារ៉េត

ឧបាសក លឹម ស៊ាង

ឧបាសក ឈុន គឹមអេង

❋ឧបាសក ឈុំ គឹម គឹមហោ ឧបាសិកា គួ ប៊ុនគាង

ឧបាសក សោម សាខន ឧបាសិកា ឈុំ សុធា (ហៅអាហួយ)

ឧបាសក សារុន សេងហួរ ឧបាសិកា ឈុំ សុរីណែត

ឧបាសក ឈុំ សុរិណា (ហៅប៊ុន ឃីម) ឧបាសិកា ណៃ គឹមហុង

ឧបាសក ឈុំ សុបូរី ឧបាសិកា កើត កុលាប

❋ឧបាសិកា ច័ន្ទ បុប្ផាណា

ឧបាសក ស្ងួន សុធីរ

ឧបាសិកា ស្ងួន កល្យាណ

ឧបាសិកា ស្ងួន ចរណៃ

ឧបាសិកា ស្ងួន កញ្ញារ័ត្ន

❋ឧបាសិកា ម៉ក់ នាង ព្រមទាំងកូនចៅ

ឧបាសក តាំង គីមបៃ និងភរិយា ព្រមទាំងកូនចៅ

ឧបាសក តាំង គីមលន់ និងភរិយា ព្រមទាំងកូនចៅ

ឧបាសិកា តាំង លាងងិម និងស្វាមី ព្រមទាំងកូនចៅ

❋ពុទ្ធសាសនបណ្ឌិត្យ អ្នកគ្រូ ម៉ម សុខហេង+ពុទ្ធបរិស័ទ+សៀមរាប

ឧបាសក រស់ សុខ ឧបាសិកា សោម ផាន

ឧបាសិកា នួង ឈុំ សោភ័ណ រស្មី

ឧបាសក ជោគ ឌី ឧបាសិកា ដុះ ចំណាន

ឧបាសិកា វិញ ពូន

❋ឧបាសក ឡាំ ជៀន ឧបាសិកា សឺន ចន្ថា

ឧបាសក លឹម សេងយូ ឧបាសិកា ឡាំ ចាន់សុភី

ឧបាសក ឡាំ ចាន់ណា ឧបាសិកា ទុច ចាន់សាក់គ្រីយ៉ា

ឧបាសក ឡាំ ដាវណ្ណ ឧបាសិកា ឡាំ ចាន់វារី

❋ឧបាសក ជុំ លាង ឧបាសិកា ចៀម អ៊ួន ព្រមទាំងបុត្រ

ញោម ឥម្មុន្ទីនិងធូ ញោម ហាន ញោម វ៉ែន ញោម ភ័ណ្ឌ ញោម

សុមនា ញោម ជោត ញោម មាស សុភា ញោម ឡៃ លី កញ្ញា នា ញោម ធាង ញោម ជឹង ឡេង ញោម អៀម ញោម ភួង ញោម អុំកា ញោម សុភា ញោម វល័ក្ខ ញោម ធាលី លីណា ញោម ថាក ញោម ផារិន ញោម ឈឿន ញោម ឡាង ញោម ស៊ិន ញោម ភាព សាវឿន ញោម ហ៊ន ញោម ប៊ូ សៀកលីវ ញោម យក់ វ៉ាន់ថា ។

❋ឧបាសិកា អ៊ុន ខាត់ណា ឧបាសិកា អ៊ុន ញ៉ាណ ឧបាសក អ៊ុនសេរី

លោក ដែង រស្មី និងអ្នកស្រី ជុង កុយយ៉ា ព្រមទាំងបុត្រ

❋ឧបាសក អ៊ឹង ហ្គេចឡេង ឧបាសិកា តាំង ប៉េជីង ព្រមទាំងបុត្រ

លោក ឆៃ ហេង អ្នកស្រី អ៊ឹង ស៊ីវគៀង ព្រមទាំងបុត្រ

លោក ភួ ពុយ អ្នកស្រី អ៊ឹង ណាងពិន ព្រមទាំងបុត្រ

លោក អ៊ឹង វណ្ណម៉ៅ អ្នកស្រី ហេង ហ៊ុយទៀង ព្រមទាំងបុត្រ

លោក ប៊ី ទី អ្នកស្រី តាំង ប៉េគិម ព្រមទាំងបុត្រ

ឧបាសិកា ជា នាងនិងស្វាមី ព្រមទាំងបុត្រ

❋ឧបាសិកា ង៉ែត យូអេង ព្រមទាំងបុត្រ

ឧបាសិកា គង់ ង៉ោ និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ច័ន្ទនី និងស្វាមី ព្រមទាំងបុត្រ

✵ឧបាសិកា សាម៉ុល គឹមធន និងអ្នកម្តាយ

ឧបាសិកា គី វណ្ណហាក់ ព្រមទាំងបុត្រ

លោក សេង យុវនាថ ឧបាសិកា គុជ ឡាំងអេង

ឧបាសិកា ឈន សុកនី ឧបាសក ជីវ និងភរិយា

ឧបាសក សុខ សំ និងភរិយា ព្រមទាំងបុត្រ

ឧបាសក នុត កុសល និងភរិយា ព្រមទាំងបុត្រ

ឧបាសិកា អៀន ភី + អ៊ុំ សុភាព + ឈិត ស្រស់ + សឹម ឡាយ

ញោម ហ៊ឺ ជាង + ជាមុយហាង + គុយ លឹម + សេង មុយនី

ញោម ចៅ ជីវ ស៊ុយលៀប+ប៉ែ អេង+គឹម ធី+ខៀវ វ៉ន+ គឹម

ញោម នៀង+យាយ ធឹង+គួង ភាង+សើន គា+សៀង+គឹម អាង

ញោម សេង ឆេង+ផាន់ វ៉ាន់+យាយ រុ+ឡាំម៉ាលី+ជាន សុផាត

យាយ ម៉ៅ + ពៅ + ឈួន+ ក. កាវ៉ាឡែន+ ហ៊ុង+ ប៉ែ ង៉ា+ រី រុត្ន

ញោមអ្នកគ្រូ វ៉ាន់ + យុវសិស្ស អ៊ុំ រតនា + សាមណោវ អ៊ុំ វីរៈ

ញោមប៉ែ ង៉ាថ្មគោល+អ្នកស្រី លេង យ៉ុង+តី លី+នាង ឈៀត

ញោម ហ៊ឹង+នាង មឿន+អូនប៉ុច+ ឡាត វ៉ាន់យិន+ ម៉ម សុខហេង

ញោម គឹម ឡេង+តាំង វេន+យុន+យាយ ធុច + យាយ យន ញោម ហ៊ិន ស៊ីម ញោម អឿន ភី+វ៉ាន់ ស៊ុនឡាយ+ផល្លី+សវាមី ញោម ឡុង សាវី+ជា សុខហ៊ាង+គុយ លឹម+សេង ទូច+ស៊ីវ ទី ញោម ណៅ ហ្គេចណៃ+វ៉ាន់ សុផានី+សា វឿន+សំ គី+ចាន់ ណារ៉ា ញោម ធារ៉ា+យឿត និងស្វាមី+ហួត អេង+អាវ សុវណ្ណី+ណា ស៊ី ញោម យាយ នៅ+ឈុន គាវ+ យាយ ឌី+ សំ វ៉ាន់នី+ គឹម អ៊ី ញោម អៀប សាន្ទួន+ យាយ ហឿន+យាយ ឡាំ+កេន សេងមុំ ស ខាន់ថង+ស៊ី ណាត+យឿន+ចាន់ នី+ផន សារ៉ែន+កោ ហុង ។

# នាមពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

លោកម្ចាស់ សោម ហួន

លោកគ្រូធម្មបណ្ឌិត ( ទក្ខប្បញ្ញោ ) អឿ សៅ

ឧបាសិកា ជឹក ស្រ៊ិន ព្រមទាំងកូនប្រុស អ៊ីង រិទ្ធី និងកិរិយា

ឧបាសក ប៊ូហោ នាង ឧបាសិកា អ៊ីង រិទ្ធារី ព្រមទាំងបុត្រធីតា

ឧបាសក យេម សំណាង ឧបាសិកា យេម ឡរ៉ា ព្រមទាំងបុត្រ

ឧបាសក សៅ ហ៊ាន ឧបាសិកា មាស ម៉ូនីកា ព្រមទាំងបុត្រ

ឧបាសក ឈៀងសាវឿន ឧបាសិកា ឈុំ ធដា ព្រមទាំងបុត្រធីតា

ឧបាសក ម៉ៅ វង្ស ឧបាសិកា ចាន់ កាន់ជួង ព្រមទាំងបុត្រ

ឧបាសក និន ហាក់ ឧបាសិកា លុយ ចាន់ថន ព្រមទាំងបុត្រ

ឧបាសិកា ម៉ី ចាន់រ៉ាវី ព្រមទាំងបុត្រធីតា

ឧបាសិកា យ៉ក់ ស៊ីមូរ៉ា ព្រមទាំងបុត្រ

ឧបាសិកា វ៉ាន់ចាន់ ព្រមទាំងបុត្រធីតា

ឧបាសិកា ខៀវ ណាត ព្រមទាំងបុត្រធីតា

## នាមពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា

## ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ឆាយ អ៊ីវស៊ាង ឧបាសិកា ហុង គីមសែ កូន+ចៅ

ឧបាសិកា យូ ស៊ាងនន្ទលី ព្រមទាំងកូនចៅ

## នាមពុទ្ធបរិស័ទនៅអូស្ត្រាលីមានសទ្ធាជ្រះថ្លា

## ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ប៊ុន ហេង

ឧបាសិកា ហេង ស្រីជា

ឧបាសិកា ហេង គង្គា

ឧបាសិកា ជុំ សុខុម

ឧបាសិកា ហេង ស្រីចន្ទ

ឧបាសក ហេង សុកត្រ័

## នាមពុទ្ធបរិស័ទនៅខេត្តបាត់ដំបងមានសទ្ធាជ្រះថ្លា

## ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក អ៊ឹង ហ្គិចឡេង ឧបាសិកា តាំង ប៉េងជីង ព្រមទាំងកូនចៅ

ឧបាសក វៀម ឈើន ឧបាសិកា ប៊ូ ម៉ុន ព្រមទាំងកូនចៅ

ឧបាសក ញ៉ែម មឿន ឧបាសិកា វៀម ថុល ព្រមទាំងកូនចៅ

ឧបាសក អ៊ីង ប៊ុនហួរ ឧបាសិកា បួ ម៉ាឡា ព្រមទាំងកូនចៅ

ឧបាសក ឈុំ គឹមហោ ឧបាសិកា គួ ប៊ុនគាង ព្រមទាំងកូនចៅ

ឧបាសក សោម សាខន ឧបាសិកា ឈុំ សុជា ព្រមទាំងកូន

ឧបាសក នាង ក៉ា ឧបាសិកា តែម ធារីម ព្រមទាំងកូនចៅ

ឧបាសក សៅ ស៊ុន្ធរា ឧបាសិកា ប៊ុន មុំ ព្រមទាំងកូនចៅ

ឧបាសក ណូ ស្វែង ឧបាសិកា សោម គឹមលួន ព្រមទាំងកូនចៅ

ឧបាសិកា ងិន យ៉ុន ឧបាសិកា សួស សុខា ព្រមទាំងកូនចៅ

ឧបាសិកា សោម គឹមលឿម និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា គឹម ធាវី និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ទាវ គឹមយក់ ឧបាសិកា អ៊ុម គឹមជីវ

ឧបាសិកា គី វណ្ណហាក់ ឧបាសិកា ឡាំ ម៉ាលី

ឧបាសិកា ហួត អេង ឧបាសិកា ឡេា សាយហ៊ុច

ឧបាសិកា ង៉ែត យូអេង ព្រមទាំងកូនក្មួយ

ឧបាសិកា ហោ ភាព ព្រមទាំងកូនក្មួយ

ឧបាសិកា អ៊ុក នៅ ព្រមទាំងបុត្រ

ឧបាសិកា សឿង ព្រមទាំងបុត្រ

# នាមពុទ្ធបរិស័ទនៅស្អិចមានជ័យភ្នំពេញមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសិកា ឆេង ស៊ីម ព្រមទាំងកូនចៅ

លោក លី ហុង លោកស្រី ជា ណារី ព្រមទាំងបុត្រ ធីតា

លោក ផូ ចាន់ថន លោកស្រី ជា ណាវី ព្រមទាំងបុត្រ ធីតា

លោក លឹម ចាន់ឌី លោកស្រី ទេព ចិន្តា ព្រមទាំងបុត្រ ធីតា

កញ្ញា ហុង លីដា

លោក ហុង សុវណ្ណតារា និងភរិយា លឹម ចាន់មុនីរ័ត្ន

ឧបាសក ហុង សុវណ្ណារិទ្ធ

ឧបាសក ហុង សុវណ្ណារ៉េត

យុវជន ហុង ប៊ុនឡុង

ឧបាសក ហ៊ុន ហេងគង់ ឧបាសិកា ទូច សារុន ព្រមទាំងកូនចៅ

ឧបាសិកា ធុយ ឈីវអូន ព្រមទាំងកូនចៅ

ឧបាសក យ៉ែម យ៉ន ឧបាសិកា យ៉ង់ ទូច ព្រមទាំងកូនចៅ

ឧបាសក មិន ម៉ាង ឧបាសិកា ឈិន គឹមហ៊ាន ព្រមទាំងកូនចៅ

ឧបាសិកា ជា សុផល ព្រមទាំងកូនចៅ

ឧបាសិកា មៀច យ៉ន ព្រមទាំងកូនចៅ

ឧបាសិកា មុំ សុន ព្រមទាំងកូនចៅ

លោក លន់ វ៉ាន់ថា លោកស្រី មុំ ដាន់ ព្រមទាំងបុត្រ ធីតា

លោក ចាប សោភ័គ លោកស្រី មុំ ដា ព្រមទាំងបុត្រ ធីតា

លោក ឈឺន សាគឹម លោកស្រី ខឹម អូន ព្រមទាំងបុត្រ ធីតា

លោក រស់ ប៊ុនឡេង លោកស្រី ឡេង ស៊ីនី ព្រមទាំងបុត្រ ធីតា

ឧបាសិកា ឈួន សុ ព្រមទាំងកូនចៅ

ឧបាសិកា ថ្វាង តាំងគៀន ព្រមទាំងកូនចៅ

ឧបាសិកា ប៉ែន នាង ព្រមទាំងកូនចៅ

ឧបាសិកា អៀវ ងឹម និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ុន ដារ៉ុង ព្រមទាំងកូនចៅ

ឧបាសិកា គឹម សេង ព្រមទាំងកូនចៅ

ឧបាសិកា ហួយ ជន ព្រមទាំងកូនចៅ

ឧបាសិកា រ័ត្ន សុផល ព្រមទាំងកូនចៅ

លោកស្រី ជុន បូណ៌ិមី និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ធា ព្រមទាំងកូនក្មួយ

ឧបាសិកា គឹម អាន់ ព្រមទាំងកូនចៅ

ឧបាសិកា ជាវ ស៊ីយន ព្រមទាំងកូនចៅ

លោក កេត ចាន់តារា

លោក កេត សំបូរ និង កុមារី សុជាតា

ឧបាសិកា ជា រួចទៀង ព្រមទាំងកូនចៅ

ឧបាសក ជឹ សុខអៀម ឧបាសិកា តាំង ស៊ូអេង ព្រមទាំងកូនចៅ

ឧបាសិកា តាំង ស៊ូហៀង ព្រមទាំងកូនចៅ

ឧបាសិកា ជឹ ញ៉ៅ ព្រមទាំងកូនចៅ

ឧបាសិកា ខៀវ សុធី ហៅ អ៊ុំម៉ៅ ព្រមទាំងកូនចៅ

ឧបាសិកា ទូច ព្រមទាំងកូនចៅ

ឧបាសក ឡាយ ឧបាសិកា លន់ ព្រមទាំងកូនចៅ

ឧបាសិកា ជាវ ហិន ព្រមទាំងកូនចៅ

ឧបាសិកា មិល មម ព្រមទាំងកូនចៅ

ឧបាសក រស់ ស្រេង ឧបាសិកា ឡា ហ៊ុយឡេង ព្រមទាំងកូនចៅ

ឧបាសិកា ឡា ស៊ីវឡេង ព្រមទាំងកូនចៅ

ឧបាសិកា គី បួយ ព្រមទាំងកូនចៅ

លោក យឹម សារ៉ាវុទ្ធ លោកស្រី រស់ ចិន្តា ព្រមទាំងបុត្រ

កុមារា យាន ពិសិដ្ឋ

ឧបាសិកា យន សាក ព្រមទាំងកូនចៅ

ឧបាសិកា ហោ យិចឡាំង ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ុន ចាន់ថា ព្រមទាំងកូនចៅ

ឧបាសិកា ជី ជុន ព្រមទាំងកូនចៅ

ឧបាសិកា លឹម ម៉ាលី (គីម ហ៊ួយ) និងស្វាមី ព្រមទាំងបុត្រ ធីតា

ឧបាសិកា ស៊ុន ឡាច ព្រមទាំងក្រុមគ្រួសារ

ឧបាសក ប៊ុន បួន ឧបាសិកា យុត សួគ៌ ព្រមទាំងកូនចៅ

លោក ផាន សុបិន អ្នកស្រី សំ សុវណ្ណមល្លិកា ព្រមទាំងបុត្រ

បងស្រី ណៅ សុភី និង ប្អូនស្រី ណៅ សុផល

ឧបាសិកា ឈឹន សុន ព្រមទាំងកូនចៅ

លោក ម៉ាន់ រិទ្ធី និង អ្នកស្រី អ៊ួន សារ៉េត ព្រមទាំងបុត្រ

លោក ឱម ឡូត លោកស្រី ស៊ុំ ស្រីពៅ ព្រមទាំងបុត្រ

លោក ម៉ាន់ សាវឿន លោកស្រី ម៉ម សុជា ព្រមទាំងបុត្រ

លោក ស៊ឹម សារ៉ាន់ លោកស្រី លី សុខរ៉េត ព្រមទាំងបុត្រ

ឧបាសក ទិត្យ លី ឧបាសិកា ហេង វណ្ណា ព្រមទាំងកូនចៅ

ឧបាសិកា ថោង គីមលន់ ព្រមទាំងកូនចៅ

ឧបាសិកា ប៉ូ ប៉ុក ព្រមទាំងកូនចៅ

ឧបាសិកា សោម សូត្រ ព្រមទាំងកូនចៅ

ឧបាសិកា ឈឹន សង់ ព្រមទាំងកូនចៅ

លោក ឈឹន ចំរើន លោកស្រី ហោ វាសនា ព្រមទាំងបុត្រធីតា

ឧបាសិកា ប៉េ សារ៉ា(ម្តាយ) ឧបាសក ម៉ុី ធារី

ឧបាសិកា ម៉ៅ ណារី ព្រមទាំងកូនចៅ

ឧបាសក ប៉ែ ស៊ីថា ឧបាសិកា ងួន សាលីន ព្រមទាំងកូនចៅ

ឧបាសិកា ប៊ូច សាមុត ព្រមទាំងកូនចៅ

ឧបាសិកា មាស អួន ព្រមទាំងកូនចៅ

ឧបាសក សៅ ម៉េង ឧបាសិកា ថោង វង្ស ព្រមទាំងកូនចៅ

ឧបាសិកា ថោង រ៉ែត ព្រមទាំងកូនចៅ

ឧបាសក ជូ បូរិន ឧបាសិកា ហែម យ៉ានី ព្រមទាំងកូនចៅ

អ្នកគ្រូ ឱម សុផាត ព្រមទាំងកូនចៅ

ឧបាសក ធីង ផាត់ ឧបាសិកា ណុប សៀងហេង ព្រមទាំងកូនចៅ

លោក អុិត សារឿន លោកស្រី ញឹក សោភ័ណ ព្រមទាំងបុត្រ

# នាមពុទ្ធបរិស័ទអ្នកមានឧបការៈក្នុងការចារធម្មទាន

១- ឧបាសិកា ប៉េង តាំង ឧបាសិកា ហ៊ូ គឹមងៀក

២- ឧបាសក ស្រេង ស្រ៊ាង ឧបាសិកា គិម ចន្ថា

៣- ឧបាសក ឡាយ សុខុម ឧបាសិកា គី គឹមហាប់

៤- ឧបាសិកា បួ ម៉ាឡា កញ្ញា បួ ដាវី

៥- ឧបាសិកា ង៉ែង យូអេង កញ្ញា អ៊ុង មុយហៀក

៦- ឧបាសក លឹម ខូង ឧបាសិកា កែវ អុន

៧- ឧបាសិកា កែវ កល្យាណ ឧបាសិកា សុខ សុទ្ធី

៨- ឧបាសិកា សឺន ចន្ថា លោក ឡាំ ដាវណ្ណ

៩- ឧបាសិកា គួ ប៊ុនគាង ឧបាសិកា ឈុំ សុធា

១០- ឧបាសិកា នេត្រ នរិន្ទ ឧបាសិកា ទន់

១១-ឧបាសិកា ឱម លក្ខណា ឧបាសិកា ហេង ច័ន្ទបុញ្ញវត្តី

១២-ឧបាសិកា គី យក់បួយ ឧបាសិកា ឈុន ណាត

១៣-ឧបាសិកា អ៊ឹង វិទ្ធារី ឧបាសក អ៊ុន សេរី

១៤-ឧបាសិកា វៀម ជុល ឧបាសិកា ម៉ៅ នី

១៥-ឧបាសិកា សន ឈៀត ឧបាសក ឡាន សុខុម

១៦-ឧបាសិកា គី វណ្ណហាក់ ឧបាសិកា ប៉ុន ណាម

១៧-ឧបាសិកា ស្ងួន កល្យាណ ឧបាសិកា កយង់ កក្តី

១៨-ឧបាសក អ៊ុង វ៉ៃយ៉ា ឧបាសក កុយ សាមន

១៩-ឧបាសក ហុង សុវណ្ណារិទ្ធ ឧបាសក ហុង សុវណ្ណារ៉េត

ខ្ញុំព្រះករុណា អាត្មាភាពមានបំណងនឹងបោះពុម្ពសៀវភៅព្រះធម៌ជាច្រើនមុខទៀត ដើម្បីចែកជាធម្មទាន បើញាតិញោមពុទ្ធបរិស័ទ មានបំណងចង់ចូលរួមបោះពុម្ពសៀវភៅជាធម្មទាននោះ សូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទនេះ ០១២ ៣០៥ ៧៦៦, ០៨ ៨៨ ៧៧ ៩៩ ៦៦ ០៧៧ ៦៦ ៦៦ ៣៨ ចំពោះសៀវភៅដែលត្រូវបោះពុម្ពនោះ ដូចមានខាងក្រោមនេះ គឺ

**-ជីវប្រវត្តិពុទ្ធឧបាសក** មាន ៥ ភាគ ដែលជាភាគបញ្ចប់ ហើយសព្វថ្ងៃនេះ ក៏បានធ្វើចប់រួចអស់ហើយដែរ ទាំង ៥ ភាគ នៅតែមានការបោះពុម្ពជាបន្តបន្ទាប់ទៀតតែប៉ុណ្ណោះ ។

**-ជីវប្រវត្តិពុទ្ធឧបាសិកា** មាន ៤ ភាគ ដែលជាភាគបញ្ចប់ ហើយ

សព្វថ្ងៃនេះ ក៏បានធ្វើចប់រួចអស់ហើយដែរ ទាំង ៤ ភាគ នៅតែមានការបោះពុម្ពជាបន្តបន្ទាប់ទៀតតែប៉ុណ្ណោះ ។

**-វចនានុក្រមព្រះអភិធម្ម ៧ គម្ពីរ** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់ រហូតទៅដល់ ៨៣៣ ទំព័រ ។

**-វិសុទ្ធិមគ្គ** និង **បរមត្ថមញ្ជូសាមហាដីកា បញ្ញានិទ្ទេស** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេចដែរ ដែលមាន ៣ ភាគ ។

**-គម្ពីរសារត្ថសង្គហៈ** ហើយសព្វថ្ងៃនេះ បានធ្វើរួចជាស្ថាពរ គឺវាយកុំព្យូទ័ររួចជាស្រេចអស់ហើយទាំង ២ ភាគ ដែលមានកម្រាស់ រហូតទៅដល់ ៦០០ ទំព័រជាង ។

**-គម្ពីរអភិធម្មត្ថសង្គហៈ** និង **វិភាវិនីដីកា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់ រហូតទៅដល់ ៦៥០ ទំព័រជាង ។

**-អភិធម្មត្ថសង្គហៈ** និង **បរមត្ថទីបនីដីកា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់

វហូតទៅដល់ ៩៨៩ ទំព័រជាង ។

-គម្ពីរអភិធម្មាវតា សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់វហូតទៅដល់ ៥៩៧ ទំព័រ ។

-មិលិន្ទប្បញ្ហា សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់វហូតទៅដល់ ៥០០ ទំព័រ ។

-រឿងរ៉ាវដែលទាកទង់ នឹងពុទ្ធស្ថាន បានធ្វើសម្រេចជាស្ថាពរហើយ ដែលមានចំនួន ៥ ភាគ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់វហូតទៅដល់ ៦០០-៧០០ ទំព័រជាងក៏មាន ។

-ខ្ញុំព្រះករុណា អាត្មាភាព មានបំណងនឹងរាបចំធ្វើ គម្ពីរព្រះត្រៃបិដក និងគម្ពីរព្រះអដ្ឋកថា បញ្ចូលជាមួយគ្នា ដោយដាក់ព្រះត្រៃបិដកហើយ ដាក់ព្រះអដ្ឋកថាពីខាងក្រោមព្រះត្រៃបិដក ក្នុងការបញ្ចូលគម្ពីរព្រះត្រៃបិដក និងគម្ពីរព្រះអដ្ឋកថាជាមួយគ្នានោះ ព្រះត្រៃបិដកយកតាមបិដកខ្មែរយើង ដែលមាន ១១០ ក្បាល ។

-ព្រះត្រៃបិដកខ្មែរយើងដែលមាន ១១០ ក្បាល បានវាយកុំព្យូទ័ររចប់ហើយ ( ០១.០៥.២០១០, ២៧.០៣.២០១១ ) ។

-ការដាក់ព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នានោះ ដែលធ្វើសម្រេចជាស្ថាពរនោះ មានដូចខាងក្រោមនេះ គឺ

-គម្ពីរវិន័យបិដក បានធ្វើរួចជាស្រេចហើយ មានចំនួន ១៤ភាគ

-គម្ពីរទីឃនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ៦ ភាគ

-គម្ពីរមជ្ឈិមនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ៩ ភាគ

-គម្ពីរសំយុត្តនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ១១ ភាគ

-គម្ពីរអង្គុត្តរនិកាយ កំពុងតែប្រែជិតចប់ហើយដែរ

-គម្ពីរខុទ្ទកនិកាយ ប្រែបាន ៦ ភាគហើយ

សរុបការប្រែព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នានោះ សព្វថ្ងៃនេះ បានចំនួន ៥០ ក្បាលជាងហើយ ។

# សៀវភៅដែលប្រមូលរៀបរៀង និងបោះពុម្ពហើយដោយ
# ខ្ញុំព្រះករុណា អាត្មាភាព
## ✍ យង់ សុផាត ✍

-ជីវប្រវត្តិព្រះអសីតិមហាសាវក មាន ៨ ភាគ ពីភាគ ១ ដល់ភាគ ៨

-ជីវប្រវត្តិព្រះពុទ្ធសាវិកា មាន ៤ ភាគ ពីភាគ ១ ដល់ភាគ ៤

-ជីវប្រវត្តិព្រះពុទ្ធឧបាសក មាន ៥ ភាគ ពីភាគ ១ ដល់ភាគ ៥

-រឿងរ៉ាវដែលទាកទង់នឹងពុទ្ធស្ថាន មាន ៥ ភាគ ពីភាគ ១ ដល់ភាគ ៥

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សីលនិទ្ទេស មួយភាគ ១

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សមាធិនិទ្ទេស មាន ៤ ភាគ

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា បញ្ញានិទ្ទេស ភាគ ១

-ធម៌សូធ្យនមស្ការបែបសម័យទំនើប

-គម្ពីរមហាសតិប្បដ្ឋានភាវនា

-គម្ពីរសារត្ថសង្គហៈ ភាគ ១

-ពុទ្ធប្បវត្តិ

សូមអនុមោទនាជម្ទាន !!!

   

# នឹកឃើញស្រុកព្រះ

នឹកឃើញស្រុកព្រះ បានក្រាបសំពះ អង្គព្រះសាស្តា
សិរសាលំទោន ទុកដូចឈូកផ្កា បូជាសាស្តា
ជ្រះថ្លាក្រៃលែង ។
៦៥ អង្គា គាល់ព្រះភគវា ៥១ កន្លែង
នៅស្រុកឥណ្ឌា ចង់ចាំមិនលែង សោមនស្សពន់ពេក
ក្នុង ព.ស.២៥៥០ ។